# សៀវភៅរឿង ព្រះយេស៊ូវ តាមរយៈព្រះគម្ពីរ



រឿងរ៉ាវទាំងអស់និយាយខ្សឹបខ្សៀវពីព្រះនាមទ្រង់



និពន្ធដោយ Sally Lloyd-Jones និង គូររូបដោយ Jago

# សៀវភៅរឿង



# ព្រះយេស៊ូវ

រឿងរ៉ាវទាំងអស់និយាយខ្សឹបខ្សៀវពីព្រះនាមទ្រង់ តាមរយៈព្រះគម្ពីរ

## និពន្ធសម្រាប់៖

សម្រាប់ Harry, Olivia, Emily, Eleanor និង Jonathan
ដោយសាររឿងព្រេងនេះពិតជាបានកើតឡើងមែន!
SLJ

លោកស្រី Alex ដែលជាភរិយារបស់យើងខ្ញុំ។
បើគ្មានគាត់ នោះយើងខ្ញុំក៏មិនអាចបញ្ចប់សៀវភៅដ៏ធំនេះបានឡើយ។
Jago



បោះពុម្ពជាភាសាខ្មែររក្សាសិទ្ធិ ២០១៨
Copyright © 2007 by Zondervan
Text copyright © 2007 by Sally Lloyd-Jones
Illustration copyright © 2007 by Jago Silver
All rights reserved.
Published in the USA by Zonderkidz.
Zonderkidz is a trademark of Zondervan.
Worldwide co-edition produced by Lion Hudson plc, Wilkinson House, Jordan Hill Road, Oxford, OX2 8DR, England.
Tel: +44 (0) 1865 302750  Fax: +44 (0) 1865 302757
Email: coed@lionhudson.com.
Printed in Singapore

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ឆ្នាំ១៩៥៤, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួលឆ្នាំ២០១៤ និង២០១៦ (គកស), ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន (គខប), ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ (គគខ), ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

រក្សាសិទ្ធិគ្រប់បែបយ៉ាង។ លោកអ្នកមិនអាចបោះពុម្ពផ្សាយចំណែកណាមួយនៃការបោះពុម្ពនេះបានឡើយ ឬក៏រក្សាទុកក្នុងប្រព័ន្ធដែលអាចយកបាន ឬធ្វើបរិធានប្រើបញ្ចូលសញ្ញាទូរលេខតាមរបៀបណាមួយ ឬតាមន័យណាមួយជាបច្ចេកទេសអេឡិចត្រូនិក ជារបៀបយន្តកម្ម ការថតចម្លង ថតជាសម្លេង ឬក៏ជារបៀបណាផ្សេងទៀតក្តី លើកលែងតែសម្រាប់សម្រង់សម្តីសង្ខេបក្នុងពិនិត្យបោះពុម្ព ដោយក្នុងករណីនេះ លោកអ្នកពុំចាំបាច់សុំការអនុញ្ញាតជាមុនពីម្ចាស់បោះពុម្ពទេ។
All rights reserved. No part of this publication may be reproduced, stored in a retrieval system, or transmitted in any form or by any means—electronic, mechanical, photocopy, recording, or any other—except for brief quotations in printed reviews, without the prior permission of the publisher.

បោះពុម្ពដោយ Emerald Bible Fellowship ដោយមានការសហការជាមួយ ACTION Cambodia
resources@actioncambodia.org

បកប្រែដោយ៖ លោកខែម ករុណា និងលោកស្រី ខែម អេលីសាបិត
កែសម្រួលដោយ៖ លោកស្រី ឌឹត សារី, លោកស្រី ហង្ស សោភ័ណ, លោកស្រី ធី លីដា, លោក ទេព រ៉ូ, លោក ឈាង បូរ៉ា, លោក ជួប ប៊ុនហាក់, កញ្ញា ឡូញ ស្រីរដ្ឋ, កញ្ញា យ៉ុន សាឯម និងលោក វ៉ើល ណាថាន
អ្នកត្រួតពិនិត្យ៖ កុមារី ពេជ្រ សោភា, កុមារី នឿន រក្សា, កុមារា រិន ភក្តី, កុមារា ស៊ីវន វរៈ, កុមារា ជួន រដ្ឋា, កុមារី សុភក្តិ អែលណា មេត្តា, កុមារី សុភក្តិ អែលណា ខេមា និងកុមារី សាំង ស៊ីលីណា
ចាងហ្វាងវិចិត្រកម្ម៖ លោក វ៉ើល ណាថាន និងលោក ទេព រ៉ូ
អ្នកពិនិត្យខាងឯទេវវិទ្យា៖ លោក វ៉ើល ណាថាន

For more information about this book please visit:
ប្រសិនបើលោកអ្នកចង់បានព័ត៌មានថែមទៀតអំពីសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖
http://www.cambodianchristianresources.com/jesusstorybookbible/

# សេចក្តីថ្លែងអំណរគុណ

«នេះមិនមែនថា ខ្ញុំបានជ្រើសយកព្រះអង្គនោះទេ
ចំពោះព្រះអម្ចាស់ នោះខ្ញុំមិនអាចធ្វើបានឡើយ
ដួងចិត្តទូលបង្គំមួយនេះនឹងតែងតែបដិសេធព្រះអង្គ
ប្រសិនបើព្រះអង្គមិនបានជ្រើសយកទូលបង្គំ...
ដួងចិត្តទូលបង្គំគ្មានអ្វីទាល់តែសោះនៅចំពោះព្រះអង្គ
ដួងចិត្តទូលបង្គំស្រេកឃ្លាននូវព្រះគុណដ៏អស្ចារ្យរបស់ទ្រង់
ដោយដឹង ដូច្នេះបានជាទូលបង្គំស្រឡាញ់ព្រះអង្គ
ពីព្រោះព្រះអង្គបានស្រឡាញ់ទូលបង្គំជាមុន។»
*Josiah Conder, 1836*

យើងខ្ញុំជំពាក់គុណបំណាច់ដ៏លើសលុបចំពោះលោកអ្នកបងប្អូនទាំងអស់ បើគ្មានលោកអ្នកបងប្អូនទាំងអស់គ្នាទេ នោះយើងខ្ញុំក៏មិនអាចសរសេរសៀវភៅនេះបានដែរ។ ចំពោះលោកបណ្ឌិត ធីម៉ូធី ខែល្លី (Timothy Keller) យើងខ្ញុំបានខ្ចីសេចក្តីបង្រៀនសម្រាប់គ្រប់រឿងអស់ទាំង៖ ប្រាជ្ញារបស់គាត់ ការផ្តល់នូវវាក្យស័ព្ទនៃជំនឿ និងការបើកឲ្យភ្នែកយើងខ្ញុំបានឃើញនូវព្រះគុណដ៏អស្ចារ្យ។ ចំពោះឪពុកម្តាយយើងខ្ញុំ ដែលជាអ្នកដំបូង ដែលបាននិទានពីដំណើររឿងនេះប្រាប់យើងខ្ញុំ កាលដែលយើងខ្ញុំមានអាយុបួនឆ្នាំ—និងចំពោះលោក ហែនម័រ (Hanmer) ជាអ្នកធ្វើឲ្យសាច់រឿងនេះលេចចេញរូបរាងឡើង។  ចំពោះមិត្តភ័ក្តិទាំងអស់របស់យើងខ្ញុំនៅ Zondervan—លោក Kris ដ៏ពូកែ និងជាពិសេសចំពោះលោកស្រី Catherine ដែលជាអ្នកជួយកែសម្រួលដល់ខ្ញុំ គាត់បានយល់ពីទស្សនៈ ហើយក៏បានរក្សាឲ្យវារស់រវើកផងដែរ។ ចំពោះក្រុមដែលពលិការពីខាងក្រៅ—លោកស្រី Julie និងលោកស្រី Linda។ ចំពោះលោក Jago ដ៏ឈ្លាសវៃបំផុត—គឺជាអភ័យឯកសិទ្ធិដែលយើងខ្ញុំបានធ្វើការជាមួយលោក (យើងខ្ញុំជាអ្នកគាំទ្រដ៏ធំរបស់លោក)។ ចំពោះគ្រួសារលោក Keiths លោក Brownes និងលោក Paul ដែលតែងតែផ្តល់ទីកន្លែងដ៏កក់ក្តៅដល់យើងខ្ញុំសម្រាប់សរសេរ។ ចំពោះលោក Todd និងលោកស្រី Laura និងគ្រួសារ និងមិត្តភ័ក្តិរបស់យើងខ្ញុំដែលមានការអត់ធ្មត់មិនចេះចប់ដល់យើងខ្ញុំ—អ្នករាល់គ្នាបានដឹងថាខ្លួនជាអ្នកណាហើយ!—ដែលបានណែនាំយើងខ្ញុំគ្រប់ជ្រុងជ្រោយ និងអធិស្ឋានឲ្យខ្ញុំ។ ហើយជាការពិតណាស់ គ្រប់អ្វីៗទាំងអស់សំដៅទៅលើតែម្នាក់គត់ដែលជាជីវិតរបស់យើងខ្ញុំ—គ្រប់ការសរសើរតម្កើងគឺសំដៅចំពោះព្រះអង្គ។ —SLJ

# មាតិកា

## ដកស្រង់ចេញពីព្រះគម្ពីរសញ្ញាចាស់


ដំណើររឿង និងបទចម្រៀង ........ ១២
កាលដើមដំបូង៖ ទីលំនៅដ៏ល្អឥតខ្ចោះ ........ ១៨
សេចក្តីភូតភរដ៏អាក្រក់ ........ ២៨
ចប់ដោយបរិបូរណ៍ ........ ៣៥
ការចាប់ផ្តើមជាថ្មី ........ ៣៨
កាំជណ្តើរដ៏ខ្ពស់ឡើងទៅស្ថានសួគ៌ ........ ៤៨
កូននៃសំណើច ........ ៥៦
ការជូនកាដូ ........ ៦២
នារីម្នាក់ដែលគ្មាននរណាចង់បាន ........ ៧០
ព្រះអម្ចាស់ដែលពេញដោយការអត់ទោស ........ ៧៦
ព្រះជាម្ចាស់ដែលយាងមកសង្គ្រោះ! ........ ៨៤
ព្រះជាម្ចាស់នឹងរៀបចំផ្លូវមួយ ........ ៩២
ប្រការដប់យ៉ាងដើម្បីឲ្យបានល្អឥតខ្ចោះ ........ ១០០
អ្នកដឹកនាំដែលជាមេទ័ពចម្បាំង ........ ១០៨
ស្តេចពិតប្រាកដ ដែលតូចល្អិត ........ ១១៦
វីរបុរសវ័យក្មេង និងយក្សដ៏យង់ឃ្នង ........ ១២២
អ្នកគង្វាលដ៏ល្អ ........ ១៣០
ក្មេងស្រីបម្រើម្នាក់ និងមេទ័ពដ៏ក្រអឺតក្រទម ........ ១៣៦
ប្រតិបត្តិការ «គ្មានទឹកភ្នែកទៀតទេ!» ........ ១៤៤
ហោរា ដានីយ៉ែល និងកន្លែងដ៏គួរឲ្យខ្លាច ........ ១៥២
អ្នកនាំសាររបស់ព្រះជាម្ចាស់ ........ ១៦០
ត្រៀមខ្លួនជាស្រេច ........ ១៧០




## ដកស្រង់ចេញពីព្រះគម្ពីរសញ្ញាថ្មី


ព្រះអង្គមកដល់ហើយ! ........ ១៧៦
ពន្លឺនៃលោកីយ៍ទាំងមូល ........ ១៨៤
ស្តេចលើអស់ទាំងស្តេច ........ ១៩២
ស្ថានសួគ៌បានទម្លុះចូលផែនដី ........ ២០០
តោះ! យើងទៅ! ........ ២០៨
ក្មេងស្រីតូច និងស្ត្រីកម្សត់ម្នាក់ ........ ២១៤
របៀបអធិស្ឋាន ........ ២២២
អ្នកចម្រៀង ........ ២២៨
មេបញ្ជាការខ្យល់ព្យុះ ........ ២៣៦
ពេញបរិបូរណ៍ ........ ២៤៤
ការស្វែងរកកំណប់ ........ ២៥០
មិត្តសម្លាញ់របស់កុមារតូចៗ ........ ២៥៦
បុរសម្នាក់ដែលគ្មានមិត្តភក្តិនឹងគេសោះ ........ ២៦៤
ការចាកចេញទៅ ........ ២៧២
ការលាងសម្អាតដោយទឹកភ្នែក ........ ២៨០
ស្តេចដែលជាអ្នកបម្រើ ........ ២៨៦
យប់ដ៏ខ្មៅងងឹតនៅឯសួនច្បារ ........ ២៩៤
ថ្ងៃដែលព្រះអាទិត្យលែងជះពន្លឺ ........ ៣០២
ការភ្ញាក់ផ្អើលដ៏អស្ចារ្យពីព្រះ ........ ៣១០
ការវិលត្រឡប់ទៅផ្ទះវិញ ........ ៣១៨
ព្រះជាម្ចាស់បញ្ជូនជំនួយ ........ ៣២៦
របៀបមើលថ្មី ........ ៣៣៤
ក្តីសុបិនអំពីស្ថានសួគ៌ ........ ៣៤២
នៅមានវគ្គបន្ត... ........ ៣៥០

# សម្រង់សម្ដី



ព្រះយេស៊ូវមានបន្ទូលថា «យើងជាដើមដំបូង ហើយជាចុងបង្អស់»។ (វិវរណៈ ២២:១៣ គកស)

«បន្ទាប់មក ព្រះអង្គក៏ស្រាយន័យសេចក្តីដែលចែងអំពីព្រះអង្គនៅក្នុងគម្ពីរទាំងមូល ឲ្យគេស្តាប់ ចាប់ពីគម្ពីរលោក ម៉ូសេ និងគម្ពីរហោរាៗមក»។ (លូកា ២៤:២៧ គកស)

ព្រះយេស៊ូវមានបន្ទូលថា «ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះនឹងបានជីវិតអស់កល្បជានិច្ច ហើយនឹងមិនស្លាប់ឡើយ។ ព្រះអង្គមិនបានបញ្ជូនព្រះរាជបុត្រាទ្រង់មក ដើម្បីឲ្យជំនុំជម្រះលោកីយ៍ទេ ព្រះអង្គបញ្ជូនទ្រង់មក ដើម្បីឲ្យជួយសង្គ្រោះគេវិញ»។ (យ៉ូហាន ៣:១៦-១៧)



«ខ្ញុំបានមកជាពន្លឺបំភ្លឺពិភពលោក ដើម្បីកុំឲ្យអ្នកណាដែលជឿដល់ខ្ញុំនៅជាប់នៅក្នុងសេចក្តីងងឹត»។ (យ៉ូហាន ១២:៤៦ គកស)

«ព្រះអម្ចាស់យេហូវ៉ានឹងជូតទឹកភ្នែកពីមុខមនុស្សទាំងអស់»។ (អេសាយ ២៥:៨)

«យើងខ្ញុំតែងតែមានអារម្មណ៍ថា ដំបូង ជីវិតគឺជារឿងមួយ ហើយប្រសិនបើមានរឿង នោះក៏ត្រូវមានអ្នកនិទានរឿងដែរ»។

*(GK Chesterton)*

# ដំណើររឿង និងបទចម្រៀង

(ដកស្រង់ចេញពីកណ្ឌទំនុកតម្កើង ១៩ និងហេព្រើរ ១)

ស្ថានសួគ៌ស្រែកច្រៀងពីភាពឧត្តមនៃព្រះជាម្ចាស់ជាយ៉ាងណា
នោះផ្ទៃមេឃក៏លាន់ឮរំពងឡើងយ៉ាងនោះដែរ
«មើលនឹ៍ ស្នាព្រះហស្តនៃព្រះជាម្ចាស់បានបង្កើតឡើង!»
ពីមួយថ្ងៃទៅមួយថ្ងៃ...មួយយប់ទៅមួយយប់...
ទាំងអស់និយាយមកកាន់យើង
*(ទំនុកតម្កើង ១៩:១-២)*

ព្រះជាម្ចាស់បានសរសេរចុះថា៖ «យើងស្រឡាញ់អ្នក» ព្រះអង្គបានសរសេរពាក្យពេចន៍នេះនៅលើផ្ទៃមេឃ និងផែនដី ហើយនិងបាតសមុទ្រផងដែរ។ ទ្រង់បានសរសេរព្រះបន្ទូលទ្រង់គ្រប់ទិសទីទាំងអស់ ពីព្រោះព្រះអង្គបានបង្កើតរបស់ទាំងអស់ នៅក្នុងពិភពលោករបស់ទ្រង់ ដើម្បីនឹងឆ្លុះបញ្ចាំងមកទ្រង់វិញដូចជាកញ្ចក់មួយ បង្ហាញឲ្យយើងដឹងពីទ្រង់ថា ទ្រង់មានភាពយ៉ាងណា ជួយឲ្យយើងស្គាល់ទ្រង់ និងនាំឲ្យចិត្តយើងបានរីករាយឡើងផងដែរ។

គឺរីករាយដូចជាកូនឆ្មាដែលដេញចាប់កន្ទុយខ្លួនឯង ឬដូចជាផ្កាព្រៃពណ៌ក្រហមដុះជាច្រើន និងដូចជាត្រីផ្សោតដែលហែលលេងក្នុងទឹកអញ្ចឹង។

ព្រះជាម្ចាស់ក៏បានរៀបចំជាពាក្យពេចន៍ឡើង ហើយពាក្យពេចន៍នោះជាព្រះបន្ទូលទ្រង់ ដែលទ្រង់បានសរសេរចុះជាសៀវភៅដែលយើងហៅថា «ព្រះគម្ពីរ»។








សព្វថ្ងៃនេះ មានមនុស្សខ្លះបានគិតថា ព្រះគម្ពីរគឺជាសៀវភៅក្រឹត្យវិន័យ ប្រាប់អ្នកនូវអ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ។ ប្រាកដណាស់ក្នុងព្រះគម្ពីរពិតជាមានក្រឹត្យវិន័យមួយចំនួនមែន ដែលបង្ហាញដល់អ្នកអំពីអ្វីៗដែលសំខាន់សម្រាប់ជីវិតរបស់អ្នក។ ប៉ុន្តែ គោលការណ៍សំខាន់នៃព្រះគម្ពីរ មិនមែនសំដៅទៅលើអ្វីដែលអ្នកត្រូវធ្វើ ឬមិនត្រូវធ្វើនោះទេ តែព្រះគម្ពីរបានសម្ដែងអំពីព្រះជាម្ចាស់ ហើយនិងអ្វីដែលព្រះជាម្ចាស់បានធ្វើវិញ។




មានមនុស្សផ្សេងទៀតបានគិតថា ព្រះគម្ពីរគឺជាសៀវភៅនិយាយអំពីរឿងអ្នកក្លាហាន ដែលបង្ហាញឲ្យអ្នករាល់គ្នាត្រូវយកគំរូតាម។ ព្រះគម្ពីរពិតជាបាននិយាយពីអ្នកក្លាហានមួយចំនួននៅក្នុងនោះមែន ប៉ុន្តែ (អ្នកនឹងបានឃើញនាពេលឆាប់ៗនេះ) មានមនុស្សមួយចំនួនធំទៀតនៅក្នុងព្រះគម្ពីរមិនមែនជាអ្នកក្លាហានទេ។ ពួកគេបានប្រព្រឹត្តអំពើខុសឆ្គងធ្ងន់ធ្ងរមួយចំនួនដែរ (ជួនកាលដោយមានចេតនាផង)។ ពួកគេមានការតក់ស្លុត ហើយក៏រត់គេចបាត់ទៅ ហើយមានពេលខ្លះគេក៏មានចិត្តអាក្រក់កាចសាហាវផងដែរ។




មិនដូច្នោះឡើយ! ព្រះគម្ពីរមិនមែនជាសៀវភៅក្រឹត្យវិន័យ ឬជាសៀវភៅនិយាយពីអ្នកក្លាហាននោះឡើយ។ ស្ទើរតែទាំងមូល ព្រះគម្ពីរគឺជាដំណើររឿងមួយ គឺជាដំណើររឿងប្រថុយប្រថានមួយស្តីអំពីកុមារក្លាហានម្នាក់ ដែលបានមកពីប្រទេសឆ្ងាយ ដើម្បីនឹងប្រមូលទ្រព្យសម្បត្តិ ដែលគាត់បានបាត់បង់មកវិញ។ ជាដំណើររឿងនៃសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ចំពោះកុមារម្នាក់នោះ ដែលបានចាកចេញពីវាំងខ្លួន និងអ្វីៗទាំងអស់ ដើម្បីមកជួយរំដោះអស់អ្នកដែលទ្រង់ស្រឡាញ់។ ដំណើររឿងនេះគឺប្រៀបដូចជារឿងនិទានដ៏អស្ចារ្យដែលបានក្លាយមកជាការពិតក្នុងជីវិតមួយអញ្ចឹង!

តើអ្នកឃើញទេ ចំណុចដ៏ប្រសើរបំផុតក្នុងដំណើររឿងនេះ គឺត្រង់ថាដំណើររឿងនេះជារឿងដ៏ពិត!

មានរឿងជាច្រើនណាស់នៅក្នុងព្រះគម្ពីរ ប៉ុន្តែ រឿងទាំងអស់នោះបាននិយាយសង្ខេបជារឿងដ៏ធំតែមួយ គឺជាដំណើររឿងដែលបញ្ជាក់ប្រាប់អំពីក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះកូនស្ងួនភ្ងារបស់ព្រះអង្គ ហើយបានយាងចុះមក ដើម្បីសង្គ្រោះពួកគេ។

មានតែព្រះគម្ពីរទាំងមូលទេ ទើបអាចនិទានដំណើររឿងមួយនេះបាន ហើយនៅកណ្តាលដំណើររឿងនិទាននេះ មាននិយាយពីទារកតូចមួយដែរ។ រឿងទាំងអស់ក្នុងព្រះគម្ពីរ បាននិយាយខ្សឹបខ្សៀវពីព្រះនាមទ្រង់។ ព្រះអង្គគឺជាតួអង្គដ៏សំខាន់ណាស់ ដែលមិនអាចដកចេញបានឡើយក្នុងការផ្តល់នូវដំណោះស្រាយ ជាតួឯកដែលតភ្ជាប់លើរាល់តួអង្គទាំងអស់ ហើយគ្រាន់តែមួយរំពេចនោះ អ្នកអាចនឹងឃើញពីរូបភាពដ៏ស្រស់បំព្រងនេះបាន។

ព្រះអង្គមិនមែនជាទារកធម្មតាទេ ព្រះអង្គគឺជាព្រះរាជបុត្រាដែលមនុស្សគ្រប់គ្នាត្រូវការ។ ព្រះអង្គ គឺជាព្រះរាជបុត្រា ដែលថ្ងៃមួយ...ប៉ុន្តែ សូមបង្អង់ចាំសិន។ ដំណើររឿងនិទានរបស់យើងចាប់ផ្តើមដូចរឿងល្អៗទាំងអស់ គឺចាប់ផ្តើមពីដើមដំបូងមក...

# កាលដើមដំបូង៖ ទីលំនៅដ៏ល្អឥតខ្ចោះ

បទចម្រៀងនៃការបង្កបង្កើត (ដកស្រង់ចេញពីកណ្ឌ លោកុប្បត្តិ ១-២)

**កាលដើមដំបូងឡើយ** គឺគ្មានអ្វីសោះ។

គ្មានឮសំឡេងអ្វី។ គ្មានអ្វីគួរឲ្យចាប់អារម្មណ៍។ គ្មានអ្វីអាចមើលឃើញបានឡើយ។

មានតែភាពទទេស្អាត។ និងងងឹតសូន្យសុង។ ហើយ...គ្មានអ្វីទាល់តែសោះ។

ប៉ុន្តែ មានព្រះជាម្ចាស់គង់នៅទីនោះ ហើយព្រះអង្គក៏មានផែនការដ៏ល្អបំផុតមួយដែរ។

ព្រះជាម្ចាស់មានបន្ទូលថា៖ «យើងនឹងបំពេញភាពទទេ ក្នុងភាពងងឹតសូន្យសុងនេះ យើងនឹងធ្វើឲ្យមានពន្លឺឡើង! ក្នុងភាពទទេនោះ យើងនឹងធ្វើឲ្យមានគ្រប់អ្វីៗទាំងអស់!»។

ដូចជាសត្វស្លាបត្រដាងស្លាបគ្របលើកូនរបស់វា ដើម្បីជួយឲ្យកូនវាញាស់ នោះព្រះជាម្ចាស់សំកាំងលើទីជម្រៅដ៏ងងឹតស្ងាត់សូន្យដែរ ហើយទ្រង់បានបង្កើតឲ្យមានជីវិតឡើង។

ព្រះជាម្ចាស់មានបន្ទូលថា «ល្អហើយ»។ ហើយវាពិតជាល្អមែន ព្រោះព្រះជាម្ចាស់បានមានបន្ទូលថា វាល្អ។







ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរឲ្យមានពន្លឺ!» នោះពន្លឺក៏ភ្លឺឡើងចាំងដល់ទីងងឹត ព្រះជាម្ចាស់បានហៅពន្លឺថាជា «ថ្ងៃ» ហើយងងឹតថាជា «យប់»។ ព្រះជាម្ចាស់មានបន្ទូលថា «ល្អហើយ»។ ហើយវាពិតជាល្អមែន ព្រោះព្រះជាម្ចាស់បានមានបន្ទូលថា វាល្អ។

បន្ទាប់មកព្រះជាម្ចាស់មានបន្ទូលទៀតថា៖ «ចូរឲ្យមានដីគោក!» នោះដីក៏បានផុសចេញពីសមុទ្រឡើង ដែលមានពេញទៅដោយជ្រោះជ្រលងភ្នំ និងឆ្នេរខ្សាច់។ ព្រះជាម្ចាស់មានបន្ទូលថា «ល្អហើយ»។ ហើយវាពិតជាល្អមែន ព្រោះព្រះជាម្ចាស់បានមានបន្ទូលថា វាល្អ។

ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរឲ្យមានដើមឈើ ចូរឲ្យមានស្មៅ ចូរឲ្យមានផ្កាដុះឡើង!»។ នោះស្មៅ និងផ្កាក៏បានដុះឡើងគ្រប់ទីកន្លែង។ ព្រះអង្គបានបង្កើតដើមមានមើម ដើមមានលម្អង និងពូជផ្កាផ្សេងៗ។ ព្រះជាម្ចាស់មានបន្ទូលថា «ល្អហើយ»។ ហើយវាពិតជាល្អមែន ព្រោះព្រះជាម្ចាស់បានមានបន្ទូលថា វាល្អ។





ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរឲ្យមានផ្កាយ ចូរឲ្យមានព្រះអាទិត្យ ចូរឲ្យមានព្រះចន្ទ!» នោះស្រាប់តែមានដុំមូល លេចឡើងពីក្នុងទីងងឹតជាមួយរំពេច ដុំនោះមានកម្ដៅដ៏ក្ដៅក្រៃលែង ហើយវិលជុំវិញ ដោយបញ្ចេញពណ៌ទឹកក្រូច ពណ៌ស្វាយ និងពណ៌មាស។ ព្រះជាម្ចាស់មានបន្ទូលថា «ល្អហើយ»។ ហើយវាពិតជាល្អមែន ព្រោះព្រះជាម្ចាស់បានមានបន្ទូលថា វាល្អ។



ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរឲ្យមានសត្វស្លាប!» នោះស្រាប់តែសត្វស្លាបហើរមក ខ្លះត្រដាងស្លាប ខ្លះទទះស្លាប ហើយខ្លះទៀតហើរច្រៀងរំពងពេញវេហា។ ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរឲ្យមានត្រី!» នោះស្រាប់តែមានត្រីហែលត្របាញ់ ប្រដេញគ្នាខ្វាយពេញទឹកសមុទ្រ! ព្រះជាម្ចាស់មានបន្ទូលថា «ល្អហើយ»។ ហើយវាពិតជាល្អមែន ព្រោះព្រះជាម្ចាស់បានមានបន្ទូលថា វាល្អ។

ព្រះជាម្ចាស់ក៏មានបន្ទូលទៀតថា៖ «ចូរឲ្យមានសត្វពាហនៈ!» នោះគ្រប់ទាំងសត្វបានចេញមកលេង ដោយបន្លឺជាសំឡេង គ្រហឹម រោទ៍ ស្រមុក និងសប្បាយអឺងកងពេញដី។ ព្រះជាម្ចាស់មានបន្ទូលថា «ល្អហើយ»។ ហើយវាពិតជាល្អមែន ព្រោះព្រះជាម្ចាស់បានមានបន្ទូលថា វាល្អ។

ព្រះជាម្ចាស់បានមើលឃើញរបស់ទាំងអស់ដែលព្រះអង្គបានបង្កើត ហើយព្រះអង្គស្រឡាញ់ពួកវាណាស់។ របស់ទាំងនោះគួរឲ្យស្រឡាញ់ ដោយព្រោះព្រះជាម្ចាស់ស្រឡាញ់វា។

ប៉ុន្តែ ព្រះជាម្ចាស់បានទុកការល្អបំផុត នៅចុងក្រោយវិញ គឺចាប់តាំងពីថ្ងៃដំបូងមក ព្រះជាម្ចាស់មានផែនការដ៏ល្អក្នុងចិត្តទ្រង់ ព្រះអង្គចង់បង្កើតមនុស្សដើម្បីឲ្យពួកគេមានចំណែកក្នុងអំណរដ៏អស់កល្បជានិច្ចរបស់ទ្រង់។ ពួកគេនឹងធ្វើជាកូនរបស់ព្រះអង្គ ហើយផែនដីនេះនឹងបានជាទីលំនៅដ៏ល្អបំផុតសម្រាប់ពួកគេ។





ដូច្នេះ ព្រះអង្គបានផ្លុំខ្យល់ដង្ហើមជីវិតចូលទៅក្នុងលោក អ័ដាម និងនាង អេវ៉ា។

នៅពេលដែលអ្នកទាំងពីរបើកភ្នែកឡើង ជាដំបូងបង្អស់ គេបានឃើញព្រះភក្ត្រព្រះអង្គ។

ហើយនៅពេលដែលព្រះជាម្ចាស់បានមើលឃើញគេមានជីវិតឡើង នោះព្រះអង្គមានអារម្មណ៍ថា ទ្រង់ជាឪពុកដំបូងរបស់គេ។ ព្រះជាម្ចាស់មានបន្ទូលថា៖ «ឯងដូចយើងណាស់! ឯងល្អផ្តាច់គេ ក្នុងចំណោមរបស់ទាំងអស់ដែលយើងបានបង្កើត»។

ព្រះជាម្ចាស់បានស្រឡាញ់គេអស់ពីដួងចិត្តរបស់ទ្រង់ អ្នកទាំងពីរគួរឲ្យស្រឡាញ់ណាស់ពីព្រោះទ្រង់ស្រឡាញ់ពួកគេ។

លោក អ័ដាម និងនាង អេវ៉ា ចូលរួមបន្លឺចម្រៀងច្រៀងរៀបរាប់ពីផ្កាយ ទឹកជ្រោះ និងសំឡេងខ្យល់ ជាចម្រៀងនៃសេចក្តីស្រឡាញ់មួយបទយ៉ាងពីរោះ ទៅកាន់ព្រះជាម្ចាស់ ដែលបានបង្កើតខ្លួនមក។ ចិត្តរបស់ពួកគេពេញទៅដោយសេចក្តីសុខសាន្ត គ្មានអ្វីដែលអាចធ្វើឲ្យគេពិបាកចិត្ត រស់នៅឯកា ឈឺថ្កាត់ ឬមានការភ័យខ្លាចឡើយ។

ព្រះជាម្ចាស់ទតមើលគ្រប់របស់ទាំងអស់ដែលព្រះអង្គបានបង្កើត រួចព្រះអង្គមានបន្ទូលថា៖ «ល្អណាស់!» ហើយអ្វីទាំងអស់ពិតជាល្អណាស់ ព្រោះព្រះជាម្ចាស់បានមានបន្ទូលថា វាល្អណាស់។

ប៉ុន្តែ ផ្កាយ ភ្នំ សមុទ្រ កញ្ចុំផ្កាយ និងគ្រប់របស់ទាំងអស់ គ្មានអ្វីអាចប្រៀបផ្ទឹមបានទៅនឹងសេចក្តីស្រឡាញ់ដែលព្រះអង្គមានចំពោះកូនរបស់ទ្រង់ឡើយ។ ព្រះអង្គចង់ទាញស្ថានសួគ៌ និងផែនដីឲ្យបាននៅជិតគ្នាជានិច្ច ទោះមានអ្វីបានកើតឡើង ឬទោះត្រូវលះបង់អ្វីក៏ដោយ ក៏ព្រះអង្គតែងតែស្រឡាញ់ពួកគេជានិច្ច។

ហេតុដូច្នេះហើយ បានជារឿងស្តីអំពីសេចក្តីស្រឡាញ់ដ៏អស្ចារ្យ បានចាប់ផ្តើមឡើង...

# សេចក្តីភូតភរដ៏អាក្រក់

លោក អ័ដាម និងនាង អេវ៉ា បាត់បង់គ្រប់អ្វីៗទាំងអស់ (ដកស្រង់ចេញពីកណ្ឌ លោកុប្បត្តិ ៣)

**លោក អ័ដាម និងនាង អេវ៉ា** រួមរស់ជាមួយគ្នាយ៉ាងសុខសាន្តនៅក្នុងលំនៅថ្មីដ៏ស្អាតរបស់ពួកគាត់ ហើយគ្រប់ទាំងអស់ល្អឥតខ្ចោះ–ក្នុងមួយរយៈ។

រហូតមកដល់ថ្ងៃមួយ រាល់គ្រប់អ្វីៗបានធ្លាក់ទៅក្នុងផ្លូវខុស។

ព្រះជាម្ចាស់មានសត្រូវដ៏កំណាចម្នាក់ វាឈ្មោះថា សាតាំង។ ពីមុន សាតាំងជាទេវតាដ៏ល្អស្អាតស្រស់បំព្រងម្នាក់របស់ព្រះជាម្ចាស់។ ប៉ុន្តែ វាមិនគ្រាន់តែចង់ធ្វើជាទេវតារបស់ព្រះជាម្ចាស់ប៉ុណ្ណោះទេ គឺវាមានបំណងចង់ក្លាយដូចជាព្រះជាម្ចាស់។ វាមានចិត្តអួតអាង និងចិត្តកំណាច ហើយពោរពេញទៅដោយសម្អប់ ដូច្នេះហើយទើបព្រះជាម្ចាស់បានបណ្តេញវា ឲ្យចេញពីស្ថានសួគ៌។ សាតាំងមានចិត្តក្តៅក្រហាយ ហើយខឹងយ៉ាងខ្លាំង វាស្វែងរកផ្លូវ ដើម្បីធ្វើឲ្យព្រះជាម្ចាស់មានការឈឺចាប់វិញ។ វាមានបំណងចង់បញ្ឈប់ផែនការរបស់ព្រះជាម្ចាស់ ចង់បញ្ចប់រឿងនៃសេចក្តីស្រឡាញ់តែត្រឹមហ្នឹង ដូច្នេះវាក៏បានក្លែងខ្លួនធ្វើជាសត្វពស់ ហើយមករង់ចាំនៅក្នុងសួនច្បារ។

ព្រះជាម្ចាស់បានឲ្យសេចក្តីបង្គាប់មួយដល់លោក អ័ដាម និងនាង អេវ៉ា គឺទ្រង់បានបង្គាប់ដល់ពួកគាត់ថា៖ «ចូរឯងកុំបរិភោគផ្លែដែលចេញពីដើមមួយនេះឲ្យសោះ បើសិនជាឯងបរិភោគ នោះឯងនឹងគិតថា ឯងចេះដឹងលើរាល់គ្រប់អ្វីៗទាំងអស់។ ឯងនឹងលែងទុកចិត្តលើយើង។ បន្ទាប់មកឯងនឹងជួបសេចក្តីស្លាប់ ទុក្ខលំបាក និងការយំសោកជាមិនខាន»។



(អ្នកឃើញទេ ព្រះជាម្ចាស់បានដឹងរួចជាមុនហើយថា បើសិនជាពួកគេបរិភោគផ្លែឈើនោះ ពួកគេនឹងមិនត្រូវការព្រះជាម្ចាស់ទេ ហើយគេនឹងខំប្រឹងធ្វើឲ្យខ្លួនគេបានសប្បាយចិត្ត ដោយមិនចាំបាច់ពឹងទ្រង់ដែរ។ ប៉ុន្តែ ព្រះជាម្ចាស់ក៏បានជ្រាបជាមុនដែរថា គ្មានសេចក្ដីសុខសាន្តបែបនេះទេ ប្រសិនបើជាគ្មានទំនាក់ទំនងជាមួយនឹងព្រះអង្គនោះ ហើយជីវិតដែលគ្មានទំនាក់ទំនងជាមួយព្រះជាម្ចាស់ នោះស្មើនឹងគ្មានជីវិតតែម្ដង។)

នៅពេលដែលសត្វពស់បានឃើញឱកាសល្អ វាក៏ចូលទៅរកនាង អេវ៉ា ដោយស្ងៀមស្ងាត់។ សត្វពស់ខ្សឹបសួរនាងថា៖ «តើព្រះជាម្ចាស់ពិតប្រាកដជាស្រឡាញ់នាងមែនទេ? បើព្រះជាម្ចាស់ពិតជាស្រឡាញ់នាងមែន ហេតុអ្វីបានជាព្រះអង្គមិនឲ្យនាងបរិភោគផ្លែឈើដ៏ល្អ ហើយឆ្ងាញ់នេះ? ឱ! នាងដ៏គួរឲ្យអាណិតអើយ! ប្រហែលជាព្រះជាម្ចាស់មិនចង់ឲ្យនាងបានសប្បាយរីករាយទេដឹង»។

ពាក្យខ្សឹបខ្សៀវរបស់សត្វពស់បានជ្រាបចូលតាមត្រចៀកទៅដល់ជម្រៅចិត្តរបស់នាងដូចជាពិស។ នាង អេវ៉ា ឆ្ងល់ថា៖ *«តើព្រះជាម្ចាស់ពិតជាស្រឡាញ់ខ្ញុំមែនទេឬ?»* រំពេចនោះ នាងក៏មានមន្ទិលសង្ស័យលើក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។

សត្វពស់បានខ្សឹបប្រាប់នាងទៀតថា៖ «ជឿខ្ញុំចុះ! នាងមិនបាច់ត្រូវការព្រះជាម្ចាស់ទេ បើគ្រាន់តែភ្លក់បន្តិចប៉ុណ្ណោះ នាងនឹងទទួលការសប្បាយចិត្តហួសពីការស្រមៃរបស់នាងទៅទៀតជាមិនខាន...»។



នាង អេវ៉ា ក៏បានបេះផ្លែឈើនោះមក ហើយបរិភោគខ្លះ រួចហុចទៅឲ្យលោក អ័ដាម ហើយគាត់ក៏បានបរិភោគខ្លះដែរ។

ដូច្នេះ ការភូតភរដ៏អាក្រក់នេះ បានចូលមកក្នុងលោកីយ៍ ហើយមិនដែលចាកចេញទៅណាឆ្ងាយពីមនុស្សលោកទេ គឺវារស់នៅក្នុងចិត្តរបស់មនុស្សគ្រប់ៗរូប ទាំងខ្សឹបប្រាប់កូនព្រះជាម្ចាស់គ្រប់រូបថា៖ «ព្រះជាម្ចាស់មិនស្រឡាញ់អ្នកឡើយ»។



នេះមិនមែនគ្រាន់តែជាសុបិនធម្មតាទេ តែជាសុបិនដ៏អាក្រក់មួយទៅវិញ។

សត្វព្រាបមួយបានហើរចេញពីដៃលោក អ័ដាម ទៅ សត្វក្ដាន់បានបោលក្ដុងចូលទៅក្នុងព្រៃជ្រៅ គឺដោយសារវាខ្លាចនឹងអ្វីមួយ។ ខ្យល់មានភាពត្រជាក់ ធ្វើឲ្យព្រឺបាសរោមខ្វាកៗ ហាក់បីដូចជាមានហេតុចម្លែកអ្វីមួយកើតឡើង។ ពីមុនមកជាធម្មតាពួកគាត់ធ្លាប់តែនៅខ្លួនទទេ ឥតស្លៀកពាក់ទេ ប៉ុន្តែឥឡូវនេះ ពួកគាត់មានអារម្មណ៍ថា នៅខ្លួនទទេ មិនសមរម្យ ហើយពួកគាត់មិនចង់ឲ្យនរណាម្នាក់ឃើញពួកគាត់ឡើយ ដូច្នេះហើយបានជាពួកគាត់រត់ពួន។

ពេលល្ងាចបន្តិចនៅថ្ងៃនោះ ព្រះជាម្ចាស់បានយាងទៅ ព្រះអង្គស្រែកហៅពួកគាត់ថា៖ «កូនអើយ!»។

តាមធម្មតាលោក អ័ដាម និងនាង អេវ៉ា ចង់ឮសំឡេងរបស់ព្រះជាម្ចាស់ណាស់ ព្រមទាំងរត់មករកទ្រង់ផង ប៉ុន្តែ ពេលនេះពួកគាត់បែរជារត់គេចចេញពីព្រះអង្គទៅពួនក្នុងទីងងឹតវិញ។

ព្រះជាម្ចាស់បានស្រែកហៅថា៖ «ពួកឯងនៅឯណា?»។

លោក អ័ដាម ឆ្លើយថា៖ «ខ្ញុំកំពុងតែពួន យើងខ្ញុំខ្លាចព្រះអង្គណាស់»។

ព្រះជាម្ចាស់បានសួរពួកគេថា៖ «តើឯងបានបរិភោគផ្លែឈើ ដែលយើងបានប្រាប់មិនឲ្យឯងបរិភោគនោះឬ?»។

លោក អ័ដាម ឆ្លើយថា៖ «គឺនាង អេវ៉ា ជាអ្នកនាំខ្ញុំញ៉ាំ!»។

ព្រះជាម្ចាស់បានមានបន្ទូលសួរនាង អេវ៉ា ថា៖ «តើឯងបានធ្វើអ្វី?»។

នាង អេវ៉ា ឆ្លើយថា៖ «គឺសត្វពស់ វាប្រាប់ខ្ញុំឲ្យធ្វើតើ»។

ព្រះជាម្ចាស់ឈឺចាប់ក្នុងចិត្តយ៉ាងខ្លាំង ដោយព្រោះកូនរបស់ព្រះអង្គមិនគ្រាន់តែមិនបានធ្វើតាមបញ្ញត្តិមួយរបស់ព្រះអង្គទេ គឺគេថែមទាំងបានធ្វើឲ្យព្រះអង្គខកចិត្តជាខ្លាំងទៀតផង។ គេបានកាត់ផ្ដាច់ចំណងមិត្តភាពដ៏វិសេសរបស់ពួកគេចេញពីព្រះជាម្ចាស់។ ឥឡូវនេះ ព្រះជាម្ចាស់បានដឹងថា អ្វីៗផ្សេងទៀត ក៏ត្រូវបាក់បែកខូចខាតដែរ។ រីឯ ការបង្កបង្កើតរបស់ទ្រង់ នឹងទៅជាស្មុគស្មាញដោះស្រាយមិនចេញ ហើយក៏មិនបានដល់ទីបញ្ចប់ ហើយក៏មិនបានសមតាមបំណងរបស់ទ្រង់ទៀតផង។ ចាប់ពីពេលនេះទៅ អ្វីៗក៏ត្រូវស្លាប់ ទោះបើពីមុនមកបានសន្មតថា នឹងត្រូវរស់នៅអស់កល្បជានិច្ចក៏ដោយ។





អ្នកឃើញទេ អំពើបាបបានចូលមកក្នុងផែនដីដ៏ល្អរបស់ព្រះជាម្ចាស់ ហើយវាមិនព្រមចាកចេញឡើយ។ ឯកូនរបស់ព្រះជាម្ចាស់វិញនឹងតែងតែរត់ចេញពីទ្រង់ ហើយលាក់ខ្លួនក្នុងទីងងឹត។ ពេលនេះចិត្តរបស់គេត្រូវខ្ទេចខ្ទាំ ហើយមិនអាចត្រឡប់ឲ្យល្អដូចដើមវិញបានឡើយ។

ព្រះអង្គមិនចង់ឲ្យកូនៗរបស់ទ្រង់រស់នៅក្នុងការឈឺចាប់បែបនេះ ដោយគ្មានព្រះអង្គជារៀងរហូតនោះទេ គឺមានតែផ្លូវមួយគត់ ដើម្បីការពារពួកគេ។

ព្រះជាម្ចាស់មានបន្ទូលប្រាប់កូនព្រះអង្គទាំងទឹកភ្នែកស្រក់ចុះមកផងថា៖ «ឯងត្រូវតែចាកចេញពីសួនច្បារ ឥឡូវនេះ! ទីនេះមិនមែនជាផ្ទះពិតរបស់ឯងទៀតទេ គឺមិនមែនជាទីកន្លែងរបស់ឯងតទៅទៀតឡើយ»។

ប៉ុន្តែ មុនពេលពួកគេចេញពីសួនច្បារទៅ ព្រះជាម្ចាស់បានកាត់ខោអាវឲ្យកូនរបស់ទ្រង់ ដើម្បីបិទបាំងរាងកាយពួកគេ។ ព្រះអង្គបានស្លៀកពាក់ឲ្យពួកគេដោយថ្នាក់ថ្នម ហើយទ្រង់បានឲ្យគេចេញដំណើរទៅឆ្ងាយពីសួនច្បារ ចេញពីផ្ទះរបស់ពួកគេ។

តាមពិតទៅ បើក្នុងដំណើររឿងមួយផ្សេងទៀត ការនោះនឹងប្រាកដជាដាច់ស្រេចជាមិនខាន...

## ចប់ដោយបរិបូរណ៍

ប៉ុន្តែ មិនមែនក្នុងដំណើររឿងនេះទេ។

ព្រះជាម្ចាស់បានស្រឡាញ់កូនៗទ្រង់ខ្លាំងណាស់ ដូច្នេះទ្រង់មិនឲ្យរឿងនោះបញ្ចប់នៅត្រឹមនេះទេ។ ទោះបីជាព្រះអង្គជ្រាបថា ទ្រង់នឹងទទួលការឈឺចាប់ក៏ដោយ ក៏ព្រះអង្គនៅមានផែនការមួយជាផែនការដ៏ល្អបំផុត គឺថានៅថ្ងៃមួយ ព្រះអង្គនឹងប្រមូលយកកូនៗទ្រង់មកវិញ។ ហើយនៅថ្ងៃមួយ ទ្រង់នឹងធ្វើឲ្យផែនដីនេះក្លាយជាលំនៅដ៏ល្អបំផុតសម្រាប់គេវិញម្តងទៀត ហើយនៅថ្ងៃនោះ ព្រះអង្គនឹងជូតរាល់ទាំងទឹកភ្នែករបស់ពួកគេ។

មើលហ្ន៎! ទោះជាកូនទ្រង់បានចាកចេញដោយបានធ្វើខុសក៏ដោយ ក៏ព្រះជាម្ចាស់នៅតែស្រឡាញ់កូនទ្រង់ គ្មានទីបញ្ចប់ មិនអាចបោះបង់បាន មិនអាចបំបែកចេញបានដែរ ជាសេចក្តីស្រឡាញ់ដ៏អស់កល្បជានិច្ច។

ហើយទោះបើពួកគេបានភ្លេចព្រះអង្គ ហើយបានរត់គេចចេញពីទ្រង់ក៏ដោយ ក៏ប៉ុន្តែក្នុងជម្រៅចិត្តរបស់ពួកគេដែលជាកូនៗព្រះជាម្ចាស់ ក៏ពួកគេនៅតែមានការនឹករលឹកមកព្រះអង្គជានិច្ច–កូនវង្វេងរបស់ព្រះជាម្ចាស់បានប្រាថ្នាចង់ត្រឡប់ទៅផ្ទះរបស់គេវិញ។

មុនពេលដែលគេបានចាកចេញពីសួនច្បារទៅ ព្រះជាម្ចាស់បានខ្សឹបប្រាប់លោក អ័ដាម និងនាង អេវ៉ា ដោយសន្យាថា៖ «ទោះបីយើងមិនបាននៅជាមួយឯង តែយើងនឹងមករំដោះឯង ហើយនៅពេលដែលយើងមក នោះយើងនឹងតតាំងជាមួយសត្វពស់ ហើយយើងនឹងវាយកំចាត់អំពើបាប ភាពងងឹត និងការសោកសង្រេង ដែលឯងនាំវាចូលមកទីនេះ យើងនឹងមករកពួកឯងវិញ!»។

ហើយទ្រង់នឹងយាងមកវិញ នៅថ្ងៃមួយ ព្រះជាម្ចាស់នឹងយាងមកវិញ ដោយអង្គឯងផ្ទាល់។



# ការចាប់ផ្ដើមជាថ្មី

ទូកលោក ណូអេ (ដកស្រង់ចេញពីកណ្ឌ លោកុប្បត្តិ ៦-៩)




**ពេលវេលា**ចេះតែកន្លងទៅ ហើយមនុស្សបានកើតពាសពេញលើផែនដី។ នៅគ្រប់ទីកន្លែងគេគ្រប់គ្នាបានភ្លេចព្រះជាម្ចាស់ រួចគេប្រព្រឹត្តតែអំពើអាក្រក់តែប៉ុណ្ណោះ។

ព្រះអង្គឈឺចិត្តយ៉ាងខ្លាំង នៅពេលដែលព្រះអង្គបានឃើញការទាំងនោះកើតឡើងនៅលើផែនដីដែលទ្រង់ស្រឡាញ់។ គ្រប់ទីកន្លែងមានពេញទៅដោយជំងឺរោគា សេចក្ដីស្លាប់ និងគ្រោះមហន្តរាយ ដែលទាំងអស់នោះសុទ្ធតែជាអ្វីដែលព្រះអង្គស្អប់យ៉ាងខ្លាំង។

កាលនោះមានបុគ្គលម្នាក់ឈ្មោះលោក ណូអេ ដែលមានតែគាត់ម្នាក់គត់ជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ (ដែលនៅកាលនោះគ្មាននរណាផ្សេងទៀតក្រៅពីគាត់ឡើយ)។ លោក ណូអេ បានស្ដាប់បង្គាប់ព្រះជាម្ចាស់។ គាត់និយាយលេងជាមួយព្រះជាម្ចាស់។ គាត់ចូលចិត្តនៅជាមួយនឹងព្រះជាម្ចាស់ ដូចជាអ្នកចូលចិត្តនៅជាមួយនឹងមិត្តសម្លាញ់ដ៏ល្អរបស់អ្នកដែរ។

ព្រះជាម្ចាស់មានបន្ទូលថា៖ «ណូអេ! អ្វីៗបានប្ដូរទៅជាអាក្រក់ទាំងអស់ មនុស្សទាំងអស់ដែលរស់នៅលើផែនដីយើង មានចិត្តពេញទៅដោយការស្អប់ខ្ពើមគ្នាជំនួសសេចក្ដីស្រឡាញ់ទៅវិញ ពួកគេកំពុងតែបំផ្លាញខ្លួនឯង...និងគ្នាឯង...ហើយនិងផែនដីយើង យើងត្រូវតែបញ្ឈប់ពួកគេ តែជាដំបូង ឯងត្រូវធ្វើទូកមួយសិន» (តើអ្នកចេះធ្វើទូកដែរឬទេ? លោក ណូអេ ក៏មិនចេះធ្វើទូកដែរ។ តែជាការល្អណាស់ដែលព្រះជាម្ចាស់ចេះធ្វើទូក ហើយទ្រង់នឹងបង្ហាញឲ្យគាត់ចេះពីរបៀបធ្វើទូកផងដែរ)។



ព្រះជាម្ចាស់មានបន្ទូលប្រាប់លោក ណូអេ ទៀតថា៖ «ព្យុះសង្ឃរានឹងកើតមានឡើង ប៉ុន្តែ យើងសន្យាថា យើងនឹងសង្គ្រោះឯង។ យើងនឹងបញ្ជូនសត្វទាំងអស់មកឯឯង គឺមានពួកសត្វដែលវារ ពួកសត្វដែលលូនវារ ពួកសត្វដែលលូននឹងពោះ ពួកសត្វដែលរំកិលខ្លួន ពួកសត្វដែលផាយ ពួកសត្វដែលលោត ពួកសត្វដែលរត់ ដោយលោត និងសត្វដែលប្រតោង។ ហើយកុំភ្លេចនាំយកចំណីអាហារសម្រាប់គ្រប់សត្វទាំងអស់ផង»។

ព្យុះសង្ឃរានឹងបោសសម្អាតនូវភាពសម្អប់ ទុក្ខសោក និងគ្រប់អ្វីៗដែលជាការអាក្រក់ទាំងអស់ ហើយយើងនឹងសម្អាតផែនដីឲ្យបានស្អាតម្តងទៀត។ ទ្រង់មានគម្រោង ដើម្បីឲ្យលោក ណូអេ រួចផុតពីគ្រោះថ្នាក់ ប៉ុន្តែ លោក ណូអេ ត្រូវតែមានទំនុកចិត្តចំពោះព្រះជាម្ចាស់ ហើយធ្វើតាមអ្វីដែលព្រះជាម្ចាស់បានប្រាប់គាត់ឲ្យធ្វើ។

ដូច្នេះ លោក ណូអេ ក៏សង់ទូកដ៏ធំមួយឡើង។

រីឯ អ្នកជិតខាងរបស់លោក ណូអេ បានចេញពីផ្ទះមកមើល...គេបានចង្អុល...ហើយសើចចំអកដាក់គាត់ ពីព្រោះគេពុំបានជឿតាមលោក ណូអេ ទាក់ទងនឹងការសង់ទូកធំ...ទាក់ទងនឹងព្យុះសង្ឃរា...ឬក៏តម្រូវការនៃការជួយសង្គ្រោះឡើយ។ ចំពោះពួកគេ មើលទៅលោក ណូអេ ហាក់បីដូចជាល្ងីល្ងើមែនទែន។ គាត់បានសង់ទូកនៅកណ្តាលទីរហោស្ថាន គឺជាកន្លែងមួយដែលនៅឆ្ងាយពីសមុទ្រ មិនត្រឹមតែប៉ុណ្ណោះ ថែមទាំងមេឃស្រឡះធេងគ្មានពពកផង។ និយាយឲ្យខ្លីទៅ កាលនោះគ្មានអ្នកណាត្រូវការឆ័ត្រផង ហើយតើឲ្យត្រូវការទូកធ្វើអីទៅ?







ប៉ុន្តែ ចំពោះគំនិតរបស់ពួកមនុស្សទាំងនោះ លោក ណូអេ មិនខ្វល់ទេ តែគាត់ខ្វល់ខ្វាយតែពីគំនិតរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ ដូច្នេះ គាត់បានធ្វើនូវអ្វីៗដែលព្រះជាម្ចាស់បានបង្គាប់ឲ្យគាត់ធ្វើ។

នៅពេលដែលទូកធំនោះបានសង់រួចស្រេចហើយ ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរនាំគ្នាចូលទៅចុះ» ដូច្នេះ ក្រុមគ្រួសារលោក ណូអេ ទាំងអស់គ្នា ព្រមទាំងពពួកសត្វទាំងប៉ុន្មានក៏នាំគ្នាចូលទៅក្នុងទូក។

រួចមកព្រះជាម្ចាស់ក៏បិទទ្វារទូកធំនោះទៅ។

ហើយភ្លៀងក៏ចាប់ផ្ដើមធ្លាក់មក ជាច្រើននាទី រហូតដល់ច្រើនម៉ោង ដល់ច្រើនថ្ងៃ ដល់ច្រើនអាទិត្យ ហើយច្រើនអាទិត្យទៀត។ រួចភ្លៀងក៏បង្កើតជាថ្លុក ថ្លុកបង្កើតជាស្ទឹង ស្ទឹងបង្កើតជាបឹង បឹងបង្កើតជាទន្លេរហូតដល់ក្លាយជាទឹកជំនន់ដ៏ធំគ្របដណ្ដប់ផែនដីទាំងមូលតែម្ដង។

ពីមុន ទូករបស់គាត់ មើលទៅហាក់បីដូចជាធំណាស់ ស្រាប់តែឥឡូវ ពេលអណ្ដែតនៅលើផ្ទៃទឹក មើលម្ដងទៀតទៅហាក់បីដូចជាតូចមែនទែន។ ប៉ុន្តែ នៅចំកណ្ដាលព្យុះសង្ឃរា ដែលមានរលកធំៗបោកកញ្ជ្រោល លាយនឹងរន្ទះ ព្រមទាំងផ្លេកបន្ទោរផ្លេកៗផងនោះ គឺនៅក្នុងហេតុការណ៍ទាំងនេះ ព្រះជាម្ចាស់គង់នៅជាមួយពួកគាត់ ហើយព្រះជាម្ចាស់បានការពារពួកគាត់ឲ្យផុតពីគ្រោះថ្នាក់នេះអស់រយៈពេល៤០ថ្ងៃ៤០យប់។

ហើយនៅទីបំផុត ភ្លៀងក៏បានស្ងប់ឈឹងទៅ ព្រះអាទិត្យក៏រះឡើង។ លោក ណូអេ ក៏បើកបង្អួចទូក «អ្ហេ!» គ្រប់គ្នាលាន់មាត់ឡើង។

លោក ណូអេ បានលែងសត្វព្រាបឲ្យហើរចេញពីទូកទៅ ដើម្បីមើលសភាពការណ៍ខាងក្រៅ មិនយូរប៉ុន្មាន សត្វព្រាបក៏បានពាំស្លឹកអូលីវដ៏ស្រស់មួយមកផង។ គ្រប់គ្នាក៏បានដឹងច្បាស់ថា សត្វព្រាបបានរកឃើញដើមឈើ ហើយនិងដីគោក! នេះមានន័យថាទឹកបានស្រកហើយ។





នៅទីបំផុត ស្រាប់តែទូកលោក ណូអេ បានកឿងដោយស្រួលនៅលើកំពូលភ្នំដ៏ធំមួយ។ ពេលដែលទូកនឹងថ្កល់ហើយ ព្រះជាម្ចាស់មានបន្ទូលប្រាប់គេថា៖ «ចូរនាំគ្នាចេញមក!» គ្រប់គ្នាក៏ចេញពីទូកទៅ ដោយរីករាយសប្បាយ គេលោតកញ្ឆេង និងរាំលើដីស្ងួត។

មុនដំបូងបង្អស់ លោក ណូអេ បានអរព្រះគុណដល់ព្រះជាម្ចាស់ ពីព្រោះព្រះជាម្ចាស់បានជួយសង្គ្រោះក្រុមគ្រួសារគាត់ ដូចដែលព្រះអង្គបានសន្យានឹងគាត់មែន។

ហើយជាដំបូងក្នុងពេលនោះ ព្រះជាម្ចាស់បានសន្យាថា៖ «យើងនឹងមិនបំផ្លាញផែនដីនេះទៀតទេ»។ នេះប្រៀបដូចជាអ្នកចម្បាំងម្នាក់ ដែលបានយកធ្នូ និងព្រួញទៅទុកបន្ទាប់ពីបានច្បាំងហើយ ព្រះជាម្ចាស់មានបន្ទូលថា៖ «ឃើញទេ យើងបានព្យួរធ្នូរបស់យើងនៅលើពពកហើយ»។



ហើយនៅទីនោះ ក្នុងពពក ដែលជាកន្លែងដែលខ្យល់ព្យុះជួបនឹងព្រះអាទិត្យ វាបានបង្កើតចេញជាធ្នូដ៏ស្អាតបង្កើតដោយពន្លឺ។

នេះគឺជាការចាប់ផ្ដើមជាថ្មីមួយទៀត នៅលើផែនដីរបស់ព្រះជាម្ចាស់។

តែមិនយូរប៉ុន្មានផង ការទាំងអស់បានធ្លាក់ចូលផ្លូវអាក្រក់ម្ដងទៀត ក៏ប៉ុន្តែ ព្រះជាម្ចាស់មិនមានភាពភ្ញាក់ផ្អើលនោះឡើយ ព្រោះព្រះអង្គបានដឹងជាមុនរួចស្រេចហើយថា នឹងមានការនេះកើតឡើងម្ដងទៀត។ មូលហេតុនេះហើយបានជាមុនពេលកំណត់ ព្រះជាម្ចាស់មានផែនការមួយទៀតដែលល្អជាងមុន គឺជាផែនការដែលមិនបំផ្លាញផែនដីនេះទៀតទេ ប៉ុន្តែ ជាផែនការសង្គ្រោះឲ្យរួចពីបាបវិញ។ នៅថ្ងៃមួយ ព្រះអង្គនឹងចាត់ព្រះរាជបុត្រាតែមួយគត់របស់ព្រះអង្គ មកធ្វើជាអ្នកសង្គ្រោះឲ្យរួចពីបាប។

ព្រះជាម្ចាស់នឹងមានចិត្តខឹងយ៉ាងខ្លាំងម្ដងទៀត ចំពោះភាពសម្អប់ ទុក្ខព្រួយ និងសេចក្ដីស្លាប់ ប៉ុន្តែម្ដងនោះគឺមិនមែនលើរាស្ត្រ ឬផែនដីរបស់ព្រះជាម្ចាស់ទេ។ ធ្នូចម្បាំងរបស់ព្រះអង្គ មិនបានតម្រង់ឆ្ពោះទៅរាស្ត្ររបស់ព្រះអង្គទេ។

វាបានតម្រង់ទៅលើចំកណ្ដាលបេះដូងនៃស្ថានសួគ៌វិញ។



# កាំជណ្ដើរដ៏ខ្ពស់ឡើងទៅស្ថានសួគ៌

ប៉មបាបិល (ដកស្រង់ចេញពីកណ្ឌ លោកុប្បត្តិ ១១)

**លោក ណូអេ និងគ្រួសារ**បានរស់នៅលើដីគោក កូនៗរបស់គាត់ក៏បានបង្កបង្កើតកូនគ្រប់ៗគ្នា រួចកូនរបស់កូនគាត់ក៏បង្កើតកូនតៗគ្នាដែរ ហើយកូនចៅរបស់គាត់ចេះតែកើនកាន់តែច្រើនឡើងៗ។ តើអ្នកដឹងថាច្រើនប៉ុណ្ណាទេ? គឺមានមនុស្សជាច្រើនលើផែនដីជាថ្មីទៀត។

កាលជំនាន់នោះ គ្រប់មនុស្សជាតិនិយាយភាសាតែមួយគត់ ដូច្នេះអ្នកមិនចាំបាច់រៀនភាសាអង់គ្លេស ឬជប៉ុន ឬភាសាណាមួយឡើយ ពីព្រោះអ្នកអាចនិយាយពាក្យ «ជំរាបសួរ» ទៅអ្នកណាម្នាក់ក៏បាន គឺគេយល់ន័យដែលអ្នកបាននិយាយនោះ។

មានថ្ងៃមួយ នៅពេលដែលពួកគេកំពុងជជែកគ្នា នោះពួកគេក៏មានគំនិតមួយព្រមគ្នាថា៖ «ចូរយើងបង្កើតទីក្រុងដ៏ស្អាតមួយសម្រាប់យើងរស់នៅ! គឺជាទីលំនៅរបស់យើងទាំងអស់គ្នា ហើយយើងនឹងមានសុវត្ថិភាពជារៀងរហូត»។ បន្ទាប់មកពួកគេមានគំនិតមួយទៀតថា៖ «ចូរយើងសង់ប៉មដ៏ខ្ពស់មួយទៅដល់ស្ថានសួគ៌»។



គ្រប់គ្នាឆ្លើយព្រមគ្នាថា៖ «យល់ព្រម! ពេលនោះយើងនឹងនិយាយថា សូមងើយមើលមកយើងខាងលើ! ហើយគ្រប់គ្នានឹងមើលមកកាន់យើង រួចយើងនឹងមើលចុះទៅគេវិញ។ នៅពេលនោះយើងនឹងដឹងថា យើងដូចនរណា គឺយើងក៏ដូចជាព្រះជាម្ចាស់ដែរ យើងនឹងមានកេរ្តិ៍ឈ្មោះល្បីល្បាញ មានសុវត្ថិភាព មានសេចក្តីសុខសប្បាយ ហើយគ្រប់ការអ្វីៗទៀតនឹងបានល្អទាំងអស់»។

ដូច្នេះ គេក៏ចាប់ផ្តើមសង់ប៉ម ដោយរៀបឥដ្ឋបន្តពីលើគ្នាខ្ពស់ទៅៗ ខ្ពស់ជាងទីក្រុងរបស់គេគឺខ្ពស់ដល់លើមេឃ។ រួចគេសង់ជណ្តើរពីខាងក្នុងប៉មឡើងដល់កំពូលប៉ម ហើយប៉មនេះគឺជាជណ្តើរដ៏ធំបំផុតឆ្ពោះទៅស្ថានសួគ៌។

គេស្រែកហៅ «មើល! យើងជាបងប្អូនតែមួយ! ឃើញទេ ស្នាដៃរបស់យើង» គឺគេពេញចិត្តនឹងខ្លួនគេណាស់។

ប៉ុន្តែ ព្រះជាម្ចាស់មិនបានពេញចិត្តទេ ពីព្រោះព្រះអង្គបានទតឃើញនូវអ្វីដែលគេបានធ្វើ។



ពួកគេខំប្រឹងរស់នៅខ្លួនឯងដោយមិនត្រូវការព្រះជាម្ចាស់ ប៉ុន្តែព្រះជាម្ចាស់បានជ្រាបថា គេនឹងមិនបានជួបសេចក្តីសុខសប្បាយ ឬមានសុវត្ថិភាព ឬគ្រប់ការអ្វីនឹងបានល្អនោះឡើយ។ ប្រសិនជាពួកគេនៅតែធ្វើដូច្នេះ ពួកគេបានត្រឹមតែបំផ្លាញខ្លួនឯងប៉ុណ្ណោះ តែព្រះជាម្ចាស់បានស្រឡាញ់គេខ្លាំងណាស់ ហើយទ្រង់មិនអាចឲ្យគេធ្លាក់ក្នុងសភាពការណ៍នេះបានទេ។ ដូច្នេះហើយបានជាទ្រង់ត្រូវតែបញ្ឈប់ផែនការរបស់ពួកគេ។



នៅវេលាព្រឹកមួយនោះ ពួកគេបាននាំគ្នាទៅធ្វើការដូចធម្មតា ប៉ុន្តែនៅថ្ងៃនោះ មានហេតុការណ៍ខុសពីធម្មតា ពួកគេបាននិយាយភាសាថ្មីៗ ហើយគួរឲ្យចង់សើចណាស់។ អ្នកដឹងទេថា ព្រះជាម្ចាស់បានឲ្យពួកគេនិយាយភាសាផ្សេងៗពីគ្នា! រំពេចនោះ គ្មាននរណាម្នាក់អាចស្តាប់បានភាសាដែលបុគ្គលម្នាក់ៗបាននិយាយឡើយ។ អ្នកខ្លះបាននិយាយថា៖ «តើអ្នកសុខសប្បាយជាទេ?» ប៉ុន្តែ អ្នកដទៃទៀតបានយល់ថា «តើហេតុអ្វីបានជាមុខអ្នកអាក្រក់ម្ល៉េះ?»។ សម្តីនេះមិនមែនគួរឲ្យចង់សើចនោះទេ។ អ្នកអាចនឹងនិយាយពាក្យល្អដូចជា «ព្រឹកនេះ គួរឲ្យចាប់ចិត្តណាស់!» ប៉ុន្តែបែរជាត្រូវគេដាល់មួយដៃចំច្រមុះទៅវិញ ដោយព្រោះគេស្មានតែអ្នកនោះបាននិយាយថា៖ «បិទមាត់ទៅ! ឯងគួរឲ្យធុញទ្រាន់ណាស់!» (អ្នកមិនអាចនិយាយ សូម្បីតែថា «តើអ្នកចង់និយាយថាម៉េច?» ដើម្បីបញ្ជាក់ឲ្យបានត្រឹមត្រូវនោះទេ ពីព្រោះគ្មាននរណាម្នាក់អាចយល់ពាក្យនេះឡើយ)។

ទីបំផុត គេពុំអាចបន្តការសង់ប៉មនោះតទៅទៀតបានទេ ហើយពួកគេក៏បញ្ឈប់ការងារនោះទៅ។ ពួកគេតែងតែឈ្លោះប្រកែកគ្នា ហើយវាយគ្នា ច្រឡូកច្រឡំគ្នាយ៉ាងខ្លាំង ហើយក៏ចេះតែមិនសប្បាយចិត្តទៅៗ រហូតដល់ពេលមួយពួកគេខឹងគ្នាខ្លាំងពេកដល់ដំណាក់កាលលែងចង់សាងសង់តទៅទៀត ហើយក៏ឈប់ធ្វើតែម្តង។



បន្ទាប់ពីនោះមក មនុស្សក៏បែកខ្ចាត់ខ្ចាយពាសពេញលើផែនដី (នោះហើយជាហេតុដែលយើងមានភាសាជាច្រើន រហូតមកទល់នឹងសព្វថ្ងៃនេះ)។

អ្នកឃើញទេ ព្រះជាម្ចាស់បានជ្រាបជាមុន ទោះបីជាកម្ពស់ណាដែលគេអាចទៅដល់ក៏ដោយ ទោះបីជាគេបានខិតខំធ្វើការលំបាកយ៉ាងណាក៏ដោយ មនុស្សទាំងអស់នោះមិនអាចទៅដល់ស្ថានសួគ៌ដោយខ្លួនឯងបានទេ។ មនុស្សមិនត្រូវការកាំជណ្ដើរទេ គឺគេត្រូវការអ្នកជួយសង្គ្រោះ ពីព្រោះផ្លូវត្រឡប់ទៅស្ថានសួគ៌វិញមិនមែនតាមរយៈកាំជណ្ដើរឡើយ គឺតាមរយៈមនុស្សម្នាក់វិញទេតើ។

មនុស្សមិនអាចឡើងទៅដល់ស្ថានសួគ៌បានទេ ដូច្នេះហើយបានជាស្ថានសួគ៌ត្រូវតែចុះមករកមនុស្សវិញ។

ហើយនៅថ្ងៃមួយ ស្ថានសួគ៌នឹងចុះមកមែន។



# កូននៃសំណើច

ព្រះជាម្ចាស់បានសន្យាពិសេសមួយដល់លោក អ័ប្រាហាំ

(ដកស្រង់ចេញពីកណ្ឌ លោកុប្បត្តិ ១២-២១)

**ជាច្រើនឆ្នាំ**បានកន្លងផុតទៅ គ្មានអ្វីបានប្រសើរឡើងសោះ។ មនុស្សនៅតែមានចិត្តឃោរឃៅ និងកាចសាហាវចំពោះគ្នាទៅវិញទៅមក។ ពួកគេនៅតែមានការឈឺចុកចាប់ ហើយស្លាប់។ ផែនដីរបស់ព្រះជាម្ចាស់នៅតែពេញទៅដោយការយំសោក។ វាមិនគួរណាក្លាយទៅជាបែបហ្នឹងសោះ។

ប៉ុន្តែ ព្រះជាម្ចាស់បានរៀបចំផែនការរួចហើយ ដើម្បីធ្វើការនេះ ព្រះអង្គនឹងកែកំហុស ឲ្យមកជាត្រូវវិញ ហើយទ្រង់នឹងធ្វើការនេះតាមរយៈគ្រួសារមួយ...

ព្រះជាម្ចាស់មានបន្ទូលសួរលោក អ័ប្រាហាំ ថា៖ «តើមានផ្កាយប៉ុន្មាននៅកន្លែងនោះ?» (ព្រះអង្គចង់ប្រាប់មិត្តសម្លាញ់របស់ទ្រង់ពីការអាថ៌កំបាំងដ៏អស្ចារ្យមួយ)។

លោក អ័ប្រាហាំ ក៏មូរដៃអាវឡើង ទាំងឆ្លើយតបថា៖ «ខ្ញុំសូមមើលបន្តិចសិន» (តើអ្នកដែលសាកល្បងរាប់ផ្កាយឬទេ? បើធ្លាប់ អ្នកនឹងដឹងថា ពិបាកយ៉ាងណាហើយ)។ ហើយលោក អ័ប្រាហាំ ក៏រាប់ «៩៩៣ ៩៩៤ ៩៩៧ អូហ៍ ទេ ចាំបន្តិចសិន ១ ២...»។ ប្រាកដណាស់ គាត់នៅតែមានការច្រឡំតួលេខក្នុងការរាប់ផ្កាយ ហើយគាត់ក៏លាន់មាត់ថា៖ «អូរ! វាច្រើនពេកណាស់! ខ្ញុំរាប់មិនអស់ទេ!»។






«ទាយមើលទៅ!» ព្រះជាម្ចាស់សើច រួចមានបន្ទូលថា៖ «យើងនឹងឲ្យឯងបង្កើតកូន ចៅ និងចៅទួត បានច្រើននាក់ថែមទៀត ដែលឯងមិនអាចរាប់គេបានសោះឡើយ។

លោក អ័ប្រាហាំ អស់សំណើចនឹងគំនិតដ៏ល្អពេកហើយរបស់ទ្រង់ ប៉ុន្តែ គាត់ខំទប់សំណើច។ តើឲ្យគាត់អាចនឹងបង្កើតគ្រួសារមួយបានយ៉ាងដូចម្ដេចទៅ? វាមិនអាចទៅរួចទេ! គាត់ថែមទាំងមិនមានកូនផង តើធ្វើដូចម្ដេចឲ្យគាត់អាចមានចៅបានទៅ។ គាត់ក៏ជូតទឹកភ្នែក។ ទោះជាយ៉ាងណាក៏ដោយ ក៏វាហួសពេលទៅហើយសម្រាប់គាត់ ដែលនឹងមានកូននោះ ពីព្រោះគាត់អាយុ៩៩ឆ្នាំហើយ។ តើព្រះជាម្ចាស់ចង់មានន័យយ៉ាងដូចម្ដេចទៅ? ព្រះជាម្ចាស់មានបន្ទូលទៅលោក អ័ប្រាហាំ ថា៖ «ចូរជឿយើងចុះ»។

រួចទ្រង់បានប្រាប់លោក អ័ប្រាហាំ ពីផែនការសង្គ្រោះរបស់ទ្រង់ថា៖ «ឱ! អ័ប្រាហាំ អើយ! យើងនឹងធ្វើឲ្យគ្រួសារឯងចម្រើនឡើងជាច្រើន» ហើយទ្រង់ក៏បានសន្យានឹងគាត់ថា៖ «រហូតដល់ថ្ងៃមួយ គ្រួសារឯងនឹងមានចំនួនច្រើនជាងផ្កាយនៅលើមេឃនេះទៅទៀត»។

លោក អ័ប្រាហាំ បានងើយមើលទៅលើមេឃនៅពេលយប់ងងឹតនោះ គាត់ឃើញមានផ្កាយរះពាសពេញមេឃ។

ព្រះជាម្ចាស់បន្តមានបន្ទូលទៀតថា «ឯងនឹងក្លាយជាគ្រួសារមួយដ៏សំខាន់របស់យើង ជារាស្ត្រយើង គឺតាមរយៈឯង នោះគ្រប់គ្នានៅលើផែនដីនឹងទទួលបានពរពីយើង»។






នេះជាសេចក្ដីសន្យាមួយដែលមិនគួរឲ្យជឿសោះ៖ ព្រះជាម្ចាស់នឹងជួយសង្គ្រោះមនុស្សលោកនៅផែនដីនេះតាមរយៈគ្រួសារលោក អ័ប្រាហាំ! ចៅលាម្នាក់របស់គាត់ ដែលព្រះជាម្ចាស់បានសន្យាថា នឹងប្រទានមកធ្វើជាព្រះអង្គសង្គ្រោះ។

«នោះគឺជាការដ៏អស្ចារ្យខ្លាំងណាស់!» លោក អ័ប្រាហាំ សួរទៅទ្រង់ថា៖ «តើនេះជាការពិតមែនឬ?»។

ព្រះជាម្ចាស់មានបន្ទូលសួរលោក អ័ប្រាហាំ ថា៖ «ចំពោះយើង តើមានអ្វីទៅដែលអស្ចារ្យខ្លាំងពេក ហើយក៏ពិបាកធ្វើ?»។

ដូច្នេះ លោក អ័ប្រាហាំ បានទុកចិត្តលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាជាងលើកែវភ្នែកដែលគាត់អាចមើលឃើញទៅទៀត។ ហើយគាត់ក៏បានជឿ។

នៅពេលដែលនាង សារ៉ា ដែលជាប្រពន្ធរបស់គាត់បានឮពីសេចក្ដីសន្យារបស់ព្រះជាម្ចាស់ នាងក៏លួចសើចនៅក្នុងចិត្ត ប៉ុន្តែនាងមិនបានសើចដោយព្រោះត្រេកអរនោះទេ តែសើចដោយមានទុក្ខសោក។ នាងចង់មានកូនមួយយ៉ាងខ្លាំង តើអាចទេឲ្យក្ដីស្រមៃរបស់នាងបានក្លាយជាការពិត? ទោះបើនាងមានអាយុ៩០ឆ្នាំហើយ តើឲ្យនាងមានកូនយ៉ាងដូចម្ដេចបានទៅ? ទេ! មិនអាចទៅរួចបានទេ! វាហួសពេលទៅហើយ។

នាង សារ៉ា ពុំបានជឿថា ព្រះជាម្ចាស់អាចធ្វើការនេះដូចដែលទ្រង់បានសន្យានោះទេ។ នាងបានភ្លេចថា អ្វីក៏ដោយដែលព្រះជាម្ចាស់បានមានបន្ទូល នោះគឺដូចជាបានសម្រេចរួចទៅហើយ។ (ប្រាកដណាស់ គឺជាការងាយបំផុតសម្រាប់ព្រះជាម្ចាស់ ដែលទ្រង់នឹងប្រទានឲ្យនាងបានកូនប្រុសមួយ គឺដូចជាទ្រង់បានបង្កើតផ្កាយទាំងអស់នៅលើមេឃដែរ។)

ពិតមែន! ប្រាំបួនខែក្រោយមក ដូចជាព្រះជាម្ចាស់បានសន្យា នាង សារ៉ា សម្រាលបានកូនប្រុសមួយ។ ពួកគាត់បានដាក់ឈ្មោះកូននោះថា អ៊ីសាក ដែលឈ្មោះនេះមានន័យថា «កូននៃសំណើច» ព្រោះនាង សារ៉ា បានសើច។ ក៏ប៉ុន្តែម្តងនេះនាងបានសើចដោយមានអំណរវិញ នាងសប្បាយចិត្ត។ ក្តីស្រមៃរបស់នាងបានក្លាយជាការពិតមែន!

ព្រះជាម្ចាស់បានធ្វើដូចដែលទ្រង់បានសន្យា។ ទ្រង់តែងតែជួយថែរក្សាដល់គ្រួសារលោកអ័ប្រាហាំ ដែលជាមនុស្សពិសេសរបស់ទ្រង់។

ហើយនៅថ្ងៃមួយ ព្រះអង្គនឹងប្រទានទារកមួយទៀត ដូចជាទ្រង់បានសន្យាដល់ស្ត្រីម្នាក់ដែលពុំដែលមានប្តីសោះ។ ប៉ុន្តែ ទារកនោះនឹងនាំមកនូវសេចក្តីសុខសប្បាយដល់ផែនដីទាំងមូល។ ទារកមួយនេះគឺជាទារកនៃក្តីស្រមៃរបស់មនុស្សគ្រប់ៗរូបនោះ នឹងបានក្លាយជាការពិត។



# ការជូនកាដូ

សាច់រឿងរបស់លោក អ័ប្រាហាំ និងកុមារា អ៊ីសាក (ដកស្រង់ចេញពីកណ្ឌ លោកុប្បត្តិ ២២)

**ព្រះជាម្ចាស់**បានដឹងថា ផែនការសម្ងាត់នៃសេចក្ដីសង្គ្រោះរបស់ទ្រង់ អាចនឹងកើតឡើងបាន ដរាបណាលោក អ័ប្រាហាំ មានទំនុកចិត្តលើព្រះអង្គទាំងស្រុង។ ព្រះជាម្ចាស់ចង់ដឹងច្បាស់ថា តើលោក អ័ប្រាហាំ នឹងធ្វើអ្វីៗទាំងអស់ដែលទ្រង់បានបង្គាប់គាត់ដែរឬទេ។

ដូច្នេះ ប៉ុន្មានឆ្នាំក្រោយមក ព្រះជាម្ចាស់បានបង្គាប់ឲ្យលោក អ័ប្រាហាំ ជូនកាដូដល់ទ្រង់។

លោក អ័ប្រាហាំ ចូលចិត្តជូនកាដូដល់ព្រះជាម្ចាស់ គឺគាត់បានជូនសត្វពាហនៈរបស់គាត់ដល់ទ្រង់ ពួកគេបានហៅកាដូនោះថាជា «យញ្ញបូជា» គឺជារបៀបដែលពួកគេធ្វើ ដើម្បីបញ្ជាក់ទៅព្រះជាម្ចាស់ថា៖ «ខ្ញុំស្រឡាញ់ព្រះអង្គ»។

ប៉ុន្តែ ម្ដងនេះព្រះជាម្ចាស់មិនចង់បានសត្វចៀម ឬសត្វពពែនោះទេ ព្រះអង្គចង់ឲ្យលោក អ័ប្រាហាំ ជូនដល់ទ្រង់ឲ្យលើសពីនេះទៅទៀត គឺព្រះអង្គចង់ឲ្យលោក អ័ប្រាហាំ ជូនដល់ទ្រង់នូវកូនប្រុសតែមួយគត់របស់គាត់ ដែលគាត់ស្រឡាញ់ជាទីបំផុត នោះគឺជាកុមារា អ៊ីសាក។

ព្រះជាម្ចាស់បង្គាប់ឲ្យគាត់យកកូនរបស់គាត់ទៅដាក់លើអាសនា ហើយសម្លាប់ធ្វើជាយញ្ញបូជា! ហេតុដូចម្ដេចបានជាព្រះជាម្ចាស់ចង់ឲ្យគាត់ធ្វើការដ៏សែនអាក្រក់បែបនេះ? លោក អ័ប្រាហាំ មិនយល់ទាល់តែសោះ។ ប៉ុន្តែ គាត់បានដឹងថា ព្រះជាម្ចាស់ជាឪពុករបស់គាត់ ហើយព្រះអង្គស្រឡាញ់គាត់។ ដូច្នេះហើយបានជាលោក អ័ប្រាហាំ ទុកចិត្តលើព្រះជាម្ចាស់។

ពេលព្រឹកព្រលឹមស្អែកឡើងលោក អ័ប្រាហាំ និងកុមារា អ៊ីសាក ក៏ចេញដំណើរទៅ។ ពួកគេបានឡើងទៅលើភ្នំ ផ្លូវឡើងនោះគឺចោត ហើយមានថ្មរដិបរដុបច្រើនណាស់។ កុមារា អ៊ីសាក លីអុសលើស្មា ហើយឪពុករបស់គាត់កាន់កាំបិត និងរងើកភ្លើង។





កុមារា អ៊ីសាក បាននិយាយថា៖ «លោកប៉ា យើងមានគ្រប់ទាំងអស់ តែយើងភ្លេចយកសត្វចៀមមកធ្វើជាយញ្ញបូជាហើយ»។

លោក អ័ប្រាហាំ បានឆ្លើយវិញថា៖ «កូនប្រុស! ព្រះជាម្ចាស់នឹងប្រទានសត្វចៀមមកយើងជាមិនខាន»។

ពួកគេក៏បាននាំគ្នាស្អាងអាសនាឡើង ហើយបានរៀបអុសដាក់ពីលើផង លោក អ័ប្រាហាំ ប្រាប់ឲ្យកូនគាត់ឡើងទៅលើគំនរអុសនោះ។ កុមារា អ៊ីសាក មិនបានយល់ពីកិច្ចការនេះទេ ប៉ុន្តែគាត់ដឹងថា ឪពុករបស់គាត់ស្រឡាញ់គាត់ណាស់។ ដូច្នេះ គាត់ទុកចិត្តលើឪពុកគាត់ គាត់ក៏បានឡើងទៅលើអាសនានោះ រួចលោក អ័ប្រាហាំ បានចងកូនគាត់ភ្ជាប់ទៅនឹងគំនរអុសនោះ។ កុមារា អ៊ីសាក មិនបានរើបម្រះ ឬក៏ព្យាយាមរត់ចេញពីទីនោះឡើយ គាត់បានដេកយ៉ាងស្ងៀមដោយមិនបន្លឺសំឡេងអ្វីឡើយ។

នៅពេលដែលគ្រប់ការទាំងអស់បានរៀបចំហើយជាស្រេច នោះលោក អ័ប្រាហាំ ក៏ហូតកាំបិតថែមទាំងស្រក់ទឹកភ្នែករលីងរលោងទៀតផង។ បេះដូងរបស់គាត់ពោរពេញទៅដោយការឈឺចាប់ ដៃរបស់គាត់ក៏ញ័រ។ លោក អ័ប្រាហាំ បានលើកកាំបិតឡើងទៅលើយ៉ាងខ្ពស់ ប៉ុន្តែ – ភ្លាមៗនោះ ព្រះជាម្ចាស់បានឃាត់គាត់ថា៖ «ឈប់! កុំឲ្យក្មេងនេះមានរបួសឡើយ។ យើងមិនចង់ឲ្យគាត់ស្លាប់ទេ គឺឲ្យគាត់រស់។ យើងដឹងហើយឥឡូវនេះ ថាឯងស្រឡាញ់យើង ពីព្រោះឯងបានយកកូនតែមួយរបស់ឯងមកធ្វើជាយញ្ញបូជាដល់យើង»។

លោក អ័ប្រាហាំ មានចិត្តពេញដោយអំណរ គាត់ក៏ស្រាយចំណងចេញពីកុមារា អ៊ីសាក ព្រមទាំងឱបកូនយ៉ាងពេញទំហឹង។ មនុស្សដែលមានវ័យចំណាស់ម្នាក់នេះយំអណ្ដឹតអណ្ដក ខ្លួនប្រាណញ័រខ្លាំង ទឹកភ្នែកក្ដៅឧណ្ហៗដក់ក្នុងភ្នែករបស់គាត់។ គេទាំងពីរនាក់បានឈរឱបគ្នាយ៉ាងយូរ កូនស្ថិតនៅក្នុងរង្វង់ដៃឪពុក ហើយឪពុកនៅក្នុងរង្វង់ដៃកូន។

រំពេចនោះលោក អ័ប្រាហាំ ក៏បានឃើញពពែឈ្មោលមួយក្បាល ជាប់នៅក្នុងគុម្ពបន្លា ហើយគាត់ដឹងយ៉ាងជាក់ច្បាស់ថា សត្វនេះគឺសម្រាប់ជាតង្វាយយញ្ញបូជា។ ព្រះជាម្ចាស់បានប្រទានដល់ពួកគេទាំងពីរនាក់ក្នុងវេលាដែលពួកគេកំពុងតែត្រូវការ។ ពពែត្រូវងាប់ជំនួសកុមារា អ៊ីសាក ដើម្បីមិនឲ្យគាត់ស្លាប់។ ដូច្នេះលោក អ័ប្រាហាំ បានយកពពែធ្វើជាយញ្ញបូជា ជំនួសកូនប្រុសរបស់គាត់វិញ។





ខណៈពេលដែលពួកគេទាំងពីរនាក់កំពុងអង្គុយនៅលើកំពូលភ្នំ មើលរងើកភ្លើងដែលកំពុងតែរលត់ ដោយខ្យល់ត្រជាក់ធ្លាក់នៅពេលយប់ ហើយផ្កាយទាំងឡាយដែលនៅពីលើពួកគេកំពុងរះភ្លឺផ្លេកៗពេញផ្ទៃមេឃ នោះព្រះជាម្ចាស់បានជួយឲ្យលោកអ័ប្រាហាំ និងកុមារា អ៊ីសាក យល់ពីការមួយៈ គឺព្រះជាម្ចាស់ចង់ឲ្យរាស្ត្ររបស់ព្រះអង្គបានរស់មិនមែនស្លាប់ទេ។ ព្រះអង្គចង់ជួយសង្គ្រោះដល់រាស្ត្រព្រះអង្គ មិនមែនដាក់ទោសពួកគេនោះទេ។ ប៉ុន្តែ ពួកគេត្រូវតែទុកចិត្តលើទ្រង់។

ព្រះជាម្ចាស់បានសន្យាដល់ពួកគេថា៖ «នាថ្ងៃមួយ នឹងមានបុគ្គលម្នាក់មកកើតក្នុងគ្រួសាររបស់ឯង ហើយបុគ្គលម្នាក់នោះនឹងនាំនូវសេចក្តីសុខសាន្តមកដល់ផែនដីទាំងមូល»។

ព្រះជាម្ចាស់បានប្រុងប្រៀបរួចជាស្រេចនឹងប្រទានមកកាន់លោកីយ៍នូវកាដូដ៏អស្ចារ្យមួយ។ នេះគឺជារបៀបដែលព្រះអង្គចង់បង្ហាញដល់រាស្ត្រទ្រង់ថា៖ «ព្រះអង្គស្រឡាញ់រាស្ត្ររបស់ទ្រង់ណាស់»។

ប្រមាណជាច្រើនឆ្នាំក្រោយមក នឹងមានបុត្រាម្នាក់ទៀតដែលនឹងយាងមកលើភ្នំមួយទៀត ដោយលីឈើនៅលើស្មារបស់ព្រះអង្គ ដូចជាកុមារា អ៊ីសាក ដែរ។ ព្រះអង្គនឹងទុកចិត្តលើព្រះវរបិតារបស់ទ្រង់ ហើយនឹងធ្វើតាមតែបង្គាប់របស់ព្រះវរបិតា បុត្រាមួយអង្គនេះនឹងមិនរើបម្រះ ឬព្យាយាមរត់ចេញឡើយ។

តើព្រះអង្គជាអ្នកណាហ្ន៎? ទ្រង់គឺជាបុត្រារបស់ព្រះជាម្ចាស់ ហើយក៏ជាបុត្រាតែមួយគត់របស់ព្រះជាម្ចាស់ ដែលព្រះអង្គស្រឡាញ់យ៉ាងខ្លាំង។

គឺជាកូនចៀមនៃព្រះជាម្ចាស់។

# នារីម្នាក់ដែលគ្មាននរណាចង់បាន







សាច់រឿងស្ដីពីលោក យ៉ាកុប នាង រ៉ាជែល និងនាង លេអា
(ដកស្រង់ចេញពីកណ្ឌ លោកុប្បត្តិ ២៩-៣០)

**នាពេលមួយ** មានបងប្អូនស្រីពីរនាក់។ ប្អូនស្រីជានារីម្នាក់ដែលមានរូបស្រស់ឆោមស្អាត នាងមានឈ្មោះថា រ៉ាជែល។ ប៉ុន្តែ ចំណែកបងស្រីវិញ មានរូបឆោមមិនស្អាតដូចប្អូននោះទេ (អ្នកខ្លះបានគិតថា នាងមានរូបអាក្រក់ណាស់) ហើយនាងមានឈ្មោះថា លេអា។

នាង រ៉ាជែល ជានារីម្នាក់ ដែលគេចូលចិត្តអញ្ជើញឲ្យទៅចូលរួមក្នុងពិធីផ្សេងៗ ហើយគេក៏ចូលចិត្តជ្រើសរើសនាងឲ្យចូលក្នុងក្រុមរបស់គេផងដែរ។ គ្រប់គ្នាស្រឡាញ់ ព្រមទាំងចូលចិត្តនាងណាស់។ រីឯ នាង លេអា វិញ នាងគួរឲ្យអាណិតណាស់។ មិនសូវមាននរណាចាប់អារម្មណ៍នឹងនាងទេ។

មានថ្ងៃមួយលោក យ៉ាកុប ដែលជាបងជីដូនមួយរបស់នាងទាំងពីរបានមកស្នាក់នៅក្នុងផ្ទះជាមួយគ្រួសារពួកគេ។ លោក យ៉ាកុប គឺជាកូនប្រុសម្នាក់ក្នុងចំណោមកូនប្រុសរបស់លោក អ៊ីសាក នៅពេលនោះគាត់កំពុងតែរត់គេចខ្លួន (លោក យ៉ាកុប បានលួច និងបោកប្រាស់គេ ដែលបណ្ដាលឲ្យគាត់មានសត្រូវមួយចំនួន រួមទាំងបងប្រុសគាត់ម្នាក់ផងដែរ ហើយឥឡូវនេះគាត់កំពុងតែលាក់ខ្លួន)។

អ្វីដែលគួរឲ្យអស់សំណើចនោះគឺ ក្នុងចំណោមមនុស្សទាំងអស់ ព្រះជាម្ចាស់ប្រទានសេចក្ដីសន្យាយ៉ាងពិសេសដល់លោក យ៉ាកុប ជាសេចក្ដីសន្យាដូចគ្នានឹងការសន្យារបស់ព្រះជាម្ចាស់ ដែលព្រះអង្គបានធ្វើជាមួយនឹងលោក អ័ប្រាហាំ ជាជីតារបស់គាត់ថា៖ «យើងនឹងជួយសង្គ្រោះលោកីយ៍ តាមរយៈគ្រួសាររបស់ឯង» (ប៉ុន្តែ ព្រះជាម្ចាស់បានជ្រើសរើសយកមនុស្ស ដែលយើងនឹកស្មានមិនដល់ ដូចដែលយើងបានឃើញរួចមកហើយ)។

លោក យ៉ាកុប បាននៅបម្រើពូរបស់គាត់ឈ្មោះ ឡាបាន់ អស់រយៈពេលជាយូរឆ្នាំ។







ថ្ងៃមួយ លោក ឡាបាន់ និយាយថា៖ «យ៉ាកុប! ពូបានសម្រេចចិត្តនឹងចេញថ្លៃឈ្នួលដល់ការងារដែលឯងបានធ្វើ តើឯងចង់បានអ្វី?» រំពេចនោះ គាត់ក៏មានគំនិតមួយទៀតថា៖ *«ចុះបើពូលើកកូនស្រីម្នាក់ឲ្យឯង?»*។

យ៉ាកុបបានសម្លឹងមើលទៅនាង រ៉ាជែល ហើយនិងនាង លេអា។ តើគាត់នឹងជ្រើសរើសអ្នកណា? ប្រាកដណាស់ គាត់នឹងជ្រើសរើសយកនាង រ៉ាជែល។

លោក យ៉ាកុប និយាយថា៖ «ខ្ញុំនឹងធ្វើការ៧ឆ្នាំដោយឥតគិតថ្លៃ សូមឲ្យតែខ្ញុំបានរៀបការជាមួយនឹងនាង រ៉ាជែល ចុះ»។

ដូច្នេះ លោក យ៉ាកុប បានធ្វើការ៧ឆ្នាំដូចដែលបានកំណត់ ហើយថ្ងៃអាពាហ៍ពិពាហ៍របស់គាត់ក៏បានមកដល់។

ប៉ុន្តែ នៅយប់នោះលោក ឡាបាន់ បានលេងល្បិចកលដ៏សាហាវបន្លំភ្នែកលោក យ៉ាកុប គឺគាត់បានឲ្យនាង លេអា មករៀបការជាមួយលោក យ៉ាកុប ជំនួសនាង រ៉ាជែល វិញ។ (ក្នុងជំនាន់មុននោះ ពួកគេពុំមានភ្លើងអគ្គិសនីប្រើទេ ដូច្នេះនៅក្នុងរោងការក៏ងងឹតដែរ មិនត្រឹមតែប៉ុណ្ណោះទេ កូនក្រមុំជំនាន់នោះគេតែងតែពាក់ស្បៃបាំងមុខ ហើយគ្មានអ្នកណាអាចមើលឃើញមុខកូនក្រមុំយ៉ាងច្បាស់នោះទេ ដូច្នេះសូម្បីតែលោក យ៉ាកុប ក៏មិនមានការមន្ទិលសង្ស័យអ្វីឡើយ)។

ពេលព្រឹកព្រលឹមស្អែកឡើង ពេលលោក យ៉ាកុប ភ្ញាក់ឡើងគាត់បានស្រែកយ៉ាងខ្លាំង ដោយគាត់បានឃើញប្រពន្ធថ្មី ដែលគេងជិតគាត់មិនមែនជានាង រ៉ាជែល ទេ គឺជានាង លេអា ទៅវិញ។ លោក យ៉ាកុប បានស្ទុះចុះពីគ្រែ ហើយក៏បានស្រែកឡើងថា៖ «ឡាបាន់! លោកជាមនុស្សចោលម្សៀតណាស់!» ប៉ុន្តែលោក ឡាបាន់ បានតបទៅវិញថា៖ «សូមឲ្យឯងធ្វើការ៧ឆ្នាំទៀត ទើបឯងអាចរៀបការជាមួយនាង រ៉ាជែល បាន»។





ដូច្នេះ លោក យ៉ាកុប ក៏បន្តធ្វើការឲ្យឡាបាន់អស់រយៈពេល៧ឆ្នាំទៀត ដូចដែលបានកំណត់ ហើយនាង រ៉ាជែល ក៏ក្លាយជាប្រពន្ធរបស់គាត់។ ឥឡូវនេះលោក យ៉ាកុប មានប្រពន្ធពីរនាក់ ប៉ុន្តែ ក្នុងចំណោមប្រពន្ធទាំងពីរនេះលោក យ៉ាកុប បានស្រឡាញ់នាង រ៉ាជែល ជាងគេ។

នាង លេអា ក៏បានត្អូញត្អែរថា៖ «ខ្ញុំមានរូបអាក្រក់ណាស់ គ្មានអ្នកណាស្រឡាញ់ខ្ញុំទេ»។

ប៉ុន្តែ ព្រះជាម្ចាស់មិនបានយល់ថានាងមានរូបអាក្រក់នោះទេ ហើយពេលដែលទ្រង់បានទតឃើញថា គ្មាននរណាស្រឡាញ់ និងចង់បាននាង ព្រះជាម្ចាស់បានជ្រើសរើសនាង ហើយស្រឡាញ់នាងពិសេសជាងគេ រួចព្រះអង្គបានប្រទានការងារដ៏សំខាន់មួយដល់នាង គឺនៅថ្ងៃមួយ ព្រះជាម្ចាស់នឹងរំដោះលោកីយ៍ទាំងមូលនេះតាមរយៈគ្រួសារនាង។

ហើយនៅពេលដែលនាង លេអា បានដឹងថា ព្រះជាម្ចាស់ស្រឡាញ់នាង នោះក្នុងចិត្តនាង នាងលែងខ្វល់ទៀតហើយថា តើប្តីរបស់នាងស្រឡាញ់នាងជាងគេ ឬក៏មិនស្រឡាញ់ ឬក៏ថាតើនាងមាន ឬក៏មិនមានរូបឆោមស្រស់ស្អាតដូចគេទេ។ ព្រះជាម្ចាស់បានជ្រើសរើសយកនាង ព្រះអង្គមិនដែលឈប់ស្រឡាញ់នាង មិនដែលបោះបង់នាងចោល ក៏គ្មាននរណាម្នាក់អាចកាត់ផ្តាច់នាងពីទ្រង់បានដែរ—ក្តីស្រឡាញ់ដែលគ្មានទីបញ្ចប់ មិនអាចបោះបង់បាន មិនអាចបំបែកចេញបាន ជាសេចក្តីស្រឡាញ់ដ៏អស់កល្ប។

ដូច្នេះ នៅពេលដែលនាងកើតបានកូនប្រុសមួយ នាងបានដាក់ឈ្មោះកូននោះថា យូដា ដែលមានន័យថា៖ «ពេលនេះ ខ្ញុំនឹងសរសើរតម្កើងព្រះជាម្ចាស់» ហើយនាងក៏បានធ្វើបែបនោះមែន។ អ្នកប្រហែលជាមិនអាចនឹកស្មានដល់ទេថា តើព្រះជាម្ចាស់បានប្រទានការងារអ្វីឲ្យនាង លេអា។ មើលហ្ន៎! ពេលដែលព្រះជាម្ចាស់មើលនាង លេអា ទ្រង់មើលឃើញនាងថាជាម្ចាស់ក្សត្រី។ ហើយប្រាកដណាស់ នាងពិតជាបានក្លាយទៅជាដូច្នេះមែន។ ចៅទួតប្រុសម្នាក់របស់នាង លេអា នឹងធ្វើជាព្រះអម្ចាស់ ជាព្រះអម្ចាស់នៃស្ថានសួគ៌ ជាកូនរបស់ព្រះជាម្ចាស់។

កូនម្នាក់នេះនឹងស្រឡាញ់រាស្ត្ររបស់ទ្រង់ទាំងអស់ មិនចាំបាច់គេមានសម្រស់ល្អឆើត ទើបគាត់ស្រឡាញ់ពួកគេនោះទេ។ គាត់ស្រឡាញ់ពួកគេអស់ពីដួងចិត្ត ហើយពួកគេនឹងមានរូបឆោមស្រស់ស្អាត ដោយសារព្រះទ្រង់ស្រឡាញ់ពួកគេ។

គឺដូចនាង លេអា ដែរ។





# ព្រះអម្ចាស់ដែលពេញដោយការអត់ទោស

យ៉ូសែប និងបងប្អូនប្រុស (ដកស្រង់ចេញពីកណ្ឌ លោកុប្បត្តិ ៣៧-៤៦)

**លោក យ៉ាកុប** មានកូនប្រុសដប់ពីរនាក់ ប៉ុន្តែក្នុងចំណោមកូនទាំងអស់ គាត់ស្រឡាញ់លោក យ៉ូសែប ជាងគេ។

នៅថ្ងៃមួយលោក យ៉ាកុប បានឲ្យអាវផាយថ្មីមួយយ៉ាងឆើតឆាយ មានពណ៌ចម្រុះដូចឥន្ទធនូដល់លោក យ៉ូសែប ប៉ុន្តែ ការនេះបានធ្វើឲ្យបងៗរបស់គាត់មានចិត្តច្រណែន ពីព្រោះពួកគេក៏ចង់បានអាវផាយដែលមានពណ៌ចម្រុះដូចឥន្ទធនូនោះដែរ។

ហើយការដែលធ្ងន់ធ្ងរលើសនេះទៅទៀតនោះ គឺលោក យ៉ូសែប ចេះតែយល់សប្តិចម្លែកៗ។ គាត់បានប្រាប់ទៅបងៗរបស់គាត់ថា៖ «ខ្ញុំបានយល់សប្តិថា ខ្ញុំនឹងបានធ្វើជាអ្នកធំ! ខ្ញុំជាស្តេច! ហើយបងទាំងអស់គ្នា នឹងក្រាបសំពះនៅចំពោះមុខខ្ញុំ!»។

ប្រាកដណាស់ឥឡូវនេះ ខ្ញុំដឹងថាអ្នកបានយល់ សូម្បីតែលោក យ៉ូសែប មិនបានយល់ក៏ដោយថា ការដែលគាត់ប្រាប់បងប្រុសគាត់របៀបនេះ មិនមែនជាគំនិតល្អនោះទេ។ ពួកបងប្រុសរបស់លោក យ៉ូសែប រឹតតែស្អប់គាត់ថែមទៀត ពួកគេមិនចង់ឮការយល់សប្តិរបស់លោក យ៉ូសែប តទៅទៀតទេ ហើយពួកគេថែមទាំងចង់សម្លាប់លោក យ៉ូសែប ចោល ទៀតផង។

ហើយនៅថ្ងៃមួយ គេពិតជាសាកល្បងធ្វើបែបនោះមែន។

គេបានហែកអាវផាយពណ៌ដូចឥន្ទធនូ ហើយដោះអាវនោះចេញពីលោក យ៉ូសែប រួចហើយក៏បានលក់គាត់ឲ្យពួកឈ្មួញដែលជួញឈ្នួលបម្រើដាច់ថ្លៃ ក្នុងតម្លៃជាសាច់ប្រាក់សុទ្ធចំនួន ២០កាក់។





ពួកឈ្មួញទាំងនោះក៏បាននាំលោក យ៉ូសែប ទៅស្រុកអេស៊ីព្ទ ហើយបង្ខំឲ្យគាត់ធ្វើជាឈ្នួលបម្រើជាច់ថ្លៃ។ ចំណែកឯពួកបងៗរបស់គាត់ក៏បានត្រឡប់ទៅផ្ទះវិញ ហើយកុហកឪពុកគេថាលោក យ៉ូសែប បានស្លាប់ហើយ។

ពួកបងៗរបស់គាត់បានគិតថា នេះគឺជាទីបញ្ចប់នៃអ្នកពូកែយល់សប្តិហើយ! ប៉ុន្តែ គេបានគិតខុសវិញ។ ព្រះជាម្ចាស់បានបង្ហាញនូវសុបិនដ៏ប្រសើរលើសលុប សម្រាប់ជីវិតរបស់លោក យ៉ូសែប ទោះបីជាមើលទៅឃើញថា គ្រប់ទាំងអស់ហាក់ដូចជាខុសពីការគ្រោងទុកក៏ដោយ តែព្រះជាម្ចាស់បានរៀបចំផែនការ ដើម្បីជួយឲ្យសុបិននេះក្លាយជាការពិតវិញ។ ព្រះជាម្ចាស់បានយកហេតុការណ៍ទាំងអស់ ដែលកើតឡើងចំពោះលោក យ៉ូសែប ដើម្បីធ្វើជាការដ៏ល្អប្រសើរវិញ។

ស្របពេលនោះ ការដែលកើតឡើងចំពោះលោក យ៉ូសែប នៅប្រទេសអេស៊ីព្ទ ហាក់បីដូចជាមិនល្អសោះ គឺគាត់បានឃ្លាតឆ្ងាយពីផ្ទះ និងពីឪពុករបស់គាត់។ ហើយបន្ទាប់មក គាត់ត្រូវបានគេមួលបង្កាច់ពីអ្វីដែលគាត់មិនបានធ្វើ ទោះបើគាត់មិនដែលបានធ្វើអ្វីខុសក៏ដោយ ក៏គាត់ត្រូវមានទោសជាប់គុកដែរ តែព្រះជាម្ចាស់គង់នៅជាមួយនឹងលោក យ៉ូសែប ផងដែរ។





មានយប់មួយស្តេច ផារ៉ោន (ជាស្តេចស្រុកអេស៊ីព្ទ) បានមានការយល់សប្តិដ៏គួរឲ្យខ្លាចមួយ អំពីហ្វូងគោស្គម មកត្របាក់លេបហ្វូងគោធាត់។ តើសុបិនគួរឲ្យខ្លាចនោះមានអត្ថន័យយ៉ាងដូចម្តេចទៅ? ស្តេច ផារ៉ោន មិនយល់ទាល់តែសោះ។ តែលោក យ៉ូសែប គឺជាអ្នកចេះកាត់ស្រាយយល់សប្តិដ៏ឆ្នើមម្នាក់។ ដូច្នេះហើយបានជាស្តេច ផារ៉ោន ឲ្យគេទៅនាំគាត់មក។ លោក យ៉ូសែប ក៏បកស្រាយអត្ថន័យនៃយល់សប្តិនោះទៅដល់ស្តេចថា «នឹងមានអំណត់អត់កើតឡើង ហើយនឹងមានការខ្វះខាតស្រូវអង្ករ»។

ស្តេច ផារ៉ោន ពេញចិត្តនឹងការកាត់យល់សប្តិរបស់លោក យ៉ូសែប ណាស់ ហើយទ្រង់ក៏ដោះលែងលោក យ៉ូសែប ឲ្យចេញពីគុកភ្លាម រួចព្រះអង្គក៏បានតែងតាំងលោក យ៉ូសែប ឲ្យធ្វើជាព្រះអម្ចាស់ម្នាក់ ដែលត្រួតត្រាលើស្រុកអេស៊ីព្ទទាំងមូល។

រីឯ នៅស្រុករបស់លោក យ៉ូសែប វិញ បងប្អូនរបស់គាត់ក៏ជួបនឹងអំណត់អត់ដែរ ពីព្រោះមានការខ្វះខាតស្បៀងអាហារ ហើយម្នាក់ៗមានការស្រេកឃ្លានជាខ្លាំង។ គ្រួសារដ៏ពិសេសរបស់ព្រះជាម្ចាស់ត្រូវជួបប្រទះនឹងគ្រោះថ្នាក់ ប្រសិនជាពួកគេរកស្បៀងអាហារមិនទាន់ពេលទេ ពួកគេនឹងត្រូវដាច់ពោះស្លាប់។

ហេតុដូច្នេះហើយ បានជាបងៗរបស់យ៉ូសែបត្រូវធ្វើដំណើរទៅស្រុកអេស៊ីព្ទ ដើម្បីទិញស្បៀងអាហារ។

ពេលដែលពួកគេបានទៅដល់ទីនោះ ពួកគេក៏លុតជង្គង់នៅចំពោះមុខព្រះអម្ចាស់ថ្មីម្នាក់នោះ។ ពួកគេមិនបានស្គាល់ថា ព្រះអម្ចាស់នេះជាលោក យ៉ូសែប នោះឡើយ។ ប៉ុន្តែលោក យ៉ូសែប ស្គាល់គេទាំងអស់ថាជាបងៗរបស់គាត់។ ឥឡូវ ការយល់សប្តិរបស់លោក យ៉ូសែប ដែលថា ថ្ងៃមួយបងៗរបស់គាត់នឹងមកឱនសំពះចំពោះគាត់នោះបានក្លាយទៅជាការពិតហើយ។

លោក យ៉ូសែប បានស្រែកឡើងថា៖ «ខ្ញុំហ្នឹងហើយជាយ៉ូសែប»។

នៅពេលដែលបងៗទាំងអស់បានឃើញថាជាលោក យ៉ូសែប មែន នោះគេមានការភ័យខ្លាច ពីព្រោះពួកគេទាំងអស់គ្នាបានធ្វើអ្វីមិនគប្បីចំពោះយ៉ូសែប។ ពួកគេទាំងអស់គ្នាបានធ្វើបាប ហើយពួកគេដឹងខ្លួន។ ហើយឥឡូវនេះលោក យ៉ូសែប នឹងប្រាកដជាធ្វើទោសពួកគេទាំងអស់គ្នាជាមិនខាន។

ប៉ុន្តែលោក យ៉ូសែប បានសម្លឹងមើលបងៗគាត់ពេញដោយទឹកភ្នែកហូរជោកជាំ។ ថ្វីបើបងៗរបស់គាត់បានធ្វើឲ្យគាត់ឈឺចាប់ និង



ស្អប់គាត់ ហើយចង់សម្លាប់គាត់ក៏ដោយ ទោះបីជាមានការទាំងនេះកើតឡើងក៏ដោយ ក៏គាត់មិនអាចនឹងឈប់ស្រឡាញ់ពួកគេបានឡើយ។ បងៗរបស់គាត់ធ្លាប់ធ្វើឲ្យគាត់មានការឈឺចាប់ខាងផ្លូវចិត្ត តែគាត់នៅតែស្រឡាញ់គេគ្រប់គ្នា ហើយគាត់ក៏បានអត់ទោសឲ្យគេគ្រប់គ្នាផងដែរ។

លោក យ៉ូសែប បានឱបពួកគេទាំងអស់គ្នា ហើយនិយាយទៅកាន់ពួកគេថា៖ «ចូរកុំភ័យខ្លាចអី អំពើដែលបងៗរាល់គ្នាបានធ្វើ ពីពេលមុនៗទាំងប៉ុន្មាននោះ ព្រះជាម្ចាស់បានធ្វើឲ្យការនោះត្រឡប់ជាល្អឡើងវិញ ហើយព្រះជាម្ចាស់បានផ្លាស់ប្រែការទាំងនោះឲ្យទៅជាត្រឹមត្រូវម្ដងទៀត»។

លោក យ៉ូសែប មិនបានដាក់ទោសដល់បងៗទេ គឺគាត់បានជួយសង្គ្រោះគេទាំងអស់គ្នាវិញ គាត់បាននាំយកគ្រួសារដ៏ពិសេសរបស់ព្រះជាម្ចាស់មករស់នៅដោយក្ដីសុខសាន្តជាមួយគាត់នៅស្រុកអេស៊ីព្ទ។

នៅថ្ងៃមួយ ព្រះជាម្ចាស់នឹងបញ្ជូនព្រះអម្ចាស់មួយអង្គ ដែលជាព្រះអម្ចាស់ដែលមានវ័យក្មេងនៅឡើយ ហើយទ្រង់នឹងមានការឈឺចាប់ខាងផ្លូវចិត្ត ដូចជាលោក យ៉ូសែប ដែរ គឺទ្រង់នឹងចាកចេញពីលំនៅ និងពីព្រះវរបិតារបស់ទ្រង់។ បងប្អូនរបស់ទ្រង់នឹងស្អប់ទ្រង់ព្រមទាំងមានបំណងនឹងសម្លាប់ទ្រង់ផង។





ពួកគេនឹងលក់ទ្រង់ ដើម្បីឲ្យបានប្រាក់ប៉ុន្មានកាក់ ហើយគេនឹងធ្វើទោសទ្រង់ ទោះជាទ្រង់គ្មានទោសអ្វីសោះក៏ដោយ។

ប៉ុន្តែ ព្រះជាម្ចាស់នឹងប្រើនូវអ្វីដែលបានកើតឡើងចំពោះព្រះអម្ចាស់វ័យក្មេងនេះ សូម្បីតែការអាក្រក់ក៏ដោយ ដើម្បីឲ្យទៅជាការល្អវិញ គឺអត់ទោសបាបឲ្យលោកីយ៍ទាំងមូលតែម្ដង។

# ព្រះជាម្ចាស់ដែលយាងមកសង្គ្រោះ!

លោក ម៉ូសេ និងការភៀសខ្លួនចេញពីស្រុកអេស៊ីព្ទ (ដកស្រង់ចេញពីកណ្ឌ និក្ខមនំ ៣-១៣)

**លោក យ៉ូសែប** និងបងប្អូនទាំងអស់មានវ័យចាស់ជរា ហើយបានស្លាប់អស់ទៅ ប៉ុន្តែកូនចៅរបស់គាត់បានរស់នៅក្នុងស្រុកអេស៊ីព្ទ ពួកគេបានកើនចំនួនឡើងទៅជាគ្រួសារដ៏ធំមួយ។

ក្រោយមក មានស្តេចថ្មីមួយអង្គបានឡើងសោយរាជ្យ ប៉ុន្តែស្តេច ផារ៉ោន មួយអង្គនេះមិនបានចងចាំអំពីប្រវត្តិរបស់លោក យ៉ូសែប ទេ ហើយស្តេចនេះក៏ពុំចូលចិត្តនឹងរាស្ត្ររបស់ព្រះជាម្ចាស់នោះដែរ។ ស្តេចនោះក៏បានបង្ខំពួកគេឲ្យធ្វើជាឈ្នួលបម្រើដាច់ថ្លៃរបស់ខ្លួន ថែមទាំងបានវាយដំបង្ខំគេឲ្យធ្វើការរឹតតែខ្លាំងឡើងៗ។

រាស្ត្ររបស់ព្រះជាម្ចាស់បានស្រែកយំ ទូលសុំឲ្យព្រះអង្គយាងមកជួយសង្គ្រោះគេ។ ហើយព្រះជាម្ចាស់បានឮសម្រែកថ្ងូចថ្ងូររបស់គេ ព្រះអង្គបាននឹកចាំពីសេចក្តីសន្យារបស់ទ្រង់ជាមួយនឹងលោក អ័ប្រាហាំ ថា ព្រះអង្គនឹងជួយថែរក្សាបណ្តាជនរបស់គាត់ ព្រះអង្គនឹងរកផ្លូវរំដោះពួកគេឲ្យមានសេរីភាព។

នៅថ្ងៃមួយ លោក ម៉ូសេ កំពុងតែឃ្វាលចៀមរបស់គាត់ គាត់បានក្រឡេកមើលទៅឃើញគុម្ពបន្លាមួយមានភាពខុសពីធម្មតាដែលមានភ្លើងឆេះភ្លឺបភ្លែតៗ ប៉ុន្តែ ស្លឹករបស់វាមិនបានឆេះឡើយ។ ដូច្នេះ គាត់ក៏បានចូលទៅជិត ដើម្បីពិនិត្យមើល។

សំឡេងខ្លាំងមួយកក្រើកឡើងថា៖ «ម៉ូសេ!»។

លោក ម៉ូសេ បានលោតថយក្រោយ ព្រោះគុម្ពបន្លានិយាយមកកាន់គាត់!

ព្រះជាម្ចាស់មានបន្ទូលថា៖ «យើងបានឮរាស្ត្រយើងស្រែករកយើង ហើយយើងបានឃើញទឹកភ្នែករបស់ពួកគេហេតុនេះបានជាយើងចុះមកដើម្បីជួយសង្គ្រោះពួកគេ។ ចូរឯងទៅប្រាប់ស្តេច ផារ៉ោន ឲ្យដោះលែងរាស្ត្ររបស់យើងឲ្យមានសេរីភាពទៅ»។

លោក ម៉ូសេ មានការភ័យខ្លាច ប៉ុន្តែ ព្រះជាម្ចាស់មានបន្ទូលថា៖ «យើងនឹងនៅជាមួយឯង»។



ដូច្នេះ លោក ម៉ូសេ បានធ្វើដំណើរទៅជួបស្តេច ផារ៉ោន។

លោក ម៉ូសេចាប់ផ្តើមនិយាយថា៖ «ឱ! ស្តេច ផារ៉ោន អើយ! ព្រះជាម្ចាស់បានមានបន្ទូលថា...» ស្តេច ផារ៉ោន ឆ្លើយកាត់ថា៖ «ព្រះជាម្ចាស់? ដូចជាមិនដែលឮអំពីព្រះជាម្ចាស់នេះទេ»។

លោក ម៉ូសេ នៅតែបន្តថា៖ «ព្រះជាម្ចាស់មានបន្ទូលថា ចូរដោះលែងរាស្ត្ររបស់ទ្រង់ឲ្យមានសេរីភាពទៅ»។

តែស្តេច ផារ៉ោន ឆ្លើយតបថា៖ «ហេតុអ្វីបានជាអញត្រូវដោះលែងគេចេញ? អញមិនចង់ដោះលែង ហើយក៏នឹងមិនដោះលែងគេដែរ» ដូច្នេះទ្រង់មិនព្រមដោះលែងគេទេ។

ហេតុដូច្នេះហើយបានជាព្រះជាម្ចាស់បានព្រមានដល់ស្តេច ផារ៉ោន ដប់ដងថានឹងមានគ្រោះកាចកើតឡើង។ មុនដំបូង ព្រះជាម្ចាស់បានធ្វើឲ្យទឹកទន្លេនីលក្លាយទៅជាឈាម គ្មានអ្នកណាម្នាក់អាចផឹកទឹកនោះបានឡើយ ប៉ុន្តែស្តេច ផារ៉ោន នៅតែមិនព្រមដោះលែងពួកគេចេញទេ។

ដូច្នេះ ព្រះជាម្ចាស់បានធ្វើឲ្យមានសត្វកង្កែប ហក់ លោត ផ្លោះៗ គ្រប់កន្លែង នៅលើគ្រែរបស់អ្នកក៏មានកង្កែប នៅលើសក់របស់អ្នកក៏មានកង្កែប នៅក្នុងសម្លរបស់អ្នកក៏មានកង្កែប ពាសពេញគ្រប់ទីកន្លែងទាំងអស់សុទ្ធតែកង្កែប! ស្តេច ផារ៉ោន ស្រែកឡើងថា៖ «ធ្វើឲ្យវាចេញបាត់ទៅវិញទៅ បន្ទាប់មក បណ្តាជនឯងអាចនឹងចេញទៅបានហើយ»។



ដូច្នេះ ព្រះជាម្ចាស់ក៏ដកយកសត្វកង្កែបចេញបាត់អស់ទៅ។

ប៉ុន្តែ ស្តេច ផារ៉ោន បានប្តូរចិត្តវិញ ដោយបញ្ជាថា៖ «ពួកឯងមិនអាចចេញទៅបានទេ»។



បន្ទាប់មក ព្រះជាម្ចាស់បញ្ជូនសត្វចៃជាច្រើនលើសលុប ប៉ុន្តែ ស្តេច ផារ៉ោន នៅតែមានបន្ទូលថា៖ «ទៅមិនបានឡើយ!» ដូច្នេះបន្ទាប់មក ព្រះជាម្ចាស់បញ្ជូនហ្វូងសត្វរុយ ហើរឮសូរងូងៗជិតចូលក្នុងភ្នែកអ្នក គឺរុយពាសពេញគ្រប់កន្លែង។

ហើយក្រោយមកទៀត ព្រះជាម្ចាស់បានបញ្ជូនជំងឺពងខ្ទុះ ដុំព្រិលធំៗ និងហ្វូងកណ្តូប បន្ទាប់មកមានងងឹត ទោះជានៅពេលថ្ងៃក៏ដោយ រហូតដល់វាហាក់ដូចជាងងឹតពេញផែនដីទាំងមូល។ ការបង្កបង្កើត និងអ្វីៗគ្រប់យ៉ាងត្រូវបានប្រែដូចពីមុនដែលមិនទាន់បានបង្កើត  គឺបានវិលត្រឡប់ទៅភាពងងឹតវិញ ជាភាពទទេ គ្មានអ្វីទាល់តែសោះ។







ប៉ុន្តែ គ្រប់ពេលទាំងអស់ដែលស្តេច ផារ៉ោន បានមានបន្ទូលថា៖ «បញ្ឈប់ការនេះទៅ រួចហើយអញនឹងឲ្យពួកឯងចេញទៅ!» ហើយគ្រប់ពេលទាំងអស់ដែលព្រះជាម្ចាស់បានបញ្ឈប់ការនោះ ស្តេច ផារ៉ោន បានប្តូរចិត្ត ហើយមានបន្ទូលថា៖ «ការពិតនោះ គឺវាមិនបានទេ! ឯងមិនអាចទៅបានទេ!»។

ទីបំផុតលោក ម៉ូសេ បានព្រមានស្តេច ផារ៉ោន ថា៖ «ទ្រង់ត្រូវស្តាប់បង្គាប់ព្រះជាម្ចាស់ ប្រយ័ត្នព្រះអង្គបញ្ជូនការអាក្រក់បំផុតមក» តែស្តេច ផារ៉ោន បែរជាសើចចំអកទៅវិញ។

ដូច្នេះ ព្រះជាម្ចាស់មានបន្ទូលថា៖ «កូនប្រុសច្បងនៃគ្រួសារអេស៊ីព្ទនីមួយៗត្រូវតែស្លាប់ ប៉ុន្តែពួករាស្ត្រយើងនឹងបានសុខវិញ»។

ព្រះជាម្ចាស់មានបន្ទូលប្រាប់ទៅរាស្ត្រទ្រង់ឲ្យយកកូនចៀមដ៏ល្អឥតខ្ចោះមកសម្លាប់ ហើយយកឈាមវាខ្លះទៅលាបនៅមាត់ទ្វារផ្ទះខាងមុខ។ លោក ម៉ូសេ បានពន្យល់គេថា៖ «កាលណាព្រះជាម្ចាស់យាងកាត់មុខផ្ទះពួកឯង ព្រះអង្គនឹងឃើញឈាម ហើយទ្រង់បានដឹងថា ចៀមបានស្លាប់ជំនួសឯងហើយ»។





នៅយប់នោះ ដូចជាព្រះជាម្ចាស់មានបន្ទូលមែន ភាពងងឹតសូន្យសុងនោះ បាននាំមកនូវសម្រែកដែលស្រែកយ៉ាងដាច់សរសៃកគួរឲ្យរន្ធត់ ចេញមកពីច្រកផ្លូវនៃព្រះរាជវាំង។ កូនប្រុសច្បងរបស់ស្តេច ផារ៉ោន បានស្លាប់ហើយ! នៅទីបំផុត ស្តេច ផារ៉ោន ក៏បានធ្វើតាមការដែលព្រះជាម្ចាស់បានបង្គាប់។

ស្តេច ផារ៉ោន ស្រែកប្រាប់ថា៖ «ចេញទៅ! ឲ្យគេចេញទៅចុះ!»។



ដូច្នេះហើយ នៅគ្រាយប់នោះលោក ម៉ូសេ និងរាស្ត្ររបស់ព្រះជាម្ចាស់ បានភៀសខ្លួនចេញពីស្រុកអេស៊ីព្ទ និងចេញពីភាពជាឈ្មួលបម្រើដាច់ថ្លៃដែរ ទីបំផុតពួកគេមានសេរីភាពហើយ!

រាស្ត្ររបស់ព្រះជាម្ចាស់បានចងចាំជានិច្ចនូវការជួយសង្គ្រោះដ៏ធំនេះ ហើយគេបានដាក់ឈ្មោះយប់នោះថា «បុណ្យរំលង»។ ប៉ុន្តែ នៅមានសេចក្តីសង្គ្រោះដ៏ធំមួយទៀតនឹងមកដល់។

ជាច្រើនឆ្នាំកន្លងមក ព្រះជាម្ចាស់នឹងធ្វើការនេះម្តងទៀត ព្រះអង្គទ្រង់នឹងយាងចុះមកម្តងទៀត ដើម្បីជួយសង្គ្រោះរាស្ត្ររបស់ទ្រង់ ប៉ុន្តែលើកនេះព្រះអង្គនឹងជួយសង្គ្រោះឲ្យពួកគេមានសេរីភាពដែលនឹងនៅដ៏អស់កល្បជានិច្ច។

# ព្រះជាម្ចាស់នឹងរៀបចំផ្លូវមួយ



លោក ម៉ូសេ និងសមុទ្រក្រហម

(ដកស្រង់ចេញពីកណ្ឌ និក្ខមនំ ១៤-១៥)



**លោក ម៉ូសេ** និងរាស្ត្ររបស់ព្រះជាម្ចាស់ បានភៀសខ្លួនចេញពីស្រុកអេស៊ីព្ទទៅទីវាលរហោស្ថាន។ ពួកគេពុំស្គាល់ផ្លូវទេ – ប៉ុន្តែទ្រង់ស្គាល់ផ្លូវ ហើយព្រះអង្គនឹងបង្ហាញផ្លូវដល់ពួកគេ។

ព្រះជាម្ចាស់បានសន្យាដល់ពួកគេថា៖ «យើងនឹងនាំឯងទៅកាន់ទីលំនៅថ្មីមួយ គឺជាដែនដីដ៏វិសេស យើងនឹងថែរក្សាពួកឯង យើងនឹងនៅជាមួយឯង»។

ព្រះជាម្ចាស់បានបញ្ជូនដុំពពកធំមួយឲ្យពួកគេដើរតាម ជាបង្គោលមួយដែលលូតឡើងទៅលើមេឃ។ វារំកិលនៅមុខពួកគេ ពេលដែលគេដើរ វាធ្វើជាម្លប់បាំងកំដៅដល់ពួកគេជារៀងរាល់ថ្ងៃ។ ហើយដល់ពេលឈប់សម្រាក វាក៏ឈប់ដែរ។ ទោះបីជានៅទីវាលពេលយប់ត្រជាក់ វាបញ្ចេញកំដៅឲ្យពួកគេបានកក់ក្តៅ ដោយជះពន្លឺដូចជាភ្លើងនៅពេលយប់។

ព្រះជាម្ចាស់បាននាំផ្លូវរាស្ត្រទ្រង់ ទៅតាមទីវាលទៅដល់មាត់សមុទ្រដ៏ធំធេង។ ពួកគេងឿងឆ្ងល់ថា តើត្រូវឆ្លងសមុទ្រនោះដោយរបៀបណា រំពេចនោះពួកគេបានឮសូររន្ទះបាញ់មួយដ៏គួរឲ្យភ័យខ្លាច និងស្នូរសំឡេងលាន់រណ្តំហាក់ដូចជាសំឡេងក្រចកជើងសេះ។ ពួកគេបានយកដៃបាំងភ្នែកសម្លឹងមើលទៅក្រោយ ហើយក៏ស្រែកជាខ្លាំង ពីព្រោះស្តេច ផារ៉ោន និងកងទ័ព កំពុងដេញតាមចាប់ពួកគេ!

ស្តេច ផារ៉ោន បានប្តូរចិត្តម្តងទៀត ហើយស្រែកទាំងភ្លាត់សំឡេង និងដេញតាមរាស្ត្ររបស់ព្រះជាម្ចាស់ទៅក្នុងទីវាលហើយនិយាយថា៖ «យកឈ្នួលបម្រើដាច់ថ្លៃរបស់យើងមកវិញ!» ស្តេច ផារ៉ោន បានដេញតាមពួកគេ ដោយប្រើប្រាស់កងទ័ពសេះដ៏លឿនបំផុត ដែលមានចំនួន៦០០នាក់ និងគ្រប់រទេះចម្បាំងទាំងអស់របស់ស្រុកអេស៊ីព្ទផង។





តើរាស្ត្ររបស់ព្រះជាម្ចាស់ត្រូវធ្វើយ៉ាងណា? នៅខាងមុខរបស់ពួកគេ គឺជាសមុទ្រដ៏ធំធេង។ សមុទ្រធំយ៉ាងនេះគ្មានផ្លូវវាងអាចនឹងដើរបានទេ ក៏គ្មានផ្លូវណាចុះទៅតាមទឹកបានដែរ ពីព្រោះទឹកជ្រៅណាស់ ហើយពួកគេគ្មានទូកដើម្បីនឹងឆ្លងទៅត្រើយម្ខាងទៀតឡើយ។ ពួកគេមិនអាចហែលឆ្លងបានទេ ពីព្រោះឆ្ងាយពេក ហើយពួកគេអាចនឹងលង់ទឹកស្លាប់បាន។ ពួកគេក៏មិនអាចបែរក្រោយបានដែរ ពីព្រោះស្ដេច ផារ៉ោន កំពុងតែដេញតាមពួកគេ។ ពួកគេអាចមើលឃើញពន្លឺដាវចាំងផ្លេកៗតាមពន្លឺព្រះអាទិត្យដែលកំពុងតែក្ដៅហែង ព្រមជាមួយនឹងធូលីដីហុយបែកផ្សេងហើយនិងរទេះចម្បាំងដ៏គួរឲ្យខ្លាចកំពុងតែដេញសំដៅមករកពួកគេ។ ដូច្នេះ ពួកគេសល់តែការមួយគត់ គឺភ័យស្លន់រកគិតអ្វីមិនចេញ!

ពួកគេស្រែកឡើងយ៉ាងគ្រលួចថា៖ «យើងនឹងត្រូវស្លាប់ហើយៗ!»។

តែលោក ម៉ូសេ បានប្រាប់ពួកគេថា៖ «កុំឲ្យខ្លាចឡើយ!»។

ពួកគេបានស្រែកឡើងថា៖ «ប៉ុន្តែ យើងរាល់គ្នាមិនអាចធ្វើអ្វីបានទេ!»។

លោក ម៉ូសេ ឆ្លើយថា៖ «ព្រះជាម្ចាស់បានដឹងថា ពួកឯងមិនអាចធ្វើអ្វីបានទេ! ព្រះជាម្ចាស់នឹងបើកផ្លូវឲ្យឯង ដូច្នេះត្រូវទុកចិត្តលើព្រះជាម្ចាស់ ហើយចាំមើលចុះ!»។

ពួកគេស្រែកឡើងថា «ប៉ុន្តែគ្មានផ្លូវចេញទេ!»។

លោក ម៉ូសេ ឆ្លើយថា៖ «ព្រះជាម្ចាស់នឹងបើកផ្លូវឲ្យ!»។

នៅសល់តែបន្តិចទៀត អ្វីៗនឹងត្រូវខ្ទេចអស់ហើយ ប៉ុន្តែពេលនោះ មានការចម្លែកបំផុតមួយបានកើតឡើង។



ព្រះជាម្ចាស់បានរំកិលសសរផ្សែងនោះ វាក៏បានរំកិលទៅនៅពីខាងក្រោយរាស្ត្ររបស់ទ្រង់។ ហើយបំបាំងពួកគេពីពួកអេស៊ីព្ទ។ រួចព្រះជាម្ចាស់បានបញ្ជូនខ្យល់មានកម្លាំងខ្លាំងពីទិសខាងកើតបក់ពេញមួយយប់។ ខ្យល់បានបក់ទឹកក្នុងសមុទ្រដ៏ធំធេងនោះ គឺវាបានបក់ទឹកទៅខាងឆ្វេង ហើយនិងទៅខាងស្តាំបក់រហូតដល់បង្កើតជាជញ្ជាំងទឹកពីរដ៏ខ្ពស់សន្ធឹម។ ហើយនៅចំកណ្តាលទឹកនោះ មានស្នាមផ្លូវភក់បានបើកឡើង។ រាស្ត្ររបស់ព្រះជាម្ចាស់ក៏បានដើរឆ្លងលើដីគោកនោះ!

នៅពេលដែលពួកអេស៊ីព្ទព្យាយាមតាមពួកគេនោះជញ្ជាំងនៃទឹកបានធ្លាក់ចុះមកវិញគ្រប ដណ្ដប់លេបគេបាត់អស់ទៅ។

រាស្ត្ររបស់ព្រះជាម្ចាស់បានរួចខ្លួន ពួកគេបានរាំសើចសប្បាយ ហើយច្រៀងអរព្រះគុណដល់ព្រះជាម្ចាស់ ពីព្រោះនៅពេលដែលគ្មានផ្លូវចេញសោះ ព្រះជាម្ចាស់បានបើកផ្លូវឲ្យ។

ជាច្រើនឆ្នាំក្រោយមក ព្រះជាម្ចាស់នឹងបើកច្រកផ្លូវឲ្យម្ដងទៀត នៅពេលដែលគ្មានផ្លូវចេញសោះ។

ចាប់តាំងពីដើមដំបូងមក កូនៗរបស់ព្រះជាម្ចាស់បានរត់ចេញពីទ្រង់ ហើយលាក់ខ្លួន។ ព្រះជាម្ចាស់បានជ្រាបថា កូនៗរបស់ទ្រង់មិនអាចមានសេចក្ដីសុខសាន្តដោយគ្មានទ្រង់បានទេ។ ប៉ុន្តែ ពួកគេមិនអាចត្រឡប់មករកទ្រង់វិញដោយខ្លួនឯងនោះទេ ពួកគេបានវង្វេង ពួកគេមិនអាចស្គាល់ផ្លូវត្រឡប់ទៅវិញឡើយ។

ប៉ុន្តែ ព្រះជាម្ចាស់ស្គាល់ផ្លូវ។

ហើយនៅថ្ងៃមួយ ព្រះអង្គនឹងបង្ហាញដល់ពួកគេ។





# ប្រការដប់យ៉ាងដើម្បីឲ្យបានល្អឥតខ្ចោះ

លោក ម៉ូសេ និងក្រឹត្យវិន័យ១០ប្រការ (ដកស្រង់ចេញពីកណ្ឌ និក្ខមនំ)

**នៅទីនោះ** ពួកគេនៅជុំគ្នាមានឪពុក ម្ដាយ ពូ មីង យាយ តា និងក្មេងៗ ហើយនៅកណ្ដាលទីវាលនោះ ពួកគេគ្រប់គ្នាមានពងបែកលើស្បែក ដោយសារការធ្វើដំណើរថ្មើរជើង ពួកគេឃ្លាន និងស្រេកទឹក ពីព្រោះក្ដៅខ្លាំងណាស់។

គេនិយាយថា៖ «យើងមិនចូលចិត្តទេ! ធុំក្លិនស្អុយណាស់!» (ពួកគេធុំក្លិនអញ្ចឹងមែន ពីព្រោះគ្មានអ្នកណាម្នាក់បានងូតទឹកអស់ជាច្រើនអាទិត្យមកហើយ)។

ចូរចងចាំពីការអស្ចារ្យជាច្រើនដែលព្រះជាម្ចាស់បានធ្វើសម្រាប់ពួកគេ ដ្បិតការនោះឯងជាអ្វីដែលពួកគេបានភ្លេច។ ព្រះអង្គបានបំបាំងពួកគេក្នុងពពក។ ព្រះអង្គបានញែកទឹកសមុទ្រចេញ។ ហើយបានរំដោះពួកគេឲ្យមានសេរីភាព។

ប៉ុន្តែ រាស្ត្ររបស់ព្រះអង្គនៅតែមិនសប្បាយចិត្ត ពួកគេមិនខ្វល់អំពីការមានសេរីភាពនោះទេ។ តើពេលដែលពួកគេធ្វើជាឈ្នួលបម្រើដាច់ថ្លៃ វាប្រសើរជាងនេះឬអី? ពួកគេគិតថា យ៉ាងហោចណាស់នៅពេលនោះក៏ពួកគេមានម្ហូបអាហារឆ្ងាញ់ៗជាច្រើនសម្រាប់បរិភោគដែរ។

ពួកគេនិយាយថា៖ «ព្រះជាម្ចាស់មិនចង់ឲ្យយើងរាល់គ្នាសប្បាយចិត្តទេ»។ នេះជាពាក្យកុហក ដូចកាលដែលលោក អ័ដាម និងនាង អេវ៉ា ធ្លាប់បានឮជាច្រើនឆ្នាំកន្លងមកហើយ។ ពួកគេនិយាយទៀតថា៖ «ព្រះជាម្ចាស់បាននាំយើងចេញមកទីនេះ ដើម្បីនឹងសម្លាប់ពួកយើង ព្រះអង្គមិនបានស្រឡាញ់យើងទេ!»។ ប៉ុន្តែ ពួកគេមិនបានស្គាល់ព្រះជាម្ចាស់ច្បាស់លាស់ទេ។





ជារៀងរាល់ថ្ងៃ ក្នុងការធ្វើដំណើររបស់ពួកគេ ព្រះជាម្ចាស់បានបង្ហាញឲ្យគេឃើញថា ព្រះអង្គតែងតែរក្សាការពារពួកគេ ប្រសិនបើពួកគេទុកចិត្ត និងស្តាប់បង្គាប់ព្រះអង្គ។ នៅពេលដែលពួកគេឃ្លាន ព្រះជាម្ចាស់បានបង្អុរអាហារពីលើមេឃមកឲ្យពួកគេ គឺនំបុ័ងធ្លាក់ចុះពីស្ថានសួគ៌មក! ពួកគេសួរគ្នាថា៖ «ស្អីគេហ្នឹង?» ពីព្រោះពួកគេមិនដែលស្គាល់ទេ។ ដូច្នេះ ពួកគេបានហៅថានំនោះថា៖ «ស្អីគេហ្នឹង?» (ជាការពិតណាស់ នេះជាឈ្មោះដ៏ល្អមួយសម្រាប់របស់អ្វីមួយ ដែលអ្នកមិនស្គាល់)។ នៅពេលដែលពួកគេស្រេកទឹក ហើយចាប់ផ្តើមឈ្លោះគ្នា ព្រះជាម្ចាស់បានធ្វើឲ្យទឹកហូរចេញពីថ្មមក ហើយលោក ម៉ូសេ បានហៅកន្លែងនោះថា៖ «ឈ្លោះប្រកែក» ពីព្រោះមើលទៅហាក់ដូចជាឈ្មោះមួយល្អដែរ។

ទោះបើពួកគេបានឃើញប៉ុណ្ណឹងហើយក៏ដោយ ក៏កូនៗរបស់ព្រះជាម្ចាស់នៅតែមិនទុកចិត្តទ្រង់ ឬធ្វើតាមអ្វីដែលព្រះអង្គបានបង្គាប់ពួកគេដែរ។ ពួកគេបានគិតថា គេអាចមើលថែទាំខ្លួនគេបានយ៉ាងល្អ ដោយខ្លួនឯងបាន ហើយធ្វើឲ្យខ្លួនគេបានសប្បាយចិត្ត។ ប៉ុន្តែ ព្រះជាម្ចាស់ជ្រាបហើយថា ពួកគេមិនមានភាពរីករាយទេ បើសិនជាគ្មានព្រះអង្គនោះ។

ដូច្នេះ ព្រះជាម្ចាស់បាននាំពួកគេទៅឯភ្នំខ្ពស់មួយ។ ព្រះអង្គចង់មានបន្ទូលទៅកាន់រាស្ត្ររបស់ទ្រង់ ហើយបង្ហាញប្រាប់គេថា ព្រះអង្គមានភាពយ៉ាងដូចម្តេច។ ព្រះអង្គចង់ជួយពួកគេឲ្យបានស្គាល់ទ្រង់កាន់តែប្រសើរឡើង ហើយទ្រង់ចង់ប្រាប់ពួកគេ អំពីដែនទឹកដីពិសេសមួយ ដែលព្រះអង្គនឹងប្រទានឲ្យពួកគេ។

ព្រះអង្គមានបន្ទូលថា៖ «ផែនដីទាំងមូលជារបស់យើង! ប៉ុន្តែ យើងបានជ្រើសរើសពួកឯង ពីព្រោះពួកឯងជាគ្រួសារដ៏ពិសេសរបស់យើង ហើយយើងចង់ឲ្យឯងរស់នៅក្នុងផ្លូវមួយដែលបង្ហាញឲ្យអ្នកដទៃឃើញថា យើងមានលក្ខណសម្បត្តិយ៉ាងណា ដើម្បីឲ្យគេអាចស្គាល់យើង ដូចជាឯងរាល់គ្នាស្គាល់យើងដែរ»។





ព្រះជាម្ចាស់បានហៅលោក ម៉ូសេ ឲ្យឡើងទៅលើភ្នំ។ ភ្នំដ៏ធំសម្បើមនោះក៏បានកក្រើកឡើង ដុំពពកដ៏ក្រាស់ក៏បានធ្លាក់ចុះមកផ្គរលាន់ឮរំពង រួចរន្ទះភ្លឺផ្លេកពាសពេញមេឃ ហើយព្រះជាម្ចាស់បានប្រគល់បញ្ញត្តិ១០ប្រការដល់លោក ម៉ូសេ ដែលហៅថា៖ «ក្រឹត្យវិន័យ»។

ព្រះជាម្ចាស់បានប្រាប់ទៅពួកគេថា៖ «យើងចង់ឲ្យឯងរាល់គ្នាស្រឡាញ់យើង លើសអ្វីៗទាំងអស់នៅលើលោកីយ៍នេះ ហើយចង់ឲ្យពួកឯងរាល់គ្នាដឹងថា យើងស្រឡាញ់ពួកឯងរាល់គ្នាដែរ នេះគឺជាសេចក្ដីសំខាន់លើសជាងអ្វីទាំងអស់»។



ព្រះជាម្ចាស់បានឲ្យក្រឹត្យវិន័យផ្សេងៗទៀតដល់ពួកគេដែរ ដូចជា កុំឲ្យតាំងព្រះក្លែងក្លាយជាព្រះរបស់ឯងឡើយ កុំសម្លាប់មនុស្ស កុំលួច ឬកុហក។ ក្រឹត្យវិន័យបានបង្ហាញដល់រាស្ត្ររបស់ព្រះជាម្ចាស់ ពីរបៀបរស់នៅ និងពីរបៀបចូលទៅជិតព្រះអង្គ ព្រមទាំងពីរបៀបធ្វើយ៉ាងណា ដើម្បីឲ្យមានភាពរីករាយផង។ ក្រឹត្យវិន័យនឹងបង្ហាញនូវអ្វីដែលល្អបំផុតសម្រាប់ជីវិត។

លោក ម៉ូសេ បាននិយាយប្រាប់ថា៖ «ព្រះជាម្ចាស់បានសន្យាថា នឹងថែរក្សាពួកអ្នករាល់គ្នាជានិច្ច» រួចលោកសួរគេថា៖ «តើឯងរាល់គ្នានឹងស្រឡាញ់ព្រះជាម្ចាស់ ហើយរក្សាទុកនូវក្រឹត្យវិន័យទាំងនេះបានដែរឬទេ?»។

ពួកគេបានឆ្លើយថា «យើងអាចធ្វើបាន! យល់ព្រម យើងសូមសន្យា!»។

ក៏ប៉ុន្តែ ពួកគេយល់ខុសហើយ ពួកគេមិនអាចធ្វើបានទេ។ ទោះបីពួកគេខំព្យាយាមយ៉ាងណាក៏ដោយ ក៏ពួកគេមិនអាចរក្សាក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ឲ្យបានគ្រប់ពេលវេលាឡើយ។

ព្រះជាម្ចាស់បានជ្រាបថា ពួកគេមិនអាចរក្សាបានទេ ហើយព្រះអង្គចង់ឲ្យពួកគេបានដឹងខ្លួនដែរ។

គឺមានតែមនុស្សម្នាក់គត់ ដែលអាចរក្សាទុកនូវក្រឹត្យវិន័យទាំងអស់បាន ហើយជាច្រើនឆ្នាំក្រោយមក ព្រះជាម្ចាស់នឹងចាត់ព្រះរាជបុត្រារបស់ទ្រង់ ឲ្យមកឈរនៅកន្លែងជំនួសពួកគេ ហើយធ្វើជាបុគ្គលដ៏ល្អឥតខ្ចោះជំនួសពួកគេ។

ពីព្រោះក្រឹត្យវិន័យ មិនអាចសង្គ្រោះពួកគេបានទេ មានតែព្រះជាម្ចាស់មួយអង្គគត់ ដែលអាចសង្គ្រោះពួកគេបាន។



# អ្នកដឹកនាំដែលជាមេទ័ពចម្បាំង

លោក យ៉ូស្វេ ប្រយុទ្ធនៅទីក្រុងយេរីខូរ (ដកស្រង់ចេញពីកណ្ឌ យ៉ូស្វេ ៣ និង៦)

**បន្ទាប់ពីពេល**ដែល លោក ម៉ូសេ បានស្លាប់បាត់ទៅ ព្រះជាម្ចាស់បានប្រទានអ្នកដឹកនាំថ្មីម្នាក់ទៀតដល់រាស្ត្រទ្រង់។ គាត់ឈ្មោះថាលោក យ៉ូស្វេ ដែលមានន័យថា៖ «ព្រះជាម្ចាស់ជាព្រះអង្គសង្គ្រោះ»។ លោក យ៉ូស្វេ នឹងដឹកនាំរាស្ត្ររបស់ព្រះជាម្ចាស់ទៅកាន់ទឹកដីពិសេស ដែលព្រះជាម្ចាស់បានសន្យាថានឹងប្រទានដល់ពួកគេ។

មកដល់ពេលនេះ ពួករាស្ត្ររបស់ព្រះជាម្ចាស់បានវង្វេងដើរវិលវល់នៅទីរហោស្ថានដែលក្ដៅហែងអស់រយៈពេល៤០ឆ្នាំហើយ! ដូច្នេះ អ្នកក៏អាចស្មានបានដែរថា តើពួកគេធុញទ្រាន់ប៉ុណ្ណានឹងដីខ្សាច់ ព្រមទាំងរបស់អ្វីដែលមានពណ៌លឿង ជម្រកតង់ ការធ្វើដំណើរ ហើយនិងអាកាសធាតុក្ដៅហួតហែង។ តើពួកគេសប្បាយចិត្តប៉ុណ្ណា នៅពេលដែលពួកគេបានឈានដល់ចុងនៃទីរហោស្ថាន ហើយបានឃើញលំនៅថ្មីដ៏ស្រស់បំព្រងរបស់ពួកគេ ដែលនៅចំពោះមុខពួកគេ គឺជាទីត្រជាក់ និងមានពណ៌ខៀវខ្ចី ហើយជាទីស្រឡាញ់ផង ប៉ុន្តែ មានបញ្ហាតែមួយប៉ុណ្ណោះគឺ៖

ទីក្រុងយេរីខូរ។

យេរីខូរជាទីក្រុងមួយ តែវាមិនមែនគ្រាន់តែជាទីក្រុងធម្មតាមួយប៉ុណ្ណោះទេ វាគឺជាទីក្រុងដែលមានកំផែងព័ទ្ធជុំវិញ បិទមិនឲ្យនរណាម្នាក់អាចចូលទៅក្នុងទីនោះបានឡើយ។

ពួកគេបានសម្លឹងមើលទៅទីក្រុងយេរីខូរ មើលទៅជញ្ជាំងជុំវិញដ៏ធំ គួរឲ្យខ្លាច។ មើលទៅកម្ពស់កំផែងប៉មព័ទ្ធជុំវិញ មើលទៅខ្លោងទ្វារដែកដែលបិទជិតឈឹង រួចគេមើលមុខគ្នាទៅវិញទៅមក។







តើពួកគេត្រូវធ្វើដូចម្ដេច? គ្មាននរណាម្នាក់ដឹងសោះ តែព្រះជាម្ចាស់បានដឹង ហើយព្រះជាម្ចាស់បានប្រាប់ដល់លោក យ៉ូស្វេ ពីអ្វីដែលត្រូវធ្វើ។ ប៉ុន្តែលោក យ៉ូស្វេ ដូចជាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ពីព្រោះនេះជាផែនការសង្គ្រាមមិនធម្មតាមួយដែលគាត់ត្រូវធ្វើ យើងនឹងឃើញក្នុងពេលឆាប់ៗនេះ។

រួចព្រះជាម្ចាស់បានធ្វើសេចក្ដីសន្យាដល់រាស្ត្រទ្រង់ថា៖ «យើងនឹងនៅជាមួយពួកឯងជានិច្ច ហើយយើងនឹងមិនដែលបោះបង់ចោលពួកឯងឡើយ។ បើឯងធ្វើតាមដែលយើងបានប្រាប់នោះ ឯងនឹងបានរស់នៅក្នុងដែនដីថ្មីនេះ នឹងបានទទួលសេចក្ដីសប្បាយរីករាយ ហើយគ្រប់ការអ្វីទាំងអស់នឹងបានប្រសើរឡើង»។

ដូច្នេះ លោក យ៉ូស្វេ ក៏ប្រមូលកងទ័ពរបស់គាត់ទាំងអស់មកជុំគ្នា ពួកគេមានដាវលំពែង ហើយនិងខែល ពួកគេបានរៀបចំខ្លួនជាស្រេច ដើម្បីចេញទៅប្រយុទ្ធ។ ប៉ុន្តែ ផែនការនេះមិនមែនជាការប្រយុទ្ធគ្នានោះទេ គឺជាការទុកចិត្តលើព្រះជាម្ចាស់ និងជាការធ្វើអ្វីដែលព្រះជាម្ចាស់បានប្រាប់។

ទ័ពរបស់លោក យ៉ូស្វេ បានចេញដំណើរ ដើរជាក្បួនម្ដងហើយម្ដងទៀត ជុំវិញទីក្រុងពីមួយថ្ងៃទៅមួយថ្ងៃទៀត។ ពួកបណ្ដាជននៅក្នុងទីក្រុងយេរីខូរបាននិយាយគ្នាថា៖ «ពួកគេមិនហ៊ានចូលមកវាយគ្នាទេ!»។



ប៉ុន្តែ ពួកគេយល់ខុសហើយ រាស្ត្ររបស់ព្រះជាម្ចាស់មិនបានខ្លាចទេ ពួកគេកំពុងរង់ចាំដំណឹងពីព្រះជាម្ចាស់ បង្គាប់ឲ្យពួកគេធ្វើយ៉ាងណា ក្នុងពេលខាងមុខនេះ។

នៅថ្ងៃទី៧ ព្រះជាម្ចាស់បានប្រាប់រាស្ត្រទ្រង់ឲ្យដើរជុំវិញទីក្រុងនេះ មិនមែនតែម្តងទេ ប៉ុន្តែ៧ដង រួចហើយព្រះជាម្ចាស់មានបន្ទូលប្រាប់ឲ្យពួកគេម្នាក់ៗ ស្រែកឲ្យខ្លាំងតាមដែលគេអាចធ្វើបាន។ (តើធ្លាប់មានអ្នកណាម្នាក់ប្រាប់អ្នកឲ្យស្រែកខ្លាំងៗ តាមដែលអ្នកអាចធ្វើទៅបានដែរឬទេ? ឥឡូវនេះ សូមស្មានពីសំឡេងនោះ បូកនឹងសំឡេងមនុស្សចំនួន៣៩.៩៩៩នាក់ទៀតដែលបានស្រែកខ្លាំងៗដែរ តើអ្នកដឹងទេ គឺបែកត្រចៀកហើយ!)

ហើយក៏មានហេតុការណ៍នេះកើតឡើង៖ ថ្មក៏ចាប់ផ្តើមបែក ព្រោះជញ្ជាំងថ្មចាប់ផ្តើមប្រេះ បណ្តាលឲ្យជញ្ជាំងដ៏ធំរឹងមាំនៃទីក្រុងយេរីខូរ បានរំលំចុះដល់ដីដូចជាគេបានធ្វើវាពីខ្សាច់ ហើយទីក្រុងយេរីខូរ ក៏បានរលាយទៅជាធូលីដី។

ដូច្នេះ ពួករាស្ត្ររបស់ព្រះជាម្ចាស់ក៏បានចូលទៅក្នុងផ្ទះថ្មីរបស់គេ គេមិនចាំបាច់នឹងច្បាំងដើម្បីចូលទៅទីនោះទេ គឺគេគ្រាន់តែដើរចូលទៅប៉ុណ្ណោះ។

លោក យ៉ូស្វេ បានសួរពួកគេថា៖ «ព្រះជាម្ចាស់បាននាំពួកឯងរាល់គ្នាមកទីនេះដោយសុខសាន្ត ឥឡូវតើឯងរាល់គ្នានឹងធ្វើតាមអ្វីដែលទ្រង់មានបន្ទូលប្រាប់ដែរឬទេ?»។

ពួកគេបានឆ្លើយព្រមគ្នាថា៖ «យើងសូមសន្យា»។

លោក យ៉ូស្វេ បាននិយាយថា៖ «មានតែព្រះជាម្ចាស់មួយប៉ុណ្ណោះ ដែលអាចធ្វើឲ្យចិត្តរបស់អ្នករាល់គ្នាបានសប្បាយ។ ដូច្នេះកុំអធិស្ឋានដល់ព្រះក្លែងក្លាយឲ្យសោះ»។

ពួកគេបានឆ្លើយថា៖ «ពិតមែនហើយ យើងមិនធ្វើទេ!»។

ខ្ញុំខ្លាចថា ពួកគេមិនបានរក្សាការសន្យារបស់គេ។ ពួកគេមិនបានធ្វើតាមអ្វីដែលព្រះជាម្ចាស់មានបន្ទូលប្រាប់ដល់ពួកគេទេ ហើយជាច្រើនឆ្នាំក្រោយមកដូចជាព្រះជាម្ចាស់បានព្រមានដល់ពួកគេរួចមកហើយថា ការអាក្រក់នឹងកើតមកដល់រាស្ត្ររបស់ព្រះអង្គ។ ពួកគេនឹងបាត់បង់ផ្ទះរបស់គេ សត្រូវនឹងចាប់ពួកគេ រួចនាំយកទៅធ្វើជាឈ្មួលបម្រើដាច់ថ្លៃ។ នៅពេលនោះ រាស្ត្ររបស់ព្រះជាម្ចាស់ នឹងត្រូវខ្ចាត់ខ្ចាយទៅនៅកន្លែងផ្សេងៗគ្នាលើផែនដី ប៉ុន្តែ ផែនការរបស់ព្រះជាម្ចាស់នៅតែបន្តទៅមុខ។

នៅថ្ងៃមួយ ព្រះជាម្ចាស់នឹងប្រទានអ្នកដឹកនាំម្នាក់ទៀតមកដល់រាស្ត្រទ្រង់ ហើយនិងលំនៅដ៏ល្អមួយទៀតដែរ។

ក៏ប៉ុន្តែលំនៅនេះ គ្មានអ្នកណាម្នាក់អាចនឹងដកយកពីពួកគេបានឡើយ។



# ស្តេចពិតប្រាកដ ដែលតូចល្អិត

ហោរា សាំយូអែល ចាក់ប្រេងតាំងឲ្យស្តេច ដាវីឌ (ដកស្រង់ចេញពីកណ្ឌ ១សាំយូអែល ១៦)

**រាស្ត្ររបស់ព្រះជាម្ចាស់**មានដីថ្មី ឥឡូវនេះពួកគេចង់បានស្តេចមួយអង្គ។

ហោរា សាំយូអែល បានប្រាប់ពួកគេថា៖ «ប៉ុន្តែ ព្រះជាម្ចាស់គឺជាស្តេចរបស់អ្នករាល់គ្នាហើយ។ ទ្រង់គឺជាអ្នកមើលថែរក្សាពួកអ្នករាល់គ្នា បានល្អប្រសើរបំផុត»។

តែពួកគេនិយាយថា៖ «យើងចង់បានស្តេចពិតប្រាកដ! គឺមួយអង្គដែលយើងអាចមើលឃើញ!»។ ព្រះជាម្ចាស់បានជ្រាបថា ស្តេចនេះប្រហែលជាពុំមានចិត្តល្អបរិសុទ្ធចំពោះរាស្ត្រទ្រង់ ឬអាចនឹងមើលថែរក្សាពួកគេឲ្យបានល្អដូចជាព្រះអង្គឡើយ។ ក៏ប៉ុន្តែ ពួករាស្ត្ររបស់ព្រះជាម្ចាស់គេមិនខ្វល់ឡើយ ពួកគេចង់បានស្តេចមួយអង្គ គឺពួកគេចង់បានស្តេចភ្លាមៗនោះ!

ដូច្នេះ ព្រះជាម្ចាស់បានប្រទានស្តេចមួយអង្គឲ្យពួកគេ។ ឈ្មោះរបស់គាត់គឺស្តេច សូល ហើយពីដំបូងគាត់ហាក់ដូចជាស្តេចដ៏ល្អមួយអង្គណាស់។ ប៉ុន្តែ ក្រោយមកគាត់បានក្លាយជាមនុស្សមានអំនួត ហើយក៏ឈប់ស្តាប់តាមព្រះជាម្ចាស់។ គាត់មិនធ្វើតាមបង្គាប់ព្រះជាម្ចាស់ ក៏មិនស្រឡាញ់ព្រះជាម្ចាស់ឲ្យអស់ពីដួងចិត្តរបស់គាត់ឡើយ។

ព្រះជាម្ចាស់បានមានបន្ទូលឡើងថា៖ «សូលមិនអាចជួយដល់ផែនការរបស់យើងបានទេ»។



«យើងត្រូវការស្តេចមួយអង្គដែលស្រឡាញ់យើង ហើយបង្រៀនរាស្ត្រយើងឲ្យស្រឡាញ់យើងដែរ យើងត្រូវការស្តេចមួយពិតប្រាកដ។» ព្រះជាម្ចាស់មានម្នាក់នៅក្នុងចិត្តរបស់ព្រះអង្គ។

ព្រះជាម្ចាស់ប្រាប់ទៅហោរា សាំយូអែល៖ «ចូរចេញទៅឯភូមិបេថ្លេហិម។ ឯងនឹងឃើញស្តេចថ្មីមួយអង្គនៅទីនោះ» (មុខងាររបស់សាំយូអែល គឺស្តាប់តាមព្រះជាម្ចាស់ ហើយប្រាប់រាស្ត្រទ្រង់នូវអ្វីដែលព្រះជាម្ចាស់មានបន្ទូលមក)។



ដូច្នេះ ហោរា សាំយូអែល ក៏ចេញទៅភូមិបេថ្លេហិម។ ព្រះជាម្ចាស់មានបន្ទូលប្រាប់ហោរា សាំយូអែល ឲ្យទៅឯផ្ទះរបស់លោក អ៊ីសាយ ពីព្រោះព្រះជាម្ចាស់នឹងរើសកូនរបស់លោក អ៊ីសាយ ម្នាក់ឲ្យធ្វើជាស្ដេចថ្មី។

លោក អ៊ីសាយ មានកូនប្រុសដ៏ខ្លាំង៧នាក់។

ហើយនៅជំនាន់នោះ បើអ្នកត្រូវធ្វើជាស្ដេច អ្នកមិនចាំបាច់ជាអ្នកមានជាងគេបំផុត ឬក៏ជាមនុស្សឈ្លាសវៃបំផុតនោះទេ (ប៉ុន្តែ បើមានការទាំងនេះក៏ប្រសើរដែរ)។ អ្នកគ្រាន់តែត្រូវតែមានរាងមើលទៅដូចជាស្ដេចតែប៉ុណ្ណោះ មានន័យថា អ្នកត្រូវមានកម្ពស់ខ្ពស់ជាងគេ និងខ្លាំងជាងគេ (ដើម្បីឲ្យអ្នកអាចកាន់ដាវវែងជាងគេ នឹងគ្រឿងសឹកដ៏ធំជាងគេ ហើយយកឈ្នះគេគ្រប់គ្នាបាន)។ ហើយវាក៏មិនទាស់ខុសអ្វីដែរ ប្រសិនជាអ្នកមានរូបរាងសង្ហានោះ។

ហោរា សាំយូអែល បានសុំឲ្យលោក អ៊ីសាយ នាំកូនចេញមកជួបគាត់ម្នាក់ម្ដងៗ។ ដូច្នេះលោក អ៊ីសាយ បាននាំកូនច្បង ដែលមានកម្ពស់ខ្ពស់ជាងគេ និងខ្លាំងជាងគេមក។ ហោរា សាំយូអែល បានគិតក្នុងចិត្តថា ម្នាក់នេះប្រហែលជាស្ដេចថ្មីហើយ ព្រោះមើលទៅគាត់ដូចជាស្ដេចមែន។

ប៉ុន្តែ ព្រះជាម្ចាស់មិនបានជ្រើសរើសម្នាក់នេះទេ ព្រះជាម្ចាស់មានបន្ទូលទៅហោរា សាំយូអែល ថា៖ «ឯងគិតតែអំពីអ្វីដែលនៅខាងក្រៅ ប៉ុន្តែយើងមើលទៅក្នុងចិត្ត គឺជាអ្វីដែលមាននៅខាងក្នុងចិត្តវិញ»។

ដូច្នេះលោក អ៊ីសាយ ក៏បង្ហាញកូនប្រុសបន្ទាប់ដល់ហោរា សាំយូអែល ដែលខ្ពស់ហើយក៏ខ្លាំងដែរ។ ប៉ុន្តែ ព្រះជាម្ចាស់ក៏មិនបានជ្រើសរើសអ្នកនេះដែរ ហើយតាមការពិតទៅ ព្រះជាម្ចាស់មិនបានជ្រើសរើសអ្នកណាម្នាក់ក្នុងចំណោមកូនប្រុសទាំងប្រាំពីរនាក់នោះទេ។

ហោរា សាំយូអែល និយាយឡើងថា៖ «លោកមានកូនតែប៉ុណ្ណោះទេឬ?»។

លោក អ៊ីសាយ អស់សំណើច «អូរ បាទ នៅមានមួយទៀតជាកូនពៅ ប៉ុន្តែគាត់ជាកូនទន់ខ្សោយជាងគេនៅក្នុងគ្រួសារនេះ ហើយគាត់មានរាងតូចល្អិតផង»។

ហោរា សាំយូអែល បញ្ជាថា៖ «ទៅហៅគាត់មក»។





កូនពៅរបស់លោក អ៊ីសាយ បានរត់ចូលមក ព្រះជាម្ចាស់មានបន្ទូលប្រាប់ហោរា សាំយូអែល ដោយស្ងៀមស្ងាត់ថា៖ «គឺម្នាក់នេះហើយ!»។

គាត់ឈ្មោះ ដាវីឌ។

ព្រះជាម្ចាស់បានមានបន្ទូលថា៖ «គាត់មានចិត្តដូចជាយើងដែរ ជាចិត្តដែលពោរពេញទៅដោយសេចក្ដីស្រឡាញ់ គាត់អាចនឹងជួយផែនការសម្ងាត់នៃសេចក្ដីសង្គ្រោះរបស់យើង។ ចៅលួតរបស់គាត់នឹងក្លាយទៅជាស្ដេច ហើយស្ដេចនោះនឹងគ្រប់គ្រងលោកីយ៍ជារៀងរហូតតទៅ»។

ហោរា សាំយូអែល បានចាក់ប្រេងតាំងលើក្បាលកុមារា ដាវីឌ គឺជាវិធីមួយដ៏វិសេស ដើម្បីបង្ហាញឲ្យដឹងថា ព្រះជាម្ចាស់បានជ្រើសតាំងគាត់ជា ស្ដេច ហើយហោរា សាំយូអែល ប្រាប់គាត់ថា៖ «ឯងនឹងបានធ្វើជាស្ដេចថ្មីនៅថ្ងៃណាមួយ»។

ហើយនេះជាការពិតមែន នៅពេលដែលគាត់បានចម្រើនវ័យធំឡើងលោក ដាវីឌ ក៏បានធ្វើជាស្ដេចមែន។

ព្រះជាម្ចាស់បានជ្រើសរើសដាវីឌឲ្យធ្វើជាស្ដេច ពីព្រោះទ្រង់កំពុងរៀបចំរាស្ដ្រទ្រង់ឲ្យត្រៀមខ្លួនជាស្រេច សម្រាប់ទទួលស្ដេចដ៏អស្ចារ្យមួយអង្គទៀត ដែលនឹងយាងមក។

ម្ដងទៀត ព្រះជាម្ចាស់មានបន្ទូលថា៖ «ទៅឯភូមិបេថ្លេហិម ឯងនឹងបានឃើញស្ដេចថ្មីមួយអង្គនៅទីនោះ» គឺនៅទីនោះហើយ ដែលមានផ្កាយដ៏រុងរឿងអស្ចារ្យមួយ។ ផ្កាយនោះនឹងរះឡើងនៅភូមិបេថ្លេហិម គឺជាទីក្រុងរបស់ស្ដេច ដាវីឌ។ អ្នកប្រាជ្ញបីនាក់នឹងរកទ្រង់ឃើញនៅទីនោះ។

# វីរបុរសវ័យក្មេង និងយក្សដ៏យង់ឃ្នង

លោក ដាវីឌ និងលោក កូលីយ៉ាត (ដកស្រង់ចេញពីកណ្ឌ ១សាំយូអែល ១៧)



**ពួករាស្ត្រ**របស់ព្រះជាម្ចាស់មានសត្រូវខ្លះគួរឲ្យខ្លាច ប៉ុន្តែពួកភីលីស្ទីនជាសត្រូវដែលគួរឲ្យខ្លាចជាងគេបំផុត។ ហើយឥឡូវនេះពួកភីលីស្ទីនបានចេញមកច្បាំងជាមួយពួកគេ។

ពួកភីលីស្ទីនមានអាវុធសម្ងាត់មួយដែលមានឈ្មោះថា «កូលីយ៉ាត»។ លោក កូលីយ៉ាត ជាទាហានដែលគួរឲ្យស្ញែងខ្លាច ហើយនិងគួរឲ្យខ្លាចជាងនោះទៅទៀត គឺគាត់មានមាឌធំដូចជាយក្ស! គឺជាយក្សដ៏ខ្លាំង ខ្ពស់មែនទែន គួរឲ្យខ្លាច ហើយមិនទាន់មាននរណាម្នាក់អាចតតាំងនឹងគាត់បានទេ។

ដូច្នេះ ពួកភីលីស្ទីនបានឈរនៅលើកំពូលភ្នំមួយ ហើយរាស្ត្ររបស់ព្រះជាម្ចាស់បានឈរនៅលើកំពូលភ្នំមួយទៀត។ ជារៀងរាល់ថ្ងៃ លោក កូលីយ៉ាត បានចេញមក ហើយស្រែកសម្លុតដាក់រាស្ត្ររបស់ព្រះជាម្ចាស់ថា៖ «បញ្ជូនទាហានដ៏ពូកែបំផុតរបស់ឯងមកច្បាំងជាមួយអញ! បើវាឈ្នះ យើងនឹងធ្វើជាឈ្មួលបម្រើដាច់ថ្លៃរបស់ពួកឯង ប៉ុន្តែបើអញឈ្នះនោះ ពួកឯងនឹងធ្វើជាឈ្មួលបម្រើដាច់ថ្លៃរបស់យើងវិញ!»។ គ្មាននរណាម្នាក់ហ៊ានហាមាត់ឆ្លើយ ហើយក៏គ្មាននរណាម្នាក់ហ៊ានកម្រើកខ្លួនផង។



«កំសាកមែន!» លោក កូលីយ៉ាត ស្រែករំពងឡើង «ព្រះពួកឯងមិនអាចជួយពួកឯងបានទេ! អញនឹងកាត់ក្បាលពួកឯងចេញ ហើយនឹងដោតលើកឡើង!» ពុកមាត់ និងភ្នែកក្រឡោតរបស់គាត់អាក្រក់ខ្លាំងណាស់។ គាត់សម្លឹងទៅរាស្ត្ររបស់ព្រះជាម្ចាស់ ហាក់ដូចជាចង់ត្របាក់ហែកស៊ីពួកគេទាំងរស់។ គាត់សើចយ៉ាងខ្លាំងគួរឲ្យរន្ធត់ «ហា-ហា-ហា-ហា!» ខ្ទរលាន់រំពងជុំវិញជ្រលងភ្នំដ៏ស្ងាត់នោះ។



ប្រហែលជាលោក កូលីយ៉ាត មានរូបរាងហាក់ដូចជាបិសាចមានក្បាលបី ពីព្រោះរាស្ត្ររបស់ព្រះជាម្ចាស់បានត្រឡប់ជាគាំងរឹងដូចគល់ឈើ ដោយព្រោះមានការភ័យខ្លាចជាខ្លាំង។ ភ្នែករបស់ពួកគេស្រអាប់ ហើយស្លេកស្លាំងដូចជាមនុស្សស្លាប់។ ពួកគេដឹងថា គ្មាននរណាហ៊ានធ្វើអ្វី ឬចេញមកជួយពួកគេទេ។

ប៉ុន្តែ ព្រះជាម្ចាស់នឹងធ្វើអ្វីមួយ គឺទ្រង់នឹងបញ្ជូនមនុស្សម្នាក់មកជួយពួកគេ។

តើអ្នកចាំពីលោក ដាវីឌ ជាកូនពៅរបស់អ៊ីសាយឬទេ? បងប្រុសរបស់គាត់ជាទាហាននៅក្នុងជួរកងទ័ព។ នៅថ្ងៃមួយលោក ដាវីឌ បានយកអាហារថ្ងៃត្រង់មកឲ្យបងៗរបស់គាត់ញ៉ាំ គាត់បានឃើញលោក កូលីយ៉ាត ហើយគាត់បានឃើញគេគ្រប់គ្នាមានការភ័យខ្លាចជាខ្លាំង។

លោក ដាវីឌ បានប្រាប់ពួកគេថា៖ «កុំខ្លាចអី ខ្ញុំនឹងច្បាំងជាមួយវា ជំនួសអ្នករាល់គ្នា!»។

ស្តេចមានបន្ទូលឡើងថា៖ «ឯងគ្រាន់តែជាក្មេងប្រុសឃ្វាលចៀមម្នាក់ប៉ុណ្ណោះ ហើយកូលីយ៉ាតគឺជាទាហានដ៏ពូកែ តើឯងច្បាំងជាមួយវាដូចម្តេចទៅ?»។

លោក ដាវីឌ ឆ្លើយតបថា៖ «ព្រះជាម្ចាស់នឹងជួយខ្ញុំ»។

ដូច្នេះ ស្តេចទ្រង់ប្រទានគ្រឿងសឹករបស់ទ្រង់ សម្រាប់ឲ្យលោក ដាវីឌ ពាក់ការពារខ្លួន ប៉ុន្តែគ្រឿងសឹកនោះធ្ងន់ ហើយធំពេក ដូច្នេះលោក ដាវីឌ មិនអាចទាំងដើររួចបានទេ។ លោក ដាវីឌ និយាយថា៖ «ខ្ញុំមិនត្រូវការគ្រឿងសឹកនេះទេ»។

លោក ដាវីឌ បែរជារើសគ្រាប់ក្រួសរលោងប្រាំដុំក្នុងអូរទៅវិញ—មួយ ពីរ បី បួន ប្រាំ—គាត់ក៏បានយកខ្សែដង្ហក់របស់គាត់មក រួចដើរតម្រង់ទៅលោក កូលីយ៉ាត។

មួយជំហាន ពីរជំហាន បីជំហាន...





លោក កូលីយ៉ាត ដើរសំដៅមករកលោក ដាវីឌ ឮសូរ តុប តុប តុប... «ឯងឬ?» កូលីយ៉ាតខំឱនសម្លឹងមើលក្មេងតូច។

លោក ដាវីឌ ស្រែកទៅលោក កូលីយ៉ាត វិញថា៖ «ខ្ញុំតូចមែន! ប៉ុន្តែ ព្រះជាម្ចាស់របស់ខ្ញុំធំអស្ចារ្យណាស់!»។

លោក កូលីយ៉ាត សើចគួរឲ្យខ្លាចខុសពីធម្មតា «ហាស...ហា-ហា-ហា!» សើចហើយសើចទៀត។

លោក កូលីយ៉ាត គ្រាន់តែហូតដាវដ៏ធំ នោះអាចនឹងបញ្ចប់ជីវិតរបស់ក្មេងនេះបាន។

ប៉ុន្តែលោក ដាវីឌ នៅតែបន្តសម្ដីទៀតថា៖ «វាមិនមែនមកពីឯងខ្លាំងប៉ុណ្ណា ឬមានដាវ និងលំពែងច្រើនយ៉ាងណា ក៏មិនអាចនឹងជួយឯងបាននោះទេ ពីព្រោះព្រះជាម្ចាស់ជាអ្នកជួយយើង! នេះជាសង្គ្រាមរបស់ព្រះជាម្ចាស់ ហើយព្រះជាម្ចាស់តែងតែឈ្នះសង្គ្រាមរបស់ទ្រង់ជានិច្ច!»។

លោក ដាវីឌ បានដាក់ដុំថ្មក្នុងខ្សែដង្ហក់របស់គាត់ គ្រវី១ជុំ ហើយក៏ប្រលែងឲ្យទៅ។ ដុំថ្មមួយដុំដ៏តូចនេះ បានហោះយ៉ាងលឿនដូចជាគ្រាប់កាំភ្លើងកាត់ខ្យល់ឮសូរស្អុយទៅបុកក្បាលលោក កូលីយ៉ាត ឮសូរភូស ចំកណ្ដាលថ្ងាសចន្លោះភ្នែកទាំងពីររបស់គាត់។ លោក កូលីយ៉ាត ឈប់សើចស្ងៀម...

គាត់ភ្លាត់ជើង...ទ្រេតទ្រោត...រួចក៏ដួលគ្រឹបស្លាប់តែម្តងទៅ។

នៅពេលពួកភីលីស្ទីនឃើញលោក កូលីយ៉ាត បានស្លាប់ហើយ ពួកគេបាននាំគ្នារត់បាត់ទៅ។ ហើយនៅពេលពួករាស្ត្ររបស់ព្រះជាម្ចាស់បានឃើញគេរត់អស់ទៅ នោះពួកគេបានស្រែកហ៊ោកញ្ជ្រៀវ។ ព្រះជាម្ចាស់បានជួយរាស្ត្ររបស់ទ្រង់ ហើយលោក ដាវីឌ ក៏បានក្លាយជាវីរបុរស!

ជាច្រើនឆ្នាំក្រោយមក ព្រះជាម្ចាស់បានបញ្ជូនវីរបុរសម្នាក់ទៀតដល់រាស្ត្ររបស់ព្រះអង្គ ដើម្បីធ្វើសង្គ្រាមជំនួសគេ ហើយនិងជួយសង្គ្រោះពួកគេ។

ប៉ុន្តែ វីរបុរសអ្នកខ្លាំងពូកែនេះ នឹងច្បាំងសង្គ្រាមដ៏ធំបំផុត ដែលពិភពលោកនេះមិនដែលជួបប្រទះសោះ។



# អ្នកគង្វាលដ៏ល្អ

លោក ដាវីឌ ជាអ្នកគង្វាលដែលត្រឡប់ធ្វើជាស្ដេច

(ដកស្រង់ចេញពីកណ្ឌ ទំនុកតម្កើង ៥១; ២សាំយូអែល ៧; ទំនុកតម្កើង ៥១ បានប្រើពាក្យផ្សេងតែមាន នំយដូចក្នុងកណ្ឌ ទំនុកតម្កើង ២៣)

**លោក ដាវីឌ** ជាអ្នកគង្វាលចៀម ក៏ប៉ុន្តែនៅពេលដែលព្រះជាម្ចាស់សម្លឹងមើលទៅគាត់ ព្រះអង្គបានឃើញថាគាត់ជាស្ដេច។

ប្រាកដណាស់ នៅពេលដែលដាវីឌបានចម្រើនវ័យធំឡើង គាត់ក៏បានក្លាយជាស្ដេចមែន ហើយលោក ដាវីឌ ជាស្ដេចដ៏ល្អណាស់ គាត់មានទឹកចិត្តដូចជាព្រះជាម្ចាស់ដែរ គឺពោរពេញទៅដោយសេចក្ដីស្រឡាញ់។

នេះមិនមែនមានន័យថា គាត់ល្អឥតខ្ចោះនោះទេ ពីព្រោះគាត់បានប្រព្រឹត្តិការណ៍អាក្រក់ខ្លះដែរ រហូតដល់បានសម្លាប់បុរសម្នាក់ផង។ ប្រាកដណាស់ស្ដេច ដាវីឌ បានធ្វើឲ្យជីវិតគាត់មានការច្របូកច្របល់ដ៏ធំមួយ ប៉ុន្តែ ព្រះជាម្ចាស់អាចទទួលយកជីវិតដ៏ច្របូកច្របល់ធំជាងនេះ ហើយប្តូរឲ្យបានល្អទៅតាមផែនការរបស់ព្រះអង្គវិញ។

ស្ដេច ដាវីឌ អធិស្ឋានថា៖ «ទូលបង្គំត្រូវការចិត្តថ្មី ព្រះអម្ចាស់អើយ ពីព្រោះចិត្តរបស់ទូលបង្គំពោរពេញទៅដោយអំពើបាប សូមសម្អាតទូលបង្គំឲ្យបានស្អាតពីខាងក្នុងមក»។

ព្រះជាម្ចាស់បានឮសេចក្ដីអធិស្ឋានរបស់ស្ដេច ដាវីឌ ព្រះអង្គបានអត់ទោសឲ្យគាត់ ហើយទ្រង់បានសន្យាជាមួយស្ដេច ដាវីឌ ថា៖ «ឱ! ដាវីឌ! យើងនឹងធ្វើឲ្យឯងបានធំអស្ចារ្យឡើង ហើយនៅថ្ងៃមួយ នឹងមានស្ដេចមួយអង្គ មកកើតក្នុងគ្រួសាររបស់ឯង ហើយព្រះអង្គនោះ ទ្រង់នឹងធ្វើឲ្យលោកីយ៍នេះបានជាសះស្បើយ»។

តើអ្នកបានដឹងទេថាស្ដេច ដាវីឌ ក៏ជាអ្នកតែងបទចម្រៀងផងដែរ? តាមការពិតទៅ ចម្រៀងរបស់ទ្រង់ពីរោះណាស់ ហើយ (ប្រសិនបើគេបានបង្កើតបញ្ជីបទចម្រៀងក្នុងសម័យនោះ) ចម្រៀងរបស់ទ្រង់អាចស្ថិតក្នុងលំដាប់៤០បទដំបូងនៃបញ្ជីបទចម្រៀងនោះ។



បទចម្រៀងរបស់ស្ដេច ដាវីឌ គឺជាបទចម្រៀងបែបអធិស្ឋាន បទទាំងនេះមានឈ្មោះថាទំនុកតម្កើង ហើយនិងបទមួយនេះទៀតឈ្មោះថា ចម្រៀងនៃអ្នកគង្វាល (បទនេះប្រហែលជាលេខ១ នៅក្នុងចំណោមតារាងបទ ទំនុកតម្កើង ហើយច្រៀងដូចតទៅនេះ...



ព្រះអម្ចាស់ជាអ្នកគង្វាលខ្ញុំ
ហើយខ្ញុំជាកូនចៀមតូចមួយរបស់ព្រះអង្គ។

ព្រះអង្គបានចិញ្ចឹមខ្ញុំ
ព្រះអង្គបានដឹកនាំខ្ញុំ
ព្រះអង្គទ្រង់បានការពារខ្ញុំ
ខ្ញុំមានគ្រប់ទាំងអ្វីដែលខ្ញុំត្រូវការ។

នៅខាងក្នុង ខ្ញុំមានចិត្តស្ងប់
ស្ងប់ស្ងាត់ដូចខ្ញុំបានដេកស្ងៀម នៅលើវាលស្មៅខៀវខ្ចីដស្រទន់
នៅទីវាលទំនាប
ក្បែរខ្សែទឹកដែលហូរគ្រើនៗ



ទោះបីខ្ញុំត្រូវដើរឆ្លងកាត់
ទីងងឹតដ៏គួរឲ្យខ្លាច កន្លែងដ៏ស្ងាត់តែម្នាក់ឯង
ក៏ខ្ញុំនឹងមិនខ្លាចដែរ
ពីព្រោះអ្នកគង្វាលខ្ញុំ ដឹងថា ខ្ញុំនៅទីណា។

ព្រះអង្គទ្រង់គង់នៅទីនេះជាមួយខ្ញុំ
ព្រះអង្គការពារខ្ញុំ ឲ្យមានសេចក្តីសុខសាន្ត
ព្រះអង្គជួយសង្គ្រោះខ្ញុំ

ព្រះអង្គផ្តល់កម្លាំង
និងសេចក្តីក្លាហានដល់ខ្ញុំ។





ព្រះអង្គទ្រង់បានរៀបចំរបស់ដ៏អស្ចារ្យ
ជាពិសេស សម្រាប់ខ្ញុំ
អ្វីគ្រប់យ៉ាងដែលខ្ញុំមិនធ្លាប់ស្រមៃ!

ព្រះអង្គបំពេញចិត្តរបស់ខ្ញុំពេញដោយភាពរីករាយ
ខ្ញុំមិនអាចផ្ទុកទាំងអស់នៅខាងក្នុងចិត្តបានទេ។

គ្រប់ទីកន្លែងដែលខ្ញុំទៅ ខ្ញុំដឹងថា
ព្រះនៅតែស្រឡាញ់កូនទ្រង់
គ្មានទីបញ្ចប់
មិនអាចបោះបង់បាន
មិនអាចបំបែកចេញបានដែរ
ជាសេចក្តីស្រឡាញ់ដ៏អស់កល្បជានិច្ច
ជាក្តីស្រឡាញ់ដែលនឹងទៅជាមួយរហូត!



ព្រះជាម្ចាស់បានប្រទានបទចម្រៀងនេះដល់ស្តេច ដាវីឌ សម្រាប់ច្រៀងដល់រាស្ត្រទ្រង់ ដើម្បីឲ្យពួកគេបានដឹងថា ព្រះជាម្ចាស់បានស្រឡាញ់ពួកគេ ហើយទ្រង់នឹងមើលថែរក្សាពួកគេជានិច្ច ដូចជាអ្នកគង្វាលដែលស្រឡាញ់ហ្វូងចៀមរបស់ខ្លួនដែរ។

ហើយនៅថ្ងៃមួយ ព្រះជាម្ចាស់នឹងធ្វើការអ្វីមួយដែលនឹងបំផុសបទចម្រៀងថ្មីឡើងទាំងពាន់ៗបទ។ ព្រះជាម្ចាស់នឹងបង្ហាញដល់រាស្ត្ររបស់ព្រះអង្គ ឲ្យគេដឹងថា ព្រះអង្គស្រឡាញ់ពួកគេប៉ុណ្ណា។

មានអ្នកគង្វាលមួយទៀតនឹងលេចមក គឺជាអ្នកគង្វាលម្នាក់ដ៏ឆ្នើម គេនឹងហៅទ្រង់ថាជាអ្នកគង្វាលដ៏ល្អណាស់ ហើយអ្នកគង្វាលនេះនឹងដឹកនាំចៀមរបស់ព្រះត្រឡប់ទៅកន្លែងដែលពួកគេធ្លាប់នៅ គឺនៅជិតដើមទ្រូងរបស់ព្រះជាម្ចាស់។





# ក្មេងស្រីបម្រើម្នាក់ និងមេទ័ពដ៏ក្រអឺតក្រទម

ក្មេងស្រីបម្រើដាច់ថ្លៃម្នាក់ និងលោក ណាម៉ាន់ (ដកស្រង់ចេញពីកណ្ឌ ២ពង្សាវតារ ៥)

**លោក ណាម៉ាន់** ជាមនុស្សម្នាក់ នៅក្នុងជួរទ័ពដ៏សំខាន់បំផុតនៃប្រទេសមួយ។ ដូច្នេះ អ្នកឃើញហើយថា គាត់ជាមនុស្សដ៏សំខាន់ សំខាន់ សំខាន់បំផុត។

ប៉ុន្តែលោក ណាម៉ាន់ មានជំងឺមួយ គាត់កើតជំងឺឃ្លង់ គឺជារោគអាក្រក់ណាស់ កាលណាវាកើតលើខ្លួនអ្នកណាហើយ អ្នកនោះនឹងរលាយបាត់អារម្មណ៍លើរាងកាយទាំងអស់។ សាច់នឹងរលួយស្អុយដាច់ចេញពីខ្លួន ដោយមិនដឹងខ្លួន ដូចជាដាច់ម្រាមដៃ និងម្រាមជើង។ ស្តាប់ទៅគួរឲ្យអស់សំណើច ប៉ុន្តែវាមិនគួរឲ្យអស់សំណើចទេ ហើយចំពោះលោក ណាម៉ាន់ វិញ នេះមិនមែនជារឿងដែលត្រូវសើចឡើយ។ គ្មានអ្វីព្យាបាលសោះ គ្មានផ្លូវជាបានទេ ហើយនៅទីបញ្ចប់ជំងឺឃ្លង់នឹងសម្លាប់គាត់។ ឥឡូវលោក ណាម៉ាន់ ត្រូវការជំនួយ។

នៅគ្រានោះ មានក្មេងស្រីជាឈ្នួលដាច់ថ្លៃម្នាក់នៅធ្វើការឲ្យលោក ណាម៉ាន់ នាងបានស្គាល់មនុស្សម្នាក់ដែលអាចជួយគាត់បាន ប៉ុន្តែមានបញ្ហាមួយគឺថាលោក ណាម៉ាន់ ជាសត្រូវរបស់នាង។

មិនយូរប៉ុន្មានមុននេះលោក ណាម៉ាន់ បានដឹកនាំកងទ័ពទៅវាយឆ្មក់ផ្ទះរបស់នាង នៅក្នុងប្រទេសអ៊ីស្រាអែល។ គាត់បានសម្លាប់ក្រុមគ្រួសារនាងទាំងមូល ចាប់យកនាងមកប្រទេសស៊ីរី ហើយបង្ខំនាងឲ្យធ្វើជាឈ្នួលដាច់ថ្លៃរបស់គាត់។ រាល់យប់ នាងតែងតែយំម្នាក់ឯង រហូតដល់គេងលក់ទៅ នាងបានបាត់បង់គ្រប់សព្វទាំងអស់។

ហេតុអ្វីបានជានាងចាំបាច់ជួយលោក ណាម៉ាន់? តើនាងមិនបានស្អប់គាត់ ឬក៏ចង់ឃើញគាត់មានការឈឺចាប់ទេឬអី? តើនាងមិនចង់ឲ្យគាត់សងនូវកំហុស ដែលគាត់បានប្រព្រឹត្តទេឬអី?

នេះគឺជាការដែលអ្នកគិតឃើញ ប៉ុន្តែជំនួសការស្អប់គាត់ នាងបែរជាបានស្រឡាញ់គាត់វិញ ជំនួសការចង់ឃើញគាត់ឈឺចាប់ នាងបានអត់ទោសឲ្យគាត់វិញ។





នាងបាននិយាយទៅកាន់ចៅហ្វាយស្រីនាងថា៖ «ខ្ញុំចង់ឲ្យលោក ណាម៉ាន់ បានជាវិញ! មានមនុស្សម្នាក់នៅស្រុកអ៊ីស្រាអែលឈ្មោះហោរា អេលីសេ គាត់អាចមើលលោកឲ្យជាបាន»។

លោក ណាម៉ាន់ និយាយតបថា៖ «យើងនឹងចេញទៅ» រួចក៏រៀបរទេះ ហើយស្ទៀកពាក់ខោអាវចម្បាំងចេញទៅ «ប៉ុន្តែយើងនឹងទៅឯវាំងស្តេច ជាកន្លែងដែលអាចនឹងព្យាបាលមនុស្សសំខាន់ដូចយើង!»។

ដូច្នេះ គាត់ក៏បានចេញដំណើរយ៉ាងលឿន ទៅស្រុកអ៊ីស្រាអែល តម្រង់ទៅរកស្តេចស្រុកនោះ ហើយគាត់ក៏ស្រែកឡើងថា៖ «ចូរព្យាបាលជំងឺខ្ញុំឥឡូវនេះ!»។

ស្តេចបានតបថា៖ «យើងអាចធ្វើការបានច្រើនយ៉ាង ប៉ុន្តែមានតែព្រះជាម្ចាស់មួយប៉ុណ្ណោះដែលអាចមើលជំងឺលោកឲ្យជាបាន»។

ភ្លាមនោះ សំបុត្រពីហោរា អេលីសេ ក៏បានមកដល់ ហើយសំបុត្រនោះបានប្រាប់ថា៖ «សូមបញ្ជូនលោក ណាម៉ាន់ មកនេះ»។

ដូច្នេះ លោក ណាម៉ាន់ ក៏ប្រញាប់ធ្វើដំណើរទៅផ្ទះរបស់ហោរា អេលីសេ ប៉ុន្តែហោរា អេលីសេ មិនបានចេញមកទទួលគាត់ទេ គាត់បានចាត់ឲ្យអ្នកបម្រើម្នាក់ទៅទទួលគាត់ជំនួសវិញ។ លោក ណាម៉ាន់ បានគិតក្នុងចិត្តថា តើហោរា អេលីសេ ស្គាល់ថាយើងជានរណាដែរឬទេ?





ប៉ុន្តែ អ្វីដែលអ្នកបម្រើបាននិយាយ ធ្វើឲ្យគាត់មានការភាន់ច្រឡំខ្លាំងមែនទែន។ អ្នកបម្រើប្រាប់ថា៖ «ចុះមុជទឹកនៅទីនោះ នោះលោកនឹងបានជាហើយ»។

លោក ណាម៉ាន់ អស់សំណើច «គ្រាន់តែមុជទឹកសម្អាត ក្នុងទឹកទន្លេពេញដោយទឹកអន្ទិលកខ្វក់ស្អុយដូច្នេះឬ?» គាត់បានមើលជុំវិញ ក្រែងលោការនេះគ្រាន់តែជាការលេងសើចនឹងគាត់តែប៉ុណ្ណោះ។ ប៉ុន្តែ មិនមែនជាការលេងសើចទេ គាត់បានគិតក្នុងចិត្តថា អ្នកណាក៏អាចសម្អាតខ្លួនក្នុងទន្លេបានដែរ យើងជាណាម៉ាន់ យើងជាមនុស្សសំខាន់។ យើងត្រូវតែធ្វើការអ្វីមួយសំខាន់ ដើម្បីឲ្យព្រះជាម្ចាស់ជួយប្រោសជំងឺយើងឲ្យជា! ហើយគាត់ក៏ជិះសេះចេញទៅទាំងពេញដោយកំហឹង។ (ប្រាកដណាស់ អ្នកនិងខ្ញុំ យើងទាំងពីរនាក់បានដឹងថា នេះមិនមែនជារបៀបដែលព្រះជាម្ចាស់ធ្វើនោះទេ អ្វីដែលលោក ណាម៉ាន់ ត្រូវការគឺការគ្មានអ្វីសោះ នោះហើយគឺជាអ្វីដែលគាត់មិនមាន។)

ព្រះជាម្ចាស់បានជ្រាបថាលោក ណាម៉ាន់ មានជំងឺផ្នែកខាងក្នុង ជាជាងជំងឺដែលមានបង្ហាញនៅខាងក្រៅ។ លោក ណាម៉ាន់ មានចិត្តក្រអឺតក្រទម គាត់បានគិតថា គាត់មិនត្រូវការព្រះជាម្ចាស់ទេ។ គាត់មិនមានចិត្តត្រឹមត្រូវ មើលទៅស្ពឹក ដោយគ្មានអារម្មណ៍លើអ្វីទាំងអស់។ អ្នកឃើញទេថា លោក ណាម៉ាន់ មានជំងឺឃ្លង់នៅក្នុងចិត្តរបស់គាត់ ព្រះជាម្ចាស់មិនត្រឹមតែនឹងប្រោសឲ្យស្បែកលោក ណាម៉ាន់ បានជាប៉ុណ្ណោះទេ ប៉ុន្តែ ទ្រង់នឹងប្រោសចិត្តដ៏ក្រអឺតក្រទមរបស់គាត់ឲ្យបានជាផងដែរ។



នៅទីបំផុតលោក ណាម៉ាន់ បានយល់ព្រមចុះមុជទឹកសម្អាតនៅក្នុងទន្លេ ហើយមួយរំពេចនោះស្បែកគាត់ក៏បានរលោងដូចស្បែកកូនក្មេង។

លោក ណាម៉ាន់ ចង់បង់ថ្លៃឈ្នួលដល់ហោរា អេលីសេ។

ហោរា អេលីសេ បាននិយាយថា៖ «ព្រះជាម្ចាស់បានប្រោសអ្នកឲ្យជា អ្នកមិនបាច់បង់ថ្លៃទេ គឺជាការឥតគិតថ្លៃ»។

ដូច្នេះ បុរសម្នាក់នេះដែលឈឺយ៉ាងខ្លាំងត្រូវបានប្រោសឲ្យជា ការនេះគឺដោយសារតែក្មេងស្រីជាអ្នកបម្រើម្នាក់បានអត់ទោសឲ្យគាត់ដែរ។

ព្រះជាម្ចាស់ជ្រាបថា អំពើបាបប្រៀបដូចជាជំងឺឃ្លង់អញ្ចឹង វាបានបង្ខាំងចិត្តរបស់កូនព្រះជាម្ចាស់មិនឲ្យដើរតាមផ្លូវត្រូវ ហើយនៅទីបញ្ចប់ វានឹងបំផ្លាញជីវិតរបស់ពួកគេទៀតផង។ ច្រើនឆ្នាំក្រោយមក ព្រះជាម្ចាស់នឹងចាត់អ្នកបម្រើមួយទៀត ឲ្យអត់ទោសដូចជាក្មេងស្រីនេះបានធ្វើដែរ គឺអត់ទោសដល់កូនព្រះអង្គទាំងអស់ ហើយនឹងផ្សះជំងឺដ៏គួរឲ្យខ្លាចនៅក្នុងចិត្តគេរាល់គ្នាចេញទៅ។

ចិត្តរបស់ពួកគេត្រូវបានខ្ទេចខ្ទាំ។

ប៉ុន្តែ ព្រះជាម្ចាស់អាចនឹងព្យាបាលចិត្តដែលខ្ទេចខ្ទាំឲ្យបានល្អឡើងវិញ។



# ប្រតិបត្តិការ «គ្មានទឹកភ្នែកទៀតទេ!»

អ្នកជួយសង្គ្រោះនឹងមក (ទំនាយដកស្រង់ចេញពីកណ្ឌ អេសាយ ៩; ១១; ៤០; ៥០; ៥៣; ៥៥ និង៦០)




**តើអ្នកដឹងទេថា** ឈ្មោះរបស់អ្នកមានន័យដូចម្តេច? តាមពិតទៅ នាពេលនោះ មានបុរសម្នាក់ឈ្មោះហោរា អេសាយ ហើយឈ្មោះគាត់មានន័យថា «ព្រះជាម្ចាស់យាងមកដើម្បីសង្គ្រោះ!»។

ប្រហែលជាឈ្មោះនេះស្តាប់ទៅធ្វើឲ្យអ្នកចង់អស់សំណើចណាស់ តែនេះគឺជាឈ្មោះដ៏ត្រឹមត្រូវសម្រាប់ហោរា អេសាយ ពីព្រោះព្រះជាម្ចាស់មានការពិសេសមួយសម្រាប់ឲ្យគាត់ធ្វើ។ អ្នកដឹងទេ មុខងាររបស់ហោរា អេសាយ គឺស្តាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ រួចហើយប្រាប់បណ្តាជនទាំងអស់ឲ្យដឹងពីអ្វីដែលគាត់បានឮ។

ព្រះជាម្ចាស់ឲ្យហោរា អេសាយ ដឹងពីការសម្ងាត់មួយ ព្រះជាម្ចាស់នឹងជួសជុលផែនដីដែលបានខូចរបស់ទ្រង់ ព្រះជាម្ចាស់នឹងបង្ហាញដល់ហោរា អេសាយ ពីការសម្ងាត់នៃផែនការជួយសង្គ្រោះរបស់ទ្រង់៖  គឺប្រតិបត្តិការ «គ្មានទឹកភ្នែកទៀតទេ!»។

នេះគឺជាព្រះបន្ទូលដែលព្រះអង្គបានប្រាប់ដល់ហោរា អេសាយ (គឺដូចជាសំបុត្រមួយដែលព្រះអង្គបានសរសេរទៅកូនៗរបស់ទ្រង់)...







ឱ! កូនចៀមៗជាទីស្រឡាញ់ទាំងអស់គ្នាអើយ!

ឯងរាល់គ្នាបានវង្វេងចេញពីយើង ដូចជាកូនចៀមនៅកណ្ដាលទីវាល ពួកឯងបានរត់ចេញឆ្ងាយពីយើងជានិច្ច ហើយអស់ឆ្នាំនេះឯងបានវង្វេង ឯងមិនអាចរកផ្លូវត្រឡប់មកវិញបានទេ។

ប៉ុន្តែ យើងមិនអាចឈប់ស្រឡាញ់ពួកឯងរាល់គ្នាបានឡើយ យើងនឹងមករកពួកឯង ដូច្នេះយើងនឹងបញ្ជូនអ្នកគង្វាលម្នាក់ឲ្យមកជួយមើលថែរក្សា និងស្រឡាញ់ពួកឯង នាំពួកឯងត្រឡប់មកជួបនឹងយើងវិញ។





ពួកឯងបានរង់ចាំយើង ប្រៀបដូចជាមនុស្សនៅក្នុងបន្ទប់ងងឹត ប៉ុន្តែនៅក្នុងទីងងឹត នឹងមានពន្លឺភ្លឺចាំងឡើង វានឹងដេញស្រមោលទាំងនោះចេញ ដូចជាពន្លឺព្រះអាទិត្យ។

ទារកម្នាក់នឹងប្រសូតមក គឺជាព្រះរាជបុត្រានៃព្រះបរមក្សត្រ មាតារបស់ទ្រង់គឺជាក្មេងស្រីម្នាក់ពុំដែលមានប្ដីសោះ ព្រះអង្គមានព្រះនាមថា «អេម៉ាញូអែល» ដែលមានន័យថា «ព្រះជាម្ចាស់យាងមកគង់នៅជាមួយយើងរាល់គ្នា» ទ្រង់គឺជាចៅទួតចៅលួតរបស់ស្ដេច ដាវីឌ គឺជាព្រះអម្ចាស់នៃសន្តិភាព។



ហែនហើយ មានមនុស្សម្នាក់នឹងចុះមកសង្គ្រោះឯង! ប៉ុន្តែ ព្រះអង្គមិនមែនជាមនុស្សដែលមានភាពស៊ីគ្នានឹងសេចក្ដីរំពឹងរបស់គេឡើយ។





ព្រះអង្គនឹងធ្វើជាស្តេច តែមិនបានរស់នៅក្នុងវាំងទេ
ហើយព្រះអង្គក៏គ្មានលុយច្រើនដែរ ព្រះអង្គជាស្តេចដែលក្រ
ព្រមទាំងធ្វើជាអ្នកបម្រើគេ។ ប៉ុន្តែ ស្តេចអង្គនេះ នឹងគ្រប់គ្រង
ផែនដីទាំងមូល។

គេនឹងរាប់ព្រះអង្គជាអ្នកក្បាបាន! ព្រះអង្គនឹងឈ្នះ ដើម្បីរាស្ត្រ
របស់ទ្រង់ ហើយនឹងសង្គ្រោះពួកគេឲ្យរួចពីទាំងសត្រូវរបស់ពួកគេដែរ។
ប៉ុន្តែ ព្រះអង្គមិនមានកងទ័ពច្រើនសោះទេ ហើយព្រះអង្គក៏មិនខ្លាំង
ដោយប្រើអាវុធដែរ។



ព្រះអង្គនឹងធ្វើឲ្យមនុស្សខ្វាក់មើលឃើញ ព្រះអង្គនឹងធ្វើឲ្យមនុស្សខ្វិនលោតដូចជាសត្វឈ្លូស!
ព្រះអង្គនឹងធ្វើឲ្យអ្វីគ្រប់យ៉ាងបានត្រឡប់ដូចពីដើមគឺពីកាលដែលព្រះអង្គបានបង្កើតវា។
ប៉ុន្តែ មនុស្សនឹងស្អប់ទ្រង់ ហើយពួកគេនឹងមិនស្តាប់តាមទ្រង់ទេ ព្រះអង្គប្រៀបដូចជា
កូនចៀមមួយ ដែលនឹងត្រូវទទួលទោសរហូតដល់ក្ស័យជីវិត។

នេះជាផែនការសង្គ្រោះដ៏អស្ចារ្យ ដែលយើងមានតាំងពីមុនយើងចាប់ផ្តើម
បង្កើតផែនដីនេះ ដែលយើងត្រូវធ្វើ!
ហើយក៏ជាផ្លូវតែមួយគត់ ដើម្បីនាំអ្នករាល់គ្នាត្រឡប់មកយើងវិញ។
ប៉ុន្តែ ព្រះអង្គមិននៅសុខតែរហូតទេ យើងនឹងធ្វើឲ្យព្រះរាជបុត្រានេះមានជីវិតរស់វិញ!
ហើយនៅថ្ងៃមួយ ព្រះអង្គនឹងយាងមកវិញ ដើម្បីគ្រប់គ្រងជាស្តេចរហូត។ ភ្នំ និង
ដើមឈើទាំងឡាយនឹងច្រៀងរាំសប្បាយពេញដោយអំណរ! ផែនដីនឹងក្រោករាំងឡើង!
ព្រះរាជបុត្រនឹងបានពេញរាជ្យពេញផែនដី ប្រៀបដូចជាទឹកដែលគ្របដណ្តប់លើផ្ទៃសមុទ្រ!
គ្រប់ទាំងសេចក្តីទុក្ខលំបាកនឹងត្រូវលុបចេញ សេចក្តីស្លាប់នឹងត្រូវបាត់ទៅ! ហើយព្រះអង្គ
នឹងជូតទឹកភ្នែកចេញឲ្យអស់ពីភ្នែក។
ពិតប្រាកដណាស់ ព្រះអង្គសង្គ្រោះនឹងយាងមក។ ចូរត្រៀមរង់ចាំទ្រង់។ ចូរចាំយាម
ពេលទ្រង់យាងមក។ ចូរចាំទទួលទ្រង់។ ព្រះអង្គនឹងយាងមក!
យើងសន្យា។



ហោរា អេសាយ ដ៏កំសត់នេះ បានអានសំបុត្រពីព្រះម្តងហើយម្តងទៀត ឲ្យរាស្រ្តរបស់ព្រះស្តាប់ តែគ្មាននរណាម្នាក់ស្តាប់តាមគាត់ទាល់តែសោះ ពួកគេមិនចង់ឮការសន្យារបស់ព្រះឡើយ ពួកគេមិនជឿទេ។

តើស្តាប់ទៅប្រហែលជាមិនគួរនឹងជឿមែនឬ? តើជារឿងមួយដែលនឹងត្រូវបញ្ចប់ទៅដោយភាពសប្បាយរីករាយឬ? តើវាហាក់បីដូចជារឿងនិទានមែន ឬមិនមែន? ពីព្រោះមានគេប្រាប់អ្នកថា នេះជារឿងនិទាន មិនមែនជារឿងពិតទេ។

ឬក៏រឿងនេះជាការពិត?



# ហោរា ដានីយ៉ែល និងកន្លែងដ៏គួរឲ្យខ្លាច

ហោរា ដានីយ៉ែល និងរូងតោ (ដកស្រង់ចេញពីកណ្ឌ ដានីយ៉ែល ៦)

**មានការជាច្រើន**ដែលមើលទៅហាក់បីដូចជាមិនល្អទាល់តែសោះ ចំពោះរាស្ត្ររបស់ព្រះជាម្ចាស់ ដោយសារត្រូវគេចាប់ចង ហើយបាននាំពួកគេយកចេញទៅឆ្ងាយពីស្រុកកំណើត។ ហើយឥឡូវនេះ ពួកគេបានក្លាយជាឈ្នួលបម្រើដាច់ថ្លៃរបស់ស្តេចស្រុកបាប៊ីឡូន។ ប៉ុន្តែ ព្រះជាម្ចាស់មិនបានចាកចោលរាស្ត្ររបស់ទ្រង់ទេ ព្រះអង្គបានគង់នៅជាមួយពួកគេ ហើយចាំមើលថែរក្សាពួកគេជានិច្ច។



ហោរា ដានីយ៉ែល ស្រឡាញ់ព្រះជាម្ចាស់ណាស់ ហើយស្តាប់បង្គាប់ព្រះអង្គជានិច្ច។ នៅពេលនេះ ព្រះជាម្ចាស់បានប្រទានឲ្យហោរា ដានីយ៉ែល អាចយល់ដឹងពីការលំបាកជាច្រើន។ ហេតុដូច្នេះហើយ បានជាមិនយូរប៉ុន្មាន ស្តេចនៃស្រុកបាប៊ីឡូនបានកត់សម្គាល់ដឹងពីគាត់។ ស្តេច ដារីយុស បានពេញចិត្តលើប្រាជ្ញាវាងវៃរបស់ហោរា ដានីយ៉ែល។ ដូច្នេះ ទ្រង់ក៏ចាត់តាំងគាត់ឲ្យធ្វើជាអ្នកជំនួយដ៏សំខាន់ជាងគេ ក្នុងចំណោមអ្នកជំនួយទាំងអស់ ហើយទ្រង់ក៏បានដាក់គាត់ជាអ្នកត្រួតត្រាលើពួកជំនួយការជាច្រើនផ្សេងទៀតផងដែរ។



ក៏ប៉ុន្តែ ពួកអ្នកជំនួយទាំងនោះពួកគេមិនពេញចិត្តនឹងការនេះទេ គឺពួកគេចង់ឲ្យស្តេចពេញចិត្តលើពួកគេជាង បានជាពួកគេចង់កំចាត់ហោរា ដានីយ៉ែល ចោល។

ដូច្នេះ ពួកគេបាននាំគ្នាឃ្លាំមើលហោរា ដានីយ៉ែល ពួកគេបានខំរិះរកចំណុចខ្សោយរបស់ហោរា ដានីយ៉ែល ពីការអ្វីដែលពួកគេអាចទូលប្រាប់ស្តេចបាន តាមអ្វីដែលពួកគេអាច...ប៉ុន្តែគ្មានទាល់តែសោះ។ ទទេស្អាត! ពួកគេរកមិនឃើញចំណុចខ្សោយអ្វីសោះ។

លើកលែងតែមានការមួយគឺ ជារៀងរាល់ថ្ងៃ ក្នុងមួយថ្ងៃបីដង មិនដែលភ្លាំងភ្លាត់ ទោះបីជាមានការអ្វីក៏ដោយ ហោរា ដានីយ៉ែល ក៏នៅបន្តចូលទៅក្នុងបន្ទប់គាត់ បិទទ្វារ ហើយអធិស្ឋាន។





ពួកគេបានចាប់ចំណុចនោះទុក «ចូរសូមឲ្យស្ដេចបង្កើតច្បាប់មួយថា គ្មាននរណាម្នាក់អាចអធិស្ឋានទៅអ្នកណាមួយបានឡើយ លើកលែងតែទៅស្ដេចផ្ទាល់! ហោរា ដានីយ៉ែល នឹងមិនធ្វើតាមបង្គាប់នៃច្បាប់នេះទេ ដូច្នេះវានឹងត្រូវទទួលទោសហើយ!»។

ពួកគេរីករាយពេញចិត្តនឹងខ្លួនឯង ដោយព្រោះមានប្រាជ្ញាឈ្លាសវៃជាខ្លាំង ហើយក៏នាំគ្នាប្រញាប់ប្រញាល់ចេញទៅជួបស្ដេច។ ស្ដេចបានពេញចិត្តចំពោះគំនិតរបស់ពួកគេ ព្រះអង្គមិនបានជ្រាបថា ពួកគេបានប្រើល្បិចបំភាន់ភ្នែកទ្រង់ឡើយ។ ដូច្នេះ ព្រះអង្គក៏បានបង្កើតច្បាប់នេះឡើង «គ្រប់គ្នាត្រូវតែអធិស្ឋានទៅយើងតែមួយប៉ុណ្ណោះ! បើឯងមិនព្រមធ្វើតាមទេ ឯងនឹងក្លាយជាចំណីសត្វតោហើយ!»។

ពេលដែលហោរា ដានីយ៉ែល បានឮពីដំណឹងនេះ គាត់ក៏បានដឹងថា វាជាការខុសឆ្គង បើគាត់អធិស្ឋានទៅអ្នកផ្សេង ជាជាងអធិស្ឋានទៅកាន់ព្រះជាម្ចាស់តែមួយប៉ុណ្ណោះ។ គាត់ត្រូវតែធ្វើតាមអ្វីដែលព្រះជាម្ចាស់បានប្រាប់ ទោះបីជាគាត់ត្រូវខាតបង់ ឬរហូតដល់អស់ជីវិតក៏ដោយ។ ដូច្នេះ ហោរា ដានីយ៉ែល ចូលទៅក្នុងបន្ទប់គាត់ បិទទ្វារ ហើយអធិស្ឋាន។

ពួកមនុស្សអាក្រក់បានដឹងថា ហោរា ដានីយ៉ែល នឹងធ្វើយ៉ាងនោះ ដូច្នេះ ពួកគេក៏ស្ទុះភ្លែតទៅទូលស្ដេចថា «ឱ! ព្រះអម្ចាស់ជីវិតលើត្បូង! តើបញ្ញត្តិរបស់ទ្រង់មិនបានចែងថា មនុស្សគ្រប់គ្នាត្រូវតែអធិស្ឋានទៅទ្រង់តែមួយប៉ុណ្ណោះទេឬអីព្រះអង្គ?»។

ស្ដេចទ្រង់ឆ្លើយថា៖ «ពិតមែនហើយ»។

«ឱ! ព្រះអម្ចាស់ជីវិតលើត្បូង ដ៏ឈ្លាសវៃអើយ! សូមព្រះអង្គកែតម្រង់យើងខ្ញុំ បើសិនជាយើងខ្ញុំខុស ប៉ុន្តែ...ហោរា ដានីយ៉ែល ហាក់បីដូចជាកំពុងតែអធិស្ឋានទៅកាន់ព្រះជាម្ចាស់របស់គាត់ តែមិនមែនអធិស្ឋានទៅកាន់ស្ដេចនោះទេ!»។

ស្ដេចមានចិត្តព្រួយ ពីព្រោះទ្រង់ត្រូវបានចាញ់ល្បិចកលគេ! ព្រះអង្គមិនចង់ធ្វើបាបហោរា ដានីយ៉ែល ទេ ប៉ុន្តែទ្រង់ក៏មិនអាចកែប្រែច្បាប់របស់ព្រះអង្គបានដែរ ដូច្នេះ ហើយបានជាព្រះអង្គអនុញ្ញាតឲ្យពួកទាហាន បោះហោរា ដានីយ៉ែល ទៅក្នុងរូងតោទៅ។ ស្ដេចទ្រង់មានបន្ទូលថា៖ «ចូរឲ្យព្រះជាម្ចាស់នៃឯង ជាព្រះជាម្ចាស់ដែលឯងស្រឡាញ់ជាខ្លាំងលើសលុប មកជួយសង្គ្រោះឯងចុះ!»។







ស្ដេចក៏យាងត្រឡប់ចូលដំណាក់ទ្រង់វិញទៅ ប៉ុន្តែទ្រង់ផ្ទំមិនលក់ទាល់តែសោះក្នុងយប់នោះ។ សូម្បីតែមួយប៉ប្រិចភ្នែកក៏មិនបានដែរ។ ទ្រង់ដេករើចុះឡើង រហូតដល់ពេលព្រលឹមភ្លឺស្រាងៗឡើង ព្រះអង្គស្ទុះក្រោកចេញពីគ្រែ រួចរត់តម្រង់ទៅរូងតោ។ ព្រះអង្គបានស្រែកថា៖ «ឱ! ដានីយ៉ែល! តើព្រះជាម្ចាស់របស់ឯងបានជួយសង្គ្រោះឯងឬទេ?»។

ហោរា ដានីយ៉ែល ឆ្លើយតបថា៖ «ព្រះករុណាថ្លៃវិសេស។ ព្រះជាម្ចាស់របស់ទូលបង្គំ បានបញ្ជូនទេវតាមកបិទមាត់សត្វតោ!»។



ហើយនៅទីនោះ សត្វតោធំជាងគេបានដាក់ក្បាលវាកើយលើភ្លៅរបស់ហោរា ដានីយ៉ែល ដោយស្រមុកខុលៗ ដូចជាកូនឆ្មាតូចមួយអញ្ចឹង។

ស្ដេចបានយកហោរា ដានីយ៉ែល ចេញពីរូងតោរួចទ្រង់មានបន្ទូលថា៖ «មើល! ហោរា ដានីយ៉ែល គ្មានរលាត់ស្បែកអ្វីបន្តិចសោះ!»។

ស្ដេចក៏បង្កើតច្បាប់ថ្មីមួយទៀត «ព្រះរបស់ហោរា ដានីយ៉ែល គឺជាព្រះជាម្ចាស់ដ៏ពិត ជាព្រះដែលជួយសង្គ្រោះ ចូរអធិស្ឋានទៅទ្រង់ ជាជាងអធិស្ឋានមកយើង!»។

ព្រះជាម្ចាស់នៅតែជួយសង្គ្រោះរាស្ត្ររបស់ទ្រង់ជានិច្ច។ ហើយនៅពេលអនាគតមកដល់ ព្រះជាម្ចាស់នឹងបញ្ជូនអ្នកក្លាហានមួយទៀតដូចជាដានីយ៉ែលដែរ អ្នកនោះជាអ្នកស្រឡាញ់ព្រះ ហើយធ្វើតាមព្រះបន្ទូលរបស់ទ្រង់ ទោះបីជាគេត្រូវខាតបង់អ្វីក៏ដោយ សូម្បីតែត្រូវក្ស័យជីវិតក៏ដោយ។

សរុបសេចក្ដីមក អ្នកនោះ នឹងសម្រេចសេចក្ដីសង្គ្រោះដ៏អស្ចារ្យនៅលើលោកីយ៍នេះដែលមិនធ្លាប់មាន។



# អ្នកនាំសាររបស់ព្រះជាម្ចាស់

ហោរា យ៉ូណាស និងត្រីដ៏ធំមួយ (ដកស្រង់ចេញពីកណ្ឌ យ៉ូណាស ១-២ និងហេព្រើរ ១:១-២)

**ព្រះជាម្ចាស់**មានការងារមួយឲ្យហោរា យ៉ូណាស ធ្វើ ប៉ុន្តែហោរា យ៉ូណាស មិនចង់ធ្វើការនោះទេ។

ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរទៅទីក្រុងនីនីវេ ហើយប្រាប់ទោសត្រូវដ៏អាក្រក់របស់ឯងថា យើងក៏ស្រឡាញ់ពួកគេដែរ»។

ហោរា យ៉ូណាស ទូលតបថា៖ «ទេ! ពួកទាំងនោះជាមនុស្សអាក្រក់ ធ្វើតែការអាក្រក់ប៉ុណ្ណោះ!»។

ព្រះជាម្ចាស់ឆ្លើយថា៖ «ប្រាកដណាស់! ពួកគេបានរត់ទៅឆ្ងាយពីយើង ក៏ប៉ុន្តែយើងមិនអាចឈប់ស្រឡាញ់ពួកគេបានឡើយ យើងនឹងឲ្យពួកគេចាប់ផ្ដើមសារជាថ្មី យើងនឹងអត់ទោសដល់ពួកគេ»។

ហោរា យ៉ូណាស ឆ្លើយតបទៅព្រះជាម្ចាស់វិញថា៖ «ទេ! ពួកគេមិនសមនឹងទទួលការអត់ទោសនោះទេ!»។

ហោរា យ៉ូណាស បានគិតក្នុងចិត្តថា៖ *«ខ្ញុំនឹងរត់ទៅឲ្យឆ្ងាយ! គឺឆ្ងាយ-ឆ្ងាយណាស់រហូត ព្រះជាម្ចាស់មិនអាចរកខ្ញុំឃើញ។ ហើយខ្ញុំមិនបាច់ធ្វើការដែលព្រះជាម្ចាស់បានបង្គាប់ឲ្យធ្វើឡើយ!»*។ តាមគំនិតរបស់គាត់ គាត់គិតឃើញថា នេះគឺជាផែនការល្អណាស់!




ប៉ុន្តែ តាមការពិតទៅ នេះមិនមែនជាផែនការល្អទាល់តែសោះ តែវាគឺជាផែនការដ៏ល្ងីល្ងើមួយ (ពីព្រោះអ្នកអាចរត់ចេញឆ្ងាយពីព្រះជាម្ចាស់បាន ប៉ុន្តែព្រះអង្គនៅតែតាមរកអ្នកឃើញជានិច្ច)។

ហោរា យ៉ូណាស បានធ្វើតាមផែនការមិនល្អរបស់គាត់៖ «សូមទិញសំបុត្រមួយសំបុត្រទៅកន្លែងផ្សេង ក្រៅពីទៅទីក្រុងនីនីវេ!» រួចហើយ គាត់ក៏ជិះសំពៅដែលចេញទៅបញ្ច្រាសទិសពីក្រុងនីនីវេ។

មែន មិនយូរប៉ុន្មានមានខ្យល់បក់បោកជាខ្លាំង ហើយសំពៅក៏ចាប់ផ្តើមផ្អៀងផ្អង មុជងើបៗ ហើយឃ្លីងឃ្លោង គ្រប់ៗគ្នាក៏ចាប់ផ្តើមមានការភ័យតក់ស្លុត។ ភ្លាមៗនោះហោរា យ៉ូណាស បានងើបអង្គុយត្រង់ឆ្អឹងលើគ្រែរបស់គាត់។ អ្នកឃើញទេ ការដំបូងដែលកើតឡើងដល់ផែនការមិនល្អរបស់ហោរា យ៉ូណាស គឺព្រះជាម្ចាស់បានបញ្ជូនព្យុះដ៏ធំមួយឲ្យដេញតាមគាត់។

ពួកអ្នកបើកសំពៅមិនអាចបើកបានស្រួលនោះទេ គេស្រែកឡើងថា៖ «យើងនឹងលិចលង់ហើយ!» រួចក៏ចាប់ផ្តើមបោះអ្វីៗចេញពីសំពៅ និងចំណីអាហារ ចេញពីសំពៅ រួមទាំងអ្វីៗក៏ដោយ ក៏គេបោះចោលទាំងអស់ដែរ។

មកទល់ពេលនេះហោរា យ៉ូណាស ក៏បានដឹងច្បាស់ថា ខ្យល់ព្យុះដែលកើតឡើងនេះ គឺមកពីកំហុសរបស់គាត់។ គាត់បានស្រែកប្រាប់ពួកអ្នកបើកសំពៅថា៖ «បោះខ្ញុំចុះទៅក្នុងសមុទ្រជំនួសរបស់ទាំងនោះទៅ នោះខ្យល់ព្យុះនឹងស្ងប់វិញហើយ!»។ អ្នកបើកសំពៅស្តាប់មិនសូវច្បាស់ទេ បានជាហោរា យ៉ូណាស ស្រែកឡើងម្តងទៀតថា៖ «វាជាមធ្យោបាយតែមួយគត់ ដែលអ្នករាល់គ្នាអាចនឹងរួចជីវិតបាន»។

ដូច្នេះ មួយ...ពីរ...បី...



ប្រូង...ទឹកបែកខ្ចាយ!

មិនយូរប៉ុន្មានក្រោយដែលហោរា យ៉ូណាស បានធ្លាក់ចូលក្នុងទឹក រលកសមុទ្រក៏បានស្ងប់ស្ងាត់ទៅវិញទៅ ខ្យល់ក៏ថយចុះ ហើយខ្យល់ព្យុះក៏ស្ងប់ឈឹងដែរ។

តែបន្ទាប់មក ក្នុងពេលដែលហោរា យ៉ូណាស បានគិតថាអ្វីៗទាំងអស់នឹងកន្លងផុតទៅ ហើយនៅពេលដែលគាត់បានប្រាកដថា គាត់មុខជាលង់ទឹកស្លាប់នោះ ព្រះជាម្ចាស់បានបញ្ជូនត្រីធំមួយមកជួយសង្គ្រោះគាត់ ត្រីនោះបានលេបហោរា យ៉ូណាស ទាំងមូលតែក្នុងមួយម៉ាត់ប៉ុណ្ណោះ។





ហោរា យ៉ូណាស ប្រហែលជាគិតថា គាត់ស្លាប់ហើយ ពីព្រោះនៅក្នុងនោះងងឹតណាស់ គឺដូចជានៅក្នុងផ្នូរខ្មោចអញ្ចឹង។ ប៉ុន្តែ នៅពេលដែលគាត់បានធំក្លិនអាហារស្អុយរលួយ ហើយក៏មានសារាយសមុទ្រនៅក្នុងទីនោះដែរ នោះគាត់ក៏បានដឹងថា គាត់មិនបានស្លាប់ទេ គឺគាត់កំពុងតែនៅក្នុងពោះត្រី!

ហោរា យ៉ូណាស អង្គុយនៅក្នុងទីងងឹតនៅក្នុងពោះត្រីអស់រយៈពេលបីថ្ងៃបីយប់ គាត់មានពេលជាច្រើនដើម្បីនឹងគិត។ បន្តិចក្រោយមកគាត់បានគិតឃើញថា ផែនការរបស់គាត់ពិតជា...ជាផែនការល្ងីល្ងើមែនទែន។ គាត់មានការសោកស្តាយក្នុងការដែលគាត់បានរត់ចេញពីព្រះជាម្ចាស់ គាត់បានអធិស្ឋានទៅព្រះជាម្ចាស់អំឡុងពេលដែលគាត់នៅក្នុងពោះត្រីដ៏ធំនៅឡើយ ហើយអង្វរសូមឲ្យព្រះអង្គអត់ទោសឲ្យគាត់។

បីថ្ងៃក្រោយមក ត្រីបានខ្ជាក់ហោរា យ៉ូណាស ដោយសុខស្រួល នៅលើឆ្នេរខ្សាច់សមុទ្រមួយ។

ភ្លាមៗនោះហោរា យ៉ូណាស បានឮសំឡេងនរណាម្នាក់ហៅឈ្មោះគាត់ ព្រះជាម្ចាស់បានស្រែកប្រាប់ថា៖ «ចូរទៅទីក្រុងនីនីវេ»។

ហោរា យ៉ូណាស សួរថា៖ «ក្នុងពេលនេះឬ?» ព្រះជាម្ចាស់ឆ្លើយតបថា៖ «អើ!» គាត់ក៏ចេញតម្រង់ទៅក្រុងនីនីវេ ហើយក៏បានប្រាប់មនុស្សគ្រប់គ្នាពីព្រះបន្ទូលដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។



ហោរា យ៉ូណាស បានប្រាប់ពួកគេថា៖ «ទោះបីជាអ្នកបានរត់ចេញឆ្ងាយពីព្រះជាម្ចាស់ក៏ដោយ ក៏ព្រះជាម្ចាស់នៅតែមិនឈប់ស្រឡាញ់អ្នកដែរ ចូរមករកព្រះអង្គវិញ ដើម្បីឲ្យព្រះអង្គអាចនឹងអត់ទោសឲ្យអ្នក»។

បណ្ដាជននៅទីក្រុងនីនីវេនាំគ្នាស្ដាប់តាមហោរា យ៉ូណាស ហើយពួកគេក៏ចាប់ផ្ដើមស្រឡាញ់ព្រះជាម្ចាស់។ ពួកគេបានរៀនធ្វើនូវអ្វីៗដែលព្រះជាម្ចាស់ប្រាប់ដល់ពួកគេ និងឈប់រត់ចេញពីទ្រង់ដូចជាហោរា យ៉ូណាស។

ជាច្រើនឆ្នាំក្រោយមក ព្រះជាម្ចាស់នឹងចាត់អ្នកនាំសារម្នាក់ទៀត រួមជាមួយនឹងព្រះបន្ទូលដ៏អស្ចារ្យដូចនេះដែរ។ ដូចជាហោរា យ៉ូណាស ព្រះអង្គមួយនោះនឹងត្រូវជាប់ក្នុងទីងងឹតឈឹងអស់រយៈពេលបីថ្ងៃដែរ។

ប៉ុន្តែ អ្នកនាំសាររបស់ទ្រង់លើកនេះ គឺជាព្រះរាជបុត្រារបស់ទ្រង់ផ្ទាល់តែម្ដង។ ព្រះអង្គត្រូវបានគេហៅថា «ព្រះបន្ទូល» ពីព្រោះអង្គទ្រង់ គឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះបន្ទូលរបស់ព្រះ បានបកប្រែតាមភាសារបស់យើងនីមួយៗ។ គ្រប់ការទាំងអស់ ដែលព្រះជាម្ចាស់ចង់មានព្រះបន្ទូល ទៅកាន់លោកីយ៍ទាំងមូល ក្នុងភាពជាមនុស្សម្នាក់។

# ត្រៀមខ្លួនជាស្រេច

រាស្ត្ររបស់ព្រះជាម្ចាស់បានវិលត្រឡប់ចេញពីភាពជាឈ្លើយបម្រើដាច់ថ្លៃហើយ

(ដកស្រង់ចេញពីកណ្ឌ នេហេមា ៨-១០; ម៉ាឡាគី ១; ៣; ៤, និងអែសរ៉ា ៧)

**តើអ្នកធ្លាប់**បានទៅចូលរួមពិធីជប់លៀងមួយ ដែលមានរយៈពេលមួយអាទិត្យដែរឬទេ? ឬក៏ធ្លាប់ស្ដាប់ការអធិប្បាយដែលយូរ ពេញមួយថ្ងៃដែរឬទេ?

មែនហើយ! គឺដូចជាការដែលបានកើតឡើងដល់ពួករាស្ត្ររបស់ព្រះជាម្ចាស់ដែរ ក្រោយពេលដែលគេវិលត្រឡប់មកផ្ទះវិញ បន្ទាប់ពីរួចខ្លួនចេញពីភាពជាឈ្លើយបម្រើដាច់ថ្លៃនោះ។ ពួកគេបានភ្លេចពីរបៀបដែលព្រះជាម្ចាស់ចង់ឲ្យគេរស់នៅ ឬក៏ពួកគេត្រូវសន្មតថា ខ្លួនគេជាអ្នកណា។ ដូច្នេះ ហោរា អែសរ៉ា និងហោរា នេហេមា បានអានក្រឹត្យវិន័យដែលព្រះជាម្ចាស់ប្រទានមកលោក ម៉ូសេ ឲ្យពួកគេស្ដាប់។

ប៉ុន្តែ ការចម្លែកមួយបានកើតឡើង៖ គឺនៅពេលដែលការអធិប្បាយកាន់តែយូរ គេកាន់តែមានទុក្ខព្រួយខ្លាំងឡើងៗដែរ។ ហេតុអ្វី? តើសេចក្តីអធិប្បាយបានធ្វើឲ្យគេធុញទ្រាន់ណាស់ទៅឬ? ទេ! មិនពិតទេ! ជាការចម្លែកណាស់ សូមមើល នៅពេលដែលហោរា អែសរ៉ា អានកណ្ឌគម្ពីរក្រឹត្យវិន័យនោះ វាដូចជាកញ្ចក់មួយ ដែលបានឆ្លុះបង្ហាញឲ្យពួកគេមើលឃើញថា គេមានសភាពដូចម្ដេច។ ហេតុនេះហើយបានជាពួកគេមិនចូលចិត្តនូវអ្វីៗដែលពួកគេបានឃើញ។ ពួកគេបានឃើញថា ខ្លួនមិនបានរស់នៅតាមផ្លូវដែលពួកគេគួរនឹងរស់នៅនោះទេ ពួកគេបានឃើញថា ពួកគេឃោរឃៅ និងអាត្មានិយមផង។

ពួកគេបានស្រែកឡើងថា៖ «ពួកយើងខុសហើយ ឥឡូវនេះព្រះជាម្ចាស់នឹងកាត់ទោសយើងហើយ!»។

ពួកគេគិតថា គេបានដឹងរួចហើយថា ព្រះជាម្ចាស់បម្រុងនឹងធ្វើ ប៉ុន្តែពួកគេមិនបានដឹងពីអ្វីដែលទ្រង់នឹងធ្វើទាល់តែសោះ។ ពិតណាស់ ពួកគេប្រហែលជាបានឃើញនូវតម្រុយចេញពីអត្ថន័យនៃឈ្មោះហោរា អែសរ៉ា ដែលមានន័យថា៖ «ជំនួយនៅទីនេះ!» ហើយខ្លាំងជាងនេះទៀតគឺចាប់យកអត្ថន័យពីឈ្មោះរបស់ហោរា នេហេមា ពីព្រោះឈ្មោះគាត់មានន័យថា៖ «ព្រះជាម្ចាស់នឹងជូតទឹកភ្នែកយើងចេញ»។ ហើយជាការពិតប្រាកដណាស់ អ្នកនឹងឃើញថា នេះជាការដែលព្រះជាម្ចាស់ប្រុងប្រៀបជាស្រេចដើម្បីនឹងធ្វើ។

ហោរា អែសរ៉ា សម្លឹងមើលទៅពួកកូនៗរបស់ព្រះជាម្ចាស់ អស្ចារ្យណាស់ ទឹកភ្នែកក្ដៅ ឧណ្ហៗ រលីងរលោងបានចេញមកពេញភ្នែករបស់ពួកគេ ហើយបានហូរជោកថ្ពាល់ពួកគេ។ គាត់ក៏បញ្ឈប់សេចក្តីបង្រៀន ត្រឹមពាក់កណ្ដាលឃ្លា ហើយក៏បិទគម្ពីរ។ គាត់បានប្រកាសថា៖ «យើងនឹងធ្វើពិធីជប់លៀងវិញ!»

ដូច្នេះ ពួកគេក៏នាំគ្នាជប់លៀង! គឺពេញមួយអាទិត្យ។



ហោរា អែសរ៉ា និយាយថា៖ «ព្រះជាម្ចាស់ចង់ឲ្យយើងសប្បាយរីករាយ!»។

ពួកគេបានស្ដាប់រឿងពីការអស្ចារ្យ ដែលព្រះជាម្ចាស់បានធ្វើសម្រាប់រាស្ដ្ររបស់ទ្រង់អស់ពេញមួយថ្ងៃ៖ ពីរបៀបដែលទ្រង់បានបង្កើតពិភពលោក ពីសេចក្ដីសន្យាពិសេសដែលព្រះអង្គបានធ្វើជាមួយលោក អ័ប្រាហាំ ពីរបៀបដែលទ្រង់បានជួយសង្គ្រោះពួកគេឲ្យរួចចេញពីភាពជាឈ្នួលដាច់ថ្លៃ ពីអ្វីដែលព្រះអង្គបានប្រាប់លោក ម៉ូសេ និងបង្ហាញពួកគេពីរបៀបដែលត្រូវរស់នៅ ពីបែបដែលទ្រង់បានដឹកនាំពួកគេទៅដល់ទឹកដីពិសេស ពីរបៀបដែលទ្រង់បានជួយសង្គ្រោះពួកគេទោះជាមានបញ្ហាអ្វីក៏ដោយ ពីមួយពេលទៅមួយពេល ម្ដងហើយម្ដងទៀត គឺដោយព្រោះព្រះអង្គនៅតែស្រឡាញ់កូនទ្រង់ គ្មានទីបញ្ចប់ មិនអាចបោះបង់បាន មិនអាចបំបែកចេញបាន ជាសេចក្ដីស្រឡាញ់ដ៏អស់កល្បជានិច្ច។

ពួកគេបានចងចាំថា ក្នុងរយៈពេលជាច្រើនកន្លងទៅ ព្រះជាម្ចាស់បានស្រឡាញ់កូនរបស់ទ្រង់ ព្រះអង្គប្រកាន់ខ្ជាប់នូវកិច្ចសន្យាជាមួយលោក អ័ប្រាហាំ ថែរក្សាពួកគេទាំងអស់គ្នា និងបានអត់ទោសឲ្យពួកគេផង។ ទោះបីជានៅពេលដែលពួកគេមិនស្ដាប់បង្គាប់ បានរត់ចេញពីទ្រង់ ទោះបើនៅពេលនោះក៏ពួកគេបានគិតថា ខ្លួនមិនត្រូវការទ្រង់ដែរ។

រួចហើយព្រះជាម្ចាស់បានប្រាប់ដល់កូនរបស់ទ្រង់នូវអ្វីៗជាច្រើនផ្សេងទៀត...



យើងមិនអាចឈប់ស្រឡាញ់ឯងបានទេ
ឯងជាកំណប់ក្នុងបេះដូងរបស់យើង
ប៉ុន្តែ យើងបានបាត់ឯង
ឥឡូវនេះ យើងកំពុងតែត្រឡប់មកវិញ ដើម្បីឯង។

យើងដូចជាព្រះអាទិត្យដែលបំភ្លឺយ៉ាងស្រទន់ទៅលើឯង
ដេញអស់ទាំងភាពងងឹត និងសេចក្តីភ័យខ្លាច ហើយនិងសេចក្តីស្លាប់ចេញ។
ឯងនឹងបានសប្បាយចិត្តជាខ្លាំង
ឯងនឹងរត់លេងដោយសេរី ដូចជាកូនគោតូចមួយ
នៅទីវាលដ៏ស្រឡះ។

យើងនឹងបញ្ជូនអ្នកនាំសាររបស់យើងគឺជាម្នាក់ដែលយើងបានសន្យា។
ជាម្នាក់ដែលឯងកំពុងរង់ចាំ
ជាអ្នកសង្គ្រោះ។

ទ្រង់នឹងយាងមក ដូច្នេះ ត្រូវត្រៀមខ្លួនជាស្រេច!





រាស្ត្ររបស់ព្រះជាម្ចាស់ចំណាយពេលជាច្រើនរយឆ្នាំក្នុងការត្រៀមខ្លួន ប៉ុន្តែឥឡូវនេះ ពេលវេលានៃផ្នែកសំខាន់សម្រាប់ផែនការរបស់ព្រះជាម្ចាស់ជិតមកដល់។

ព្រះអង្គនឹងយាងចុះមកផ្ទាល់ មិនមែនមក ដើម្បីនឹងដាក់ទោសដល់រាស្ត្រទ្រង់ទេ ប៉ុន្តែមក ដើម្បីជួយសង្គ្រោះពួកគេវិញ។

ព្រះជាម្ចាស់បានប្រុងប្រៀបជាស្រេច ដើម្បីនឹងជូតទឹកភ្នែកពីភ្នែកពួកគេចេញ។

ហើយពិធីជប់លៀងដ៏ពិតប្រាកដគឺជិតដល់ពេលនឹងចាប់ផ្តើមដែរ...

# ព្រះអង្គមកដល់ហើយ!

ឈុតឆាករូបសិប្បនិមិត្ត (ដកស្រង់ចេញពីកណ្ឌ លូកា ១-២)

**គ្រប់អ្វីៗទាំងអស់**បានរៀបចំជាស្រេច ទីបំផុត ពេលវេលាដែលព្រះជាម្ចាស់រង់ចាំបានមកដល់ហើយ! ព្រះជាម្ចាស់បានយាងមក ដើម្បីជួយដល់រាស្ត្ររបស់ទ្រង់ ដូចដែលទ្រង់បានសន្យាតាំងពីដើមដំបូងមកម្ល៉េះ។

ប៉ុន្តែ តើព្រះអង្គយាងមកដោយរបៀបណា? តើព្រះអង្គទ្រង់មានសភាពដូចម្ដេច? តើព្រះអង្គនឹងធ្វើអ្វីទៅ?

ភ្នំទាំងឡាយនឹងឱនចុះ។ សមុទ្រនឹងកក្រើកឡើង។ ដើមឈើទាំងឡាយនឹងទះដៃអបអរ។ ប៉ុន្តែ ផែនដីនឹងទប់ដង្ហើមដោយស្ងប់ស្ងាត់។ ទ្រង់នឹងយាងមកដូចជាភ្លៀងដែលកំពុងធ្លាក់ស្រិចៗអញ្ចឹង។ ព្រះអង្គទ្រង់នឹងយាងមក នៅក្នុងទីងងឹត នៅពេលដែលគ្មាននរណាម្នាក់រំពឹង។



មានស្ត្រីវ័យក្មេងម្នាក់ បានភ្ជាប់ពាក្យជាមួយនឹងបុរសម្នាក់ឈ្មោះ យ៉ូសែប (លោក យ៉ូសែប ជាចៅច្រើនតំណរបស់ស្តេច ដាវីឌ)។

នៅព្រឹកមួយ ពេលស្ត្រីវ័យក្មេងម្នាក់នេះកំពុងតែធ្វើការដូចដែលនាងធ្វើសព្វដង ស្រាប់តែមានទេវតាដែលពេញដោយពន្លឺលេចចេញមកក្នុងបន្ទប់គេងរបស់នាង។ ទេវតានេះឈ្មោះ កាព្រីយ៉ែល ជាអ្នកនាំសារពិសេសមកពីស្ថានសួគ៌។ ពេលដែលនាងឃើញទេវតាដ៏មានពន្លឺនោះបានឈរនៅចំពោះមុខនាង នាងក៏មានអារម្មណ៍ភ័យខ្លាច។

ទេវតាបាននិយាយទៅកាន់នាងថា៖ «កុំខ្លាចអីនាង ព្រះជាម្ចាស់ពេញចិត្តនឹងនាងហើយ»។

នាង ម៉ារា ងាករកមើលជុំវិញខ្លួន ក្រែងលោទេវតានិយាយជាមួយនរណាម្នាក់ផ្សេងទៀត។

ទេវតា កាព្រីយ៉ែល បាននិយាយទៅកាន់នាងថា៖ «ឱ! នាង ម៉ារា អើយ!» ហើយទេវតានោះក៏បានសើចដោយមានពេញដោយអំណរ រហូតដល់បណ្ដាលឲ្យនាង ម៉ារា មានទឹកភ្នែករលីងរលោង។





«ឱ! នាង ម៉ារា អើយ! នាងនឹងមានបុត្រាមួយ។ នាងត្រូវដាក់នាមទ្រង់ថា «យេស៊ូវ»។ ទ្រង់ជាបុត្រាផ្ទាល់របស់ព្រះជាម្ចាស់។ ទ្រង់នេះហើយដែលជាព្រះអង្គសង្គ្រោះ!»។

ព្រះជាម្ចាស់ដែលគ្រវែងផែនដីនេះទៅក្នុងលំហអាកាស ហើយទុកឲ្យផែនដីនេះវិលទៅវិលមកនៅទីនោះ គឺជាព្រះអាទិករដែលបានបង្កើតសកលលោកទាំងមូល ដោយគ្រាន់តែមានបន្ទូលប៉ុណ្ណោះ គឺជាព្រះដែលអាចធ្វើអ្វីៗគ្រប់ទាំងអស់។ ទ្រង់បានបន្ទាបអង្គទ្រង់ចុះ ហើយយាងមកប្រសូតជាទារកម្នាក់។

ឈប់សិន! តើព្រះជាម្ចាស់កំពុងតែបញ្ជូនទារកម្នាក់ឲ្យមក ដើម្បីជួយសង្គ្រោះពិភពលោកឬ?

ពេលដែលនាង ម៉ារា និយាយ កាលនោះបេះដូងរបស់នាងក៏កំពុងតែញាប់ញ័ររំជួលយ៉ាងខ្លាំងផងដែរ «ប៉ុន្តែ នេះជាការអស្ចារ្យខ្លាំងណាស់! តើឲ្យការនេះកើតឡើងយ៉ាងដូចម្ដេចបានទៅ?»។

តែទេវតា កាព្រីយ៉ែល សួរនាងថា៖ «តើមានការអ្វីដែលអស្ចារ្យខ្លាំងពេកទៅចំពោះព្រះជាម្ចាស់?»។

ដូច្នេះ នាង ម៉ារា បានទុកចិត្តលើព្រះជាម្ចាស់ ខ្លាំងជាងអ្វីដែលកែវភ្នែកនាងបានឃើញទៅទៀត។ ហើយនាងបានជឿ។ នាងបាននិយាយឡើងថា៖ «ខ្ញុំជាអ្នកបម្រើព្រះ អ្វីក៏ដោយដែលព្រះជាម្ចាស់ទ្រង់មានបន្ទូលខ្ញុំនឹងធ្វើតាម»។

ពិតប្រាកដណាស់ ដូចជាទេវតាបានប្រាប់មែន គឺប្រាំបួនខែក្រោយមកនាង ម៉ារា ជិតគ្រប់ខែឆ្លងទន្លេហើយ។

ឥឡូវនេះនាង ម៉ារា និងលោក យ៉ូសែប ត្រូវចេញដំណើរទៅភូមិបេថ្លេហិម ដែលជាស្រុកកំណើតរបស់ស្តេច ដាវីឌ។ ប៉ុន្តែ នៅពេលដែលពួកគេបានទៅដល់ភូមិតូចនោះ គ្រប់បន្ទប់នៃផ្ទះសំណាក់ពេញទាំងអស់ គ្មានកន្លែងណាដែលទំនេរសោះ។

អ្នកបម្រើភ្ញៀវក្នុងផ្ទះសំណាក់បានប្រាប់ពួកគេថា៖ «អស់បន្ទប់ហើយ សូមរកកន្លែងផ្សេងចុះ»។

តើឲ្យពួកគេទៅជ្រកនៅកន្លែងណា? នៅតែបន្តិចទៀតនាង ម៉ារា នឹងឆ្លងទន្លេហើយ។

ពួកគេមិនអាចរកកន្លែងជ្រកបានសោះ លើកលែងតែក្រោលសត្វមួយដែលទ្រុឌទ្រោមទៅហើយ ដូច្នេះ ពួកគេក៏បានសម្រាកនៅកន្លែងនោះ ជាកន្លែងដែលហ្វូងគោ ហ្វូងលា ហើយនិងហ្វូងសេះកំពុងនៅ។



នៅក្នុងក្រោលសត្វនាយប់ដ៏សែនស្ងាត់ជ្រងំនោះ ក្នុងចំណោមសត្វមាន់ សត្វលា ហើយនិងសត្វគោ ព្រះបានប្រទានដល់លោកីយ៍នូវអំណោយទានដ៏ល្អបំផុតរបស់ទ្រង់មួយ។ ទារកមួយនេះបានប្រសូតមក ហើយទ្រង់នឹងបំផ្លាស់បំប្រែផែនដីទាំងមូលនេះ។ ទ្រង់គឺជាបុត្រារបស់ព្រះជាម្ចាស់ផ្ទាល់។

នាង ម៉ារា និងលោក យ៉ូសែប បានរុំទារកនឹងសំពត់ ដើម្បីជួយឲ្យបានកក់ក្ដៅ ពួកគេបានរៀបចំធ្វើគ្រែថ្វាយទ្រង់ពីចំបើង ដោយប្រើស្នូកដាក់ចំណីឲ្យសត្វធ្វើជាគ្រែសម្រាប់ថ្វាយបុត្រតូច។ ពួកគេសម្លឹងមើលទៅអំណោយដ៏អស្ចារ្យដែលព្រះជាម្ចាស់បានប្រទានមក គឺបុត្រដែលរុំនឹងសំពត់ ហើយផ្ទំនៅក្នុងស្នូកសត្វ។

នាង ម៉ារា និងលោក យ៉ូសែប បានដាក់ឈ្មោះទ្រង់ថា យេស៊ូវ «អេម៉ាញ៉ូអែល» ដែលមានន័យថា៖ «ព្រះជាម្ចាស់យាងមករស់នៅជាមួយយើង»។

ព្រោះនេះគឺជាការពិតណាស់ ដ្បិតទ្រង់បានយាងមកពិតមែន។



# ពន្លឺនៃលោកីយ៍ទាំងមូល

សាច់រឿងពីពួកអ្នកគង្វាលចៀម (ដកស្រង់ចេញពីកណ្ឌ លូកា ២)

**នៅក្នុងយប់**ដដែលនោះ ក្នុងចំណោមផ្កាយទាំងអស់ មានផ្កាយថ្មីមួយដែលភ្លឺចែងចាំងជាងគេបានរះឡើង។ ក្នុងចំណោមផ្កាយទាំងអស់ដែលស្ថិតនៅលើមេឃមានតែផ្កាយមួយនេះទេដែលមានពន្លឺច្បាស់ជាងគេ។ វាបានបញ្ចាំងរស្មីយ៉ាងខ្លាំង និងភ្លឺចាំងចែងនៅយប់នោះ ធ្វើឲ្យផ្កាយដទៃទៀតដែលនៅក្បែរនោះ មើលទៅមានពន្លឺព្រឹមៗទៅវិញ។

ព្រះជាម្ចាស់បានដាក់ផ្កាយនេះនៅត្រង់កន្លែងហ្នឹង ក្នុងពេលដែលបុត្រារបស់ព្រះអង្គបានប្រសូតមក ដើម្បីឲ្យមានពន្លឺបញ្ចាំងរស្មីមកលើបុត្រ និងបំភ្លឺទីងងឹត ដើម្បីបង្ហាញមនុស្សឲ្យឃើញផ្លូវចូលទៅឯទ្រង់។

អ្នកឃើញទេ ព្រះអង្គគឺដូចជាឪពុកម្នាក់ ទ្រង់មិនដែលលាក់ដំណឹងល្អនេះសម្រាប់តែខ្លួនព្រះអង្គនោះទេ។ ព្រះអង្គបានរង់ចាំឲ្យការនេះកើតឡើងអស់ជាច្រើនឆ្នាំមកហើយ ហើយឥឡូវនេះ ព្រះអង្គចង់ប្រាប់ដល់មនុស្សគ្រប់គ្នាឲ្យដឹង។



ដូច្នេះ ព្រះអង្គក៏បានធ្វើយ៉ាងពេញទី ព្រះអង្គបានបញ្ជូនទេវតាមកប្រាប់នាង ម៉ារា ពីដំណឹងល្អ។ ព្រះអង្គទ្រង់បានដាក់ផ្កាយពិសេសមួយនៅលើមេឃ ដើម្បីបង្ហាញឲ្យដឹងថា ព្រះរាជបុត្រាទ្រង់នៅឯណា ហើយឥឡូវនេះ ព្រះអង្គនឹងបញ្ជូនពួកទេវតា ឲ្យមកច្រៀងចម្រៀងសប្បាយរីករាយរបស់ព្រះអង្គដល់លោកីយ៍៖ ទ្រង់នៅទីនេះ! ទ្រង់យាងមកហើយ! ចូរចេញទៅមើលព្រះអង្គជាកូនស្ងួនភ្ញារបស់យើង។

តើអ្នកនឹងបញ្ជូនក្រុមចម្រៀងដ៏អស្ចារ្យរបស់អ្នកទៅឯណា? ទៅរោងប្រគំភ្លេងមែនទេ? ឬប្រហែលជាទៅឯដំណាក់ស្តេច? ព្រះជាម្ចាស់បានបញ្ជូនក្រុមចម្រៀងរបស់ព្រះអង្គទៅឯជើងភ្នំតូចមួយ នៅខាងក្រៅភូមិតូចមួយទាំងពាក់កណ្តាលអធ្រាត្រ ទ្រង់បានបញ្ជូនពួកទេវតាទាំងនោះ ដើម្បីច្រៀងដល់អ្នកគង្វាលចៀមក្រីក្រមួយក្រុម ដែលនៅចាំឃ្វាលចៀមខាងក្រៅភូមិបេថ្លេហិម។

ចូរនឹកចាំថា ក្នុងសម័យនោះមនុស្សទាំងឡាយតែងតែនាំគ្នាសើចចំអកដាក់ពួកអ្នកគង្វាលចៀម ហើយនិយាយថា គេមានក្លិនអាក្រក់ ហើយដាក់រហស្សនាមមិនល្អៗឲ្យពួកគេផង (តែខ្ញុំនឹងមិនរៀបរាប់នៅក្នុងទីនេះទេ)។ អ្នកឃើញទេ មនុស្សទាំងឡាយតែងនាំគ្នាគិតថា ពួកអ្នកគង្វាលចៀមជាមនុស្សក្រកខ្វក់ ជាមនុស្សគ្មានគេរាប់រក។

ប៉ុន្តែ ព្រះជាម្ចាស់បានគិតថា ពួកអ្នកគង្វាលចៀមទាំងនោះជាមនុស្សសំខាន់ ដែលព្រះអង្គត្រូវការ ពីព្រោះពួកគេជាក្រុមដែលព្រះជាម្ចាស់ទ្រង់ជ្រើសរើស ដើម្បីប្រាប់ពីដំណឹងល្អមុនគេ ហើយក៏បានជ្រើសរើស ដើម្បីឲ្យពួកគេប្រកាសពីដំណឹងល្អប្រាប់អ្នកដទៃមុនគេបង្អស់ដែរ។

នៅយប់នោះ មានពួកអ្នកគង្វាលខ្លះបានចេញទៅនៅឯទីវាល គេនាំគ្នាអាំងភ្លើងកម្តៅខ្លួនស្រាប់តែភ្លាមៗនោះហ្វូងចៀមរបស់គេបានផ្អើលឡើង។ ចៀមទាំងនោះមានការភ័យខ្លាចនឹងអ្វីមួយ។ ដើមអូលីវរង្គើអ្វីហ្នឹងខ្លាំងណាស់ហ្ន៎...សូរសំឡេងទទះស្លាបមែនឬ?



គេងាកមកក្រោយ ឃើញបុរសដ៏មានពន្លឺភ្លឺផ្លេកៗឈរនៅពីមុខ ចាំងរស្មីពីទីងងឹតមក បុរសដ៏មានពន្លឺចាំងចែងនិយាយឡើងថា៖ «សូមកុំខ្លាចខ្ញុំឡើយ ខ្ញុំមិនមែនមក ដើម្បីធ្វើបាបអ្នកទេ ខ្ញុំមកដើម្បីនាំដំណឹងដ៏ល្អមកសម្រាប់មនុស្សគ្រប់ៗគ្នា នៅគ្រប់ទីកន្លែងទាំងអស់ គឺនៅថ្ងៃនេះ ក្នុងទីក្រុងស្តេច ដាវីឌ នៅភូមិបេថ្លេហិម ព្រះរាជបុត្រានៃព្រះបានប្រសូតមក! អ្នកអាចនាំគ្នាទៅមើលព្រះអង្គបាន ព្រះអង្គផ្ទែកនៅក្នុងស្នូកសត្វ»។

នៅពីក្រោយខ្នងទេវតា ពួកគេបានឃើញពពកភ្លឺចម្លែក តែមិនមែនជាពពកឡើយ គឺជាពួកទេវតា...ពួកទេវតាដែលមានជាក្រុមៗ ពេញដោយពន្លឺ! ហើយគេនាំគ្នាច្រៀងចម្រៀងយ៉ាងពីរោះ «សូមថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ សូមឲ្យព្រះនាមទ្រង់បានល្បីល្បាញឡើង! ជយោ! សូមឲ្យទ្រង់បានថ្កើងឡើង!»។

បន្ទាប់ពីបានលេចឡើងមួយរំពេចហើយនោះ ពួកទេវតាក៏បានត្រឡប់ទៅវិញ។

ពួកអ្នកគង្វាលចៀមនាំគ្នាពន្លត់ភ្នក់ភ្លើង ហើយទុកហ្វូងចៀមរបស់ខ្លួនចោល រួចនាំគ្នារត់ចុះពីលើភ្នំកាត់វាលស្មៅ ឆ្លងកាត់ខ្លោងទ្វារភូមិបេថ្លេហិម ឆ្លងកាត់ផ្លូវតូចចង្អៀត កាត់តាមទីផ្សារភូមិ ចុះតាមកាំជណ្តើរមួយកាំៗ ឆ្លងកាត់តាមផ្ទះសំណាក់ បត់តាមជ្រុងផ្លូវ កាត់តាមដុប ទីបំផុតពួកគេក៏បានទៅដល់...



ក្រោលសត្វបាក់បែក។

ពួកគេទាំងនោះហត់ដង្ហក់ តែគេខំនៅស្ងាត់ស្ងៀម រួចដើរលបៗចូលទៅក្នុង។

ពួកគេបានលុតជង្គង់នៅលើដី។ ពួកគេបានឮអំពីសេចក្ដីសន្យាពីទារកនេះ ហើយឥឡូវនេះទ្រង់បានមកដល់មែន។ ទ្រង់ជាបុត្រនៃព្រះអម្ចាស់សួគ៌។ គឺជាអ្នកបង្កើតហ្វូងផ្កាយ។ ជាទារកដែលកំពុងតែផ្ទំលក់នៅលើដៃមាតាទ្រង់។

ទារកនេះនឹងបានដូចជាផ្កាយដ៏ភ្លឺត្រចះត្រចង់ចាំងរស្មីនៅលើមេឃក្នុងយប់នោះ។ ជាពន្លឺដែលបំភ្លឺដល់លោកីយ៍ទាំងមូល។ បណ្ដេញសេចក្ដីងងឹតចេញ។ ជួយមនុស្សឲ្យអាចមើលឃើញ។

ហើយទោះបីជាយប់ងងឹតយ៉ាងណាក៏ដោយ ក៏ផ្កាយនោះរឹតតែភ្លឺចិញ្ចែងកាន់តែខ្លាំងឡើងៗ។



# ស្ដេចលើអស់ទាំងស្ដេច

សាច់រឿងពីអ្នកប្រាជ្ញទាំងបីនាក់ (ដកស្រង់ចេញពីកណ្ឌ ម៉ាថាយ ២)

**នៅឯទិសខាងកើត** មានអ្នកប្រាជ្ញឈ្លាសវៃបីនាក់បានឃើញផ្កាយនោះដែរ។ ផ្កាយដែលព្រះជាម្ចាស់បានតាំងនៅលើមេឃ នៅវេលាដែលព្រះយេស៊ូវបានប្រសូតមក។ ពួកគេបានដឹងថា ផ្កាយនេះជាទីសម្គាល់។ ទារកដែលជាស្ដេចបានប្រសូតហើយ។ ពួកគេបានរង់ចាំមើលផ្កាយនោះ។

ពួកគេដឹងថា ផ្កាយនោះនឹងលេចមកជាពិតមែន។

ពួកគេបានស្រែកឡើងថា៖ «ព្រះអង្គបានមកដល់ហើយ! ព្រះអង្គបានមកដល់ហើយ!» (ហើយខ្ញុំដឹងច្បាស់ថា បើសិនជាអ្នកនៅទីនោះដែរ អ្នកច្បាស់ជាពួកគេសើចសប្បាយរាំច្រៀង រហូតដល់ភ្លឺ)។

ពេលភ្លឺស្រាងឡើង ពួកគេនាំគ្នារៀបចំសត្វអូដ្ឋរបស់ខ្លួន ព្រមទាំងខ្ចប់តង្វាយសម្រាប់ទារកនោះផង ពួកគេបាននាំយកនូវទ្រព្យសម្បត្តិដ៏មានតម្លៃបំផុតដែលពួកគេមានដូចជា៖ ជ័រល្វីងទេស មាស និងកំញាន។ ទ្រព្យដ៏វិសេសចាំងភ្លឺផ្លេក ក្លិនក្រអូបគួរឲ្យចូលចិត្ត ជាគ្រឿងដែលគួរនឹងថ្វាយដល់ស្ដេច។







អ្នកប្រាជ្ញទាំងបីនាក់ (តាមពិតទៅ បើសិនជាអ្នកបានជួបនឹងពួកគេ អ្នកនឹងច្រឡំថា ពួកគេជាស្ដេច ពីព្រោះពួកគេជាអ្នកមានទ្រព្យសម្បត្តិច្រើន ឈ្លាសវៃ ហើយបើមើលពីក្រៅទៅជាមនុស្សសំខាន់ណាស់) ក៏បាននាំគ្នាចេញដំណើរទៅ។



ពួកគេជិះអូដ្ឋរបស់ខ្លួនចេញទៅ...



ឆ្លងកាត់ទីរហោស្ថាន ឆ្ងាយដាច់កន្ទុយភ្នែក...



ឡើងទួលភ្នំដ៏ចោតៗ...



ចុះទៅក្នុងជ្រលងភ្នំដ៏ជ្រៅៗ...



ឆ្លងកាត់ទឹកស្ទឹងដែលហូរយ៉ាងខ្លាំង...



ដើរកាត់តាមទីវាលស្មៅដ៏ធំធេង...

យប់ និងថ្ងៃ ហើយថ្ងៃ និងយប់ រាប់ម៉ោងឆ្លងចូលទៅរាប់ថ្ងៃ ចូលទៅរាប់អាទិត្យ ចូលទៅរាប់ខែ ហើយច្រើនខែ រហូតដល់ទីបញ្ចប់ គេក៏បានមកដល់...



ទីក្រុងយេរូសាឡឹម។

យេរូសាឡឹមគឺជាទីក្រុងមួយដ៏សំខាន់បំផុត គ្មានទីក្រុងណាសំខាន់ស្មើវាទេ ហើយអស់អ្នកណាដែលដឹងអំពីទីក្រុងដែលសំខាន់ នោះគេនឹងប្រាប់លោកអ្នកថា វាគឺជាកន្លែងដែលមានដំណាក់ ហើយពួកស្ដេចក៏នឹងប្រសូតក្នុងដំណាក់នោះដែរ។ ដូច្នេះហើយបានជាពួកគេនាំគ្នាទៅទីនោះ ប៉ុន្តែពួកគេប្រទះនឹងការភ្ញាក់ផ្អើល។

ពួកគេបានចូលទៅជួបស្ដេច ហេរ៉ូឌ។ ពួកគេបានគិតថា ទ្រង់ច្បាស់ជាដឹងថាទារកនោះនៅទីណាហើយ។

ប៉ុន្តែ តាមពិតទៅស្ដេច ហេរ៉ូឌ មិនបានដឹងទេ។ ហើយក៏មិនចូលចិត្តដំណឹងដែរថា មានស្ដេចមួយថ្មីទៀតដែរ។ ការនោះធ្វើឲ្យទ្រង់ខ្វាល់ណាស់។ ទ្រង់មិនចង់ឲ្យអ្នកណាក្រៅពីទ្រង់ធ្វើជាស្ដេចឡើយ គឺឲ្យមានតែព្រះអង្គមួយប៉ុណ្ណោះ។

ប៉ុន្តែ ក្រុមប្រឹក្សារបស់ស្ដេច ហេរ៉ូឌ បានប្រាប់ដល់ហោរា និងអ្នកប្រាជ្ញទាំងបីនេះ ពីសេចក្ដីដែលបានកត់ទុកក្នុងសៀវភៅរបស់ពួកគេ និងអ្វីដែលព្រះជាម្ចាស់បានមានបន្ទូលស្ដីពីទារកដែលនឹងកើតមកធ្វើជាស្ដេចថា៖ «ចូរទៅភូមិបេថ្លេហិមទៅ នៅទីនោះហើយដែលអ្នកនឹងបានឃើញទ្រង់»។

រំពេចនោះ ផ្កាយដែលពួកគេបានឃើញរះនៅទិសខាងកើត ក៏ចាប់ផ្ដើមរំកិលម្ដងទៀតដើម្បីបង្ហាញផ្លូវដល់ពួកគេ។ ដូច្នេះ អ្នកប្រាជ្ញទាំងបីនាក់នេះក៏នាំគ្នាដើរតាមផ្កាយនោះចេញពីទីក្រុងធំនេះ ចូលទៅភូមិតូចមួយដែលគេហៅថា បេថ្លេហិម ពួកគេដើរតាមផ្កាយ ឆ្លងកាត់តាមដងផ្លូវភូមិបេថ្លេហិម ហើយចេញពីកន្លែងមួយដ៏ស្រស់ស្អាត ឆ្លងកាត់ទៅកន្លែងដែលមិនស្រស់ស្អាតចូលទៅដល់កន្លែងមួយទៀតដែលកាន់តែមិនស្រស់ស្អាតទាល់តែសោះនៅក្នុងភូមិនេះ រហូតដល់ចុះទៅតាមផ្លូវតូចដីហុយរហូតដល់ផ្ទះតូចមួយ...ដែលផ្កាយនោះបានឈប់ពី
លើទីនោះ។

ប៉ុន្តែឈប់សិនៗ។ ទីនេះមិនមែនជារាជដំណាក់ឯណា។ ហើយគ្មានអ្នកយាម។ គ្មានពួកអ្នកបម្រើ។ ឬទង់ជ័យ។ កម្រាលព្រំក្រហម។ ស្នូរផ្លុំត្រែ ឬក៏អ្វីផ្សេងទៀតសោះ។ តើពួកគេបានមកខុសកន្លែងទេដឹង?



ឬក៏តើទីនេះហើយដែលជាកន្លែងដែលព្រះជាម្ចាស់មានបន្ទូលសំដៅលើ?

ពិតណាស់ នៅក្នុងផ្ទះតូចនេះគេឃើញព្រះអង្គអង្គុយនៅលើភ្លៅរបស់មាតាទ្រង់។ ទារកនោះគឺជាស្តេចតូច។

អ្នកប្រាជ្ញទាំងបីនាក់ក៏បានលុតជង្គង់ក្រាបចុះនៅចំពោះស្តេចតូច។ ពួកគេនាំគ្នាដោះឈ្នួតក្បាលដ៏មានតម្លៃ និងមកុដមាសដ៏ភ្លឺចាំងថែងរបស់ខ្លួនចេញ។ ពួកគេឱនក្បាលរបស់ខ្លួនចុះដល់ដី ហើយថ្វាយទ្រព្យដ៏មានតម្លៃដល់ទ្រង់។

ដំណើរដែលបានចាប់ផ្តើមជាច្រើនសតវត្សកន្លងមកហើយ បាននាំអ្នកប្រាជ្ញទាំងបីនាក់មកដល់ភូមិតូចនេះ មកដល់ផ្ទះតូចមួយ មកជួបជាមួយនឹងទារកតូច។

មកដល់ស្តេច ដែលព្រះជាម្ចាស់បានសន្យាជាមួយនឹងស្តេច ដាវីឌ ជាច្រើនឆ្នាំកន្លងមកហើយ។

ប៉ុន្តែ ទារកនេះគឺជាស្តេចបែបថ្មី។ ទោះបីទ្រង់ជាព្រះអម្ចាស់នៃស្ថានសួគ៌ក្តី  តែព្រះអង្គបានយាងមកចាប់កំណើតជាអ្នកក្រម្នាក់។ ទោះបីព្រះអង្គជាព្រះដ៏មានគ្រប់ទាំងព្រះចេស្តាយ៉ាងណាក្តី ព្រះអង្គបានត្រឡប់ទៅជាទារកដែលមិនអាចជួយខ្លួនឯងបាន។ ស្តេចអង្គនេះមិនបានយាងមក ដើម្បីធ្វើជាចៅហ្វាយទេ គឺព្រះអង្គបានយាងមក ដើម្បីធ្វើជាអ្នកបម្រើវិញ។





# ស្ថានសួគ៌បានទម្លុះចូលផែនដី

សាច់រឿងរបស់លោក យ៉ូហាន-បាទីស្ទ (ដកស្រង់ចេញពីកណ្ឌ ម៉ាថាយ ៣; លូកា ១; ៣ និងយ៉ូហាន ១)

**ក្នុងពេលដំណាលគ្នា**ដែលព្រះយេស៊ូវបានប្រសូត ក៏មានទារកមួយទៀតបានកើតមកដែរ។ គាត់ឈ្មោះថា យ៉ូហាន ហើយព្រះជាម្ចាស់មានការងារពិសេសមួយសម្រាប់គាត់ គឺគាត់ត្រូវតែរៀបចំឲ្យមនុស្សគ្រប់គ្នាបានត្រៀមខ្លួនជាស្រេចសម្រាប់ព្រះយេស៊ូវ។

នៅថ្ងៃដែលលោក យ៉ូហាន បានកើតមក ឪពុករបស់គាត់បានដឹងច្បាស់ពីសេចក្តីសន្យារបស់ព្រះដល់លោក អ័ប្រាហាំ ថានឹងក្លាយជាការពិត៖ ព្រះជាម្ចាស់នឹងបញ្ជូនអ្នកសង្គ្រោះមួយមក។ ហើយឪពុកគាត់មានអំណរជាខ្លាំងក៏ច្រៀងចម្រៀងមួយបទ៖

ពីព្រោះព្រះជាម្ចាស់ស្រឡាញ់យើង ក្តីស្រឡាញ់នោះគ្មានទីបញ្ចប់
មិនអាចបោះបង់បាន មិនអាចបំបែកចេញបានដែរ
ជាសេចក្តីស្រឡាញ់ដ៏អស់កល្បជានិច្ច។
ស្ថានសួគ៌បានទម្លុះចូលផែនដី!
ព្រះអង្គបានបញ្ជូនពន្លឺមួយពីស្ថានសួគ៌ មកដល់យើង
ដើម្បីបំភ្លឺលើយើង ដូចជាព្រះអាទិត្យ
ដើម្បីបំភ្លឺដល់អស់អ្នកណាដែលរស់នៅក្នុងភាពងងឹត
និងក្នុងម្លប់នៃសេចក្តីស្លាប់
ដើម្បីនាំផ្លូវយើងសំដៅទៅរកផ្លូវនៃសន្តិភាព។

ដូច្នេះ លោក យ៉ូហាន ក៏ចម្រើនវ័យធំធាត់ឡើងល្អណាស់។ សូមបញ្ជាក់ថា គាត់ជាមនុស្សមិនធម្មតាទេ។ គាត់រស់នៅក្នុងទីរហោស្ថាន គាត់ស្លៀកពាក់ខោអាវដែលរមាស់ៗធ្វើពីរោមសត្វអូដ្ឋ។ គាត់មានពុកមាត់វែងស្រមេមស្រមាម និងមានសក់វែងអន្លាយ ហើយចម្លែកជាងនេះទៅទៀតនោះ គឺគាត់បរិភោគតែសត្វកណ្តូបប៉ុណ្ណោះ (សត្វកណ្តូបធំគួរឲ្យខ្លាចប៉ុន្តែស្រួយខ្ទោក) គាត់បានជ្រលក់វានឹងទឹកឃ្មុំ (ប្រហែលដើម្បីបន្ថំរសជាតិ)។



ប៉ុន្តែ ព្រះជាម្ចាស់បានបញ្ជូនលោក យ៉ូហាន ឲ្យមកដើម្បីប្រាប់ដល់រាស្ត្រទ្រង់ពីការសំខាន់ខ្លះៗ។ លោក យ៉ូហាន បាននិយាយថា៖ «ឈប់រត់ចេញពីព្រះជាម្ចាស់ ហើយត្រឡប់មករកព្រះអង្គវិញ អ្នករាល់គ្នាត្រូវការអ្នកជួយសង្គ្រោះ ខ្ញុំមានដំណឹងល្អ អ្នកជួយសង្គ្រោះមកដល់ហើយ! ចូររៀបចំចិត្តអ្នកជាស្រេចសម្រាប់ទ្រង់។ មែនហើយ! ត្រូវត្រៀមខ្លួនជាស្រេច ពីព្រោះស្តេចរបស់អ្នកកំពុងយាងមកដើម្បីអ្នករាល់គ្នា»។

មនុស្សជាច្រើនបានមកស្តាប់លោក យ៉ូហាន។ ពួកគេមានការសោកស្តាយណាស់ដែលខ្លួនបានប្រព្រឹត្តអំពើបាប ហើយពួកគេចង់ឈប់រត់ចេញពីព្រះជាម្ចាស់។ ពួកគេចង់បានអ្នកជួយសង្គ្រោះ។ ដូច្នេះលោក យ៉ូហាន ក៏ធ្វើពិធីជ្រមុជទឹកឲ្យពួកគេ មានន័យថា គាត់ជ្រមុជគេទៅក្នុងទឹក ហើយលើកចេញពីទឹកមកវិញ។ ការនេះបញ្ជាក់ថា ពួកគេចង់ដើរតាមព្រះ ហើយចាប់ផ្តើមជីវិតសាជាថ្មី។



នៅថ្ងៃមួយលោក យ៉ូហាន កំពុងតែធ្វើពិធីជ្រមុជទឹកឲ្យបណ្ដាជនក្នុងទន្លេយ័រដាន់ដូចសព្វដង ពេលដែលគាត់បានងើបភ្នែកឡើង គាត់បានឃើញមនុស្សម្នាក់ដើរចុះមកដល់មាត់ទឹក។

ព្រះជាម្ចាស់បានខ្សឹបតិចៗប្រាប់យ៉ូហានថា៖ «គឺម្នាក់នេះហើយ!»។

បេះដូងលោក យ៉ូហាន បានពុះកញ្ជ្រោលឡើង នេះគឺជាពេលដែលគាត់បានរង់ចាំអស់មួយជីវិតមកហើយ។

លោក យ៉ូហាន បានស្រែកឡើងថា៖ «មើលហ្ន៎!» ទន្ទឹមពេលដែលព្រះយេស៊ូវកំពុងយាងចុះមកក្នុងទឹក។ ប៉ុន្តែ សំឡេងគាត់និយាយចេញមកបែរជាខ្សាវៗទៅវិញ។ គាត់មិនអាចនិយាយឲ្យឮជាងនេះបានទេ គឺគាត់អាចនិយាយបានតែត្រឹមប៉ុណ្ណឹង។ «កូនចៀមរបស់ព្រះជាម្ចាស់...ចៀមដ៏ល្អរបស់ព្រះ...ទ្រង់នឹងទទួលយកនូវអំពើបាបទាំងអស់នៃលោកីយ៍ទាំងមូលចេញ»។

ព្រះយេស៊ូវសួរលោក យ៉ូហាន ថា៖ «តើអ្នកអាចជ្រមុជទឹកឲ្យខ្ញុំផងបានឬទេ?»។

លោក យ៉ូហាន ឆ្លើយថា៖ «តើខ្ញុំជានរណាដែលហ៊ានជ្រមុជទឹកថ្វាយទ្រង់?»។

ព្រះយេស៊ូវឆ្លើយថា៖ «នេះគឺជាការដែលព្រះជាម្ចាស់ចង់ឲ្យខ្ញុំទទួល»។

ដូច្នេះ លោក យ៉ូហាន ក៏បានជ្រមុជទឹកជូនព្រះយេស៊ូវ។



រំពេចនោះ ដូចជាមាននរណាម្នាក់បានទាញបើកវាំងននក្នុងបន្ទប់ងងឹតបើកឡើង គឺដូចជាស្ថានសួគ៌បានបើកចំហឡើងដោយខ្លួនឯងតែម្តង ពីព្រោះមានពន្លឺដ៏ល្អប្រណីតបានបើកឡើងជ្រែកពពក ហើយចាំងរស្មីទៅលើព្រះយេស៊ូវ ឃើញដូចជាទ្រង់បាននៅក្នុងទឹកមាស។ គ្រាប់ទឹកភ្លឺផ្លេកព្រិចៗ ដូចជាគ្រាប់ពេជ្រតូចៗ ចែងចាំងនៅលើសក់ទ្រង់។

មានសត្វព្រាបពណ៌សហោះចុះមក ហើយទំយ៉ាងរំភើយលើព្រះយេស៊ូវ។

ហើយមានឮសំឡេងចុះពីស្ថានសួគ៌មក លាន់ឮយ៉ាងខ្លាំង ហើយច្បាស់ ដូច្នេះគ្រប់គ្នាអាចស្តាប់ឮថា៖ «នេះជាកូនស្ងួនភ្ងារបស់យើង យើងស្រឡាញ់ទ្រង់ យើងពេញចិត្តនឹងទ្រង់ណាស់» រួចព្រះជាម្ចាស់មានបន្ទូលទៀតថា៖ «ចូរស្តាប់តាមទ្រង់ចុះ»។

ស្ថានសួគ៌បានទម្លុះចូលផែនដី។

សេចក្តីសង្គ្រោះដ៏ធំអស្ចារ្យបានចាប់ផ្តើមហើយ...



# តោះ! យើងទៅ!

ព្រះយេស៊ូវជួបការល្បួងនៅទីរហោស្ថាន ហើយព្រះអង្គបានជ្រើសរើសអ្នកជំនួយការរបស់ទ្រង់

(ដកស្រង់ចេញពីកណ្ឌ ម៉ាថាយ ៤; ម៉ាកុស ១ និងលូកា ៤-៦)

**បន្ទាប់ពីពេល**ដែលព្រះយេស៊ូវបានទទួលពិធីបុណ្យជ្រមុជទឹកហើយ នោះទ្រង់បានយាងតម្រង់ទៅទីរហោស្ថាន។ មើលទៅហាក់ដូចជាកន្លែងចម្លែកមិនគួរទៅសោះ ពីព្រោះដូចអ្នកដឹងហើយថា ទីរហោស្ថានជាកន្លែងដែលក្តៅបំផុត ហើយនៅទីនោះគ្មានម្ហូបអាហារ គ្មានទឹក និងកន្លែងស្នាក់នៅទេ។ ប៉ុន្តែ ព្រះយេស៊ូវទ្រង់ត្រូវការយាងទៅឲ្យឆ្ងាយ ទៅកន្លែងដែលស្ងាត់ស្ងៀមតែម្នាក់ឯង។ ព្រះអង្គត្រូវការជួបជាមួយនឹងព្រះវរបិតាទ្រង់ ដើម្បីរៀបចំសម្រាប់ជីវិតថ្មីរបស់ទ្រង់។

នៅទីរហោស្ថាន ព្រះយេស៊ូវទ្រង់បានត្រិះរិះគិតពីគម្រោងសម្ងាត់នៃការសង្គ្រោះដែលព្រះអង្គបានរៀបចំជាមួយព្រះវរបិតាទ្រង់ មុនពេលដែលកកើតផែនដីមកម្ល៉េះ។ ព្រះអង្គ និងព្រះវរបិតាបានជ្រាបជាស្រេចថា ដើម្បីជួយសង្គ្រោះរាស្ត្ររបស់ទ្រង់ ព្រះយេស៊ូវត្រូវតែទទួលការសុគត គឺគ្មានផ្លូវឯណាទៀតឡើយ។ នេះឯងជាមូលហេតុនៃការយាងមករបស់ព្រះអង្គ។

ប៉ុន្តែ សត្រូវចាស់របស់ព្រះអង្គ គឺជាអ្នកដែលនិយាយតាមរយៈសត្វពស់ទៅលោក អ័ដាម និងនាង អេវ៉ា កាលពីនៅក្នុងសួនច្បារ។ តើអ្នកនៅចាំវាទេ? វាមិនចង់ឲ្យព្រះយេស៊ូវជួយសង្គ្រោះរាស្ត្រទ្រង់ឡើយ ដូច្នេះវាបានកុហកព្រះយេស៊ូវថា៖ «តើអ្នកពិតជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់មែនឬ?»។

វាខ្សឹបថា៖ «ឱ! អ្នកដែលគួរឲ្យអាណិតអើយ! ព្រះជាម្ចាស់ច្បាស់ជាមិនស្រឡាញ់អ្នកទេ អ្នកមិនគួរនឹងត្រូវស្លាប់ទេ ចូរធ្វើតាមខ្ញុំវិញ នោះអ្នកនឹងបាន...»។

ព្រះយេស៊ូវឆ្លើយទៅអាកំភូតនោះវិញថា៖ «ទេ! យើងនឹងធ្វើតាមអ្វីដែលព្រះជាម្ចាស់មានបន្ទូល»។

ចាប់ពីពេលនោះមក គ្មានអ្វីដែលនៅដដែលទៀតនោះទេ។

ព្រះយេស៊ូវមិនដូចលោក អ័ដាម ទេ ព្រះយេស៊ូវជាមនុស្សសណ្ឋានថ្មី ព្រះអង្គមិនជឿសេចក្តីកំភូតដ៏អាក្រក់របស់សត្រូវនេះទេ។ ព្រះយេស៊ូវជ្រាបថា ព្រះជាម្ចាស់ស្រឡាញ់ព្រះអង្គ ហើយព្រះអង្គត្រូវតែទុកចិត្តលើទ្រង់ ទោះជាយ៉ាងណាក៏ដោយ។

ដូចដែលព្រះជាម្ចាស់បានសន្យាជាមួយនឹងលោក អ័ដាម និងនាង អេវ៉ា ជាច្រើនឆ្នាំកន្លងមកហើយ។ ព្រះយេស៊ូវនឹងយាងមក ដើម្បីតតាំង ទាស់ជាមួយនឹងការងាររបស់សត្វពស់។ ទ្រង់នឹងកំចាត់អំពើបាប ភាពងងឹត និងជូតទឹកភ្នែកពីភ្នែកគេចេញ ហើយព្រះអង្គនឹងត្រូវរងទុក្ខ ប៉ុន្តែ ព្រះអង្គនឹងទទួលបានជ័យជម្នះ។







ព្រះយេស៊ូវបានយាងចេញពីទីរហោស្ថាន ដើម្បីរៀបចំសេចក្តីសង្គ្រោះដ៏អស្ចារ្យ។ ព្រះអង្គនឹងប្រមូលរាស្ត្ររបស់ព្រះជាម្ចាស់មកវិញ។

ប៉ុន្តែ ជាដំបូងព្រះអង្គត្រូវរកមិត្តភក្តិ និងអ្នកជំនួយ។ មានការជាច្រើនដែលត្រូវធ្វើ ដូច្នេះព្រះអង្គត្រូវការមនុស្សមួយចំនួន ដើម្បីជាជំនួយដល់ទ្រង់។

តើអ្នកគិតថា នរណាដែលជាអ្នកជំនួយល្អ? ជាអ្នកឈ្លាសវៃ? ជាអ្នកមាន? ជាអ្នកខ្លាំងពូកែ? ជាមនុស្សសំខាន់? មានមនុស្សខ្លះបានគិតយ៉ាងដូច្នេះ ប៉ុន្តែ អ្នកក៏ដឹងច្បាស់ណាស់ហើយ នៅពេលនេះអ្នកមិនចាំបាច់ឲ្យខ្ញុំប្រាប់អ្នកថា គេបានគិតខុសឡើយ។ ពីព្រោះមនុស្សដែលព្រះជាម្ចាស់ត្រូវប្រើនោះមិនចាំបាច់មានចំណេះដឹងច្រើន ឬក៏ជាអ្នកដែលមានទ្រព្យសម្បត្តិច្រើននោះទេ តាមពិតទៅពួកគេគ្រាន់តែត្រូវការទ្រង់ច្រើនជាងនោះបានហើយ។

នៅថ្ងៃមួយ ព្រះយេស៊ូវបានយាងតាមឆ្នេរសមុទ្រកាលីឡេ ហើយព្រះអង្គបានឃើញបងប្អូន និងមិត្តភក្តិខ្លះកំពុងជួសជុលអួនរបស់ខ្លួន។ ពួកគេជាអ្នកនេសាទត្រីក្រ។

ព្រះយេស៊ូវបានស្រែកហៅពួកគេ «តោះ! យើងទៅ!»។





ពេត្រុស អនទ្រេ យ៉ាកុប និងយ៉ូហាន បានក្រឡេកមើលមនុស្សម្នាក់នេះនៅឯឆ្នេរសមុទ្រ។ ពួកគេមិនដឹងថាគួរពន្យល់យ៉ាងដូចម្តេច៖ ពួកគេត្រូវការយកទូកទៅទុក ជួសជុលអួន ហើយត្រីនៅលោតពេញឆ្នេរ។ ប៉ុន្តែមានចំណុចចម្លែកខ្លះអំពីជនម្នាក់នេះ ដែលបណ្តាលឲ្យពួកគេទម្លាក់សំណាញ់ និងត្រីចោល ហើយចាកចេញពីទូកខ្លួន–បើនិយាយឲ្យខ្លីទៅ គឺចោលទាំងអស់–ហើយដើរតាមទ្រង់។

ពួកគេមិនដែលជួបប្រទះបុគ្គលដែលជាព្រះផងនិងមនុស្សផងទេ។ នៅពេលដែលពួកគេបានមើលទៅឯព្រះយេស៊ូវ ចិត្តរបស់ពួកគេពោរពេញទៅដោយភាពអស្ចារ្យ និងភាពរីករាយជារៀងរហូត ហើយនៅក្នុងចិត្តរបស់គេមានអារម្មណ៍ដូចជាគេរត់ដោយសេរីនៅទីវាលដ៏ល្អល្ហេវមួយអញ្ចឹង។

ព្រះយេស៊ូវបានហៅមនុស្ស១២នាក់ធ្វើជាអ្នកជំនួយការរបស់ព្រះអង្គគឺ៖ ពេត្រុស អនទ្រេ យ៉ាកុប និងយ៉ូហាន ម៉ាថាយ  ភីលីព បារថូល៉ូមេ ថូម៉ាស យ៉ាកុបមួយទៀត ស៊ីម៉ូន ថាដេ និង យូដាស។

ការជួបព្រះយេស៊ូវបានបំផ្លាស់បំប្រែជីវិតរបស់ពួកគេជារៀងរហូតតទៅ។

# ក្មេងស្រីតូច និងស្ត្រីកម្សត់ម្នាក់

សាច់រឿងអំពីកូនស្រីរបស់លោក យ៉ៃរ៉ុស (ដកស្រង់ចេញពីកណ្ឌ លូកា ៨)

**នាពេលមួយ** មានក្មេងស្រីតូចម្នាក់ នៅពេលព្រឹកមួយនាងមិនអាចងើបចេញពីគ្រែបានទេ ហើយស្អែកឡើងក៏មិនអាច ហើយនិងខានស្អែកមួយទៀត ក៏ស្រីតូចម្នាក់នោះនៅតែមិនអាចងើបចេញពីគ្រែបានដដែល។ ប៉ុន្តែ តាមពិតទៅ នាងមិនបានក្រោកចេញពីគ្រែអស់រយៈពេលពេញមួយខែហើយ។ នាងមានជំងឺដ៏ធ្ងន់ដែលគ្មាននរណាម្នាក់អាចព្យាបាលនាងឲ្យបានជាសះស្បើយបានឡើយ។

លោក យ៉ៃរ៉ុស ជាឪពុករបស់នាង គាត់ស្រឡាញ់នាងណាស់។ ថ្ងៃមួយ ពេលដែលគាត់កំពុងអង្គុយនៅលើគ្រែក្បែរនាង កាន់ដៃនាង ហើយមានចិត្តចង់ធ្វើអ្វីគ្រប់យ៉ាង ដើម្បីនឹងជួយនាង។ «អ៊ុំ! ខ្ញុំដឹងហើយ!» រួចគាត់បានស្ទុះងើបឡើង ទាញអាវធំមកពាក់ ឱនថើបកូនស្រីរបស់គាត់ ហើយក៏រត់ចុះតាមកាំជណ្ដើរម្ដងមួយកាំៗ រត់កាត់អ្នកបម្រើ ចេញពីផ្ទះ...កាត់តាមច្រកទ្វាររបង ទៅតាមផ្លូវកាត់តាមភូមិ ឡើងជណ្ដើរមួយកាំៗ ហើយចូលទៅក្នុងព្រះវិហារ។

គាត់បានប្រជ្រៀតចូលតាមហ្វូងមនុស្សរហូតទាល់តែគាត់បានជួបអ្នកដែលគាត់បានតាមរក។







គាត់និយាយថា៖ «ព្រះយេស៊ូវ!» រួចគាត់ទម្លាក់ខ្លួនក្បែរជើងព្រះយេស៊ូវ អង្វរថា៖ «សូមអាណិតមេត្តាកូនស្រីខ្ញុំផង»។

ប៉ុន្តែ គាត់មិនចាំបាច់ទាំងអង្វរផង ពីព្រោះគាត់ពុំទាន់បានឈប់និយាយផង នោះព្រះយេស៊ូវក៏បានលូកចាប់ដៃទាញគាត់ឲ្យក្រោកឈរឡើង ហើយមានបន្ទូលថា៖ «ខ្ញុំនឹងចេញទៅឥឡូវនេះ»។

លោក យ៉ៃរ៉ុស មានទឹកភ្នែករលីងរលោង ព្រោះព្រះយេស៊ូវកំពុងតែយាងមក អ្វីៗប្រាកដជានឹងបានប្រសើរជាមិនខាន។

ជាការពិតណាស់ នៅជំនាន់នោះ គេពុំទាន់មានឡានពេទ្យសង្គ្រោះបន្ទាន់ទេ ដូច្នេះគេត្រូវតែដើរថ្មើរជើង។ អ្នកជំនួយរបស់ព្រះយេស៊ូវដឹងថា ព្រះអង្គអាចប្រោសក្មេងស្រីដែលឈឺនេះឲ្យបានជាសះស្បើយ ប៉ុន្តែ ពួកគេត្រូវតែប្រញាប់បន្តិច ប្រសិនជាព្រះយេស៊ូវមិនប្រញាប់ទេ នោះច្បាស់ជាហួសពេលហើយ។

ប៉ុន្តែ មានមនុស្សពាសពេញផ្លូវរុញច្រានគ្នាច្របូកច្របល់ ប្រជ្រៀត និងដើរប៉ះគ្នា។ ពួកសិស្សទ្រង់នាំគ្នារត់ទៅមុខ ញែកហ្វូងមនុស្ស។

ភ្លាមៗនោះព្រះយេស៊ូវទ្រង់បានឈប់ មិត្តសម្លាញ់របស់ព្រះអង្គបានងាកក្រោយមើល តើព្រះអង្គកំពុងធ្វើអ្វីហ្នឹង?

ព្រះយេស៊ូវសួរថា៖ «អ្នកណាពាល់ខ្ញុំ?» ពីព្រោះព្រះអង្គបានដឹងថា មានអំណាចបានចេញពីព្រះអង្គទៅ។

នោះមានស្ត្រីទន់ខ្សោយម្នាក់បានឆ្លើយថា៖ «ខ្ញុំម្ចាស់» ដោយឱនមុខចុះ ព្រោះគាត់មានការអៀនខ្មាស។ ស្ត្រីកម្សត់ម្នាក់នេះមានជំងឺដប់ពីរឆ្នាំមកហើយ គាត់ចង់ជាពីជំងឺនេះណាស់។ ហើយគាត់បានដឹងថា បើគាត់គ្រាន់តែបានប៉ះអាវវែងរបស់ព្រះយេស៊ូវ នោះគាត់នឹងបានជាសះស្បើយមិនខាន។ ដូច្នេះ នៅពេលដែលគាត់បានប៉ះអាវវែងរបស់ព្រះយេស៊ូវ រំពេចនោះស្រាប់តែគាត់ក៏បានជាភ្លាមៗតែម្តង។



មិត្តសម្លាញ់របស់ព្រះយេស៊ូវបាននិយាយថា៖ «យើងអត់មានពេលទៀតទេ!»។

ប៉ុន្តែ ព្រះយេស៊ូវមានពេលជានិច្ច។ ព្រះអង្គលូកដៃទ្រង់ទៅងើយក្បាលស្ត្រីនោះឡើងដោយថ្នមៗ។ ព្រះអង្គបានសម្លឹងមើលចំភ្នែកគាត់ ហើយញញឹម។ បន្ទាប់មកក៏មានបន្ទូលថា៖ «អ្នកបានជឿ» រួចទ្រង់បានជូតទឹកភ្នែកពីភ្នែកគាត់ចេញ ហើយបន្តមានបន្ទូលទៀតថា៖ «ឥឡូវនេះ អ្នកបានជាហើយ»។

នៅពេលនោះ អ្នកបម្រើរបស់លោកយ៉ៃរ៉ុស បានរត់មកប្រាប់ ទាំងហត់ដង្ហក់ថា៖ «ហួសពេលហើយលោក! កូនស្រីរបស់លោកម្ចាស់បានស្លាប់បាត់ទៅហើយ»។

ព្រះយេស៊ូវងាកមករកលោក យ៉ៃរ៉ុស ដោយមានបន្ទូលថា៖ «មិនទាន់ហួសពេលទេ ចូរទុកចិត្តលើខ្ញុំចុះ»។

នៅផ្ទះរបស់លោក យ៉ៃរ៉ុស គ្រប់គ្នាកំពុងតែយំសោក។ ប៉ុន្តែ ព្រះយេស៊ូវមានបន្ទូលថា៖ «ខ្ញុំនឹងដាស់នាងឡើង» ហើយគ្រប់គ្នាបានសើចចំអកឲ្យព្រះយេស៊ូវ ពីព្រោះគេបានដឹងថា នាងបានស្លាប់រួចទៅហើយ។





ព្រះយេស៊ូវយាងចូលទៅបន្ទប់គេងក្មេងស្រីតូចនោះ។ ហើយនៅក្បៀនជ្រុងជញ្ជាំងដ៏ងងឹតនោះ គឺមានរូបកាយក្មេងស្រីតូចនោះកំពុងតែនៅយ៉ាងស្ងៀម។ ព្រះយេស៊ូវទ្រង់គង់លើគែមគ្រែ ហើយបានលើកដៃដ៏ស្លេកស្លាំងរបស់នាងឡើង។

ព្រះអង្គមានបន្ទូលថា៖ «កូនសម្លាញ់អើយ! ដល់ម៉ោងក្រោកហើយ» រួចទ្រង់លូកដៃពាល់រូបកាយដែលស្លាប់ស្ដូកស្ដឹងនេះ ធ្វើឲ្យរូបកាយកូនស្រីតូចនេះមានជីវិតឡើងវិញ។

ក្មេងស្រីតូចនេះបានភ្ញាក់ឡើង ឈ្លីភ្នែកនាងហាក់បីដូចជានាងទើបតែភ្ញាក់ពីគេងលក់យ៉ាងស្កប់ស្កល់ ហើយបានលោតចុះពីគ្រែ។

ព្រះយេស៊ូវបានបើកវាំងននបង្អួច ហើយពន្លឺព្រះអាទិត្យចូលមកបំភ្លឺបន្ទប់ងងឹតនោះ។ ព្រះយេស៊ូវសួរថា៖ «តើនាងឃ្លានទេ?» នាងងក់ក្បាល។

ហើយព្រះយេស៊ូវក៏បានហៅគ្រួសារនាងមកដោយនិយាយថា៖ «យកអាហារពេលព្រឹកខ្លះមកឲ្យនាងញ៉ាំផង!»។

ព្រះយេស៊ូវទ្រង់បានជួយ និងប្រោសអ្នកជំងឺជាច្រើនដូចនេះដែរ ព្រះអង្គបានប្រោសមនុស្សខ្វាក់ឲ្យមើលឃើញ មនុស្សថ្លង់ឲ្យស្ដាប់ឮ ព្រះអង្គប្រោសមនុស្សខ្វិនឲ្យដើរបាន។

ព្រះយេស៊ូវកំពុងបង្វែរភាពសោកសង្រេងឲ្យទៅជាភាពអរសប្បាយ។

ទ្រង់កំពុងស្ដារនូវភាពខ្ទេចខ្ទាំនៃលោកីយ៍របស់ព្រះជាម្ចាស់ឡើងវិញ។



# របៀបអធិស្ឋាន

ព្រះយេស៊ូវបង្រៀនបណ្ដាជនពីរបៀបអធិស្ឋាន (ប្រើពាក្យផ្សេង តែមានន័យដូចគ្នានឹងការអធិស្ឋាន
របស់ព្រះអម្ចាស់ ដកស្រង់ចេញពីកណ្ឌ ម៉ាថាយ ៦)

**នៅក្នុងជំនាន់នោះ** មានមនុស្សមួយចំនួនដែលបាននឹកគិតថាខ្លួនមានលក្ខណៈបរិសុទ្ធបំផុតលើសគេ ហើយពួកគេនោះគឺពួក «ផារិស៊ី»។ ជារៀងរាល់ថ្ងៃ ពួកគេតែងតែនាំគ្នាឈរនៅកណ្ដាលផ្លូវ ហើយអធិស្ឋានស្រែកខ្លាំងៗ ដោយរាប់សំឡេងខ្លួនថាបរិសុទ្ធក្រៃលែងណាស់។ តាមពិតទៅពួកគេមិនបានអធិស្ឋានទេ តែគ្រាន់តែចង់សម្ដែងឲ្យពួកបណ្ដាជនបានឃើញប៉ុណ្ណោះ។ គេបានប្រើពាក្យពេចន៍ពិសេសៗជាច្រើន ដែលស្ដាប់ទៅដូចជាឈ្លាសវៃណាស់ តែគ្មានអ្នកណាម្នាក់អាចនឹងយល់ន័យរបស់គេសោះ។

មនុស្សដើរកាត់ទីនោះ បានឈប់ ហើយងាកមើលទៅពួកគាត់ ដោយគិតថាវាដូចជាមិនទំនងសោះ ប៉ុន្តែនេះជាអ្វីដែលអ្នកទាំងនោះចូលចិត្ត។ ពួកគេចង់ឲ្យគ្រប់គ្នានិយាយថា៖ «មើលទៅពួកគេនោះ គេបរិសុទ្ធណាស់ ព្រះជាម្ចាស់ច្បាស់ជាស្រឡាញ់ពួកគេខ្លាំងហើយមើលទៅ»។

អ្នក និងខ្ញុំបានដឹងហើយថា ពួកគេធ្វើបែបនេះខុសហើយ ព្រះជាម្ចាស់មិនគ្រាន់តែស្រឡាញ់តែពួកអ្នកបរិសុទ្ធនោះទេ។ ប៉ុន្តែ ពួកអ្នកដែលដើរក្បែរពួកគេពុំយល់ច្បាស់ពីការនេះឡើយ។ ពួកគេបានគិតថា ប្រហែលជាអ្នកត្រូវមានភាពឈ្លាសវៃ ការល្អ ឬក៏ភាពសំខាន់ខ្លាំង ដើម្បីទាក់ទាញឲ្យព្រះជាម្ចាស់ស្រឡាញ់អ្នក។ ឬក៏ថាប្រហែលជាអ្នកត្រូវការរកពាក្យពេចន៍ឈ្លាសវៃ ដើម្បីនិយាយទៅកាន់ព្រះជាម្ចាស់ទេដឹង?



ដូច្នេះហើយបានជាមានថ្ងៃមួយ ព្រះយេស៊ូវបានបង្រៀនដល់ពួកបណ្ដាជនពីរបៀបដែលត្រូវអធិស្ឋាន។ ព្រះអង្គមានបន្ទូលថា៖ «នៅពេលអ្នកអធិស្ឋាន កុំអធិស្ឋានដូចជាពួកអ្នកដែលគិតថាខ្លួនបរិសុទ្ធជាងគេនោះឡើយ។ ពួកគេគិតថា បើពួកគេនិយាយច្រើន នោះព្រះជាម្ចាស់នឹងស្ដាប់ពួកគេ។ ប៉ុន្តែ មិនមែនដោយព្រោះអ្នកឈ្លាសវៃជាងគេ ឬល្អ ឬជាមនុស្សសំខាន់ជាងគេ ទើបព្រះជាម្ចាស់ស្ដាប់អ្នកឡើយ។ ព្រះជាម្ចាស់ស្ដាប់អ្នក ពីព្រោះព្រះអង្គស្រឡាញ់អ្នក»។

ព្រះអង្គបន្តប្រាប់ពួកគេថា៖ «តើអ្នកដឹងទេថា ព្រះជាម្ចាស់តែងតែស្ដាប់អ្នកជានិច្ច? តើអ្នកដឹងទេថា ព្រះជាម្ចាស់អាចនឹងជ្រាបអ្វីដែលអ្នកខ្សឹបខ្សៀវដែលលាក់លៀមនៅក្នុងចិត្តរបស់អ្នក សូម្បីតែមុនពេលដែលអ្នកហាមាត់និយាយចេញមកទៅទៀតនោះ? ពីព្រោះព្រះជាម្ចាស់ជ្រាបនូវអ្វីៗដែលអ្នកត្រូវការ មុននឹងអ្នកហាមាត់សូមព្រះអង្គទៅទៀត!»។

«អ្នកឃើញទេ ព្រះជាម្ចាស់តែងតែចង់ឲ្យអ្នកនូវអ្វីៗដែលអ្នកត្រូវការ។ ដូច្នេះ អ្នកមិនចាំបាច់ប្រើប្រាស់ពាក្យពេចន៍ជាច្រើន ឬក៏ពិសេសឡើយ។ អ្នកគ្រាន់តែនិយាយសាមញ្ញៗតែប៉ុណ្ណោះ»។

«ដូច្នេះ ពេលដែលអ្នកអធិស្ឋាន ចូរអធិស្ឋានដោយប្រើប្រាស់ពាក្យសាមញ្ញៗ ដូចជាពេលអ្នកនិយាយទៅអ្នកណាម្នាក់ដែលអ្នកស្រឡាញ់ពេញចិត្តយ៉ាងខ្លាំងបំផុត។
គឺបែបដូច្នេះ...



ឱ! ព្រះបិតាអើយ!
កូនចង់ស្គាល់ព្រះបិតា
និងចង់នៅជិតព្រះបិតា
សូមព្រះបិតាមេត្តាបង្ហាញដល់កូនឲ្យដឹងថា ត្រូវធ្វើបែបណា។
សូមព្រះបិតាធ្វើឲ្យគ្រប់យ៉ាងក្នុងលោកីយ៍បានល្អ
ស្អាតជាថ្មីហើយនៅក្នុងចិត្តរបស់កូនផងដែរ។
សូមព្រះបិតាធ្វើអ្វីដែលល្អបំផុត ដូចដែលព្រះបិតាបានធ្វើនៅស្ថានសួគ៌
សូមព្រះបិតាមេត្តាធ្វើនៅលោកីយ៍នេះ ដូចគ្នានៅស្ថានសួគ៌យ៉ាងនោះដែរ។
សូមព្រះបិតាមេត្តាប្រទាននូវអ្វីដែលកូនត្រូវការក្នុងថ្ងៃនេះ។
សូមព្រះបិតាអត់ទោសនូវអ្វីដែលកូនបានធ្វើខុស នូវអ្វីដែលកូនធ្វើឲ្យព្រះបិតាឈឺចាប់។
សូមអត់ទោសសេចក្តីកំហុសរបស់កូន ដូចជាកូនបាន
អត់ទោសដល់អ្នកដែលបានធ្វើខុសដល់កូនដែរ
ពេលដែលគេធ្វើឲ្យយើងឈឺចាប់
សូមជួយសង្គ្រោះកូន! កូនត្រូវការព្រះអង្គ
កូនមិនចង់រត់ចេញទៅឆ្ងាយពីព្រះបិតា
និងលាក់ខ្លួនពីព្រះបិតាទៀតទេ។
សូមការពារកូនពីខ្មាំងសត្រូវរបស់កូន។
ព្រះបិតាជាព្រះជាម្ចាស់ដែលមានអំណាចខ្លាំង
ព្រះបិតាអាចធ្វើអ្វីដែលព្រះបិតាចង់ធ្វើ។
ព្រះបិតាជាអ្នកគ្រប់គ្រងលើអ្វីៗគ្រប់ទាំងអស់។
ក្នុងពេលឥឡូវនេះ និងរៀងរហូតអស់កល្បជានិច្ច!
កូនដឹងថា ព្រះបិតាធំអស្ចារ្យណាស់!
អាម៉ែន! ពិតមែន កូនដឹង!

អ្នកឃើញទេ ព្រះយេស៊ូវបានបង្ហាញមនុស្សទាំងអស់ថា ព្រះជាម្ចាស់តែងតែស្រឡាញ់ពួកគេ គ្មានទីបញ្ចប់ មិនអាចបោះបង់បាន មិនអាចបំបែកចេញបានដដែល ជាសេចក្តីស្រឡាញ់ដ៏អស់កល្បជានិច្ច។

ដូច្នេះ ពួកគេមិនត្រូវរត់ពួន ឬមានការភ័យខ្លាច ឬមានការខ្មាសអៀនទៀតទេ ពួកគេអាចនឹងឈប់រត់គេចចេញទៅឆ្ងាយពីព្រះជាម្ចាស់ទៀត។ ហើយពួកគេអាចនឹងរត់ត្រឡប់មករកព្រះអង្គវិញ។

គឺដូចជាក្មេងតូច ដែលរត់ចូលទៅក្នុងរង្វង់ដៃរបស់ឪពុកដែរ។



# អ្នកចម្រៀង

ការបង្រៀននៅលើភ្នំ (ដកស្រង់ចេញពីកណ្ឌ ម៉ាថាយ ៦; ៩ និងលូកា ១២)

**គ្រប់កន្លែង**ដែលព្រះយេស៊ូវទ្រង់យាងទៅ មានមនុស្សជាច្រើនបានទៅតាមទ្រង់ដែរ។ ពួកគេទាំងចាស់ទាំងក្មេង ចូលចិត្តនៅក្បែរព្រះអង្គ។ មនុស្សគ្រប់បែបយ៉ាងបានមកជួបព្រះយេស៊ូវ គឺទាំងមនុស្សឈឺ និងមនុស្សជា ហើយទាំងមានមនុស្សសប្បាយចិត្ត មនុស្សកើតទុក្ខកង្វល់ និងមនុស្សមានចិត្តថប់បារម្ភ ក៏មានមនុស្សជាច្រើនគេព្រួយបារម្ភច្រើនបែបច្រើនយ៉ាង។ តើមានការអ្វីកើតឡើង បើសិនជាយើងគ្មានម្ហូបអាហារគ្រប់គ្រាន់? គ្មានខោអាវ? ចុះបើយើងអស់លុយ?

ចុះបើសិនជាគ្មានអ្វីគ្រប់គ្រាន់? ហើយគ្រប់ទាំងអស់ធ្លាក់ទៅក្នុងស្ថានភាពដ៏អាក្រក់? ហើយយើងមិនមានភាពសុខស្រួលទាល់តែសោះ? តើនឹងមានការអ្វីកើតឡើងទៅ?

នៅពេលដែលព្រះយេស៊ូវបានឃើញមនុស្សទាំងអស់នោះ ចិត្តរបស់ព្រះអង្គពោរពេញទៅដោយសេចក្តីស្រឡាញ់ចំពោះពួកគេ។ ពួកគេប្រៀបបីដូចជាហ្វូងចៀមតូចមួយ ដែលគ្មានអ្នកគង្វាលមើលថែទាំ និងរក្សាគេឡើយ។ ដូច្នេះហើយបានជាព្រះយេស៊ូវឲ្យគេអង្គុយចុះ រួចព្រះអង្គនិយាយទៅកាន់ពួកគេ។

ពួកមនុស្សទាំងអស់នោះបានអង្គុយចុះយ៉ាងស្ងៀមស្ងាត់នៅលើស្មៅក្បែរជើងភ្នំ ដើម្បីចាំស្តាប់។ នៅពីលើកំពូលភ្នំនោះ ពួកគេអាចមើលឃើញបឹងពណ៌ខៀវចាំងពន្លឺផ្លេកៗខាងក្រោមពួកគេ និងឃើញទូកនេសាទតូចៗចូលមកចតក្រោយដែលបានចេញទៅនេសាទកាលពីយប់មិញ។ ហើយខ្យល់នៃរដូវស្លឹកឈើលាស់ ធ្លាក់មកត្រជាក់ ហើយខ្យល់អាកាសបរិសុទ្ធទៀតផង។





ព្រះយេស៊ូវមានបន្ទូលថា៖ «អ្នកឃើញសត្វចាបដែលទំនៅទីនោះដែរឬទេ?»។

គ្រប់គ្នាបានសម្លឹងមើលទៅកូនចាបកំពុងចឹកគ្រាប់ពូជនៅតាមបណ្ដោយផ្លូវក្រាលថ្ម។

«តើវាបានអាហារពីណាមក? ប្រហែលជាពួកវាមានជង្រុកសម្រាប់ទុកដាក់? ឬមានទូផ្ទុកពេញដោយអាហារឬ?»។

គ្រប់គ្នាអស់សំណើច តើមានអ្នកណាម្នាក់ធ្លាប់បានឃើញសត្វចាបយួរកន្ត្រកអាហារដែរឬទេ?

ព្រះយេស៊ូវមានបន្ទូលថា៖ «ទេ! វាមិនចាំបាច់ខ្វល់ពីរឿងនោះទេ ពីព្រោះព្រះជាម្ចាស់បានដឹងពីអ្វីដែលពួកវាត្រូវការរួចទៅហើយ ហើយព្រះអង្គចិញ្ចឹមពួកវា»។



ព្រះយេស៊ូវបន្តសួរថា៖ «ហើយចុះផ្កាព្រៃទាំងនេះវិញ?»។

គ្រប់គ្នាបានក្រឡេកមើលជុំវិញខ្លួន ឃើញផ្កាដែលកំពុងតែដុះ មានផ្កាអូគីដេ ផ្កាឈូក ផ្កាព្រលិតពណ៌ស។

«តើវាបានខោអាវស្អាតពីណាមក? តើវាកាត់ខោអាវនោះឬ? ឬក៏វាទៅធ្វើការរាល់ថ្ងៃដើម្បីទិញខោអាវទាំងនេះ? តើវាមានទូសម្លៀកបំពាក់ពេញដោយខោអាវឬ?»។

គ្រប់គ្នាបានអស់សំណើចម្ដងទៀត តើមាននរណាម្នាក់ធ្លាប់បានឃើញផ្កាស្លៀកសំពត់ឬទេ?

ព្រះយេស៊ូវមានបន្ទូលថា៖ «ទេ វាមិនចាំបាច់ខ្វល់អំពីរឿងនោះទេ ពីព្រោះព្រះជាម្ចាស់បានបំពាក់អាវផាយដែលមានភាពរុងរឿងឲ្យវារួចទៅហើយ សូម្បីតែស្ដេចក៏មិនបានស្លៀកពាក់បានប៉ុណ្ណឹងដែរ!»។



ពួកគេមិនដែលជួបស្ដេចមួយអង្គណាទេ ប៉ុន្តែខណៈដែលពួកគេបានសម្លឹងទៅបឹង ឃើញមានពន្លឺភ្លឺផ្លេកៗប្រដេញគ្នាលេចចេញពីក្រោមពួកគេ ហើយនៅនឹងចង្កេះភ្នំមានពេញទៅដោយពណ៌ក្រហម ពណ៌ស្វាយ និងពណ៌ទឹកមាស ពួកគេមានអារម្មណ៍ធូរទ្រូងយ៉ាងខ្លាំងពីបន្ទុកដ៏ធ្ងន់របស់ខ្លួន។ ហើយពួកគេមិនអាចនឹកគិតស្មានពីអ្វីដែលស្រស់ស្អាតដែលប្រសើរជាងនេះទៅទៀតទេ។

ព្រះយេស៊ូវបន្តមានបន្ទូលទៀតថា៖ «កូនតូចៗអើយ! អ្នករាល់គ្នាសំខាន់ជាងសត្វចាបទៅទៀត! ក៏សំខាន់ជាងផ្កាព្រៃទាំងនោះផងដែរ! សត្វស្លាប និងផ្កាព្រៃ មិនដែលចេះខ្វល់អំពីអ្វីឡើយ ហើយព្រះជាម្ចាស់ក៏មិនចង់ឲ្យកូនស្ងួនភ្ងារបស់ព្រះអង្គ មានការព្រួយបារម្ភពីអ្វីដែរ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងការមើលថែរក្សាសត្វ និងផ្កាទាំងនោះ។ ហើយព្រះអង្គក៏ពេញចិត្តនឹងថែរក្សាអ្នករាល់គ្នាផងដែរ»។

ព្រះយេស៊ូវបានជ្រាបថា ព្រះជាម្ចាស់តែងតែស្រឡាញ់ និងមើលថែទាំផែនដីដែលព្រះអង្គបានបង្កើតឡើង គ្រប់ទាំងអ្វីៗដែលមាននៅក្នុងនោះដូចជា សត្វស្លាប ផ្កា ដើមឈើ ហ្វូងសត្វ និងគ្រប់អ្វីៗទាំងអស់! លើសពីនោះទៅទៀត គឺកូនស្ងួនភ្ងារបស់ព្រះអង្គ។

ទោះបីជាមនុស្សខ្លះបានភ្លេច តែសត្វស្លាប និងផ្កាមិនបានភ្លេចទេ គេនៅតែចាំបទចម្រៀងរបស់ពួកគេ។ ជាបទចម្រៀងដែលគ្រប់ទាំងអ្វីៗដែលព្រះជាម្ចាស់បានបង្កើតមកបាននាំគ្នាច្រៀងថ្វាយទ្រង់តាំងពីដំបូងមកម្ល៉េះ។ ជាបទចម្រៀងដែលបានបង្កើតនៅក្នុងចិត្តមនុស្សគ្រប់ៗគ្នា ដើម្បីឲ្យច្រៀង៖ «ព្រះជាម្ចាស់បានបង្កើតយើង ព្រះអង្គស្រឡាញ់យើង ព្រះអង្គពេញចិត្តនឹងយើង!»។

នេះហើយជាមូលហេតុដែលព្រះយេស៊ូវបានយាងមកផែនដីនេះ៖ ដើម្បីច្រៀងដល់ពួកគេនូវបទចម្រៀងដ៏ពីរោះនេះ មិនត្រឹមតែច្រៀងជាមួយនឹងសំឡេងរបស់ព្រះអង្គប៉ុណ្ណោះនោះទេ ប៉ុន្តែច្រៀងឲ្យអស់ពេញមួយជីវិតរបស់ព្រះអង្គ ដើម្បីឲ្យកូនស្ងួនភ្ងារបស់ព្រះជាម្ចាស់អាចចងចាំ ហើយអាចចូលរួមច្រៀងបទនេះផងដែរ។

# មេបញ្ជាការខ្យល់ព្យុះ

ព្យុះនៅលើបឹង (ដកស្រង់ចេញពីកណ្ឌ ម៉ាកុស ៤ និងម៉ាថាយ ៨)

**ថ្ងៃបានលិចទៅ** ខ្យល់ក៏ស្ងប់ស្ងាត់ ហើយមានកម្ដៅភាយៗ។

ព្រះយេស៊ូវមានបន្ទូលទៅកាន់មិត្តភក្តិរបស់ទ្រង់ថា៖ «តោះយើងចេញដំណើរឆ្លងបឹងនេះ»។

ព្រះយេស៊ូវទ្រង់បានជួយពួកបណ្ដាជនអស់ពេញមួយថ្ងៃហើយ ឥឡូវនេះព្រះអង្គមានការនឿយហត់ជាខ្លាំង។ ដូច្នេះព្រះអង្គ និងពួកសិស្សទ្រង់ បានទុកហ្វូងមនុស្សឲ្យនៅឯមាត់ច្រាំង ហើយក៏នាំគ្នាចុះទូកនេសាទតូចមួយចេញទៅ។

ព្រះយេស៊ូវបានយាងចូលក្នុងទូក រួចដាក់ខ្លួនចុះ ហើយគេង។ គ្រាន់តែព្រះអង្គដាក់ក្បាលដល់ខ្នើយ នោះទ្រង់ក៏លង់លក់ទៅភ្លាមមួយរំពេច។

ពេលនោះជាពេលល្ងាចដ៏ល្អ ខ្យល់បក់រំភើយៗ រុញទូកចេញទៅ មិត្តភក្តិទាំងអស់កំពុងតែជជែកគ្នាលេងដោយរីករាយខណៈពេលដែលទូកចេញទៅកណ្ដាលបឹង។ អ្វីៗទាំងអស់ល្អឥតខ្ចោះ។ មានសភាពស្ងប់ស្ងាត់សម្រាប់ដំណើរតាមទូកនេះ...





ប្រហែលជានៅពាក់កណ្ដាលផ្លូវទៀតទើបឆ្លងទៅដល់ត្រើយម្ខាង នោះស្រាប់តែមានខ្យល់ដ៏គួរឲ្យភ្ញាក់ផ្អើលបានបក់ក្ដួចមកចំបឹងនោះ ខ្យល់បក់បោកជាខ្លាំង ហើយសាហាវដូចជាខ្យល់ព្យុះក្ដួចមួយអញ្ចឹង! ផ្លេកបន្ទោរភ្លឺចាំងស្ទើរតែខ្វាក់ភ្នែក ផ្គរលាន់ឮរំពងនៅពីលើក្បាល។

ខ្យល់ព្យុះបានបក់ទឹកបង្កើតជាទឹករលកយ៉ាងធំរុញទូកតូចឡើងខ្ពស់ទៅៗ ហើយបន្ទាប់មកក៏ធ្លាក់ចុះមកវិញយ៉ាងគំហុក និងទាបទៅៗ!

ទូកនេសាទត្រូវបានបក់បោកចុះឡើងៗ ទៅមុខ ទៅក្រោយ ទៅឆ្វេង ទៅស្ដាំ និងវិលចុះវិលឡើង!

ហើយនៅពេលដែលកំពុងតែមានព្យុះនេះ ព្រះយេស៊ូវទ្រង់នៅតែគេងលក់ដដែល។

មិត្តភក្ដិរបស់ព្រះយេស៊ូវបានធ្វើជាអ្នកនេសាទអស់មួយជីវិតមកហើយ ប៉ុន្ដែរាល់ឆ្នាំដែលគេធ្លាប់នេសាទក្នុងបឹងនេះ គេមិនដែលជួបប្រទះនឹងព្យុះដូចម្ដងនេះឡើយ។ ទោះបីពួកគេខំប្រឹងប្រែងទាញខ្សែពួរ និងក្ដោងយ៉ាងណាក៏ដោយ ក៏ពួកគេពុំអាចបញ្ជាទូករបស់ពួកគេបានដែរ។ ខ្យល់ព្យុះនេះគឺសាហាវណាស់ចំពោះពួកគេ។

ប៉ុន្តែ ព្យុះនេះមិនជាសាហាវអ្វីសោះចំពោះព្រះយេស៊ូវ។

ពួកគេបានស្រែកឡើងថា៖ «ជួយផងៗ ព្រះយេស៊ូវអើយ សូមទ្រង់ប្រញាប់ក្រោកឡើង!»។ ព្រះយេស៊ូវបើកភ្នែកឡើង។

«សូមជួយយើងខ្ញុំ! សូមសង្គ្រោះយើងខ្ញុំផង!» គេនាំគ្នាស្រែកទាំងញ័រភ័យ «តើព្រះអង្គមិនគិតដល់យើងខ្ញុំទេឬអី?»។

(ប្រាកដណាស់ ព្រះយេស៊ូវទ្រង់បានយកចិត្តទុកដាក់នឹងពួកគេ នេះហើយគឺជាមូលហេតុនាំឲ្យព្រះអង្គបានយាងមក ដើម្បីជួយ និងសង្គ្រោះពួកគេ)។

ព្រះយេស៊ូវទ្រង់ក្រោកឡើង ហើយនិយាយកំហែងទៅខ្យល់ព្យុះថា៖ «ចូរស្ងប់ទៅ» ព្រះអង្គគ្រាន់តែបញ្ជាប៉ុណ្ណឹង។

នោះការដ៏ចម្លែកក៏បានកើតឡើង...



ខ្យល់ និងទឹករលកស្គាល់សំឡេងព្រះយេស៊ូវ (វាធ្លាប់បានឮពីមុន ពិតប្រាកដណាស់ ជាសំឡេងដែលបង្កើតវាមក គឺតាំងតែពីដំបូងមកម្ល៉េះ)។ វាបានស្ដាប់តាមព្រះយេស៊ូវ ហើយធ្វើតាមបញ្ជាដែលព្រះអង្គបានបង្គាប់។

ខ្យល់ក៏បានឈប់ជាមួយរំពេច។ ទឹករលកក៏បានស្ងប់ទៅដែរ។ ពន្លឺលោកខែចាំងភ្លឺផ្លេកលើទឹកដែលស្ងប់នោះ ហើយរលកបានបោកតិចៗផ្ទប់នឹងចំហៀងទូក ហាក់បីដូចជាគ្មានអ្វីបានកើតឡើងសោះ។

ទូកតូចនោះបានមុជងើបៗចុះឡើង ហើយមានសភាពស្ងប់ស្ងាត់នៅជុំវិញផង។

បន្ទាប់មកព្រះយេស៊ូវទ្រង់បានងាកបែរទៅមិត្តភក្តិដែលខ្លាចព្យុះ ហើយមានបន្ទូលសួរថា៖ «ហេតុអ្វីបានជាអ្នកមានការភ័យខ្លាចយ៉ាងនេះ? តើអ្នកភ្លេចហើយឬថា ខ្ញុំជានរណា? តើអ្នកមានជំនឿលើការភ័យខ្លាចរបស់ខ្លួនជាជាងលើខ្ញុំមែនឬ?»។

មិត្តភក្តិរបស់ព្រះយេស៊ូវនៅស្ងៀមស្ងាត់គ្រប់ៗគ្នា គឺស្ងាត់ដូចជាខ្យល់ដែលនៅនឹងថ្កល់ និងរលកយ៉ាងដូច្នោះដែរ តែនៅក្នុងចិត្តគេកើតមានព្យុះមួយផ្សេងទៀត។

«តើលោកម្នាក់នេះជាមនុស្សបែបណាទៅ?» ពួកគេនឹកសួរក្នុងចិត្តរបស់គេដោយងឿងឆ្ងល់មែនទែន។ ពួកគេបាននិយាយថា៖ «សូម្បីតែខ្យល់ និងរលក ក៏ស្ដាប់តាមទ្រង់ដែរ!»។ ពួកគេមិនយល់ពីការនេះ ដោយព្រោះគេមិនទាន់បានដឹងច្បាស់ថា ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ។

មិត្តភក្តិរបស់ព្រះយេស៊ូវទាំងអស់មានការភ័យខ្លាចជាខ្លាំង ដោយព្រោះពួកគេបានឃើញទឹករលកធំៗ។ ពួកគេភ្លេចថា បើព្រះយេស៊ូវគង់នៅជាមួយពួកគេ នោះពួកគេមិនត្រូវមានការភ័យខ្លាចអ្វីសោះឡើយ។

ទោះបីជាទូករបស់គេតូចប៉ុណ្ណា ឬក៏ខ្យល់ព្យុះធំប៉ុណ្ណាក៏ដោយ។



# ពេញបរិបូរណ៍

ការផ្តល់អាហារដល់មនុស្ស៥.០០០នាក់ (ដកស្រង់ចេញពីកណ្ឌ ម៉ាកុស ៦ និងលូកា ៩)

**នាពេលមួយ** មានមនុស្ស៥.០០០នាក់កំពុងតែអង្គុយនៅតាមចង្កេះភ្នំ ដោយមានការនឿយហត់អស់កម្លាំង និងស្រេកឃ្លាន (ហើយប្រហែលជាមានការរអ៊ូរទាំច្រើនណាស់ផង) ពួកគេរង់ចាំអាហារពេលល្ងាចរបស់ពួកគេ។

ពួកហ្វូងមនុស្សបានមក ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូវនៅថ្ងៃនោះ។ ពួកគេបានមកតាំងពីមុនពេលអាហារពេលព្រឹកម្ល៉េះ ហើយបាននៅទីនោះអស់មួយព្រឹក និងមួយរសៀល រហូតដល់ហួសអាហារពេលល្ងាចទៅទៀត។ គ្មាននរណាម្នាក់គ្រោងនឹងនៅទីនោះជាយូរដល់ថ្នាក់ហ្នឹងទេ ប៉ុន្តែពួកគេបាននៅស្តាប់ព្រះយេស៊ូវរហូតដល់ភ្លេចខ្លួន ជ្រុលម៉ោងហាក់បីដូចជាពេលវេលានៅទ្រឹងលែងទៅមុខទៅក្រោយ។ មនុស្សជាច្រើនអាចនឹងស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូវអស់រយៈពេលជាច្រើនម៉ោង ហើយនៅថ្ងៃមួយនោះ គឺពួកគេបានធ្វើយ៉ាងដូច្នោះមែន។

ប៉ុន្តែ ពួកគេមិនបានយកអាហារមកគ្រប់គ្រាន់ទេ ហើយក៏មិនអាចទៅទិញបាយសាច់ជ្រូកដោយខ្លួនឯងបានដែរ ពីព្រោះពួកគេនៅទីវាលឆ្ងាយដាច់ស្រយាល គ្មានផ្សារ ហើយគ្មានហាងលក់ម្ហូបអ្វីសោះ។ (លើសពីនោះទៅទៀត គេមិនទាន់ច្នៃម្ហូបប្រភេទនោះទេ។)

តើពួកគេត្រូវធ្វើយ៉ាងណា? មិត្តភក្តិរបស់ព្រះយេស៊ូវមានគំនិតមួយ៖ «ចូរប្រាប់ឲ្យពួកគេគ្រប់គ្នាត្រឡប់ទៅផ្ទះ ទទួលទានបាយល្ងាចវិញទៅ»។



ព្រះយេស៊ូវមានបន្ទូលទៅកាន់ពួកសិស្សថា៖ «ពួកគេមិនចាំបាច់ចេញទៅទេ។ អ្នករាល់គ្នាអាចផ្តល់អាហារខ្លះឲ្យពួកគេបរិភោគចុះ»។

តើព្រះយេស៊ូវចង់ឲ្យពួកគេធ្វើដំណើរទៅភូមិ ដើម្បីទិញអាហារសម្រាប់គ្រប់គ្នាឬ? មិត្តភក្តិរបស់ព្រះយេស៊ូវបានភ័យស្លន់ស្លោ «តែយើងគ្មានលុយគ្រប់ល្មមនឹងទិញទេ!»។

ព្រះយេស៊ូវសួរទៅគេថា៖ «តើមានអាហារអ្វីខ្លះទៅ? ចូរទៅរកមើលមើល៍»។

ពេលនោះ មានក្មេងប្រុសម្នាក់នៅក្នុងចំណោមហ្វូងមនុស្សទាំងនេះ។ គាត់បានយកអាហារថ្ងៃត្រង់ដែលម្តាយគាត់បានខ្ចប់ឲ្យគាត់កាលពីព្រឹកព្រលឹមមកជាមួយ។ គាត់មើលទៅនំបុ័ងប្រាំដុំ និងត្រីពីរកន្ទុយដែលគាត់មាន មិនច្រើនប៉ុន្មានទេ ហើយក៏មិនគ្រប់គ្រាន់សម្រាប់មនុស្ស៥.០០០នាក់ដែរ គឺមានតែប៉ុណ្ណឹងទេ។

ប៉ុន្តែ គាត់និយាយឡើងថា៖ «ខ្ញុំមានខ្លះ!»។

មិត្តភក្តិរបស់ព្រះយេស៊ូវអស់សំណើច ដោយឃើញអាហារបន្តិចបន្តួចរបស់ក្មេងប្រុសនោះ ពួកគេក៏និយាយថា៖ «វាមិនគ្រប់ទេ!»។

ប៉ុន្តែ ពួកគេបានយល់ខុសហើយ។ ព្រះយេស៊ូវបានដឹងថា ចំនួនអាហារដែលក្មេងប្រុសតូចម្នាក់នេះមាន មិនជាបញ្ហានោះទេ។ ព្រះជាម្ចាស់នឹងធ្វើឲ្យមានគ្រប់គ្រាន់ ហើយលើសពីគ្រប់គ្រាន់ទៅទៀតផង។

ព្រះយេស៊ូវបានមានបន្ទូលថា៖ «ចូរយកអាហារដែលអ្នកមានមកឲ្យខ្ញុំ» ដូច្នេះក្មេងប្រុសតូចនេះ ក៏បានយកអាហាររបស់គាត់ទៅឲ្យព្រះយេស៊ូវ។ ហើយព្រះយេស៊ូវខ្សឹបដាក់ត្រចៀកគាត់ថា៖ «ចាំមើលណា!»។

មិត្តភក្តិរបស់ព្រះយេស៊ូវបាននិយាយថា៖ «បើមានអាហារតែប៉ុណ្ណឹង តើព្រះយេស៊ូវនឹងធ្វើដូចម្តេចដើម្បីនឹងចម្អែតមនុស្សទាំងនេះបាន?» ពីព្រោះពួកគេបានគិតថា វាជាការដែលមិនអាចនឹងធ្វើទៅរួចទេ។

ប៉ុន្តែ ព្រះយេស៊ូវបានស្គាល់អ្នកដែលបង្កើតត្រីទាំងអស់នៅក្នុងសមុទ្រ ហើយព្រះយេស៊ូវក៏បានស្គាល់ព្រះជាម្ចាស់ដែលបានបង្កើតគ្រប់របស់ទាំងអស់ចេញពីភាពទទេស្អាតមកតាំងពីដើមដំបូងបង្អស់ម្ល៉េះ តើមានការអ្វីដែលពិបាកទៅសម្រាប់ទ្រង់?





ព្រះយេស៊ូវបានយកអាហាររបស់ក្មេងប្រុសតូចម្នាក់នោះ រួចព្រះអង្គសម្លឹងទៅលើមេឃទាំងអរព្រះគុណដល់ព្រះវរបិតាទ្រង់ បន្ទាប់មកព្រះអង្គក៏ប្រគល់អាហារបន្តិចនេះទៅមិត្តភក្តិរបស់ទ្រង់។

នៅពេលមិត្តភក្តិរបស់ព្រះយេស៊ូវចាប់ផ្តើមចែកអាហារនោះ តើអ្នកដឹងទេថា មានការអ្វីកើតឡើង? គឺមានហេតុការណ៍ដ៏ចម្លែកបានកើតឡើង ទោះជាគេកាច់ប៉ុន្មានក៏ដោយ តែងតែមានថែមទៀតមិនចេះអស់ចេះតែមានបន្ត គឺគ្រប់គ្រាន់សម្រាប់មនុស្ស៥.០០០នាក់! មនុស្សគ្រប់គ្នាបានបរិភោគតាមចិត្ត ថែមលើកទីពីរ ថែមលើកទីបី រហូតដល់លើកទីបួនគេបានបរិភោគរហូតដល់បានឆ្អែតស្កប់ស្កល់ ហើយនៅតែមានអាហារនៅសល់ទៀតផង។

ជាការពិតណាស់ ព្រះយេស៊ូវបានធ្វើការអស្ចារ្យជាច្រើនដូចក្នុងរឿងនេះ ការដែលមនុស្សបានគិតថាមិនអាចទៅរួច ដែលនោះមិនមែនតាមច្បាប់ធម្មជាតិ ប៉ុន្តែនេះជាការដែលកើតឡើងតាមបែបធម្មជាតិមែន។

ប៉ុន្តែ នោះជាការពិតណាស់ អ្វីៗនៅក្នុងលោកនេះគឺសុទ្ធតែព្រះទ្រង់បានតាក់តែងឡើង តាំងពីដើមដំបូងមកម្ល៉េះ៖ ទ្រង់យករបស់ដែលគ្មាន ហើយបង្កើតវាឲ្យចេញជារបស់ទាំងអស់ ទ្រង់យកភាពទទេស្អាត ហើយបំពេញវាឲ្យចេញជារូបរាងពេញលេញ ហើយយកភាពងងឹតធ្វើឲ្យមានចេញជាពន្លឺវិញ។



# ការស្វែងរកកំណប់

សាច់រឿងនៃការលាក់ទុកកំណប់ (ដកស្រង់ចេញពីកណ្ឌ ម៉ាថាយ ១៣)

**មានថ្ងៃមួយ** កាលព្រះយេស៊ូវកំពុងមានបន្ទូលប្រាប់ពួកបណ្ដាជនពីនគររបស់ព្រះជាម្ចាស់។ ព្រះយេស៊ូវប្រាប់គេថា៖ «នៅទីណាដែលព្រះអង្គធ្វើជាស្តេច និងជាអ្នកគ្រប់គ្រង ទីនោះឯងគឺជានគរព្រះជាម្ចាស់។ ហើយទីនោះឯងជាកន្លែងដែលព្រះអង្គបំពេញនូវភាពរីករាយដ៏នៅអស់កល្បក្នុងចិត្តអ្នក ដើម្បីឲ្យអ្នកឈប់រត់ចេញឆ្ងាយពី ទ្រង់ទៀត ហើយឲ្យអ្នកស្រឡាញ់ព្រះអង្គវិញ»។

ប៉ុន្តែ ជួនកាលមនុស្សគ្រប់គ្នាមិនបានយល់អំពីអ្វីដែលព្រះយេស៊ូវបង្រៀនយ៉ាងច្បាស់លាស់នោះទេ។ ដូច្នេះ ព្រះយេស៊ូវក៏បានជួយពួកគេដោយនិទានរឿងជា «ពាក្យប្រៀបប្រដូច»។

ព្រះយេស៊ូវមានបន្ទូលថា៖ «នគរព្រះជាម្ចាស់គឺប្រៀបដូចជាកំណប់ដែលបានលាក់ទុក!» ហើយបន្ទាប់មក ព្រះអង្គបានប្រាប់ពួកគេពីរឿងនេះ...





នាពេលមួយ មានបុរសម្នាក់ កំពុងតែជីកដីនៅទីវាលមួយ។ កាលដែលគាត់កំពុងតែជីកនោះ ប៉ុន្តែគាត់មិនបានដឹងថា នៅទីនោះមានកំណប់នោះទេ។ ដូច្នេះគាត់ក៏ជីកៗ...ទៅឮសូរឃ្លីក ឃ្លុក ឃ្លុង។ ចបរបស់គាត់ប៉ះនឹងរបស់រឹងម្យ៉ាង លាន់សូរឃើះ! ស្អីអញ្ចេះ? គាត់ក៏ទាញរបស់នោះឡើងមក បបោសដីចេញ។ វាជាប្រអប់។ វាមានច្រេះស៊ី ហើយជាប់សោផង។

គាត់ក៏គាស់វាបើកឡើង ឮសូរក្រាក។ អ្វីៗដែលគាត់បានឃើញនៅខាងក្នុងបានធ្វើឲ្យគាត់បានដកដង្ហើមធំ ពីព្រោះគាត់ឃើញថា វាជាទ្រព្យដ៏មានតម្លៃ៖ ភ្លឺចាំងចែងយ៉ាងចិញ្ចាច







ភ្លឺព្រិចៗ ផ្លេកៗ! នេះគឺជាប្រអប់កំណប់!

គាត់ចង់បានកំណប់នេះ។ គាត់ត្រូវការកំណប់នេះ។ គាត់ត្រូវតែយកកំណប់នេះឲ្យបាន ទោះបីជាយ៉ាងណាក៏ដោយ។ សូម្បីតែគាត់ត្រូវលក់របស់ទាំងអស់ដែលគាត់មាន ដើម្បីបង់ថ្លៃទីវាលនេះក៏ដោយ។ គាត់ក៏កប់កំណប់នេះទៅវិញយ៉ាងរហ័ស រួចរត់ទៅផ្ទះ ហើយក៏លក់របស់ទាំងអស់ដែលគាត់មាន។ បន្ទាប់មក គាត់បានយកលុយដែលគាត់លក់បាននោះទៅទិញដីវាលនោះ។ ឥឡូវនេះ គាត់ក្លាយជាម្ចាស់របស់ដីវាលនោះ និងកំណប់ដែលកប់នៅទីនោះ! ហើយគាត់ក៏បានរត់ត្រឡប់ទៅជីកកំណប់នោះម្តងទៀត។





ព្រះយេស៊ូវមានបន្ទូលថា៖ «ការបែរមកឯព្រះជាម្ចាស់វិញនោះ ជាការល្អប្រសើរបំផុត ដូចជាការដែលរកឃើញកំណប់ដែរ! ប្រហែលជាអ្នកត្រូវជីកជាមុន ទើបរកវាឃើញ ប្រហែលជាអ្នកត្រូវស្វែងរកវាជាមុន ទើបបានឃើញវា។ ប្រហែលជាអ្នកត្រូវលះបង់ចោលរបស់ទាំងអស់ដែលមានដើម្បីឲ្យបានវាមក។ ប៉ុន្តែ ការដ៏សំខាន់ជាងអ្វីទាំងអស់នៅក្នុងផែនដីនេះ គឺនៅទីកន្លែងដែលព្រះជាម្ចាស់កំពុងគង់នៅ ពោលគឺនគររបស់ព្រះអង្គ!»។ ព្រះយេស៊ូវប្រាប់គេថា៖ «នគររបស់ព្រះជាម្ចាស់មានតម្លៃជាងរបស់នានាដែលអ្នកអាចលះបង់ចោលបានទៅទៀត ពីព្រោះព្រះជាម្ចាស់គឺជាកំណប់ដ៏ពិត»។

ជាការពិតប្រាកដណាស់ថា ព្រះជាម្ចាស់មានកំណប់មួយ គឺជាកំណប់មួយដែលបានបាត់ជាយូរយារណាស់មកហើយ។ តើអ្វីទៅជាកំណប់របស់ព្រះជាម្ចាស់? តើវាជារបស់សំខាន់បំផុតរបស់ព្រះអង្គឬ? ឬក៏ជាអ្វីដែលព្រះជាម្ចាស់ស្រឡាញ់យ៉ាងខ្លាំងបំផុតនៅលើផែនដីនេះមែនឬ?

កូនរបស់ព្រះជាម្ចាស់ គឺជាកំណប់របស់ព្រះអង្គ។

ហេតុដូច្នេះហើយបានជាព្រះយេស៊ូវទ្រង់យាងមកក្នុងផែនដីនេះ ដើម្បីរកកំណប់របស់ព្រះជាម្ចាស់។ ទ្រង់បានយករូបកាយរបស់ទ្រង់បង់ថ្លៃ ដើម្បីជាតម្លៃលោះយកគេមកវិញ ហើយព្រះយេស៊ូវទ្រង់ពិតជាបានធ្វើការនេះ ទោះបីជាព្រះអង្គត្រូវលះបង់អ្វីៗទាំងអស់ដែលទ្រង់មានក៏ដោយ។



# មិត្តសម្លាញ់របស់កុមារតូចៗ

ព្រះយេស៊ូវ និងកូនក្មេងតូចៗ (ដកស្រង់ចេញពីកណ្ឌ ម៉ាថាយ ១៨; ១៩; ម៉ាកុស ១០ និងលូកា ១៨)

**មិត្តភក្តិ**របស់ព្រះយេស៊ូវបានប្រកែកគ្នា ពីព្រោះគេចង់ដឹងថា៖ «តើនរណាជាអ្នកជំនួយសំខាន់ជាងគេនៅក្នុងនគរព្រះជាម្ចាស់?»។

លោក យ៉ាកុប ឆ្លើយថា៖ «គឺខ្ញុំ»។

លោក ពេត្រុស ឆ្លើយថា៖ «ទេៗ មិនមែនអ្នកទេ! គឺខ្ញុំតើ!»។

លោក ម៉ាថាយ ឆ្លើយថា៖ «មិនសមទេ គឺខ្ញុំជាអ្នកឈ្លាសវៃជាងគេ!»។

«ទេ! មិនមែនអ្នកទេ!»

«បាទ! គឺខ្ញុំ!»

«បាទ! ទេ! ខ្ញុំដែរ!»

ពួកគេជជែកគ្នាមិនចេះអៀនខ្មាសបែបនេះ ឆ្លើយឆ្លងគ្នាទៅវិញទៅមកមិនចេះចប់។ អ្នកដឹងទេ មិត្តភក្តិរបស់ព្រះយេស៊ូវបានចាប់ផ្តើមគិតថា ពួកគេត្រូវធ្វើអ្វីម្យ៉ាង ដើម្បីឲ្យគេក្លាយជាមនុស្សពិសេសរបស់ទ្រង់ បើសិនពួកគេជាមនុស្សឈ្លាសវៃជាងគេ ឬក៏ជាមនុស្សត្រឹមត្រូវលើសគេ ឬធ្វើអ្វីមួយ ដើម្បីឲ្យព្រះយេស៊ូវចូលចិត្តគេជាជាងអ្នកដទៃ។



ប៉ុន្តែ ពួកគេបានភ្លេចការមួយ ដែលព្រះជាម្ចាស់បានបង្រៀនដល់រាស្ត្ររបស់ព្រះអង្គតាំងពីយូរឆ្នាំកន្លងមកហើយ៖ គឺមិនថាអ្នកជាមនុស្សឈ្លាសវៃ មនុស្សល្អ អ្នកមាន អ្នកសុភាព អ្នកជា ឬមនុស្សសំខាន់យ៉ាងណានោះទេ ការទាំងនេះគ្មានអ្វីដែលខុសប្លែកជាងគេឡើយ ពីព្រោះសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ គឺជាអំណោយទាន។ ហើយមនុស្សទាំងអស់គ្នាក៏បានដឹងហើយថា អំណោយទានទាំងអស់បានមកទទេ អ្វីដែលអ្នកត្រូវធ្វើ គឺគ្រាន់តែលូកដៃឈោងចាប់ទទួលយកតែប៉ុណ្ណោះ។

ដូច្នេះ នៅពេលដែលមិត្តភក្តិរបស់ព្រះយេស៊ូវកំពុងតែជជែកគ្នានៅឡើយ មានអ្នកខ្លះបានដឹងពីការទទួលយកអំណោយទាននេះ ការពិតទៅអ្នកអាចនិយាយថា ពួកគេជាអ្នកជំនាញខាងអំណោយទាន។ ពួកគេបានចូលមកជួបព្រះយេស៊ូវ តើពួកគេជានរណា? ពួកគេជាកុមារតូចៗ។





អ្នកជំនួយរបស់ព្រះយេស៊ូវ ព្យាយាមដេញកុមារតូចៗទាំងនេះឲ្យចេញទៅវិញ។ គេបាននិយាយថា៖ «ព្រះយេស៊ូវគ្មានពេលទំនេរសម្រាប់ឯងទេ! ព្រះអង្គអស់កម្លាំងណាស់ហើយ!»។

ប៉ុន្តែ ពួកគេបានគិតខុសស្រឡះហើយ! ព្រះយេស៊ូវតែងតែមានពេលសម្រាប់ពួកកុមារតូចៗជានិច្ច។

ព្រះយេស៊ូវមានបន្ទូលឡើងថា៖ «មិនត្រូវដេញពួកក្មេងៗចេញទៅទេ! ចូរឲ្យពួកគេមកឯខ្ញុំចុះ!»។

ប្រសិនបើជាអ្នកបាននៅទីនោះដែរ តើអ្នកគិតដូចម្តេច? តើអ្នកគិតថា ខ្លួនត្រូវឈរតម្រង់ជួរយ៉ាងស្ងៀមស្ងាត់ ដើម្បីរង់ចាំជួបព្រះយេស៊ូវដែរឬទេ? តើអ្នកគិតថា ព្រះយេស៊ូវទ្រង់នឹងសួរអ្នកថា តើឯងបានធ្វើល្អអ្វីខ្លះ មុននឹងព្រះអង្គឱបអ្នក? តើអ្នកត្រូវតែមានចរិតដ៏ល្អបំផុតមែនឬ? តើអ្នកនឹងត្រូវស្លៀកសម្លៀកបំពាក់ដ៏ស្អាតៗ? ហើយមិនត្រូវនិយាយអ្វីសោះ រហូតទាល់តែព្រះយេស៊ូវនិយាយរកអ្នកមុនឬ?

ឬ...ក៏អ្នកធ្វើឲ្យដូចអ្វីៗដែលជាពួកក្មេងៗទាំងនេះបានធ្វើ គឺរត់តម្រង់ទៅរកព្រះយេស៊ូវ ហើយរង់ចាំដើម្បីឲ្យព្រះអង្គចាប់បីអ្នកឡើងនៅក្នុងដៃរបស់ព្រះអង្គ ហើយបង្វិលអ្នកជុំវិញ រួចទ្រង់ឱនថើបអ្នក និងឱបអ្នក រួចហើយទ្រង់លើកអ្នកដាក់ឲ្យអង្គុយលើភ្លៅទ្រង់ ដើម្បីស្តាប់រឿងផ្សេងៗរបស់អ្នក និងជជែកកំសាន្តជាមួយអ្នកឬ?

អ្នកដឹងទេថា ក្មេងតូចៗស្រឡាញ់ព្រះយេស៊ូវ ហើយពួកក្មេងទាំងនោះបានដឹងថាពួកគេមិនបាច់ធ្វើអ្វីមួយពិសេស ដើម្បីឲ្យព្រះយេស៊ូវទ្រង់ស្រឡាញ់ពួកគេទេ គឺពួកគេគ្រាន់តែរត់ចូលទៅក្នុងរង្វង់ដៃរបស់ព្រះអង្គតែប៉ុណ្ណោះ។ ដូច្នេះហើយពួកគេបានធ្វើយ៉ាងនោះមែន។

មែនហើយ ក្រោយពេលដែលពួកគេបានសើចក្អាកក្អាយ ហើយនិងលេងល្បែងកំសាន្តផ្សេងៗ នោះព្រះយេស៊ូវទ្រង់ងាកទៅអ្នកជំនួយរបស់ព្រះអង្គ រួចទ្រង់មានព្រះបន្ទូលថា៖ «មិនថាអ្នកបានធំធាត់ពេញវ័យប៉ុណ្ណាក៏ដោយ ក៏អ្នកមិនគួរឲ្យខ្លួនចាស់ពេក រហូតដល់ថាលែងមានចិត្តដូចជាកូនក្មេង ពោលគឺចិត្តដែលទុកចិត្តលើព្រះជាម្ចាស់យ៉ាងពេញទី។ ចូរធ្វើឲ្យដូចជាក្មេងទាំងនេះចុះ។ ពួកគេសំខាន់ខ្លាំងណាស់នៅក្នុងនគររបស់ខ្ញុំ»។







# បុរសម្នាក់ដែលគ្មានមិត្តភក្តិនឹងគេសោះ

សាច់រឿងពីលោក សាខេ (ដកស្រង់ចេញពីកណ្ឌ លូកា ១៩)

**នាពេលមួយ** មានបុរសម្នាក់ ដែលមិនសូវមានមិត្តភក្តិនឹងគេសោះ។ តើអ្នកមានមិត្តភក្តិដែរឬទេ? មែនហើយ អ្នកពិតជាមានមែន។ ប៉ុន្តែលោក សាខេ អត់មានទេ។ លោក សាខេ ដ៏អភ័ព្វម្នាក់នេះមិនដែលមានមិត្តភក្តិនឹងគេសោះ។

អ្នកប្រហែលជាមានការងឿងឆ្ងល់ណាស់ហើយថា តើមកពីហេតុអ្វី? តើដោយសារលោក សាខេជាមនុស្សតឿមែនឬ? (ការនេះមិនមែនជាមូលហេតុដែលធ្វើឲ្យអ្នកណាម្នាក់មិនចូលចិត្តអ្នកណាម្នាក់ទៀតនោះទេ។) តើមកពីឈ្មោះរបស់គាត់ពិបាកហៅពេកទេដឹង? (នោះក៏មិនមែនជាមូលហេតុដែរ។) ទោះបីគាត់ជាមនុស្សតឿ ហើយឈ្មោះគាត់ពេលហៅទៅគួរឲ្យអស់សំណើចក៏ដោយ ក៏នោះមិនមែនជាមូលហេតុដែរ។ តាមពិតទៅ ពួកបណ្ដាជនមិនចូលចិត្តនឹងលោក សាខេ ពីព្រោះគាត់បានលួចលុយកាក់របស់ពួកគេ។

លោក សាខេ ជាអ្នកយកពន្ធ (បណ្ដាជនត្រូវបង់ពន្ធទៅស្ដេច) ប៉ុន្តែ លោក សាខេ បានទារពន្ធលើសពីការកំណត់ រួចទុកលុយដែលលើសពីការកំណត់នោះសម្រាប់ខ្លួនឯង ដែលការធ្វើបែបនោះបណ្ដាលឲ្យខ្លួនគាត់ក្លាយជាអ្នកមាន។ បណ្ដាជនគ្រប់គ្នាបានដឹងនូវអ្វីៗដែលគាត់បានធ្វើ ហើយការនោះបានធ្វើឲ្យពួកគេខឹង ហើយរអ៊ូរទាំ។ ពួកគេមិនចូលចិត្តនឹងលោក សាខេ សូម្បីតែបន្តិចក៏គ្មានផង។

ដូច្នេះ ពួកគេចង់ធ្វើឲ្យគាត់ដឹងខ្លួន គឺពួកគេបានធ្វើព្រងើយកន្តើយចំពោះរូបគាត់។ ហើយនាំគ្នាដើរនៅចំហៀងផ្លូវម្ខាងទៀត ព្រមទាំងធ្វើជាមិនឃើញគាត់។ ពួកគេខ្សឹបខ្សៀវដាក់គ្នាអំពីគាត់ដូចជា «នុ៎ះន៏ មនុស្សដែលមិនសំខាន់អ្វីសោះ ហើយបែរជារាប់ខ្លួនឯងថាជាមនុស្សសំខាន់វិញ!»។ ពួកគេនិយាយខ្លាំងល្មមនឹងអាចឲ្យគាត់ឮបាន។



ទោះជាយ៉ាងនេះក៏ដោយ នៅថ្ងៃមួយ មានមនុស្សមួយក្រុមធំជួបជុំគ្នានៅតាមដងផ្លូវ ព្រោះព្រះយេស៊ូវទ្រង់យាងមកភូមិរបស់គេ ហើយគ្រប់ៗគ្នាចង់ឃើញព្រះអង្គ។

រីឯលោក សាខេ វិញក៏ចង់ឃើញព្រះយេស៊ូវដែរ ក៏ប៉ុន្តែដោយសារមនុស្សគ្រប់គ្នាខ្ពស់ៗពេកនោះគាត់បានត្រឹមតែខំលោតចុះលោតឡើង ដើម្បីអើតមើលនឹងគេនឹងឯងតែប៉ុណ្ណោះ។ ប៉ុន្តែ ជាការឥតប្រយោជន៍ គាត់មើលមិនឃើញអ្វីទាល់តែសោះ។

ពេលនោះ លោក សាខេ មានគំនិតដ៏ល្អមួយ គាត់និយាយថា៖ «ខ្ញុំនឹងឡើងលើដើមល្វានោះ!»។ ដូច្នេះគាត់ក៏ឡើង។ (ទោះបីលោក សាខេ ជាមនុស្សតឿក៏ដោយ ក៏គាត់ជាមនុស្សដែលពូកែឡើងដើមឈើម្នាក់ដែរ នេះជាការគួរឲ្យភ្ញាក់ផ្អើលណាស់ ព្រោះពេលឡើងអង្គុយលើកៅអីរបស់គាត់រាល់ព្រឹក ក៏គាត់ត្រូវតែហក់លោតឡើងដែរ។)





នៅលើដើមឈើ លោក សាខេ អាចមើលឃើញយ៉ាងច្បាស់ថែស ហើយអាចឃើញដងផ្លូវចុះទៅយ៉ាងច្បាស់ក្រឡែត។

មួយនាទីក្រោយមក ស្រាប់តែព្រះយេស៊ូវបានយាងមកដល់ដើមឈើនោះភ្លាម។ ព្រះអង្គបានឈប់ ហើយងើយមើលលើ។ លោក សាខេ បានឃើញព្រះយេស៊ូវ ហើយព្រះយេស៊ូវក៏បានឃើញលោក សាខេ វិញដែរ។

ព្រះយេស៊ូវទ្រង់មានបន្ទូលហៅលោកថា៖ «សាខេ! ខ្ញុំចង់ទៅលេងផ្ទះរបស់លោក»។

លោក សាខេ ស្ទើរតែរបូតដៃធ្លាក់ពីលើដើមឈើពេលឮថាព្រះយេស៊ូវចង់ទៅលេងផ្ទះរបស់គាត់? គ្មាននរណាម្នាក់ចង់ចូលលេងក្នុងផ្ទះរបស់គាត់ទេ សូម្បីតែទៅក្បែរផ្ទះគាត់ក៏មិនដែលមានដែរ។

ពេលដែលពួកបណ្ដាជនបានឃើញការនេះ នោះវាកាន់តែធ្វើឲ្យពួកគាត់ខឹង និងរអ៊ូរទាំខ្លាំងឡើងៗ។ ពួកគេនិយាយដោយរអ៊ូ និងបែបខ្សឹបៗថា៖ «តើហេតុអ្វីបានជាព្រះយេស៊ូវទ្រង់មានសន្ដានចិត្តល្អចំពោះមនុស្សមានបាបយ៉ាងខ្លាំងមួយនេះអញ្ចឹង? តើព្រះយេស៊ូវមិនដឹងរឿងអំពីបុគ្គលម្នាក់នេះទេឬអី?»។

លោក សាខេ ប្រវេប្រវាចុះមក រួចក៏នាំព្រះយេស៊ូវទៅឯផ្ទះគាត់ គាត់មានការប្រញាប់ប្រញាល់ជាខ្លាំង ពីព្រោះគាត់មិនចង់ឲ្យព្រះយេស៊ូវទ្រង់ប្ដូរចិត្តវិញទេ។ ប្រហែលជាព្រះយេស៊ូវទ្រង់មិនដែលឮពីគាត់ទេមើលទៅ ឬក៏ប្រហែលជាព្រះយេស៊ូវទ្រង់មិនបានដឹងអំពីការដែលគាត់ធ្លាប់លួច និងពីហេតុដែលគ្មានអ្នកណាម្នាក់ចូលចិត្តនឹងគាត់ បូករួមទាំងពីមូលហេតុបានជាគាត់គ្មានមិត្តនឹងគេសោះទេដឹង។

ប៉ុន្តែ ព្រះយេស៊ូវទ្រង់ជ្រាបពីការទាំងនេះ ព្រះអង្គជ្រាបគ្រប់ការទាំងអស់អំពីលោក សាខេ ជ្រាបពីការលួច និងគ្រប់ការទាំងអស់ តែព្រះអង្គនៅតែស្រឡាញ់គាត់។

លោក សាខេ មានការអៀនខ្មាសយ៉ាងខ្លាំងណាស់ គាត់និយាយដោយមានទឹកមុខស្លេកស្លាំងថា៖ «ព្រះអម្ចាស់! ខ្ញុំធ្លាប់បានធ្វើខុស ប៉ុន្តែឥឡូវនេះ ខ្ញុំចង់ធ្វើល្អត្រឹមត្រូវវិញ ខ្ញុំនឹងសងលុយទៅគេគ្រប់គ្នាវិញ បួនដងលើសពីអ្វីដែលខ្ញុំបានលួច!» គាត់ក៏បានធ្វើដូចដែលគាត់បាននិយាយមែន។

ព្រះយេស៊ូវក៏បានញញឹម ហើយមានបន្ទូលថា៖ «សម្លាញ់អើយ! នៅថ្ងៃនេះ ព្រះជាម្ចាស់បានសង្គ្រោះអ្នកហើយ!»។

ព្រះយេស៊ូវទ្រង់បានស្រឡាញ់លោក សាខេ នៅពេលដែលគ្មាននរណាម្នាក់ស្រឡាញ់គាត់ឡើយ។ ព្រះអង្គជាមិត្តសម្លាញ់របស់លោក សាខេ ទោះបីជាគ្មាននរណាម្នាក់ធ្វើជាមិត្តរបស់គាត់ក៏ដោយ ពីព្រោះព្រះយេស៊ូវចង់បង្ហាញបណ្ដាជនពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ថាអស្ចារ្យ គ្មានទីបញ្ចប់ មិនអាចបោះបង់បាន មិនអាចបំបែកចេញបានដដែល ជាសេចក្ដីស្រឡាញ់ដ៏អស់កល្បជានិច្ច។







# ការចាកចេញទៅ

សាច់រឿងអំពីកូនប្រុសដែលបានបាត់បង់ (ដកស្រង់ចេញពីកណ្ឌ លូកា ១៥)

**ព្រះយេស៊ូវ**មានព្រះបន្ទូលអំពីក្មេងប្រុសម្នាក់ ដែលបានរត់ចេញពីឪពុកទៅ៖ នាពេលមួយ មានក្មេងប្រុសម្នាក់ ហើយនិងឪពុករបស់គាត់។ មានថ្ងៃមួយ ក្មេងប្រុសម្នាក់នេះបានគិតថា៖ *«ប្រសិនបើខ្ញុំគ្មានឪពុករបស់ខ្ញុំនៅជាមួយខ្ញុំទេ ដែលតែងតែប្រាប់ខ្ញុំពីអ្វីដែលល្អសម្រាប់ខ្ញុំគ្រប់ពេលវេលានោះ ខ្ញុំនឹងបានសប្បាយចិត្តជាងនេះទៅទៀត។ ឪពុករបស់ខ្ញុំបានរំខានការសប្បាយរបស់ខ្ញុំណាស់»*។ ក្មេងប្រុសនោះបានគិតក្នុងចិត្តថា៖ *«តើឪពុកខ្ញុំ គាត់ពិតជាចង់ឲ្យខ្ញុំសប្បាយឬទេ? តើគាត់ពិតជាស្រឡាញ់ខ្ញុំមែនឬ?»*។ តាំងពីដើមមក កូននេះមិនដែលគិតរបៀបនេះទេ ប៉ុន្តែ ក្នុងមួយរំពេចសោះ គាត់លែងដឹងថាតើឪពុកគាត់នៅស្រឡាញ់គាត់ទៀតដែរឬទេ។

ដូច្នេះ កូនប្រុសនេះក៏ទៅឯឪពុករបស់គាត់រួចនិយាយថា៖ «បើសិនជាគ្មានលោកឪពុកនៅជាមួយនឹងខ្ញុំ នោះខ្ញុំនឹងបានប្រសើរឡើង។ ខ្ញុំអាចមើលថែរក្សាខ្លួនឯងបាន។ សូមលោកឪពុកប្រគល់លុយជាចំណែកដែលលោកឪពុកបម្រុងចែកឲ្យខ្ញុំ មកខ្ញុំចុះ»។

ឪពុកមានចិត្តក្រៀមក្រំជាខ្លាំង ប៉ុន្តែ គាត់មិនចង់បង្ខំកូនឲ្យនៅជាមួយគាត់ទៀតទេ ដូច្នេះ គាត់ក៏ប្រគល់លុយដែលកូនចង់បានឲ្យទៅ។

ពេលដែលកូននេះបានទទួលលុយហើយ គាត់ក៏ធ្វើដំណើរទៅទីឆ្ងាយយ៉ាងដាច់ស្រយាលពីស្រុករបស់ខ្លួន។

ហើយមើលទៅ គ្រប់អ្វីៗទាំងអស់ហាក់បីដូចជាបានល្អប្រសើរខ្លាំងណាស់។ គាត់ចង់ទៅណាតាមចិត្តគាត់ចង់។ ធ្វើនូវអ្វីដែលគាត់ចង់ធ្វើ។ ចង់រស់ក្នុងរបៀបណាក៏បាន តាមតែចិត្តរបស់គាត់។ គាត់ជាចៅហ្វាយរបស់ខ្លួនឯង! គាត់មានសេរីភាពពេញទី!

ពេលខ្លះ គាត់មានការប្លែកក្នុងចិត្តគាត់ ឃ្លាន មានអារម្មណ៍នឹកផ្ទះ ប៉ុន្តែបន្ទាប់មកគាត់ញ៉ាំ និងស៊ីផឹកច្រើនហើយទិញខោអាវថែមទៀត ហើយទៅចូលរួមក្នុងពិធីជប់លៀងជាច្រើនដងរហូតសឹងលែងចាំរឿងនោះ។





ប៉ុន្តែ មិនយូរប៉ុន្មានគាត់ក៏អស់លុយរលីងទៅ ហើយមិត្តភក្តិរបស់គាត់ ក៏ទៅចោលអស់ដែរ។ នៅទីបំផុតការងារដែលគាត់អាចរកបាន គឺឲ្យបាយជ្រូកតែប៉ុណ្ណោះ។ មានថ្ងៃមួយនោះ គាត់ឃ្លានខ្លាំងណាស់ គាត់ក៏សាកល្បងស៊ីបាយជ្រូក។ គាត់និយាយហាក់បីដូចជាទើបនឹងភ្ញាក់ពីការយល់សប្តិអាក្រក់ថា៖ «តើខ្ញុំកំពុងធ្វើអ្វីហ្នឹង?» គាត់ស្ដោះ ក្អួត! ចេញពីមាត់របស់គាត់។ «ឪពុកខ្ញុំជាអ្នកមាន ចុះហេតុដូចម្ដេចក៏ខ្ញុំមករស់នៅក្នុងទ្រុងជ្រូក ហើយស៊ីបាយជ្រូកអញ្ចឹង!»។

គាត់បានជូតមាត់ ហើយបោសធូលីចេញពីខ្លួន។

«ខ្ញុំនឹងត្រឡប់ទៅផ្ទះវិញ!»។

ខណៈពេលដែលគាត់បានចាប់ផ្តើមត្រឡប់ទៅផ្ទះវិញ គាត់ក៏ចាប់ផ្តើមកើតមានការព្រួយបារម្ភថា៖ *«លោកឪពុកខ្ញុំឈប់ស្រឡាញ់ខ្ញុំទៀតហើយ ខ្ញុំអាក្រក់ណាស់ គាត់នឹងមិនចង់បានខ្ញុំធ្វើជាកូនគាត់ទៀតទេ»*។ ដូច្នេះ គាត់បានរៀននិយាយពីបែបបទដែលត្រូវសូមទោស។

របូតដល់ពេលនេះ អ្វីដែលគាត់មិនបានដឹងគឺ ពីមួយថ្ងៃទៅមួយថ្ងៃ ឪពុករបស់គាត់តែងតែឈរចាំមើលផ្លូវគាត់នៅខ្លោងទ្វារផ្ទះរបស់គាត់។ គាត់ចោលភ្នែកសម្លឹងទៅឆ្ងាយ រង់ចាំមើលកូនគាត់ត្រឡប់មកផ្ទះវិញ គាត់មិនអាចឈប់ស្រឡាញ់កូនរបស់គាត់បានឡើយ។ គាត់ចង់ឮសំឡេងកូនប្រុសរបស់គាត់។ គាត់មិនអាចសប្បាយចិត្តបានទេ ទាល់តែគាត់បានឃើញកូនគាត់ត្រឡប់មកវិញ។

កូនប្រុសគាត់នៅឆ្ងាយពីគាត់នៅឡើយ ប៉ុន្តែ ឪពុករបស់គាត់បានឃើញគាត់កំពុងតែដើរមក។

តើឪពុកគាត់នឹងធ្វើដូចម្តេច? ឈរឱបដៃមើល ហើយចងចិញ្ចើម? រួចស្រែកថា៖ «នេះជាមេរៀនដល់ឯងហើយ!» ហើយបន្តថា៖ «ឯងចាំមើលទៅអាល្អិតអើយ!»។

ទេ! ដំណើររឿងនេះមិនមែនដូច្នេះទេ។

ឪពុកនេះបានស្ទុះពីខ្លោងទ្វារផ្ទះ គាត់រត់ចុះទួលសំដៅទៅឯកូនគាត់ គាត់ឆ្លងដល់របង ហើយឡើងទៅតាមផ្លូវ។ មុនពេលកូនគាត់អាចនឹងចាប់ផ្តើមនិយាយថា៖ «ខ្ញុំសូមទោស» ឪពុករបស់គាត់បានរត់សំដៅទៅឯគាត់ លើកដៃគាត់ឱបកូន ហើយថើបកូនមិនចង់ឈប់។



ឪពុកគាត់ក៏ស្រែកថា៖ «តោះ! នាំគ្នាជប់លៀង! កូនខ្ញុំបានត្រឡប់មកផ្ទះវិញហើយ គាត់បានចេញទៅឆ្ងាយចោលយើង ប៉ុន្តែឥឡូវនេះគាត់បានត្រឡប់មករកខ្ញុំវិញហើយ!»។

ព្រះយេស៊ូវមានបន្ទូលប្រាប់ពួកគេថា៖ «ព្រះជាម្ចាស់ប្រៀបដូចជាឪពុកដែលមិនអាចឈប់ស្រឡាញ់កូនប្រុសរបស់ទ្រង់បានទេ ហើយបណ្ដាជនទាំងអស់គឺប្រៀបដូចជាកូនប្រុសរបស់គាត់ដែលនិយាយថា៖ “តើឪពុករបស់ខ្ញុំពិតជាចង់ឲ្យខ្ញុំបានសប្បាយរីករាយមែនឬ?”»។

ព្រះយេស៊ូវទ្រង់មានបន្ទូលប្រាប់ពួកគេអំពីរឿងនេះ ដើម្បីបង្ហាញឲ្យពួកគេដឹងថា តើព្រះជាម្ចាស់មានចិត្តយ៉ាងដូចម្ដេច? និងដើម្បីបង្ហាញពួកបណ្ដាជនឲ្យគេបានដឹងថា តើពួកគេមានចិត្តដូចម្ដេច?

ដើម្បីឲ្យពួកគេបានដឹងថា ទោះជាពួកគេបានរត់ទៅឆ្ងាយយ៉ាងណា ទោះជាពួកគេបានលាក់ខ្លួនយ៉ាងណា ទោះជាពួកគេបានវង្វេងបាត់ក៏ដោយ ក៏នោះមិនសំខាន់ដែរ ពីព្រោះកូនរបស់ព្រះជាម្ចាស់មិនអាចរត់ទៅឆ្ងាយពេក ឬបានវង្វេងបាត់រហូត ទាល់តែព្រះជាម្ចាស់មិនអាចរកគេឃើញបាននោះឡើយ។



# ការលាងសម្អាតដោយទឹកភ្នែក

ស្ត្រីមានបាបម្នាក់មកជូតសម្អាតជើងព្រះយេស៊ូវ (ដកស្រង់ចេញពីកណ្ឌ ម៉ាកុស ១៤; លូកា ៧ និងយ៉ូហាន ១២)

**នាយប់មួយ** ព្រះយេស៊ូវបានយាងទៅបរិភោគអាហារនៅក្នុងផ្ទះមេដឹកនាំដ៏សំខាន់ម្នាក់។ មេដឹកនាំដ៏សំខាន់ម្នាក់នេះក៏បានអញ្ជើញមិត្តសម្លាញ់ដ៏សំខាន់ៗរបស់គាត់ឲ្យមកចូលរួមផងដែរ។ នៅពេលដែលពួកគេទើបតែនឹងអង្គុយចុះបរិភោគ ស្រាប់តែមានស្ត្រីម្នាក់ដើរចូលមកដោយគ្មានអ្នកណាម្នាក់បានអញ្ជើញនាងទេ ប៉ុន្តែ គេគ្រប់គ្នាក៏បានស្គាល់នាងនោះដែរ។

ពួកភ្ញៀវបានខ្សឹបខ្សៀវគ្នាថា៖ «តើស្ត្រីនេះគិតថាខ្លួនឯងជាអ្នកណាហ្នឹង? មិចក៏ហ៊ានម្ល៉េះ?»។ ពិតប្រាកដណាស់ ស្ត្រីនេះជាមនុស្សមានបាបធ្ងន់ ហើយនរណាៗក៏បានដឹងដែរ (នេះគឺជាការមើលឃើញយ៉ាងងាយស្រួល ព្រោះកាលកន្លងមក នាងបានធ្វើរំលងបញ្ញត្តិ ហើយបានធ្វើការអាក្រក់ជាច្រើនលើកច្រើនសារ)។

ស្ត្រីនោះបានដើរសំដៅឆ្ពោះទៅរកព្រះយេស៊ូវ។ នាងបានយកទឹកអប់ដ៏មានតម្លៃមកជាមួយ។

បើនិយាយអំពីទឹកអប់ពីជំនាន់នោះ គេពុំមានដបសម្រាប់ដាក់ទេ គឺគេដាក់ទឹកអប់នៅក្នុងថូ ហើយថូនោះធ្វើអំពីថ្មដ៏មានតម្លៃដូចជាពីថ្មកែវមួយអញ្ចឹង។ ប៉ុន្តែ អ្វីដែលគួរឲ្យប្លែកនោះគឺថា ថូនេះគ្មានគម្រប ឬឆ្នុកទេ។ ដូច្នេះ មានផ្លូវតែម៉្យាងគត់ ដែលអាចយកទឹកអប់នេះមកប្រើបាន គឺត្រូវតែបំបែកថូ។ កាលណាអ្នកបានបំបែកថូហើយ នោះអ្នកមិនអាចទុកទឹកអប់សល់ទៀតទេ។ មនុស្សភាគច្រើនមិនបានប្រើទឹកអប់ទេ ពីព្រោះវាមានតម្លៃខ្លាំងណាស់។ គេគ្រាន់តែដាក់វានៅលើធ្នើរតាំងសម្រាប់តែល្អមើលតែប៉ុណ្ណោះ។



ដូច្នេះ អ្នកឃើញទេ ទឹកអប់ដែលនាងមាននេះជារបស់ដែលមានតម្លៃខ្លាំងណាស់។ លើសពីគ្រប់ទាំងអ្វីដែលនាងមាន ហើយវាជាសម្បត្តិដ៏មាន



តម្លៃជាទីបំផុតរបស់នាង។

ស្ត្រីនេះបានលុតជង្គង់ចុះនៅចំពោះព្រះយេស៊ូវ ហាក់បីដូចជាព្រះអង្គជាស្តេចមួយអង្គ។ នាងបានចាប់ជើងព្រះយេស៊ូវ ហើយក៏ចាប់ផ្តើមយំ។ ទឹកភ្នែករបស់នាងបានស្រក់ធ្លាក់ចុះលើជើងរបស់ព្រះយេស៊ូវ ដើម្បីជាការលាងសម្អាតជើងរបស់ព្រះអង្គ។ នាងក៏បានថើបជើងរបស់ព្រះអង្គ ហើយយកសក់វែងពណ៌ខ្មៅរលើបរបស់នាងជូតជើងព្រះយេស៊ូវឲ្យស្ងួត។ បន្ទាប់មក នាងបានធ្វើការចម្លែកមួយ គឺនាងបានបំបែកថូ ហើយក៏ចាក់ទឹកអប់ស្រោចស្រពពីលើជើងរបស់ព្រះអង្គ។

គ្រប់គ្នាៗដកដង្ហើមធំ ដោយព្រោះទឹកអប់នេះថ្លៃខ្លាំងណាស់! ម្តេចបានជាខ្ជះខ្ជាយម្ល៉េះ! ហើយយកទៅស្រោចលើជើងរបស់គេទៅវិញ?

ទឹកអប់នេះមានក្លិនក្រអូបដូចជាផ្កាឈូកនៅទីវាលក្នុងរដូវវស្សា។

ព្រះយេស៊ូវបានមើលទៅស្ត្រីនោះ រួចទ្រង់ញញឹមដាក់នាង។ អ្វីដែលនាងបានធ្វើគឺជាការដ៏គួរឲ្យស្ងើចសរសើរណាស់។ ការនេះក៏ដូចជាហោរា សាំយូអែលបានចាក់ប្រេងតាំងឲ្យដាវីឌធ្វើជាស្តេចរបស់ព្រះជាម្ចាស់ កាលពីច្រើនឆ្នាំកន្លងមកដូច្នោះដែរ ឯស្ត្រីនេះបានចាក់ប្រេងថ្វាយព្រះយេស៊ូវ តែនាងមិនប្រើប្រេងទេ គឺនាងបានប្រើទឹកភ្នែករបស់នាងវិញ។





មនុស្សដែលសំខាន់ទាំងនោះក៏ខឹង ព្រោះគេបានគិតថា ព្រះយេស៊ូវមិនគួរមានចិត្តល្អចំពោះស្ត្រីនេះទេ។ គេរអ៊ូថា៖ «ស្ត្រីនេះ គឺជាមនុស្សមានបាប! ចំណែកពួកយើងជាមនុស្សល្អ» (ជាការពិត ពេលមើលពួកគេពីក្រៅ មើលទៅពួកគេហាក់បីដូចជាមនុស្សល្អមែន ព្រោះពួកគេបានកាន់តាមក្រឹត្យវិន័យតាំងពីដើមមក)។



ក៏ប៉ុន្តែ ព្រះយេស៊ូវអាចមើលឃើញក្នុងចិត្តរបស់មនុស្ស ហើយនិងក្នុងចិត្តរបស់ពួកគេ ព្រះយេស៊ូវបានឃើញថា ពួកគេមិនបានស្រឡាញ់ព្រះជាម្ចាស់ ឬមនុស្សដទៃទេ ពួកគេបានរត់ចេញពីព្រះជាម្ចាស់ ហើយពួកគេបានគិតថា គេមិនត្រូវការអ្នកណាសង្គ្រោះគេឡើយ។ ពួកគេបានគិតថា គេជាមនុស្សល្អគ្រប់គ្រាន់ ពីព្រោះពួកគេកាន់តាមក្រឹត្យវិន័យយ៉ាងខ្ជាប់ខ្ជួន ប៉ុន្តែ អំពើបាបបានឃាត់ឃាំងចិត្តរបស់គេមិនឲ្យប្រព្រឹត្តបែបត្រឹមត្រូវ រួចទឹកចិត្តរបស់ពួកគេត្រឡប់ជារឹងរូស ហើយព្រងើយកន្តើយ។

ព្រះយេស៊ូវមានបន្ទូលប្រាប់ពួកគេថា៖ «ស្ត្រីនេះបានដឹងថា នាងជាមនុស្សមានបាប នាងដឹងថា នាងមិនអាចនឹងធ្វើល្អគ្រប់គ្រាន់បានទេ នាងក៏ដឹងទៀតថា នាងត្រូវការឲ្យខ្ញុំជួយសង្គ្រោះនាង ហេតុនេះហើយបានជានាងស្រឡាញ់ខ្ញុំខ្លាំងដល់ម្ល៉េះ»។



«អ្នករាល់គ្នានាំគ្នាមើលងាយស្ត្រីម្នាក់នេះ ពីព្រោះអ្នកមិនគោរពព្រះជាម្ចាស់សោះ។ នាងមានបាបនៅព័ទ្ធជុំវិញពីខាងក្រៅ ប៉ុន្តែ ចំណែកឯអ្នករាល់គ្នាវិញ ជាអ្នកមានបាបនៅខាងក្នុង»។

ពួកមនុស្សសំខាន់ទាំងនោះមានកំហឹងញាប់ញ័រក្នុងខ្លួនយ៉ាងខ្លាំង។

ព្រះយេស៊ូវបែរទៅរកស្ត្រីនោះ ទ្រង់ញញឹម រួចមានបន្ទូលថា៖ «បាបរបស់នាង បានអត់ទោសឲ្យហើយ នាងបានទុកចិត្តលើខ្ញុំ នោះព្រះជាម្ចាស់បានសង្គ្រោះនាងហើយ!»។

ពួកមនុស្សសំខាន់ទាំងនោះរអ៊ូថា៖ «តើលោកគិតថា លោកជាអ្នកណា? ពីព្រោះមានតែព្រះជាម្ចាស់មួយប៉ុណ្ណោះ ដែលអាចអត់ទោសបាបបាន»។

ពួកគេរាល់គ្នាមិនជឿថា ព្រះយេស៊ូវជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ទេ។

កាលណាព្រះយេស៊ូវកាន់តែស្រឡាញ់ និងកាន់តែជួយពួកបណ្ដាជនខ្លាំងឡើងៗ នោះពួកមនុស្សសំខាន់ៗ និងពួកអ្នកដឹកនាំ ក៏កាន់តែស្អប់ព្រះអង្គខ្លាំងឡើងៗផងដែរ។ ពួកគេមានការភ័យខ្លាចថា បណ្ដាជននឹងតាមព្រះយេស៊ូវជាជាងតាមពួកគេ។ ពួកគេមានចិត្តច្រណែន និងមានកំហឹង ដែលល្មមគ្រប់គ្រាន់...ឲ្យពួកគេមានបំណងចង់សម្លាប់ព្រះយេស៊ូវ។





# ស្ដេចដែលជាអ្នកបម្រើ

ការបរិភោគអាហារចុងក្រោយបំផុត (ដកស្រង់ចេញពីកណ្ឌ ម៉ាកុស ១៤ និងយ៉ូហាន ១៣-១៥)

**នាពេលនោះ**ជាថ្ងៃបុណ្យរំលង គឺជាពេលដែលពួករាស្ត្ររបស់ព្រះជាម្ចាស់នាំគ្នាធ្វើបុណ្យរម្លឹកពីការដែលព្រះជាម្ចាស់បានរំដោះពួកគេចេញពីឈ្នួលដាច់ថ្លៃនៅស្រុកអេស៊ីព្ទ។ ជារៀងរាល់ឆ្នាំ ពួកគេបាននាំគ្នាសម្លាប់ចៀមមួយ ហើយញ៉ាំសាច់វា ហើយគេនិយាយដូច្នេះថា៖ «សត្វចៀមត្រូវស្លាប់ជំនួសពួកយើង!»។

ប៉ុន្តែ រីឯថ្ងៃបុណ្យរំលងមួយនេះវិញ ព្រះជាម្ចាស់បានរៀបចំផែនការសម្រាប់សេចក្ដីសង្គ្រោះដ៏ធំធេងជាងនេះ។

ព្រះយេស៊ូវ និងមិត្តភក្តិរបស់ព្រះអង្គនឹងបរិភោគអាហារបុណ្យរំលងរួមគ្នានៅបន្ទប់ខាងលើ។ ប៉ុន្តែ តើមិត្តរបស់ទ្រង់កំពុងតែប្រកែកគ្នាពីរឿងស្អីហ្នឹង? ពួកគេប្រកែកគ្នាអំពីក្លិនជើងស្អុយ? មែនហើយ ជើងស្អុយ។

(បើនិយាយពីរឿងជើង គឺនៅជំនាន់ដើម ពួកគេមិនបានពាក់ស្បែកជើងដូចឥឡូវនេះទេ។ គេពាក់តែស្បែកជើងសង្រែក ដែលស្ដាប់ទៅដូចជាធម្មតាសោះ ប៉ុន្តែផ្លូវថ្នល់នៅសម័យនោះកខ្វក់ ហើយវាមិនគ្រាន់តែកខ្វក់ដោយសារមានដីហុយទេ គឺកខ្វក់ដោយសារមានក្លិនស្អុយ ពីព្រោះមានសត្វគោ និងសត្វសេះគ្រប់ទីកន្លែង អ្នកអាចស្រមៃមើលទៅអ្វីៗដែលនៅលើផ្លូវនោះ។ តើមានអ្វីខ្លះបានជាប់ជើងរបស់ពួកគេ?)។

ដូច្នេះ ទោះជាយ៉ាងណាក៏ដោយ ត្រូវតែមានអ្នកណាម្នាក់លាងជម្រះជើងកខ្វក់ចេញ ប៉ុន្តែនេះជាការងារដែលគួរឲ្យខ្ពើមឆ្អើម តើមាននរណាម្នាក់ស្ម័គ្រចិត្តធ្វើការនេះ?

មានតែអ្នកបម្រើតូចតាចបំផុតប៉ុណ្ណោះ។



សាវ័ក ពេត្រុស និយាយឡើងថា៖ «ខ្ញុំមិនមែនជាអ្នកបម្រើទេ!»។

ហើយសាវ័ក ម៉ាថាយ ក៏និយាយដែរថា៖ «ខ្ញុំក៏មិនមែនដែរ!»។

ព្រះយេស៊ូវទ្រង់បានក្រោកឡើងចេញពីតុដោយស្ងៀមស្ងាត់ ដោះអាវវែងព្រះអង្គចេញ ចាប់យកចានធុង ដួសទឹកពីអាង លុតជង្គង់ចុះ ហើយព្រះអង្គក៏ចាប់ផ្តើមលាងជើងឲ្យមិត្តរបស់ទ្រង់។

សាវ័ក ពេត្រុស និយាយថា៖ «កុំធ្វើអញ្ចឹងអី» គាត់មិនបានយល់ថា ព្រះយេស៊ូវជាស្តេចដែលមកបម្រើនោះទេ។

ព្រះយេស៊ូវមានបន្ទូលថា៖ «ពេត្រុស! បើអ្នកមិនឲ្យខ្ញុំលាងសម្អាតដីនេះចេញទេ នោះអ្នកក៏មិនអាចធ្វើជាមិត្តជិតស្និទ្ធនឹងខ្ញុំបានដែរ»។

ព្រះយេស៊ូវទ្រង់បានជ្រាបថា អ្វីដែលមនុស្សត្រូវការចាំបាច់បំផុតនោះ គឺឲ្យស្អាតពីខាងក្នុងមក។ ដីដែលប្រឡាក់ជើងរបស់គេ គឺគ្មានអ្វីសំខាន់ទេ បើប្រៀបធៀបទៅនឹងអំពើបាបដែលមាននៅក្នុងចិត្តពួកគេនោះវិញ។

សាវ័ក ពេត្រុស ក៏និយាយតបថា៖ «អញ្ចឹងសូមទ្រង់លាងឲ្យខ្ញុំមក ព្រះអម្ចាស់អើយ!» គាត់និយាយទាំងមានទឹកភ្នែក «សូមទ្រង់លាងខ្លួនប្រាណខ្ញុំទាំងមូលផង!»។

ព្រះយេស៊ូវបានលាងជើងពួកគេម្តងម្នាក់ៗ។

ព្រះយេស៊ូវបានពន្យល់គេថា៖ «ខ្ញុំធ្វើដូច្នេះ ពីព្រោះខ្ញុំស្រឡាញ់អ្នករាល់គ្នា ចូរធ្វើដូច្នេះឲ្យគ្នាទៅវិញទៅមកចុះ»។





មានមិត្តភក្តិម្នាក់របស់ព្រះយេស៊ូវមានផែនការអាក្រក់មួយ។ គ្មានអ្នកណាម្នាក់ដឹងពីផែនការអាក្រក់នោះឡើយ។ ប៉ុន្តែព្រះយេស៊ូវទ្រង់បានដឹងរួចជាស្រេចហើយ ឯសាវ័ក យូដាស ក៏បានដឹងដែរ។ សាវ័ក យូដាស មានផែនការថា នឹងជួយពួកមេដឹកនាំឲ្យចាប់ព្រះយេស៊ូវ ដោយគាត់នឹងទទួលបានកម្រៃជាសាមសិបកាក់ប្រាក់។

ព្រះយេស៊ូវមានបន្ទូលថា៖ «ទៅចុះ យូដាស» រួចសាវ័ក យូដាស ក៏ក្រោកចេញពីតុបាយ ដើរចេញពីបន្ទប់ រួចចេញទៅក្រៅទាំងយប់។

បន្ទាប់ពីនោះមក ព្រះយេស៊ូវទ្រង់បានលើកនំបុ័ងឡើង ហើយកាច់បំបែក។ ទ្រង់បានប្រទានបំណែកនំបុ័ងទៅពួកមិត្តទ្រង់។ ហើយព្រះអង្គក៏យកពែងស្រាទំពាំងបាយជូរមក រួចអរព្រះគុណដល់ព្រះជាម្ចាស់ ព្រះអង្គចាក់ស្រាទំពាំងបាយជូរនោះចែកដល់ពួកគេគ្រប់ៗគ្នា។

ព្រះយេស៊ូវមានបន្ទូលប្រាប់ពួកគេថា៖ «នំបុ័ងនេះប្រៀបដូចជារូបកាយខ្ញុំដែលនឹងត្រូវបែកបាក់ ឯពែងនេះ គឺដូចជាឈាមខ្ញុំដែលនឹងបង្ហូរចេញមក»។

«ប៉ុន្តែ នេះជារបៀបដែលព្រះជាម្ចាស់នឹងជួយសង្គ្រោះដល់លោកីយ៍ទាំងមូល។ តាមរយៈការដែលជីវិតរបស់ខ្ញុំបាក់បែក នោះលោកីយ៍របស់ព្រះជាម្ចាស់ដែលបាក់បែកនឹងត្រូវបានស្តារឡើងវិញ។ ចិត្តរបស់ខ្ញុំនឹងត្រូវបែកខ្ទេចខ្ទាំ ហើយចិត្តរបស់អ្នកនឹងត្រូវសះស្បើយឡើងវិញ។ ដូចជាកូនចៀមនៃបុណ្យរំលងដែលនឹងត្រូវស្លាប់ដែរ នោះខ្ញុំក៏ត្រូវស្លាប់ជំនួសអ្នករាល់គ្នាដែរ។ ឈាមរបស់ខ្ញុំនឹងលាងសម្អាតអស់ទាំងអំពើបាបរបស់អ្នករាល់គ្នា។ ហើយអ្នករាល់គ្នានឹងបានស្អាតពីខាងក្នុងមក គឺនៅក្នុងចិត្តអ្នករាល់គ្នា»។

ព្រះយេស៊ូវមានបន្ទូលទៀតថា៖ «ដូច្នេះ នៅពេលណាដែលអ្នករាល់គ្នាទទួលទាន ឬផឹកពីពែងនេះ អ្នកចូរចាំថា ខ្ញុំបានប្រោសលោះអ្នករាល់គ្នាហើយ!»។

ព្រះយេស៊ូវដឹងថា ជិតដល់ពេលដែលព្រះអង្គនឹងចាកចេញពីលោកីយ៍នេះ ហើយយាងត្រឡប់ទៅឯព្រះជាម្ចាស់វិញ។

ដូច្នេះ ព្រះអង្គមានបន្ទូលថា៖ «ខ្ញុំនឹងមិននៅជាមួយអ្នករាល់គ្នាជាយូរប៉ុន្មានទៀតទេ អ្នករាល់គ្នានឹងមានសេចក្តីសោកសង្រេងជាខ្លាំង ប៉ុន្តែ អ្នកជំនួយរបស់ព្រះជាម្ចាស់នឹងមកដល់ បន្ទាប់មកអ្នករាល់គ្នានឹងបានពោរពេញទៅដោយសេចក្តីសុខសាន្តដ៏អស់កល្បជារៀងរហូតតទៅ។ ដូច្នេះចូរកុំឲ្យភ័យខ្លាចឡើយ អ្នករាល់គ្នាជាមិត្តរបស់ខ្ញុំ ហើយខ្ញុំស្រឡាញ់អ្នករាល់គ្នា»។

បន្ទាប់មក ពួកគេក៏នាំគ្នាច្រៀងបទចម្រៀងដែលគេចូលចិត្តច្រៀង ហើយក៏ដើរទៅសួនច្បារដើមអូលីវ ជាកន្លែងដែលពួកគេចូលចិត្ត។





# យប់ដ៏ខ្មៅងងឹតនៅឯសួនច្បារ

សួនច្បារគែតសេម៉ានី (ដកស្រង់ចេញពីកណ្ឌ លូកា ២២; ម៉ាកុស ១៤ និងយ៉ូហាន ១៨)

**នៅយប់នោះ** ខ្យល់បានបោកបក់ជាខ្លាំងឡើងៗ រុញច្រានពពកឲ្យគ្របបាំងលោកខែ ហើយភាពងងឹតក៏បានគ្របដណ្ដប់សួនច្បារ។

ព្រះយេស៊ូវមានបន្ទូលទៅមិត្តភក្តិរបស់ព្រះអង្គថា៖ «ចូរនៅចាំយាមជាមួយខ្ញុំ» ពួកគេយល់ព្រម ហើយក៏នៅរង់ចាំក្រោមដើមអូលីវនោះទៅ ប៉ុន្តែដោយព្រោះពួកគេអស់កម្លាំង បន្តិចក្រោយមកគេក៏នាំគ្នាដេកលក់អស់ទៅ។

ព្រះយេស៊ូវទ្រង់យាងទៅទីងងឹតខាងមុខតែម្នាក់ឯង ព្រះអង្គត្រូវការនិយាយជាមួយព្រះវរបិតារបស់ព្រះអង្គដែលគង់នៅស្ថានសួគ៌។

ព្រះអង្គបានដឹងថា នេះគឺជាពេលដែលទ្រង់ត្រូវសុគត។ ព្រះអង្គ និងព្រះវរបិតាទ្រង់បានរៀបចំផែនការនេះជាយូរមកហើយ។ ព្រះយេស៊ូវនឹងទទួលនូវរាល់ទោសកំហុសទាំងអស់ ដែលមនុស្សគ្រប់គ្នាបានធ្វើ និងអ្វីៗដែលមនុស្សនឹងធ្វើនាពេលខាងមុខ។

ព្រះយេស៊ូវស្រែកឡើង ហើយក៏លុតជង្គង់ចុះលើដី «លោកឪពុក! ព្រះវរបិតា! តើមានផ្លូវណាមួយផ្សេងទៀត ដើម្បីទទួលយកកូនៗរបស់ព្រះអង្គមកវិញដែរឬទេ? ដើម្បីនឹងផ្សះផ្សាចិត្តរបស់ពួកគេ? ដើម្បីដកយកពិសពុលនោះចេញដែរឬទេ?»។

ប៉ុន្តែ ព្រះយេស៊ូវទ្រង់ដឹងហើយថា គ្មានផ្លូវណាផ្សេងទៀតទេ។ គ្រប់ទាំងពិសពុលនៃអំពើបាបត្រូវតែហូរចូលទៅក្នុងបេះដូងរបស់ទ្រង់ផ្ទាល់។

ព្រះជាម្ចាស់នឹងចាក់សេចក្ដីសោកសង្រេង និងគ្រប់ទាំងភាពខ្មៅចខ្វាំក្នុងចិត្តរបស់មនុស្សជាតិចូលទៅក្នុងបេះដូងរបស់ព្រះយេស៊ូវ។ ព្រះអង្គនឹងចាក់គ្រប់ទាំងជំងឺនៅក្នុងរូបកាយរបស់មនុស្សជាតិ ទៅក្នុងរូបកាយព្រះយេស៊ូវ។ ព្រះជាម្ចាស់នឹងបន្ទោសបុត្រារបស់ទ្រង់សម្រាប់នូវរាល់អ្វីៗដែលខុសនៅលើផែនដីនេះ។ ការនោះនឹងធ្វើឲ្យព្រះយេស៊ូវទទួលភាពខ្មៅចខ្វាំយ៉ាងខ្លាំង។



ប៉ុន្តែ មានការមួយផ្សេងទៀត ជាការដែលគួរឲ្យភ័យខ្លាចជាងនេះទៅទៀត គឺនៅពេលណាដែលមនុស្សបានរត់ចេញពីព្រះជាម្ចាស់ទៅ នោះគេបានបាត់បង់ព្រះជាម្ចាស់។ ការនេះកើតឡើងនៅវេលាណាគេរត់ចេញឆ្ងាយទៅ មិនបាននៅជាប់លាប់នឹងព្រះជាម្ចាស់ គឺដូចជាត្រូវជាប់ទោស។ ព្រះយេស៊ូវនឹងទទួលទោសជំនួសពួកគេ។

ព្រះយេស៊ូវបានដឹងថាការនេះមានន័យដូចម្ដេច គឺព្រះអង្គនឹងត្រូវបាត់បង់ព្រះវរបិតាទ្រង់ ហើយព្រះយេស៊ូវបានដឹងថាការនេះ នឹងធ្វើឲ្យបេះដូងរបស់ព្រះអង្គបែកជាពីរ។

ភាពខ្សឹកខ្សួលដ៏ខ្លាំងនេះបានអង្រួនខ្លួនទាំងមូលរបស់ព្រះយេស៊ូវឲ្យញាប់ញ័រ។

ក្រោយមក ព្រះយេស៊ូវនៅស្ងៀមស្ងាត់ដូចជាសត្វចៀម។ ព្រះអង្គបានមានបន្ទូលថា៖ «ឱ! បិតាអើយ! ខ្ញុំទុកចិត្តលើព្រះអង្គហើយ ព្រះអង្គមានបន្ទូលយ៉ាងណាក៏ដោយ ខ្ញុំនឹងធ្វើតាមទាំងអស់»។





ភ្លាមៗនោះ មានពន្លឺជះដូចផ្កាយចាំងផ្លេកៗចេញពីព្រៃមក នៅក្នុងសួនច្បារដែលកំពុងតែមានភាពស្ងប់ស្ងាត់នោះ ស្រាប់តែមានសំឡេងខ្សឹបខ្សៀវរអ៊ូៗ សំឡេងដែកទង្គិចគ្នា និងសំឡេងស្បែកជើងឃ្លុបដើរចូលមក។

ព្រះយេស៊ូវបានក្រោកឈរឡើង។

ព្រះអង្គបានដាស់មិត្តរបស់ទ្រង់ឡើង ហើយមានបន្ទូលទៅពួកគេដោយទន់ភ្លន់ថា៖ «ពេលវេលាបានមកដល់ហើយ! គ្រប់ការទាំងអស់ដែលបានសរសេរអំពីខ្ញុំ នូវអ្វីដែលព្រះមានបន្ទូលប្រាប់រាស្ត្ររបស់ទ្រង់ជាយូរឆ្នាំកន្លងមក ឥឡូវនេះបានក្លាយជាការពិតហើយ»។

ហើយយប់កាន់តែជ្រៅទៅៗ ពួកគេបានមកទាំងកាន់ភ្លើងចន្លុះ និងចង្កៀង ព្រមទាំងដាវ និងដំបងហើយនិងអាវក្រោះផង ពួកគេមកជាមួយទាហានមួយក្រុម ដោយមានសាវ័ក យូដាស ជាអ្នកនាំមុខពួកគេមក។ សាវ័ក យូដាស បានដើរតម្រង់ទៅកាន់ព្រះយេស៊ូវ ដើម្បីឲ្យពួកគេចាប់ទ្រង់។

ហើយព្រះយេស៊ូវកំពុងរង់ចាំពួកគេ។



សាវ័ក ពេត្រុស ហក់ចូល ហូតដាវមួយ កាប់ដាច់ត្រចៀកទាហានម្នាក់ ហើយព្យាយាមការពារព្រះយេស៊ូវ។ រំពេចនោះព្រះយេស៊ូវទ្រង់បានយកដៃពាល់ត្រចៀកទាហាននោះ ហើយប្រោសគាត់ឲ្យបានជាដូចដើមវិញ។

ព្រះអង្គមានបន្ទូលថា៖ «ពេត្រុស! អ្នកមិនត្រូវធ្វើបែបនេះទេ»។

សាវ័ក ពេត្រុស មិនបានយល់ថា ទោះជាមានទាហានច្រើនប៉ុណ្ណាក៏ដោយ ក៏គេមិនអាចនឹងចាប់ព្រះយេស៊ូវបានឡើយ លើកលែងតែព្រះយេស៊ូវអនុញ្ញាតឲ្យគេចាប់ប៉ុណ្ណោះ។

បន្ទាប់មក គេចាប់ព្រះយេស៊ូវ ហាក់បីដូចព្រះអង្គជាមនុស្សមានទោសធ្ងន់ធ្ងរម្នាក់អញ្ចឹង តែព្រះយេស៊ូវមិនដែលធ្វើអ្វីខុសសោះ មានតែស្រឡាញ់មនុស្សគ្រប់ៗគ្នាតែប៉ុណ្ណោះ។

ពួកមិត្តភក្តិរបស់ព្រះយេស៊ូវមានការភ័យខ្លាច។ ដូច្នេះ ពួកគេបាននាំគ្នារត់ទៅលាក់ខ្លួនក្នុងទីងងឹតអស់ទៅ។

ពួកទាហានបាននាំព្រះយេស៊ូវចេញទៅ ហើយក៏នាំព្រះអង្គទៅឯពួកមេដឹកនាំរបស់ពួកគេ។

ពួកមេដឹកនាំបាននាំព្រះយេស៊ូវទៅកាត់ទោស ពួកគេបានសួរថា៖ «តើឯងជាព្រះរាជបុត្រានៃព្រះជាម្ចាស់មែនឬ?»។

ព្រះយេស៊ូវបានឆ្លើយថា៖ «គឺខ្ញុំនេះហើយ»។

«តើឯងគិតថា ឯងជាអ្នកណា ដែលហៅខ្លួនឯងថាជាព្រះនោះ? ឯងត្រូវតែស្លាប់ ដែលហ៊ានហៅខ្លួនឯងថាជាបុត្រានៃព្រះជាម្ចាស់»។

មានតែពួករ៉ូមមួយប៉ុណ្ណោះ ដែលអាចនឹងសម្លាប់អ្នកទោសបាន។ ដូច្នេះ ពួកមេដឹកនាំបានរៀបចំផែនការឡើង៖ «ពួកយើងនឹងប្រាប់ពួករ៉ូមថា មនុស្សម្នាក់នេះចង់ធ្វើជាស្តេចនៅលើពួកយើង! ប្រាប់ដូច្នេះ គេនឹងឆ្កាងវាហើយ»។

ប៉ុន្តែ មិនអីទេ ពីព្រោះនេះជាផែនការរបស់ព្រះជាម្ចាស់។

ព្រះយេស៊ូវមានបន្ទូលថា៖ «គឺដោយហេតុនេះហើយ បានជាខ្ញុំត្រូវកើតមកក្នុងលោកីយ៍នេះ»។



# ថ្ងៃដែលព្រះអាទិត្យលែងជះពន្លឺ

ការជាប់ឆ្កាង (ដកស្រង់ចេញពីកណ្ឌ ម៉ាថាយ ២៧; ម៉ាកុស ១៥; លូកា ២៣ និងយ៉ូហាន ១៩)

**ពួកទាហានរ៉ូម**សួរព្រះអង្គដោយចំអកឡកឡឺយថា៖ «ដូច្នេះ ឯងគឺជាស្តេចមែនឬ? បើឯងជាស្តេចមែន ឯងត្រូវតែមានមកុដ និងអាវផាយ»។

ពួកគេបានឲ្យមកុដធ្វើពីបន្លាមួយថ្វាយដល់ព្រះយេស៊ូវ និងបំពាក់អាវផាយពណ៌ស្វាយដល់ទ្រង់ ហើយធ្វើពុតជាឱនចុះចំពោះព្រះអង្គ។ ពួកគេនិយាយថា៖ «ថ្វាយបង្គំព្រះករុណា»។ រួចមកពួកគេនាំគ្នាវាយព្រះអង្គនឹងខ្សែតី ហើយស្តោះទឹកមាត់ដាក់ទ្រង់ទៀត។ ពួកគេមិនបានយល់ថា ព្រះអង្គជាព្រះអម្ចាស់ក្សត្រានៃជីវិត ជាស្តេចនៃស្ថានសួគ៌ និងផែនដី ដែលយាងមកដើម្បីជួយសង្គ្រោះពួកគេរាល់គ្នាឡើយ។



ពួកទាហានរ៉ូមបានធ្វើស្លាកមួយឲ្យទ្រង់ «ស្តេចយើង» ហើយគេដំដែកគោលភ្ជាប់ស្លាកនេះទៅនឹងឈើឆ្កាង។

ពួកគេបានដើរឡើងទៅលើទួលខ្ពស់មួយនៅខាងក្រៅទីក្រុង ព្រះយេស៊ូវលីឈើឆ្កាងលើខ្នងព្រះអង្គ។ ព្រះយេស៊ូវមិនដែលធ្វើអ្វីខុសសោះ ប៉ុន្តែពួកគេនឹងធ្វើគុតព្រះអង្គ តាមរបៀបដែលគេធ្លាប់សម្លាប់ពួកអ្នកមានទោសធ្ងន់។

ពួកគេក៏ដំដែកគោលឆ្កាងព្រះយេស៊ូវ។

ហើយព្រះអង្គក៏ដកដង្ហើមធំៗដោយលើកឡើងថា «ឱ! ព្រះវរបិតាអើយ! សូមអត់ទោសពួកគេចុះ ពីព្រោះគេមិនយល់ពីការដែលគេកំពុងតែធ្វើទេ»។

ពួកបណ្តាជនបានស្រែកថា៖ «ឯងបាននិយាយថា ឯងមកជួយសង្គ្រោះយើង! ប៉ុន្តែ ឯងមិនទាំងអាចជួយខ្លួនឯងបានផង!»។

ប៉ុន្តែ គេបានយល់ខុសហើយ ព្រះយេស៊ូវអាចនឹងរំដោះខ្លួនឯងបាន។ ហើយពួកហ្វូងទេវតាថែមទាំងអាចនឹងហោះមកនៅក្បែរទ្រង់ ប្រសិនជាព្រះអង្គហៅពួកគេ។

ពួកបណ្តាជននិយាយថា៖ «ប្រសិនបើឯងជាកូនព្រះជាម្ចាស់ពិតមែន នោះឯងអាចនឹងសម្រូតចុះពីលើឈើឆ្កាងមកបាន»។

ពួកគេនិយាយត្រូវប្រាកដណាស់ ព្រះយេស៊ូវអាចនឹងសម្រូតចុះមកដោយខ្លួនឯងបាន។ តាមពិតទៅ បើព្រះអង្គគ្រាន់តែមានបន្ទូលមួយម៉ាត់ នោះអ្វីៗអាចនឹងឈប់ភ្លាម គឺដូចជាក្នុងកាលព្រះអង្គបានប្រោសក្មេងស្រីម្នាក់ឲ្យជា និងបញ្ឈប់ខ្យល់ព្យុះ ហើយនិងប្រទានអាហារដល់មនុស្ស ៥.០០០នាក់។

ប៉ុន្តែ ព្រះយេស៊ូវនៅលើឈើឆ្កាងយ៉ាងស្ងៀម។

តាមពិតទៅ ពួកគេមិនយល់អ្វីសោះ។ ដែកគោលមិនមែនជាអ្វីដែលបណ្តាលឲ្យព្រះយេស៊ូវជាប់នៅលើឈើឆ្កាងនោះទេ ប៉ុន្តែគឺជាសេចក្តីស្រឡាញ់របស់ទ្រង់ទេតើ។

ព្រះយេស៊ូវទ្រង់សម្លឹងទៅលើមេឃ ដោយស្រែកយ៉ាងអន្ទះអន្ទែងថា៖ «ព្រះវរបិតាអើយ! តើទ្រង់នៅឯណា? សូមកុំចោលទូលបង្គំឡើយ!»។

នេះជាលើកដំបូង និងចុងក្រោយបំផុត ដែលព្រះយេស៊ូវមានបន្ទូល តែគ្មានអ្វីកើតឡើង គឺជាភាពស្ងៀមស្ងាត់រហូត គួរឲ្យភ័យខ្លាច។ ព្រះវរបិតាមិនបានឆ្លើយតបឡើយ ព្រះអង្គបានបែរខ្នងដាក់ព្រះរាជបុត្រាទ្រង់ហើយ។

ទឹកភ្នែកបានហូរស្រោចស្រពមុខព្រះយេស៊ូវ គឺជាមុខរបស់ព្រះអង្គផ្ទាល់ ដែលទ្រង់នឹងជូតទឹកភ្នែកចេញពីគ្រប់ភ្នែកទាំងអស់។







ទោះបីជាឥឡូវនេះ ពាក់កណ្ដាលថ្ងៃត្រង់ទៅហើយក្ដី ភាពងងឹតបានមកគ្របដណ្ដប់លើផ្ទៃផែនដីទាំងមូល។ ព្រះអាទិត្យមិនអាចនឹងបញ្ចេញពន្លឺបាន ផែនដីរញ្ជួយហើយញាប់ញ័រ ភ្នំធំៗក៏កក្រើកឡើង ផ្ទាំងថ្មបានបែកជាពីរ រហូតទាល់តែមើលទៅឃើញថាហាក់បីដូចជាផែនដីទាំងមូលបានបាក់បែក អ្វីដែលព្រះជាម្ចាស់បានបង្កើតនោះហាក់បីដូចជាអាចនឹងបណ្ដាលឲ្យរហែកចេញពីគ្នា។

ព្យុះនៃកំហឹងដ៏ខ្លាំងក្លារបស់ព្រះជាម្ចាស់ចំពោះអំពើបាប បានសម្រុកចុះមកយ៉ាងខ្លាំងមកលើព្រះរាជបុត្រាទ្រង់ ជំនួសរាស្ត្ររបស់ព្រះអង្គ។ នេះគឺជាផ្លូវតែមួយគត់ ដែលព្រះជាម្ចាស់អាចបំផ្លាញអំពើបាបបាន ដោយមិនបំផ្លាញកូនរបស់ព្រះអង្គ ដោយសារចិត្តរបស់គេពោរពេញទៅដោយអំពើបាបនោះឡើយ។

ព្រះយេស៊ូវបានស្រែករំពងឡើងថា៖ «កិច្ចការបានសម្រេចហើយ»។

ការសង្គ្រោះបានស្រេចមែន ព្រះអង្គធ្វើបានសម្រេចមែនហើយ គឺព្រះយេស៊ូវបានសង្គ្រោះលោកីយ៍ទាំងមូល។

ព្រះយេស៊ូវស្រែកឡើងថា៖ «ព្រះវរបិតាអើយ! ខ្ញុំសូមថ្វាយជីវិតខ្ញុំទៅព្រះអង្គហើយ» ជាមួយនឹងការដកដង្ហើមធំចុងក្រោយ ព្រះយេស៊ូវក៏បានដាក់ជីវិតរបស់ទ្រង់ឲ្យសុគតទៅ។

មានស្រមោល និងពពកដ៏ចម្លែកបានមកគ្របដណ្ដប់លើមេឃដោយមានពណ៌ស្វាយ ពណ៌ទឹកក្រូច ពណ៌ខ្មៅ ហាក់បីដូចជាត្រូវជាំអញ្ចឹង។

ពួកមិត្តភក្តិរបស់ព្រះយេស៊ូវបាននាំគ្នាសែងសពព្រះអង្គយ៉ាងថ្នមៗចេញទៅ។ ពួកគេបានផ្តេកសពព្រះអង្គនៅក្នុងផ្នូរថ្មីមួយដែលគេចោះក្នុងរូងថ្ម។

ហេតុអ្វីព្រះយេស៊ូវត្រូវសុគត? តើទ្រង់ខុសអ្វី? តើនេះមានន័យដូចម្តេចទៅ? ពួកគេមិនបានដឹងរឿងអ្វីទៀតទេ លើកលែងតែម្យ៉ាង គឺពួកគេមានចិត្តខ្ទេចខ្ទាំ។

ពួកមេដឹកនាំគេនិយាយថា៖ «នេះគឺជាទីបញ្ចប់របស់ព្រះយេស៊ូវហើយ»។

ប៉ុន្តែ ដើម្បីឲ្យប្រាកដច្បាស់ ពួកគេបានបញ្ជូនទាហានដែលខ្លាំងពូកែឲ្យទៅចាំយាមផ្នូរទ្រង់។ ពួកគេបានប្រមៀលផ្ទាំងថ្មមួយដុំដ៏ធំមកបិទមុខផ្នូរ ដើម្បីកុំឲ្យនរណាម្នាក់អាចចូលទៅក្នុង។

ឬក៏ចេញមកខាងក្រៅបាន។



# ការភ្ញាក់ផ្អើលដ៏អស្ចារ្យពីព្រះ

ការរស់ឡើងវិញ (ដកស្រង់ចេញពីកណ្ឌ ម៉ាថាយ ២៨; ម៉ាកុស ១៦; លូកា ២៤ និងយ៉ូហាន ២០)

**ពួកមិត្តភក្តិ**របស់ព្រះយេស៊ូវមានចិត្តសោកសង្រេង ពីព្រោះពួកគេនឹងមិនជួបមិត្តដ៏ស្និទ្ធស្នាលរបស់ពួកគេទៀតឡើយ។ តើហេតុអ្វីបានជាការនេះកើតឡើងយ៉ាងដូច្នេះ? តើព្រះយេស៊ូវមិនមែនជាអ្នកសង្រ្គោះទេឬអី? តើព្រះអង្គមិនមែនជាស្តេចដែលព្រះវរបិតាបានសន្យាឲ្យមកទេឬអី? ដំណើររឿងមួយនេះមិនគួរចប់ដោយរបៀបនេះទេ។

ពិតមែនហើយ! ប៉ុន្តែ តើនរណាបាននិយាយថានេះជាភាគបញ្ចប់?

មុនពេលថ្ងៃរះបន្តិច នៅថ្ងៃទីបី ព្រះជាម្ចាស់បានចាត់ទេវតាម្នាក់មកពីស្ថានសួគ៌ ហើយឲ្យមានការរញ្ជួយដីយ៉ាងខ្លាំង។ នៅពេលដែលពួកអ្នកយាមបានឃើញទេវតានោះ ពួកគេភ័យខ្លាច រហូតដល់ដួលសន្លប់ទាំងអស់គ្នាទៅ។ ទេវតាក៏បានប្រមៀលផ្ទាំងថ្មដ៏ធំនោះចេញ បន្ទាប់មកអង្គុយពីលើនោះ ហើយរង់ចាំ។

នាព្រឹកព្រលឹមស្រាងៗនៅឡើយនាង ម៉ារា-ម៉ាក់ដាឡា និងស្រ្តីឯទៀតៗបាននាំគ្នាទៅមើលផ្នូរ ដើម្បីលាងសម្អាតសពព្រះយេស៊ូវ។ នៅព្រឹកព្រលឹមនោះ ពន្លឺថ្ងៃបានចាំងឆ្លុះតាមចន្លោះដើមអូលីវ ទឹកសន្សើមចាំងផ្លេកៗលើស្លឹកឈើ និងស្មៅ ដូចជាដំណក់ទឹកភ្នែកគ្រប់ទីកន្លែង។ ពួកមិត្តសម្លាញ់របស់ព្រះយេស៊ូវបានដើរយ៉ាងស្ងៀមស្ងាត់តាមផ្លូវជើងភ្នំ កាត់ចំការដើមអូលីវ រហូតបានទៅដល់ផ្នូរ ហើយរំពេចនោះពួកគេបានសម្គាល់ឃើញថា ផ្នូរបានបើកចំហ។

ពួកគេបានសម្លឹងមើលទៅក្នុងផ្នូរដ៏ងងឹតតាមមាត់ច្រកបើកចំហនោះដោយប្រុងប្រយ័ត្ន។ ប៉ុន្តែ! ឈប់សិន! សពរបស់ព្រះយេស៊ូវបានបាត់ទៅហើយ!





ហើយមានអ្វីផ្សេងទៀតកើតឡើង គឺមានបុរសម្នាក់នៅទីនោះ សម្លៀកបំពាក់របស់គាត់មានពន្លឺភ្លឺចិញ្ចាចដូចជាពន្លឺរន្ទះ។

ទេវតាបានប្រាប់ថា៖ «កុំខ្លាចអី!»។

ប៉ុន្តែ (ពួកគេទប់អារម្មណ៍ខ្លាចមិនបានទេ) ហើយពួកគេនៅតែស្រែកដដែល។

ទេវតាបានសួរទៅពួកគេថា៖ «តើអ្នកទាំងអស់គ្នាមកទីនេះធ្វើអ្វី? នេះជាផ្នូរខ្មោច ហើយផ្នូរខ្មោចនេះសម្រាប់ដាក់មនុស្សស្លាប់»។

ស្ត្រីទាំងនោះឆ្លើយមិនរួច។

ទេវតាបាននិយាយថា៖ «ព្រះយេស៊ូវមិននៅស្លាប់ទៀតទេ! ព្រះអង្គបានមានព្រះជន្មរស់ឡើងវិញហើយ!»។

ពេលនោះ បេះដូងរបស់គេបានលោតពុះកញ្ជ្រោលឡើង។ បន្ទាប់មកទេវតាក៏បានសើចយ៉ាងសប្បាយ ហើយក្នុងរំពេចនោះ ពួកគេមានអារម្មណ៍ថាហាក់បីដូចជាទើបតែភ្ញាក់ពីការមានសុបិន្តដ៏អាក្រក់មួយអញ្ចឹង។

នាង ម៉ារា បានបន្តនៅទីនោះ ហើយឯស្ត្រីឯទៀតបានប្រញាប់នាំគ្នារូតរះម្នីម្នាត្រឡប់ទៅផ្ទះវិញ។ តើនេះអាចជាការពិតមែនឬ? ព្រះយេស៊ូវទ្រង់បានសុគតពិតមែន តើព្រះអង្គអាចនឹងរស់ឡើងវិញដូចម្ដេចទៅ? ទន្ទឹមពេលនោះនាង ម៉ារា បានឮសំឡេងនរណាម្នាក់នៅក្នុងសួនច្បារដែរ។ នាងបានគិតក្នុងចិត្តថា ប្រហែលជាសំឡេងរបស់អ្នកថែសួន។ គាត់ប្រហែលជាដឹងថា សពព្រះយេស៊ូវនៅទីណាហើយ។

នាង ម៉ារា បាននិយាយភ្លាមៗថា៖ «ខ្ញុំមិនដឹងថា សពព្រះយេស៊ូវទ្រង់នៅឯណាទេ! ខ្ញុំមិនអាចរកទ្រង់ឃើញទេ»។

ប៉ុន្តែ មិនអីទេ ព្រោះព្រះយេស៊ូវស្គាល់ទីកន្លែងដែលនាងកំពុងនៅ ហើយទ្រង់ក៏បានរកនាងឃើញ។

ព្រះអង្គមានបន្ទូលថា៖ «ឱ! នាង ម៉ារា អើយ!»។

មានតែមនុស្សម្នាក់ប៉ុណ្ណោះដែលហៅឈ្មោះនាងបែបនេះ។ បេះដូងរបស់នាងលោតចង្វាក់យ៉ាងខ្លាំង។ នាងក៏ងាកមើលក្រោយ ហើយឃើញស្រមោលជារូបរាងមួយ។ នាងបានយកដៃបាំងភ្នែកដើម្បីមើល...ហើយបានគិតថា នាងកំពុងតែយល់សប្តិ។

ប៉ុន្តែ នាងមិនមែនយល់សប្តិទេ គឺនាងកំពុងតែមើលឃើញ។

«ព្រះយេស៊ូវ!»

នាង ម៉ារា បានក្រាបចុះទៅលើដី រំពេចនោះទឹកភ្នែករលីងរលោងជោកក្នុងកែវភ្នែករបស់នាង ហើយនាងបានយំអណ្តឺតអណ្តកជាខ្លាំងរហូតដល់ញ័ររាងកាយទាំងមូល រួចអ្វីដែលនាងចង់បានក្នុងពេលនោះ គឺតោងព្រះយេស៊ូវឲ្យជាប់មិនឲ្យព្រះអង្គយាងទៅណាទៀតឡើយ។

ព្រះយេស៊ូវបានមានបន្ទូលដោយស្រទន់ថា៖ «នាងអាចមានឱកាសនឹងតោងខ្ញុំនៅពេលក្រោយបាន នាងនឹងនៅជាប់ជាមួយខ្ញុំជានិច្ច។ ប៉ុន្តែឥឡូវនេះ ចូរចេញទៅប្រាប់អ្នកដទៃទៀតថា ខ្ញុំរស់ឡើងវិញហើយ!»។





នាង ម៉ារា បានរត់ហើយរត់ទៀត រត់ទាល់តែដល់ទីក្រុង។ នាងមិនដែលរត់បានលឿន និងបានឆ្ងាយដូចនេះទេ! នាងមានអារម្មណ៍ថា នាងអាចរត់បានរហូត នាងមានអារម្មណ៍ទៀតថាជើងនាងហាក់ដូចជាមិនបានប៉ះដីផង។ ពន្លឺថ្ងៃហាក់ដូចជារត់តាម ហើយបញ្ចាំងរស្មីចែងចាំងយ៉ាងច្បាស់ កាត់សន្ទឹងនៅលើមេឃប្រណាំងជាមួយនាង គឺវាបានបញ្ចេញរស្មីខ្លាំងជាងរាល់ដងតាមដែលនាងចាំបាន ក្នុងជំនោរខ្យល់ល្អមួយនេះ។

នាព្រឹកនោះ ពេលដែលនាងកំពុងតែរត់ នាងមានអារម្មណ៍ថាផែនដីនេះហាក់បីដូចជាត្រូវបានបង្កើតឡើងជាថ្មីម្តងទៀត ហាក់បីដូចជាផែនដីនេះបានច្រៀងដោយអំណរ–ទាំងដើមឈើវាលស្មៅ និងសត្វស្លាប...ហើយចិត្តរបស់នាងក៏បានច្រៀងផងដែរ។

តើព្រះជាម្ចាស់កំពុងធ្វើឲ្យគ្រប់ទាំងសេចក្តីយំសោកត្រឡប់ជាមិនយំសោកវិញមែនឬ? តើព្រះអង្គទ្រង់កំពុងធ្វើឲ្យសេចក្តីស្លាប់ត្រឡប់មកវិញមិនមែនជាការពិតមែនឬ?

នាងស្ទើរតែមិនអាចរង់ចាំបានទេក្នុងការប្រាប់ដំណឹងដល់មិត្តភក្តិរបស់ព្រះយេស៊ូវ។ នាងបានគិតក្នុងចិត្តដោយអស់សំណើចថា៖ «គេនឹងមិនជឿឡើយ!»។

ប្រាកដណាស់ នាងបានគិតត្រូវមែន។

# ការវិលត្រឡប់ទៅផ្ទះវិញ

ការឡើងទៅស្ថានសួគ៌វិញ (ដកស្រង់ចេញពីកណ្ឌ ម៉ាថាយ ២៨; ម៉ាកុស ១៦; លូកា ២៤ និងយ៉ូហាន ១៤)

**ពួកមិត្តភក្តិរបស់ព្រះយេស៊ូវ** គេមានការភ័យខ្លាចជាខ្លាំង។ ដូច្នេះហើយបានជាពួកគេឡើងទៅពួននៅក្នុងបន្ទប់ខាងលើ ដោយបិទទ្វារ ដាក់គន្លឹះយ៉ាងជាប់។

ក៏ប៉ុន្តែ ការនេះមិនអាចឃាំងព្រះយេស៊ូវបានឡើយ។ ព្រះអង្គបានដើរទម្លុះជញ្ជាំង។

សាវ័ក ថូម៉ាស បានស្រែកឡើងថា៖ «ខ្មោចវើយខ្មោច!» ហើយគាត់រត់ទៅពួននៅក្រោមតុ។

ប៉ុន្តែ តាមពិតមិនមែនជាខ្មោចទេ។

ព្រះយេស៊ូវមានបន្ទូលថា៖ «ខ្ញុំឃ្លានណាស់ តើមានអ្វីបរិភោគសម្រាប់ថ្ងៃត្រង់នេះឬទេ?»។

សាវ័ក ពេត្រុស បានហុចត្រីមួយទៅទ្រង់។ ពួកគេបានថយក្រោយ ហើយឈរមើលទ្រង់បរិភោគ។ ពួកគេគិតនៅក្នុងចិត្តថា មិនអាចទៅជាអញ្ចឹងបានទេ វាមិនអាចទៅរួចទេ មិនអាចកើតឡើងបានទាល់តែសោះ។

ប៉ុន្តែ ការនេះបានកើតមកនៅចំពោះមុខពួកគេផ្ទាល់តែម្តង។







«ឆ្ងាញ់ណាស់!» ព្រះយេស៊ូវបានយកខ្នងដៃជូតមាត់ រួចហើយក៏ញញឹមដោយបញ្ចេញធ្មេញ «តើខ្មោចអាចធ្វើដូចនេះបានដែរឬទេ?» ហើយទ្រង់ក៏ព្រិចភ្នែក ហើយគេទាំងអស់គ្នាក៏ផ្ទុះសំណើចឡើង។

ព្រះយេស៊ូវមានបន្ទូលថា៖ «ពិតជាខ្ញុំដែលនៅទីនេះហើយ!»។

ហើយព្រះអង្គពិតជានៅទីនោះមែន។

បេះដូងរបស់សាវ័ក ពេត្រុស លោតកញ្ជ្រោលពេញដោយអំណរ ហើយគាត់ក៏ឱបថើបព្រះអង្គផងដែរ។ អ្នកផ្សេងទៀតក៏បានធ្វើតាមបន្តបន្ទាប់គ្នាដែរ។ គេអរសប្បាយខ្លាំងពេក គេមានអារម្មណ៍ថា បេះដូងរបស់គេលោតកញ្ជ្រោលស្ទើរតែធ្លាយចេញមកក្រៅហើយ។

មិត្តភក្តិទាំងអស់បានបរិភោគជាមួយគ្នា ព្រមទាំងជជែកគ្នាយ៉ាងសប្បាយរីករាយ ហើយម្តងម្កាល ពួកគេនាំគ្នាសម្លឹងមើលទៅព្រះយេស៊ូវ រួចគេនាំគ្នាពាល់ទៅព្រះអង្គ ដើម្បីបញ្ជាក់ឲ្យបានដឹងច្បាស់ថា ពួកគេមិនមែនកំពុងយល់សប្តិទេ។

ព្រះយេស៊ូវមានរូបកាយពិតប្រាកដ ប៉ុន្តែ រូបកាយនេះល្អប្រសើរជាងមុន គឺរូបកាយដែលបានឆ្លងកាត់សេចក្តីស្លាប់ ហើយមិនអាចនឹងមានរោគា ឬក៏អាចនឹងសម្លាប់បានទៀតឡើយ។ រូបកាយនេះនឹងរស់នៅរហូតអស់កល្ប។ ព្រះយេស៊ូវបានត្រឡប់មកវិញដោយមានរូបកាយមួយថ្មី។

ពួកមិត្តភក្តិរបស់ទ្រង់បានដឹងពិតថា មិនមែនមានតែសេចក្តីសោកសង្រេងដែលត្រឡប់ជាមិនពិតប៉ុណ្ណោះទេ ពួកគេក៏កំពុងតែត្រឡប់ទៅជាថ្មីដែរ។ តើព្រះជាម្ចាស់នឹងធ្វើគ្រប់យ៉ាងឲ្យបានជាថ្មីវិញមែនឬ?

ព្រះយេស៊ូវមានបន្ទូលថា៖ «ខ្ញុំជាអ្នករំដោះ និងជួយសង្គ្រោះលោកីយ៍នេះ» ហើយពួកគេក៏បានដឹងដែរថា ព្រះអង្គមិនចេះស្លាប់ទៀតទេ ដោយព្រោះព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ នោះអ្វីៗគ្រប់យ៉ាងនឹងបានប្រសើរឡើងវិញទាំងអស់។



ប៉ុន្មានថ្ងៃក្រោយមក នៅពេលដែលពួកគេកំពុងតែដើរជាមួយគ្នា ព្រះយេស៊ូវមានបន្ទូលប្រាប់ពួកមិត្តភក្តិព្រះអង្គថា៖ «ដល់ពេលដែលខ្ញុំត្រូវវិលត្រឡប់ទៅផ្ទះ ទៅឯព្រះវរបិតាខ្ញុំវិញហើយ»។

ពួកគេមានការព្រួយបារម្ភ ប៉ុន្តែបន្ទាប់មក គេបាននឹកចាំពីកាលដែលព្រះយេស៊ូវមានបន្ទូលប្រាប់ពួកគេមុនពេលទ្រង់សុគតថា៖ «មានកន្លែងសម្រាប់អ្នករាល់គ្នា ខ្ញុំនឹងរៀបចំឲ្យរួចជាស្រេច។ អ្នករាល់គ្នាស្គាល់ផ្លូវនោះហើយ»។

សាវ័ក ថូម៉ាស បានមានការភ័យស្លន់ស្លោ «ខ្ញុំមិនស្គាល់ផ្លូវទៅទីនោះទេ!»។

ព្រះយេស៊ូវមានបន្ទូលថា៖ «អ្នកស្គាល់ហើយ ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត»។

ហើយនៅទីបំផុត ពេលដែលពួកគេបានទៅដល់កំពូលភ្នំដ៏ខ្ពស់ជាងគេដែលនៅជិតទីក្រុងយេរូសាឡឹម ព្រះយេស៊ូវបែរទៅពួកគេហើយបានមានបន្ទូលថា៖ «ចូរទៅគ្រប់ទីកន្លែង ហើយប្រាប់មនុស្សទាំងអស់អំពីដំណឹងដ៏រីករាយនេះចុះ!»។

«ចូរប្រាប់ពួកគេថា ខ្ញុំស្រឡាញ់ពួកគេជាខ្លាំងណាស់ បានជាខ្ញុំសុខចិត្តស្លាប់ជំនួសពួកគេ។ នេះហើយគឺជាការពិតដែលឈ្នះលើសេចក្តីភូតភរដ៏គួរឲ្យភ័យខ្លាច។ ព្រះជាម្ចាស់ស្រឡាញ់ពួកកូនរបស់ទ្រង់ពិតណាស់។ ព្រះអង្គស្រឡាញ់ដោយពិតប្រាកដ!»។

រំពេចនោះ ផ្ទៃមេឃទាំងមូលបានគ្របដណ្តប់ទៅដោយពន្លឺភ្លឺត្រចះត្រចង់។

ព្រះយេស៊ូវមានបន្ទូលថា៖ «ឥឡូវនេះ គ្រប់គ្នាអាចនឹងត្រឡប់ទៅផ្ទះ ទៅឯព្រះជាម្ចាស់វិញ សេចក្តីស្លាប់មិនមែនជាទីបញ្ចប់ចំពោះអ្នករាល់គ្នាឡើយ អ្នករាល់គ្នាអាចមានជីវិតដ៏អស់កល្បជាមួយនឹងព្រះវរបិតាបាន អ្នករាល់គ្នាអាចនៅស្ថានសួគ៌ ដោយព្រោះខ្ញុំបានជួយសង្គ្រោះលោកីយ៍ទាំងមូលនេះហើយ!»។

ហើយមានការដ៏អស្ចារ្យបានកើតឡើង ព្រះយេស៊ូវបានហោះឡើងទៅក្នុងពន្លឺខ្ពស់ទៅៗ។ ពួកគេបានយកដៃបាំងភ្នែក ដើម្បីមើលព្រះអង្គឡើងទៅ រហូតទាល់តែគេមើលព្រះអង្គលែងឃើញ ដោយពពកបាំងព្រះយេស៊ូវបាត់។ ពួកគេបានឈរផ្ទឹងងើយមើលទៅលើមេឃយ៉ាងយូរ។

រំពេចនោះ មានបុរសពេញដោយពន្លឺពីរនាក់បានលេចចេញមកសួរពួកគេថា៖ «តើអ្នកកំពុងតែធ្វើអ្វីហ្នឹង? ព្រះយេស៊ូវទ្រង់បានយាងឡើងទៅស្ថានសួគ៌ហើយ។ ប៉ុន្តែ ថ្ងៃមួយព្រះអង្គនឹងយាងត្រឡប់មកវិញ មកពីលើស្ថានសួគ៌ ដូចដែលអ្នករាល់គ្នាបានឃើញទ្រង់យាងឡើងទៅលើមេឃដែរ»។

ពួកមិត្តភក្តិរបស់ព្រះយេស៊ូវបានវិលត្រឡប់ទៅទីក្រុងយេរូសាឡឹមវិញ ដោយមានការរីករាយយ៉ាងចម្លែកនៅក្នុងចិត្តរបស់ពួកគេ។ ហើយពាក្យដែលព្រះយេស៊ូវមានបន្ទូលប្រាប់ដល់ពួកគេបានដក់ជាប់នៅក្នុងគំនិតរបស់ពួកគេ៖ «ទោះបីជាអ្នករាល់គ្នាមិនបានឃើញខ្ញុំទៀតក៏ដោយ ក៏ខ្ញុំមិនឃ្លាតពីអ្នករាល់គ្នាឡើយ គឺនឹងមិនឃ្លាតទេ! ខ្ញុំនឹងនៅជាមួយអ្នករាល់គ្នា គឺគ្រប់ពេលវេលា និងដ៏នៅអស់កល្បជានិច្ច!»។

ពួកគេមានការឆ្ងល់ថា៖ «តើព្រះយេស៊ូវអាចនៅជាមួយយើង ហើយឃ្លាតចេញពីយើងក្នុងពេលតែមួយដូចម្ដេចបាន?»។

ពួកគេមិនបានយល់ឡើយ។

ប៉ុន្តែ មិនយូរប៉ុន្មាន ពួកគេនឹងបានយល់ជាមិនខាន។



# ព្រះជាម្ចាស់បញ្ជូនជំនួយ

បុណ្យថ្ងៃទី៥០ (ដកស្រង់ចេញពីកណ្ឌ កិច្ចការ ១-៥ និងយ៉ូហាន ១៥)

**មិត្តភក្តិ**របស់ព្រះយេស៊ូវ និងអ្នកជំនួយការបានរួបរួមប្រជុំជាមួយគ្នានៅក្នុងបន្ទប់មួយនៅជាន់ខាងលើ។ គេបានបិទវាំងននជិតឈឹង ទោះបីជាមានថ្ងៃរះនៅខាងក្រៅក៏ដោយ ហើយពួកគេនៅចាក់សោទ្វារឲ្យជាប់ដែរ។

ពីមុនព្រះយេស៊ូវធ្លាប់មានបន្ទូលប្រាប់ពួកគេថា៖ «ចូររង់ចាំនៅក្នុងក្រុងយេរូសាឡឹមចុះ! ខ្ញុំនឹងបញ្ជូនកាដូដ៏វិសេសមួយមកឲ្យអ្នករាល់គ្នា គឺអំណាចនៃព្រះជាម្ចាស់នឹងមកនៅក្នុងអ្នក។ ព្រះវិញ្ញាណបរិសុទ្ធនឹងយាងចុះមក!»។

ហេតុដូច្នេះហើយ ទើបពួកគេនៅទីនេះរង់ចាំ។ តែតាមពិតទៅ ពួកគេកំពុងតែលាក់ខ្លួនដោយសារការភ័យខ្លាច។ (អ្នកមិនអាចនឹងបន្ទោសពួកគេបានទេ ពីព្រោះមិត្តភក្តិដ៏ល្អបំផុតរបស់គេបានចាកចេញបាត់ទៅ ហើយពួកមនុស្សសំខាន់ៗ និងពួកមេដឹកនាំក៏បានតាមចាប់ពួកគេដែរ។ ព្រះយេស៊ូវក៏បានប្រទានកិច្ចការឲ្យពួកគេធ្វើ តែពួកគេមិនដឹងថានឹងត្រូវធ្វើដូចម្តេចឡើយ។)

ពេលដែលពួកគេកំពុងរង់ចាំ ពួកគេក៏បានអធិស្ឋាន ហើយចងចាំពីផែនការនៃការសង្គ្រោះរបស់ព្រះជាម្ចាស់ ដែលព្រះអង្គបានរៀបចំតាំងពីដើមដំបូងមកម្ល៉េះ។







រំពេចនោះ ស្រាប់តែមានខ្យល់បក់គំហុកយ៉ាងខ្លាំងចូលមកក្នុងបន្ទប់តូច បញ្ចេញសំឡេងឆ្លងកាត់ជញ្ជាំង ហើយបក់កំទេចចំបើងពីក្រាល។ មើលហ្ន៎! នៅពីលើក្បាលគេម្នាក់ៗដែលនៅទីនោះ មានពន្លឺដូចជាអណ្ដាតភ្លើងដែលភ្លឺក្នុងទីងងឹត គឺជាអណ្ដាតភ្លើងដែលមិនធ្វើឲ្យអ្នកណាម្នាក់រលាក ឬឈឺចុកចាប់ឡើយ។

លើសពីនេះទៅទៀត ពួកគេមានអារម្មណ៍ថា ដូចជាមានកម្ដៅដ៏ចម្លែកនៅក្នុងចិត្តរបស់ពួកគេ គឺដូចជាភាពត្រជាក់ទាំងឡាយ និងភាពគ្រោតគ្រាតដែលកំពុងតែរលាយទៅ ហើយដូចជាចិត្តដ៏ខ្មៅខ្មាំរបស់ពួកគេ កំពុងតែបានជាសះស្បើយឡើងវិញ ហើយព្រះជាម្ចាស់បានប្រទានឲ្យពួកគេនូវចិត្តថ្មី គឺជាចិត្តដែលអាចនឹងមានចលនាត្រឹមត្រូវបាន។

ពួកគេមិនដឹងថា ការនេះកើតឡើងបែបណាទេ ប៉ុន្តែ ពួកគេបានដឹងថា អំណាចរបស់ព្រះជាម្ចាស់បានប៉ះពាល់ចិត្តពួកគេឲ្យមានការរំភើប ហើយព្រះយេស៊ូវទ្រង់បានយាងមកគង់នៅក្នុងចិត្តរបស់ពួកគេផងដែរ។

ពួកគេបានឃើញព្រះយេស៊ូវយាងទៅឆ្ងាយ ប៉ុន្តែឥឡូវនេះ ព្រះអង្គទ្រង់គង់នៅជាមួយពួកគេជិតជាងពីមុនទៅទៀត គឺនៅក្នុងចិត្តពួកគេម្នាក់ៗតែម្ដង។ ហើយនៅពេលនេះ គ្មានអ្វីដែលអាចនឹងបំបែកគេបានឡើយ ព្រះយេស៊ូវទ្រង់តែងតែគង់នៅជាមួយពួកគេជានិច្ច ទ្រង់ស្រឡាញ់ពួកគេ ហើយខ្សឹបប្រាប់ពួកគេពីសេចក្ដីសន្យាដែលនឹងដកយកអស់ទាំងភាពពិសពុល ព្រមទាំងពាក្យភូតភរដ៏អាក្រក់ និងជំងឺនៅក្នុងចិត្តពួកគេចេញដែរ។ សេចក្ដីសន្យាដ៏វិសេសរបស់ព្រះជាម្ចាស់ចំពោះពួកគេគឺ៖ «អ្នករាល់គ្នាជាកូនស្ងួនភ្ងារបស់យើង ហើយយើងស្រឡាញ់អ្នករាល់គ្នា»។

ព្រះយេស៊ូវបានមានបន្ទូលថា៖ «ចូរមករៀបចំផ្ទះឯងនៅក្នុងខ្ញុំចុះ ដូចដែលខ្ញុំបានរៀបចំផ្ទះក្នុងឯងដែរ»។

តើអាចធ្វើបានឬទេ? ស្ថានសួគ៌កំពុងតែមកសណ្ឋិតក្នុងចិត្តរបស់ពួកគេ។



ពួកគេនាំគ្នាបើកបង្អួចឡើង ហើយពន្លឺថ្ងៃក៏ជះចូលពេញបន្ទប់ គឺដូចជាសេចក្ដីស្រឡាញ់បានជោរជន់ពេញក្នុងដួងចិត្តរបស់ពួកគេដែរ។ នៅក្នុងបន្ទប់តូចនេះពោរពេញទៅដោយសំឡេងសប្បាយរីករាយ រាំច្រៀង និងសើច។

ពួកគេបានដោះគន្លឹះចេញ ហើយបើកទ្វារ រួចរត់តាមដងផ្លូវ ហាក់បីដូចជាពួកគេមិនធ្លាប់មានការភ័យខ្លាចអ្វីទាល់តែសោះ។

សាវ័ក ពេត្រុស បាននិយាយដោយសំឡេងឮខ្លាំងៗ ដើម្បីឲ្យគ្រប់គ្នាអាចឮបាន គាត់ស្រែកថា៖ «ព្រះយេស៊ូវបានសុគតជំនួសអ្នករាល់គ្នា ពីព្រោះព្រះអង្គស្រឡាញ់អ្នករាល់គ្នា! តែព្រះជាម្ចាស់បានធ្វើឲ្យព្រះអង្គមានព្រះជន្មរស់ឡើងវិញ។ ព្រះអង្គបានជួយសង្គ្រោះអ្នករាល់គ្នា!»។

ពួកបណ្ដាជនទាំងអស់ក៏បាននាំគ្នាឈប់ ហើយចាំស្ដាប់។ ព្រះបន្ទូលបានជ្រាបចូលយ៉ាងជ្រៅទៅក្នុងដួងចិត្តរបស់ពួកគេ ហើយមានអំណាចដូចជាថ្នាំដែលព្យាបាលពួកគេឲ្យបានជា គឺដូចជាថ្នាំដែលបន្សាបភាពពិសពុលដ៏សាហាវ ក៏ដូចជាការថើបដែលធ្វើឲ្យអ្នកភ្ញាក់ពីដំណេកដ៏លង់លក់មួយអញ្ចឹង។

សាវ័ក ពេត្រុស និយាយឡើងថា៖ «ចូរឈប់រត់ចេញពីព្រះជាម្ចាស់ទៅ! ចូររត់ចូលមកឯព្រះអង្គវិញ! ដើម្បីឲ្យទ្រង់អាចនឹងស្រឡាញ់អ្នក និងរំដោះអ្នកឲ្យមានសេរីភាពចុះ!»។

បន្ទាប់មកសាវ័ក ពេត្រុស ក៏បានប្រាប់ពួកគេអំពីក្ដីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ដែលជាក្ដីស្រឡាញ់ដែលគ្មានទីបញ្ចប់ មិនអាចបោះបង់បាន មិនអាចបំបែកចេញបានដដែល ជាសេចក្ដីស្រឡាញ់ដ៏អស់កល្បជានិច្ច។ និងអំពីបែបដែលព្រះយេស៊ូវទ្រង់យាងមក។ ការទាំងអស់ហ្នឹងបានកើតឡើងហើយ។



មានមនុស្សជាច្រើនមកពីស្រុកឆ្ងាយនៅក្នុងក្រុងយេរូសាឡឹម។ ពួកគេមិនអាចនិយាយភាសាដូចគ្នាបានឡើយ ប៉ុន្តែនៅពេលដែលពួកគេបានស្ដាប់សាវ័ក ពេត្រុស ពួកគេគ្រប់ៗគ្នាអាចយល់បាននូវអ្វីៗដែលគាត់បាននិយាយតាមភាសារៀងៗខ្លួន!

មានមនុស្សជាច្រើនបានទទួលជឿ ហើយបានក្លាយទៅជាមិត្តភក្តិថ្មីៗរបស់ព្រះយេស៊ូវ និងជាអ្នកជំនួយរបស់ព្រះអង្គ។ ដំណឹងដ៏អស្ចារ្យរបស់ព្រះយេស៊ូវបានឮសុះសាយឡើង គឺដូចជាផ្កាភ្លើងដែលខ្ទាតចេញពីភ្នក់ភ្លើងទៅកាន់ស្រុក ទៅកាន់ភូមិ ហើយនិងទីក្រុងនានា។

មានមនុស្សជឿកាន់តែច្រើនឡើងៗជារៀងរាល់ថ្ងៃ។

ដូច្នេះហើយបានជាគ្រួសារនៃកូនៗរបស់ព្រះជាម្ចាស់ ជាមនុស្សដែលសំខាន់របស់ព្រះអង្គ បានរីកចម្រើនឡើងៗ។

មានមនុស្សម្នាក់ឈ្មោះលោក សុល គាត់បានមើលឃើញការនេះ  ហើយគាត់បាននិយាយថា៖ «ខ្ញុំនឹងបញ្ឈប់ការនេះ!»។

ប៉ុន្តែ នេះជាផែនការរបស់ព្រះជាម្ចាស់ ហើយគ្មានអ្វីនៅក្នុងលោកីយ៍ទាំងមូលនេះអាចនឹងបញ្ឈប់ផែនការនេះបានឡើយ។





# របៀបមើលថ្មី

សាច់រឿងអំពីសាវ័ក ប៉ុល

(ដកស្រង់ចេញពីកណ្ឌ កិច្ចការ ៦-៩, ១២-២៨; កូឡូស ២; រ៉ូម ៨ និងអេភេសូរ ២)

**ក្នុងពួកបណ្ដាជន**ដែលរក្សាក្រឹត្យវិន័យលោក សុល គឺជាមនុស្សដែលប្រសើរជាងគេ។

គាត់បានប្រាប់គេថា៖ «ខ្ញុំពិតជាល្អណាស់ ក្នុងការធ្វើការល្អ»។

គាត់ជាមនុស្សម្នាក់ដែលក្រអឺតក្រទមយ៉ាងខ្លាំងណាស់ ហើយក៏ល្អណាស់ដែរ។ ប៉ុន្តែ គាត់ក៏ជាមនុស្សកាចផងដែរ។

លោក សុល ស្អប់អ្នកណាដែលស្រឡាញ់ព្រះយេស៊ូវណាស់។ គាត់បានធ្វើដំណើរទៅគ្រប់ទីកន្លែងតាមរកពួកគេ គឺគាត់មានបំណងចាប់ពួកគេយកទៅដាក់គុក។ គាត់ចង់ឲ្យគេគ្រប់គ្នាភ្លេចព្រះយេស៊ូវ។ គាត់មិនជឿថា ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះនោះទេ ហើយគាត់ក៏មិនបានជឿថាព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញដែរ។

អ្នកដឹងទេលោក សុល មិនដែលបានជួបព្រះយេស៊ូវសោះ។

ដូច្នេះ នៅថ្ងៃមួយនោះ ព្រះយេស៊ូវបានជួបនឹងលោក សុល។







កាលលោក សុល កំពុងតែធ្វើដំណើរទៅទីក្រុងដាម៉ាស មួយរំពេចនោះ ស្រាប់តែមានពន្លឺភ្លឺយ៉ាងខ្លាំងដូចជាផ្លេកបន្ទោរ ភ្លឺជាងពន្លឺព្រះអាទិត្យទៅទៀត គឺភ្លឺខ្លាំងមែនទែន។ លោក សុល ខ្ទប់ភ្នែកគាត់ ហើយក៏ដួលចុះលើដី។

គាត់បានឮសំឡេងមួយដ៏ខ្លាំង គឺឮសូរខ្លាំងណាស់ ដែលបានធ្វើឲ្យលោក សុល ឈឺក្បាល។

សំឡេងខ្លាំងនោះបានស្រែកហៅថា៖ «សុល! សុល! ហេតុអ្វីបានជាឯងតតាំងនឹងខ្ញុំ?»។

លោក សុល ឆ្លើយតបថា៖ «ឱ! ព្រះអម្ចាស់អើយ! តើព្រះអង្គជាអ្នកណាហ្នឹង?»។

សំឡេងនោះឆ្លើយប្រាប់លោក សុល ថា៖ «ខ្ញុំជាព្រះយេស៊ូវ ពេលដែលអ្នកធ្វើទុក្ខដល់មិត្តរបស់ខ្ញុំ នោះដូចជាអ្នកបានធ្វើទុក្ខដល់ខ្ញុំដែរ»។ ខ្លួនទាំងមូលរបស់លោក សុល បានញាប់ញ័រ។

ព្រះយេស៊ូវមានបន្ទូលថា៖ «ចូរចេញទៅឯទីក្រុងទៅ ខ្ញុំនឹងប្រាប់ឯងពីការដែលត្រូវធ្វើ»។

ពេលដែលលោក សុល បានបើកភ្នែកឡើង នោះគាត់មើលមិនឃើញអ្វីសោះ។ អ្នកជំនួយរបស់គាត់ក៏បានដឹកដៃគាត់ ហើយនាំផ្លូវគាត់ដូចជាកូនក្មេងតូចមួយ។ លោក សុល បានងងឹតភ្នែកអស់រយៈបីថ្ងៃ ប៉ុន្តែ ក្រោយបីថ្ងៃនោះមក គាត់បានមើលឃើញវិញ ហើយហាក់បីដូចជាគាត់ទើបតែនឹងបានមើលឃើញជាលើកដំបូង។

ស្របពេលនោះ មានបុរសម្នាក់ឈ្មោះលោក អាន៉ានាស ជាអ្នកដែលស្រឡាញ់ព្រះយេស៊ូវ ហើយព្រះយេស៊ូវបានយាងមកជួបគាត់ក្នុងសុបិន្ត ហើយទ្រង់មានបន្ទូលថា៖ «ចូរទៅឯលោក សុល ហើយអធិស្ឋានឲ្យគាត់ មើលឃើញវិញ ខ្ញុំនឹងធ្វើឲ្យគាត់មើលឃើញម្តងទៀត»។

លោក អាន៉ានាស បានស្គាល់លោក សុល យ៉ាងច្បាស់ណាស់ ហើយក៏ដឹងផងដែរថា គាត់បានស្អប់អ្នកដែលដើរតាមព្រះយេស៊ូវដែរ ដូច្នេះ លោក អាន៉ានាស បានទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់អើយ គាត់មកធ្វើទុក្ខដល់ពួកយើងទេតើ!»។

ប៉ុន្តែ ព្រះយេស៊ូវបានឆ្លើយប្រាប់ទៅលោក អាន៉ានាស ថា៖ «គឺ សុល នេះហើយ ដែលយើងបានជ្រើសតាំងឲ្យទៅប្រាប់លោកីយ៍ទាំងមូលថា យើងជាអ្នកណា»។

ដូច្នេះ លោក អាន៉ានាស ក៏បានទៅជួបលោក សុល ហើយលោក អាន៉ានាស និយាយថា៖ «ឱ! ប្អូនប្រុស សុល អើយ! ព្រះយេស៊ូវគឺជាអង្គដែលឯងបានជួបនៅតាមផ្លូវនោះ» ហើយលោក អាន៉ានាស ក៏អធិស្ឋានឲ្យលោក សុល។

មួយរំពេចនោះលោក សុល បានមើលឃើញជាថ្មីឡើងវិញ ប៉ុន្តែគាត់បានឃើញអ្វីៗគ្រប់យ៉ាងខុសពីមុនៗ គាត់មិនកាចទៀតទេ។ គាត់ថែមទាំងប្តូរឈ្មោះរបស់គាត់ពីលោក សុល ទៅជាសាវ័ក ប៉ុល វិញ ដែលនោះមានន័យថា «តូច» និង «រាបសា» ជាពាក្យផ្ទុយនឹងពាក្យក្រអឺតក្រទម។

តើអ្នកដឹងទេថា ឈ្មោះអាន៉ានាសមានន័យថាដូចម្តេច? «គឺព្រះអម្ចាស់ពោរពេញទៅដោយព្រះគុណ» (ព្រះគុណ មានន័យថា «អំណោយ» ហើយអ្វីដែលគួរឲ្យអស់សំណើចនោះគឺត្រង់ថា នេះជាការបង្រៀនរបស់សាវ័ក ប៉ុល ចាប់ផ្តើមពីពេលនេះទៅ)។








សាវ័ក ប៉ុល បានប្រាប់ដល់ពួកបណ្ដាជនថា៖ «ដើម្បីឲ្យព្រះជាម្ចាស់ស្រឡាញ់អ្នករាល់គ្នា នោះវាមិនមែនអាស្រ័យលើការធ្វើតាមក្រឹត្យវិន័យនោះទេ! អ្នករាល់គ្នាមិនចាំបាច់ធ្វើឲ្យបានល្អក្នុងការប្រព្រឹត្តការល្អនោះទេ គឺអ្នករាល់គ្នាគ្រាន់តែត្រូវការមានជំនឿលើព្រះយេស៊ូវ នូវលើអ្វីៗដែលព្រះអង្គបានធ្វើ ហើយដើរតាមទ្រង់តែប៉ុណ្ណោះទេ។ នេះមិនទាក់ទងនឹងការខំប្រឹងប្រែងនោះទេ ប៉ុន្តែទាក់ទងនឹងការទុកចិត្តទេតើ។ វាមិនរំពឹងលើក្រឹត្យវិន័យទេ តែរំពឹងលើព្រះគុណវិញ៖ អំណោយទានដ៏ឥតគិតថ្លៃរបស់ព្រះជាម្ចាស់ ដែលព្រះអង្គបានផ្ដល់ឲ្យយើងគឺជាអំណោយទានដែលទ្រង់បានបង់គ្រប់ទាំងអស់»។

តើមានហេតុការណ៍អ្វីបានកើតឡើងចំពោះសាវ័ក ប៉ុល? គាត់បានជួបព្រះយេស៊ូវ។

សាវ័ក ប៉ុល បានទទួលការងារថ្មីមួយ គាត់បានហៅខ្លួនគាត់ថា ជាអ្នកបម្រើ ហើយគាត់បានធ្វើដំណើរទៅគ្រប់ទីកន្លែងដើម្បីប្រាប់ពួកបណ្ដាជនពីព្រះយេស៊ូវ។ គាត់បានជួបការលិចសំពៅបីដង! ហើយគាត់ថែមទាំងបានជាប់គុកទៀតផង។

គាត់បានសរសេរសំបុត្រពីក្នុងគុកថា៖ «ព្រះទ្រង់ស្រឡាញ់យើងរាល់គ្នា! គ្មានអ្វីដែលអាចកាត់ផ្ដាច់យើងចេញពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់បានទេ ជាក្ដីស្រឡាញ់ដែលទ្រង់បានបង្ហាញតាមរយៈព្រះយេស៊ូវ ដែលក្ដីស្រឡាញ់នោះគ្មានទីបញ្ចប់ មិនអាចបោះបង់បាន មិនអាចបំបែកចេញបានដែរ ជាសេចក្ដីស្រឡាញ់ដ៏អស់កល្បជានិច្ច»។

ហើយប្រាកដមែន ដូចជាព្រះជាម្ចាស់បានសន្យាជាមួយនឹងលោក អ័ប្រាហាំ នាវាត្រីងងឹតមួយអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនោះ គ្រួសារនៃរាស្ត្ររបស់ព្រះជាម្ចាស់បានរីកចម្រើនឡើង ហើយចម្រើនឡើងទៀត។

រហូតដល់ថ្ងៃមួយ ដែលគេនឹងមានចំនួនច្រើនជាងអស់ទាំងផ្កាយនៅលើមេឃទៅទៀត។







# ក្តីសុបិនអំពីស្ថានសួគ៌

សាវ័ក យ៉ូហាន មើលឃើញពីអនាគត (ដកស្រង់ចេញពីកណ្ឌ វិវរណៈ ១; ៥; ២១ និង២២)

**សាវ័ក យ៉ូហាន** ជាអ្នកជំនួយការម្នាក់របស់ព្រះយេស៊ូវ។ នៅពេលនោះ គាត់មានវ័យចាស់ជរាហើយ គាត់រស់នៅលើកោះមួយ ដែលស្តាប់ទៅហាក់ដូចជាស្រួលណាស់ ប៉ុន្តែ ទីនោះគឺជាគុក។ (ពួកមេដឹកនាំបានដាក់គុកគាត់នៅទីនោះ ដើម្បីបញ្ឈប់មិនឲ្យគាត់ផ្សាយដំណឹងពីព្រះយេស៊ូវទៀត។ ប៉ុន្តែ ខ្ញុំជឿជាក់ថា អ្នកមិនគិតឃើញថា ការដែលជាប់គុកនៅលើកោះ ក្នុងបន្ទប់តូចមួយនៅកណ្តាលសមុទ្រនោះ អាចនឹងបញ្ឈប់ផែនការរបស់ព្រះជាម្ចាស់បាននោះទេ។ មែនទេ?)

នាពេលព្រឹកមួយ ព្រះយេស៊ូវបានលេចមក នៅក្នុងបន្ទប់ឃុំឃាំងរបស់សាវ័ក យ៉ូហាន។ ព្រះនេត្ររបស់ព្រះយេស៊ូវភ្លឺចែងចាំង ដូចជាពន្លឺព្រះអាទិត្យ។ ព្រះយេស៊ូវមានបន្ទូលថា៖ «ឱ! យ៉ូហានអើយ! ខ្ញុំនឹងបង្ហាញការអាថ៌កំបាំងមួយដល់អ្នក ជាអាថ៌កំបាំងពីពេលដែលខ្ញុំនឹងត្រឡប់មកវិញ»។ សំឡេងរបស់ព្រះអង្គ ហាក់បីដូចជាសំឡេងទឹកដែលហូរខ្ទួលខ្ទាញ់៖ «ចូរកត់ទុកនូវអ្វីដែលអ្នកបានឃើញ ដើម្បីឲ្យរាស្ត្ររបស់ព្រះជាម្ចាស់អាចអានបាន ហើយរង់ចាំដោយមានក្តីរំភើប»។

បន្ទាប់មក ព្រះយេស៊ូវបានប្រទានដល់សាវ័ក យ៉ូហាន នូវសុបិនយ៉ាងល្អមួយ ប៉ុន្តែសាវ័ក យ៉ូហាន នៅដឹងខ្លួននៅឡើយ ហើយអ្វីដែលគាត់បានឃើញ គឺជាការជាក់ស្តែង ហើយនៅថ្ងៃមួយនឹងក្លាយទៅជាការពិតទាំងអស់...







ខ្ញុំឃើញបល្ល័ង្កមួយ ហើយនៅលើបល្ល័ង្កនោះមានស្ដេចមួយអង្គ
ហើយស្ដេចនោះគឺជាព្រះយេស៊ូវ។ នៅជុំវិញបល្ល័ង្កនោះ គឺមានសត្វ
បណ្ដានបានឱនក្រាបចុះ គេបានថ្វាយទ្រព្យសម្បត្តិរបស់ពួកគេ
ដល់ទ្រង់។

មានសំឡេងហោកញ្ជ្រៀវ និងផ្គរដែលលាន់រំពង
ព្រមទាំងសំណើច ហាក់បីដូចជាសំឡេងទឹកធ្លាក់
ហើយគ្រប់គ្នាក៏បន្លឺសំឡេងច្រៀងបទថ្មីមួយ...

«នេះគឺជាស្ដេចរបស់យើងរាល់គ្នា! ជាកូនចៀមដែលបានស្លាប់ ដើម្បីកុំឲ្យយើងត្រូវ
ស្លាប់ ព្រះអង្គជាព្រះសង្គ្រោះនៃយើងរាល់គ្នា។ គ្រប់គ្នាតម្កើង និងលើកសិរីទ្រង់ឡើង! អស់កល្ប
ជានិច្ច និងតរៀងទៅ»។ គ្រប់ទាំងរបស់ដែលបានបង្កើតមក នៅគ្រប់ទីកន្លែង ទាំងនៅលើ
ស្ថានសួគ៌ និងនៅលើផែនដី ហើយនៅក្រោមផែនដី និងនៅក្នុងសមុទ្រ ក៏ចូលរួមក្នុង
គ្នាច្រៀង។

ហើយបន្ទាប់មក
មកពីគ្រប់ទិស
គ្រប់ច្រកល្ហក
គឺ មាន ភាព ស្ងៀម ស្ងាត់
ដ៏ធំបរិយា
ហើយស្រស់ស្អាត
ហើយខ្ញុំក៏បានឃើញសាតាំង ដែលជាសត្រូវនៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់
បានត្រូវធ្លាក់ចុះមក ហើយក៏ត្រូវចុះចាញ់ដែរ។

ខ្ញុំបានឃើញទីក្រុងដ៏ភ្លឺផ្លេក នៅលើមេឃ៖
មានពន្លឺចាំងផ្លេកៗ ចាំងចែងចុះមកក្រោម!ពីលើឋានសួគ៌
ហើយពីលើមេឃ។
ឋានសួគ៌កំពុងតែចុះមកលើផែនដី!

ទីក្រុងរបស់ព្រះជាម្ចាស់ស្រស់ស្អាតប្រណីត ដែលមានជញ្ជាំងធ្វើពីត្បូងទេពប្រុត ត្បូងមណីជោតិ ត្បូងកណ្ដៀង។
មានផ្លូវធំទូលាយក្រាលទៅដោយមាស។ ខ្លោងទ្វារ ធ្វើពីកែវមុក្ដាភ្លឺផ្លេកៗ បើកចំហមិនដែលបិទចាក់សោ។

តើព្រះអាទិត្យនៅឯណា? ហើយលោកខែនៅឯណា?
យើងមិនត្រូវការរបស់ទាំងនេះទៀតទេ។ ព្រះជាម្ចាស់ជាពន្លឺ
ដែលមនុស្សជាតិទាំងឡាយត្រូវការ គ្មានភាពងងឹតទៀតទេ!
គ្មានយប់ទៀតទេ!



រួចស្ដេចក៏មានព្រះបន្ទូលឡើងថា៖ «មើលហ្ន៎! ព្រះជាម្ចាស់
ហើយនិងរាស្ត្ររបស់ទ្រង់ បានរួបរុំគ្នាម្ដងទៀតហើយ គ្មាន
ការចាក់ចេញទៅណាទៀតទេ ហើយក៏គ្មានការលាក់ខ្លួនដែរ។
គ្មានការយំសោក គ្មានការរស់នៅឯកាម្នាក់ឯង ហើយគ្មានការ
ភ័យខ្លាចទៀតឡើយ។
គ្មានការឈឺថ្កាត់ និងការស្លាប់ទៀតទេ។
ពីព្រោះការទាំងអស់នេះបានកន្លងផុតទៅហើយ។
ពិតហើយ ការទាំងអស់នេះរលត់បាត់ទៅជារៀងរហូត។
ការសោកសង្រេងទាំងអស់ ក្លាយជាការមិនពិត។
ហើយពេលចុះ យើងបានស្ដុតទីកន្លែងចេញពីផ្ទះរាល់គ្នា!»។

បន្ទាប់មក មានសំឡេងខ្ទរខ្ទាររលាស់នៅលើមេឃនិយាយថា៖ «មើលចុះ យើង
បានធ្វើគ្រប់ទាំងអស់សារជាថ្មីឡើងវិញ!»។

វាជាការពិបាកណាស់ក្នុងការកត់ទុកគ្រប់ទាំងអ្វីដែលសាវ័ក យ៉ូហាន បានឃើញ ទៅជាពាក្យសម្ដីសរសេរចេញជាអក្សរ ហើយដាក់ឲ្យល្មមនៅក្នុងទំព័រ រួចច្របាច់បញ្ចូលទៅក្នុងសៀវភៅមួយក្បាល។ គ្រប់ទាំងពាក្យដែលនៅលើទំព័រទាំងអស់ នៅក្នុងសៀវភៅទាំងអស់ នៅលោកីយ៍ទាំងមូល ក៏មិនអាចនឹងកត់ទុកអស់ដែរ។

ព្រះយេស៊ូវមានបន្ទូលថា៖ «យើងជាដើមដំបូង ហើយជាទីចុងបញ្ចប់!»។

សាវ័ក យ៉ូហាន បានដឹងថា នៅថ្ងៃមួយ ស្ថានសួគ៌នឹងចុះមក ហើយលោកីយ៍ដែលខូចរបស់ព្រះជាម្ចាស់ ក៏បានជួសជុលកែជាថ្មីឡើងវិញ ធ្វើជាទីលំនៅពិតប្រាកដរបស់យើង និងល្អបំផុតជាថ្មីម្តងទៀត។

គាត់បានដឹងដែរថា គ្រប់ទាំងអ្វីៗនឹងកាន់តែបានល្អស្រស់ស្អាតអស្ចារ្យឡើង ដែលពីមុនធ្លាប់តែមានសេចក្តីទុក្ខសោក ទោះបើការនោះជាអាថ៌កំបាំង ហើយពិបាកពន្យល់ប៉ុណ្ណាក៏ដោយ។

ហើយគាត់ក៏បានដឹងដែរថា នៅចុងបញ្ចប់នៃដំណើររឿងនេះនឹងត្រឡប់ជាការល្អបំផុត ដែលនឹងធ្វើឲ្យភាពសោកសង្រេង និងទឹកភ្នែក ព្រមទាំងអ្វីៗទាំងអស់ ហាក់ដូចជាស្រមោលដែលនឹងត្រូវដេញចេញបាត់ទៅ ដោយសារពន្លឺថ្ងៃនៅពេលព្រឹកព្រលឹម។

ព្រះយេស៊ូវមានបន្ទូលថា៖ «ខ្ញុំចេញទៅហើយ ខ្ញុំនឹងទៅដល់ទីនោះក្នុងពេលដ៏ឆាប់!»។

សាវ័ក យ៉ូហាន បានមកដល់ចុងបញ្ចប់នៃសៀវភៅរបស់គាត់ ប៉ុន្តែគាត់ពុំបានសរសេរពាក្យថា «ចប់ដោយបរិបូរណ៍» ទេ ពីព្រោះតាមពិតទៅ ដំណើររឿងមិនចប់ដោយរបៀបនេះទេ។ (ហើយរឿងនេះ មិនទាន់បញ្ចប់នៅឡើយដែរ។)

ដូច្នេះ ជំនួសពាក្យបញ្ចប់ គាត់សរសេរថា៖ «ឱ! ព្រះយេស៊ូវអើយ! សូមយាងមកជាឆាប់ៗនេះ»។

ដែលប្រហែលជាបែបមួយទៀត ដើម្បីនិយាយថា...







នៅមានវគ្គបន្ត...

*យ៉ូហាន ១:១២-១៣ (គគខ)*

រីឯអស់អ្នកដែលបានទទួលព្រះអង្គ
គឺអស់អ្នកដែលជឿលើព្រះនាមរបស់ព្រះអង្គ
ព្រះអង្គបានប្រទានសិទ្ធិដល់ពួកគេឲ្យត្រឡប់
ជាកូនរបស់ព្រះជាម្ចាស់
គឺជាកូនដែលមិនមែនកើតមកពីឈាម
ឬពីប្រាថ្នាខាងរូបសាច់
ឬពីចំណង់របស់មនុស្សឡើយ
គឺកើតពីព្រះជាម្ចាស់វិញ។

ពីព្រោះតាមពិតទៅ ចំណុចដ៏សំខាន់បំផុតអំពីដំណើររឿងនេះគឺ វាក៏ជារឿងរបស់អ្នកដែរ។